SPE/ MIS/ CBR/ 1066

CARERE

Cambodia Area Rehabilitation and Regeneration

គំរោង UNDP សំរាប់ជួយគាំទ្រកម្មវិធីសិលារបស់រាជរដ្ឋាភិបាល

UNDP/UNOPS

សិលា

# ការផ្លាស់ប្តូរការគ្រប់គ្រងនៅតាមមូលដ្ឋាន

## ការយល់ដឹងរបស់អ្នកភូមិ និងឥទ្ធិពលរបស់សិលា



របាយការណ៍នេះ កំមានសរសេរជាភាសាអង់គ្លេសដែរ


*ម៉ាលីន ហាស្សែលស្កូគ*

*គ្រង់ ចន្ទូ និង ជឹម ចរិយា*


ភ្នំពេញ ខែធ ឆ្នាំ២០០០

# Local Governance in Transition

## Village's Perceptions and SEILA Impact


( Malin Hasselskog)


library.ncdd.gov.kh
008230

បណ្ណាល័យ
គ.ជ.អ.ប

# មាតិកា

សេចក្តីថ្លែងអំណរគុណ ........ i
សេចក្តីសង្ខេប ........ iii
ចំនុចសំខាន់ៗក្នុងសេចក្តីសង្ខេប ........ v
អក្សរកាត់ និងបម្លានុក្រម ........ xiii

*ជំពូក១. សេចក្តីផ្តើម*
គោលបំណង ........ ២
កម្មវិធីសិក្សា ........ ២
បញ្ហា និងវិធីសាស្ត្រ ........ ៣
គំរោងរបាយការណ៍ ........ ៦
ការជ្រើសរើស និងការពិពណ៌នាភូមិដែលជាករណីសិក្សា ........ ៧

*ជំពូក២. ការយល់ឃើញរបស់អ្នកភូមិចំពោះការគ្រប់គ្រងតាមមូលដ្ឋាន* ........ ១៣
*ភូមិ* ........ ១៣
តួនាទី និងកិត្តិស័ព្ទរបស់វេជ្ជអំណាចមូលដ្ឋាន ........ ១៣
ប្រវត្តិស្ថិតិការដឹកនាំនៅក្នុងភូមិនាពេលបច្ចុប្បន្ន ........ ២០
ទំនាក់ទំនងជាមួយវេជ្ជអំណាចនៅក្នុងភូមិ ........ ២៧

*ឃុំ* ........ ៣៣
ការយល់ដឹងចំពោះថ្នាក់ឃុំ ........ ៣៣
ថ្នាក់ឃុំ និងថ្នាក់លើចុះទៅភូមិ ........ ៣៨
អ្នកភូមិទៅជួបថ្នាក់ឃុំ និងថ្នាក់លើ ........ ៤៣

*សេចក្តីសន្និដ្ឋាន* ........ ៥៨
ទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន ........ ៥៨
ភាពស្មុគស្មាញ ........ ៦០
ការទទួលយក ........ ៦១
បណ្តឹងតវ៉ា ........ ៦២

352.74
HAS
Sh.9-1

ជំពូក៣. ឥទ្ធិពលរបស់សិលាទៅលើការគ្រប់គ្រងតាមមូលដ្ឋាន ..... ៦៥

*ភូមិ* ..... ៦៥

ភារកិច្ច និងមុខតំណែងថ្មី ..... ៦៥

ការផ្លាស់ប្តូររចនាសម្ព័ន្ធផ្នែកអំណាច ..... ៧១

ឱកាស និងការទទួលខុសត្រូវចំពោះអ្នកភូមិ ..... ៧៧

*ឃុំ* ..... ៨៤

បំលាស់ប្តូរ, ការយល់ឃើញ និងទំនាក់ទំនងរបស់អ្នកភូមិជាមួយថ្នាក់ឃុំមានការប្រែប្រួល ..... ៨៤

*សេចក្តីសន្និដ្ឋាន* ..... ៩១

ការគ្រប់គ្រងនៅថ្នាក់ភូមិ ..... ៩១

ការគោរពសិទ្ធិរបស់អ្នកភូមិ ..... ៩៣

ទំនាក់ទំនងរបស់អ្នកភូមិចំពោះថ្នាក់ឃុំ ..... ៩៤

*ជំពូក៤. តើអ្វីដែលជាឥទ្ធិពលពិតប្រាកដរបស់កម្មវិធីសិលាទៅលើការគ្រប់គ្រងតាមមូលដ្ឋាន* ..... ៩៧

សិទ្ធិជាពលរដ្ឋ ..... ៩៨

អ្នកតំណាងភូមិ ..... ៩៨

ការគ្រប់គ្រងនៅថ្នាក់ឃុំ ..... ១០០

*ឧបសម្ព័ន្ធ*

១. ការបង្ហាញករណីសិក្សានៅភូមិទាំងពីរ

២. ឯកសារយោង

# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះ គឺពោរពេញទៅដោយការលំបាក ព្រមទាំងមានមេរៀនពិបាកៗជាច្រើនដែលបានសិក្សាកន្លងមក ហើយក៏មានភាពរីករាយយ៉ាងច្រើនដែរ ។

ខ្ញុំសូមថ្លែងអំណរគុណកញ្ញា ចន្ទ និង ចរិយា ចំពោះការចូលរួមដ៏មានតំលៃនៅក្នុងការសិក្សានេះ ។ ក្រៅពីជំនាញផ្ទាល់ខ្លួន ការបូជាកំលាំងកាយចិត្ត ការខំប្រឹងប្រែង គោលជំហរដ៏រឹងមាំ ភាពរួសរាយរបស់ចន្ទ ព្រមទាំងការតស៊ូ និងភាពវៃឆ្លាតរបស់នាងបានជួយអោយក្រុមសិក្សាបន្តការងាររបស់ខ្លួនដល់គោលដៅ តែបើពុំនោះទេ យើងនឹងមិនអាចទទួលបានជោគជ័យឡើយ ។ បទពិសោធន៍ដ៏ទូលំទូលាយ និងការយល់ដឹងយ៉ាងជ្រាលជ្រៅពីការរស់នៅ និងសកម្មភាពអភិវឌ្ឍន៍តាមជនបទរបស់កញ្ញាចរិយា បានជួយអោយក្រុមសិក្សា យល់ច្បាស់នូវអ្វីដែលយើងលឺ និងឃើញនៅក្នុងពេលសិក្សា ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រួសារដែលរស់នៅភូមិជ្រៃង និងភូមិគោកដូង ដែលបានផ្តល់ទីស្នាក់អាស្រ័យដ៏កក់ក្តៅ និងចំណាយកំលាំងកាយចិត្តក្នុងការធ្វើម្ហូបអាហារដ៏មានឱជារស ដល់ក្រុមសិក្សាយើង ហើយខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ដល់អ្នកភូមិទាំងអស់ដែលបានឆ្លើយតបនឹងសំនួររបស់យើងដោយសុចរិត និងសុឆន្ទៈ ព្រមទាំងបានចែករំលែកគំនិតដែលពួកគេមាន ដល់ក្រុមសិក្សារបស់យើងផងដែរ ។ ពួកគេបានជួយការងារដល់ក្រុមយើងយ៉ាងច្រើនមហិមា ។ យើងរំខានការងាររបស់ពួកគេ ប៉ុន្តែខ្ញុំជឿជាក់ថា យើងនៅចងចាំជានិច្ច ។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកកប្បការចំពោះភ្នាក់ងារ SIDA ដែលបានឧបត្ថម្ភថវិកាដល់ការសិក្សានេះ ព្រមទាំងបានផ្តល់ការទុកចិត្តចំពោះខ្ញុំអោយទទួលខុសត្រូវ ផ្តល់សិទ្ធិអោយខ្ញុំ ដើម្បីបង្កើតនិងធ្វើការងារនេះ ។ ទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ UNDP/CARERE ដែលឧបត្ថម្ភផ្នែកភស្តុភារ និងបានផ្តល់មតិទៅលើសេចក្តីពង្រាងនេះ ព្រមទាំងថ្លែងអំណរគុណដល់ប្រធានកម្មវិធី CARERE និងតំណាងខេត្តស្រុករបស់សិលាដែលបានចំណាយពេលដ៏មានតំលៃចំពោះបទសម្ភាសន៍ ។ ឈ-ចាន់សុផល តែងតែផ្តល់ការលើកទឹកចិត្ត និងការចូលរួមជាគំនិតល្អៗ ហើយ ចូអាន-ម៉ូរីសុន បានរំលែកភាពស្វាហាប់ និងសោមនស្សរបស់គាត់ដល់គំរោងនេះ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះបុគ្គលិកឃែរេទាំងអស់នៅខេត្តពោធិសាត់ និងបាត់ដំបង ជាពិសេស ឈុន-លី និង គីម-ឡេង ដែលបានស្វាគមន៍យើងខ្ញុំដោយភាពរាក់ទាក់ និងជំនួយក្នុងការអនុវត្ត ហើយក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ

ផងដែរ ចំពោះគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត គណៈកម្មាធិការប្រតិបត្តិខេត្តពោធិសាត់ ដែលបានផ្តល់យោបល់កែលំអប្រកបដោយការលើកទឹកចិត្ត ។

វីណា-ត្រីសណាម៉ូធី, ចន-ម៉ាកឃិនឡេ, ហាន់នីគី-មេយឃើ, សូ-សុវណ្ណារិទ្ធ, ខ្ញែ-វ៉ាន់ដឺ-វ៉ារិន និង ភា-វ៉ុលគ្រីន បានអានរបាយការណ៍ពង្រាង និងផ្តល់មតិយោបល់ដ៏មានតំលៃដើម្បីកែលំអរបាយការណ៍នេះ ។ ដេវីត-គ្រេក បានអោយខ្ញុំធ្វើការងារសិក្សាស្រាវជ្រាវនេះ តាមបែបប្រៀបធៀប ។ រ៉ូប៊ីន ប៊ិដឹលវ៉ី បានលើកទឹកចិត្តខ្ញុំចាប់តាំងពីយើងបានជួបគ្នាដំបូងរយៈពេលបីឆ្នាំកន្លងទៅ ហើយក្នុងរយៈពេលសិក្សានេះ គាត់ក៏បានគាំទ្រ និងលើកទឹកចិត្តខ្ញុំ ដោយគ្មានការនឿយហត់ ។

ភ្នំពេញ, ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០០

ម៉លីន ហាស្សែលស្កូត

# សេចក្តីសង្ខេប

*ការគ្រប់គ្រងតាមមូលដ្ឋាននៅក្នុងអន្តរកាលនៃការផ្លាស់ប្តូរការយល់ឃើញរបស់អ្នកភូមិ និងឥទ្ធិពលរបស់កម្មវិធីសិលា* គឺជាការសិក្សាមួយផ្តោតទៅលើភូមិពីរនៅភាគពាយព្យនៃប្រទេសកម្ពុជា ដែលភូមិមួយនៅក្នុងខេត្តពោធិសាត់ និងមួយទៀតនៅក្នុងខេត្តបាត់ដំបង ។

ទិសដៅទាំងនេះគឺ ១. ដើម្បីទទួលបាននូវការយល់ដឹងអោយបានប្រសើរពីបទពិសោធន៍ និងការយល់ឃើញរបស់អ្នកភូមិចំពោះអាជ្ញាធរមូលដ្ឋាន។ ២. ដើម្បីធ្វើសេចក្តីសន្និដ្ឋានស្តីពីឥទ្ធិពលទៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន និង ៣. ដើម្បីពិភាក្សានូវអ្វីដែលជាឥទ្ធិពលពិតរបស់កម្មវិធីសិលាទៅលើការគ្រប់គ្រងតាមមូលដ្ឋាន ។

សិលា គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាល មានគោលបំណងកាត់បន្ថយភាពក្រីក្រ និងការបង្រួបបង្រួមតាមរយៈអភិបាលកិច្ចល្អតាមបែបវិមជ្ឈការ ដោយបង្កើតអោយមានថ្នាក់ឃុំជាភ្នាក់ងារអភិវឌ្ឍន៍ចម្បង ។

ការស្រាវជ្រាវត្រូវបានធ្វើឡើងនៅខែមិថុនា ឆ្នាំ១៩៩៩ ដល់ខែមេសា ឆ្នាំ២០០០ ដោយស្ត្រីជនជាតិខ្មែរ ២នាក់ និងជំនាញការស្ត្រីបរទេសម្នាក់ ដែលបានចំណាយពេលសរុបទាំងអស់ ២ខែនៅក្នុងភូមិនីមួយៗ ។

ផ្នែកទីមួយនៃការសិក្សាដែលផ្តោតលើ ***ការយល់ឃើញរបស់អ្នកភូមិទៅលើការគ្រប់គ្រងតាមមូលដ្ឋាន*** បានបង្ហាញថា ការគ្រប់គ្រងតាមភូមិត្រូវបានកត់សំគាល់ដោយទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន ហើយបានបង្ហាញអោយដឹងដែរថា មានកង្វះខាតនូវភាពច្បាស់លាស់អំពីអាណត្តិការគ្រប់គ្រងនិងប្រភពនៃអំណាច ។ ផ្នែកនេះក៏បានបង្ហាញអោយដឹងផងដែរថា ការយល់ដឹងរបស់អ្នកភូមិចំពោះថ្នាក់ឃុំ មិនមានភាពច្បាស់លាស់ទេ ព្រោះពួកគេគ្រាន់តែដឹងថា "ថ្នាក់លើ" តែប៉ុណ្ណោះ និងបានបង្ហាញអោយដឹងថា អ្នកភូមិមិនសូវមានការយល់ដឹងអំពីថ្នាក់លើឡើយ ហើយពួកគេច្រើនស្តាប់បង្គាប់ថ្នាក់លើទាំងនេះ ។

សេចក្តីសន្និដ្ឋានគឺថា កង្វះភាពច្បាស់លាស់ និងការស្ទាក់ស្ទើរមិនចង់មានតួនាទីក្នុងការដឹកនាំដើម្បីកាត់បន្ថយការទទួលខុសត្រូវ និងភាពស្របច្បាប់របស់អ្នកដឹកនាំនៅថ្នាក់ភូមិ ហើយអ្នកភូមិច្រើនទទួលយកអ្វីដែលអាជ្ញាធរ សំរេចដោយផ្ទុយទៅនឹងការផ្លាស់ប្តូរក្នុងការគ្រប់គ្រងនៅតាមមូលដ្ឋាន ប៉ុន្តែជួនកាលអ្នកភូមិក៏ត្រៀមខ្លួនក្នុងការទាមទារសិទ្ធិរបស់ពួកគេដែរ ។

ផ្នែកទីពីរនៃការសិក្សាដែលយកចិត្តទុកដាក់លើ *ឥទ្ធិពលរបស់សិលាទៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន* បានបង្ហាញថា កម្មវិធីសិលា (អន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ដទៃទៀត) ផ្តល់ឥទ្ធិពលបន្ថែមទៅលើអំណាចដែលមានស្រាប់ ផ្ទុយទៅវិញ ក៏មានការបែងចែកភារកិច្ចយ៉ាងច្បាស់លាស់របស់អ្នកដែលមានមុខតំណែងនៅក្នុងភូមិដែរ ។ អ្នកភូមិ មិនស្គាល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិជាក្រុមទេ និងមានការស្ទាក់ស្ទើរយ៉ាងខ្លាំងក្នុងការទទួលយកមុខតំណែងផ្នែកអភិវឌ្ឍន៍ ។ ការប្រជុំ និងការចូលរួមជាថវិកា ឬជាកំលាំងពលកម្មក្តី ពុំបានធ្វើអោយអ្នកភូមិមានការយល់ដឹងពីឥទ្ធិពល ឬភាពជាម្ចាស់ណាមួយនោះទេ ។ ផ្ទុយទៅវិញ ការគ្រប់គ្រងដែលមិនច្បាស់លាស់ទៅលើសកម្មភាពអភិវឌ្ឍន៍ អាចធ្វើអោយអ្នកភូមិចាត់វិធានការដែលបានរៀបចំជាស្រេច ដើម្បីតវ៉ាជាមួយអាជ្ញាធរភូមិ ។ ផ្នែកនេះក៏បង្ហាញដែរថា អ្នកភូមិមិនដឹងច្បាស់ពីតួនាទីរបស់ឃុំនៅក្នុងការងារអភិវឌ្ឍន៍ឡើយ ប៉ុន្តែពួកគេដឹងថាមានអ្នកធ្វើការជាច្រើនទៀតដែលពួកគេយល់ឃើញថា ជាភ្នាក់ងារអភិវឌ្ឍន៍ចម្បង ។

សេចក្តីសន្និដ្ឋានដែលទាក់ទងដល់ឥទ្ធិពលរបស់សិលាទៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន ត្រូវបានកំនត់ដោយទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន ។ ១. ឥទ្ធិពលរបស់សិលាទៅលើទំនោររបស់អ្នកភូមិ ដើម្បីតាមទារសិទ្ធិ ផុសចេញមកពីទង្វើរបស់អ្នកធ្វើការដែលមកពីក្រៅភូមិ និងវត្តមានរបស់អ្នកដឹកនាំថ្មី ។ ២. ឥទ្ធិពលរបស់សិលាទៅលើទំនាក់ទំនងរបស់អ្នកភូមិចំពោះថ្នាក់ឃុំ ត្រូវបានរាំងស្ទះដោយវត្តមានរបស់អង្គការអភិវឌ្ឍន៍ផ្សេងៗ ។

សេចក្តីសន្និដ្ឋានអំពីការពិភាក្សាដែលផ្តោតថា *តើមានផលប៉ះពាល់ទូទៅអ្វីដែលជាឥទ្ធិពលពិតប្រាកដរបស់សិលាទៅលើការគ្រប់គ្រងតាមមូលដ្ឋាន?* ១. សេចក្តីសន្និដ្ឋាននេះជំទាស់ថា សិលាអាចចូលរួមបង្កើនសិទ្ធិអោយប្រជាពលរដ្ឋបាន លុះត្រាតែប្រជាជនដឹងពីសិទ្ធិនិងការទទួលខុសត្រូវរបស់គេ ។ ២. សិលាអាចចូលរួមបង្កើតអោយមានតំណាងទទួលខុសត្រូវនៅក្នុងភូមិដោយមានអាណត្តិកំណត់ ។ ៣. សិលាអាចពង្រឹងការគ្រប់គ្រងនៅថ្នាក់ឃុំបាន ប្រសិនបើភ្នាក់ងារដទៃទៀត មិនធ្វើអ្វីដែលផ្ទុយពីទិសដៅនោះ ។

របាយការណ៍នេះរួមមានការអធិប្បាយដ៏ទូលំទូលាយអំពីតួនាទី និងទំនាក់ទំនងក្នុងការដឹកនាំនៅក្នុងភូមិទាំងពីរនេះ ។ ដើម្បីជួយអ្នកអានទទួលបាននូវទស្សនៈទូទៅនៃរបាយការណ៍នេះ និងដោយផ្អែកលើផ្នែកណាមួយដើម្បីអានអោយបានពេញលេញនោះ **ចំណុចសំខាន់ក្នុងសេចក្តីសង្ខេប** ត្រូវបានផ្តល់ជូនក្នុងទំព័រខាងក្រោមនេះ ។

# ចំនុចសំខាន់ៗក្នុងសេចក្តីសង្ខេប

## ជំពូក២: ការយល់ឃើញរបស់អ្នកភូមិ ចំពោះការគ្រប់គ្រងនៅតាមមូលដ្ឋាន

## ភូមិ

### *តួនាទី និងកិត្តិស័ព្ទរបស់រដ្ឋអំណាចមូលដ្ឋាន*

*ភូមិជ្រៃង: ឪពុកស្លូត និងបុរសខ្លាំងដែលគួរអោយខ្លាច*

- មេភូមិជាមនុស្សស្លូត អ្នកភូមិជាទូទៅ ចូលចិត្តគាត់ ។ អ្នកភូមិមានទំនាក់ទំនងជាមួយមេភូមិតាមបែបគាត់មានសិទ្ធជារៀមច្បង ។
- មានប្រធានជីវពលដ៏តឹងរឹងម្នាក់ ដែលអ្នកភូមិមានការខ្លាចរអា មិនចូលចិត្តដោយសារអត្តចរិក និងបុគ្គលិកលក្ខណៈរបស់គាត់ ហើយមានអំណាចជាងមេភូមិ ព្រោះគាត់ស្គាល់អ្នកធ្វើការនៅថ្នាក់លើ ។

*ភូមិគោកដូង: ប្រធានស្លូត ហើយអនុប្រធានចេះអក្សរ*

- ការដឹកនាំនៅថ្នាក់ភូមិមានការប្រកាន់ខ្ជាប់តួនាទី ច្រើនជាងនៅភូមិជ្រៃង ។
- មេភូមិជាមនុស្សស្លូត ស្មោះត្រង់ ហើយអ្នកភូមិចូលចិត្តគាត់ ទោះបីគាត់មិនសូវឈ្លាសវៃក៏ដោយ ។
- អនុប្រធានភូមិចេះអក្សរ និងសកម្មជាងមេភូមិ ហើយអ្នកភូមិក៏ចូលចិត្តគាត់ដែរ ។
- ជនមាតុភូមិនិវត្តន៍ដែលនៅឆ្ងាយពីភូមិចាស់ មិនស្គាល់មេភូមិទេ តែគេស្គាល់អនុប្រធានច្បាស់ជាង ។

### *ប្រវត្តិនៃការដឹកនាំនៅក្នុងភូមិនាពេលបច្ចុប្បន្ន*

*ភូមិជ្រៃង: ការផ្លាស់ប្តូរ ភាពមិនច្បាស់លាស់ និងភាពស្ទាក់ស្ទើរ*

- មានការផ្លាស់ប្តូរសមាសភាពថ្នាក់ដឹកនាំនៅក្នុងភូមិជាច្រើនដង ក្នុងរយៈពេល២០ឆ្នាំកន្លងទៅនេះ ។ គ្មានអ្នកណាដឹងច្បាស់ពីសមាសភាពទាំងនេះ ត្រូវបានផ្លាស់ប្តូរដោយរបៀបណា និងនៅពេលណានោះទេ ហើយក៏នៅមិនទាន់ដឹងពិតប្រាកដថា អ្នកណាមានតួនាទីធ្វើអ្វីខ្លះនោះដែរ ។
- មានភាពស្ទាក់ស្ទើរមិនចង់បានមុខតំណែងផ្នែករអាជ្ញាធរ ។
- ព្រះសង្ឃ *អាចារ្យ* ចាស់ព្រឹទ្ធាចារ្យ ជាមនុស្សដែលអ្នកភូមិគោរពរាប់អាន និងអោយតំលៃជាអ្នកដឹកនាំក្រៅផ្លូវការ ។

*ភូមិគោកដូង: ស្ថិរភាព ច្បាស់លាស់ និងស្អាកស្ទើរ*

- ថ្នាក់ដឹកនាំនៅក្នុងភូមិកាន់តែមានស្ថិតភាព និងច្បាស់លាស់ជាងនៅភូមិជ្រែង ។
- មានភាពស្ទាក់ស្ទើរមិនចង់បានមុខតំណែងផ្នែកអាជ្ញាធរ ដូចនៅភូមិជ្រែងដែរ ។
- ព្រះសង្ឃ អាចារ្យ ចាស់ព្រឹទ្ធាចារ្យ មិនបានទទួលការគោរពជាពិសេស និង អោយតំលៃជាអ្នកដឹកនាំក្រៅផ្លូវការដូចភូមិជ្រែងទេ ។

## ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ភូមិ

*ជ្រែង: ម្នាក់មិននៅ ម្នាក់ទៀតមិនត្រឹមត្រូវ និងថ្លៃ*

- អ្នកភូមិមានការរារែកក្នុងការពិភាក្សាជាមួយអាជ្ញាធរថ្នាក់ភូមិ ព្រោះមេភូមិមិនដែលនៅផ្ទះ ហើយពួកគេមិនទុកចិត្តជីវពលឡើយ ម្យ៉ាងទៀតគាត់ទារថ្លៃឈ្នួលពេលគេអោយគាត់ជួយ ។
- ការដោះស្រាយជំលោះ គឺជាមូលហេតុដ៏សំខាន់ដែលអ្នកភូមិទៅពិគ្រោះជាមួយអាជ្ញាធរថ្នាក់ភូមិ ហើយមូលហេតុផ្សេងទៀតដែលអ្នកភូមិទៅពិភាក្សាជាមួយអាជ្ញាធរថ្នាក់ភូមិដែរនោះ គឺការធ្វើលិខិតរៀបអាពាហ៍ពិពាហ៍ ឬការលែងលះគ្នា ។
- ជីវពលកំពុងយកកិច្ចការរបស់មេភូមិដើម្បីដឹកនាំ ។

*ភូមិគោកដូង: ម្នាក់ត្រឹមត្រូវ តែមិនរហ័សរហួន ម្នាក់ទៀតមានប្រសិទ្ធិភាព ប៉ុន្តែថ្លៃ*

- រដ្ឋអំណាចថ្នាក់ភូមិមានពេលអោយអ្នកភូមិទៅជួប និងទុកចិត្តជាងនៅភូមិជ្រែង ហើយអ្នកភូមិតែងតែទៅពិគ្រោះជាមួយរដ្ឋអំណាចនៅថ្នាក់ភូមិដែរ ។ ប៉ុន្តែជនមាតុភូមិនិវត្តន៍ដែលរស់នៅឆ្ងាយពីភូមិចាស់ មានឱកាសពិភាក្សាជាមួយរដ្ឋអំណាចនៅថ្នាក់ភូមិតិចជាងអ្នកភូមិចាស់ ។
- ដូចនៅភូមិជ្រែងដែរ ការដោះស្រាយជំលោះ គឺជាមូលហេតុដ៏សំខាន់ដែលអ្នកភូមិទៅពិភាក្សាជាមួយអាជ្ញាធរថ្នាក់ភូមិ និងមូលហេតុផ្សេងទៀត ដូចជាធ្វើលិខិតរៀបអាពាហ៍ពិពាហ៍ ឬការលែងលះគ្នា ។
- អនុប្រធានភូមិមានប្រសិទ្ធិភាពជាង ប៉ុន្តែមេភូមិត្រឹមត្រូវជាង ហើយមិនទារឈ្នួលពេលអ្នកភូមិអោយគាត់ជួយទេ ។

## ឃុំ

## ការយល់ដឹងចំពោះថ្នាក់ឃុំ

*ភូមិជ្រែង: ពួកគេនិយាយអ្វី យើងធ្វើហ្នឹង*

- ការយល់ដឹងរបស់អ្នកភូមិចំពោះថ្នាក់ឃុំមានភាពស្រពិចស្រពិលដោយគ្រាន់តែដឹងថា "ថ្នាក់លើ" ។
- អ្នកភូមិមិនសូវស្គាល់មុខ និងឈ្មោះរបស់មន្ត្រីថ្នាក់ឃុំ ស្រុក និង ខេត្តទេ ប៉ុន្តែគេកាន់តែដឹងច្បាស់ថាថ្នាក់លើជាកន្លែងមួយដែលនៅឆ្ងាយដាច់ស្រយាល និងមិនអាចមានឱកាសចូលជួបបាន ។

- មេភូមិ មេឃុំ មិនសូវជិតដិត និងមានឋានៈទាបជាងអាជ្ញាធរថ្នាក់លើ ។

*ភូមិគោកដូង: ខ្ញុំគ្រាន់តែជាអ្នកនៅថ្នាក់ក្រោមប៉ុណ្ណោះ ខ្ញុំត្រូវស្តាប់គេ*

- ដូចនៅភូមិជ្រែងដែរ ជាទូទៅ អ្នកភូមិមិនបែកថ្នាក់ឃុំអោយដាច់ពី "ថ្នាក់លើ" ទេ ។
- អ្នកភូមិមានភាពជិតដិតជាមួយមន្ត្រីថ្នាក់លើដោយលក្ខណៈបុគ្គលតិចជាងភូមិជ្រែង ប៉ុន្តែគេមានទំនោរក្នុងការរកថ្នាក់លើអោយជួយច្រើនជាងអ្នកភូមិជ្រែង ប្រសិនបើគេមានកិច្ចការដែលត្រូវទៅ ។
- មេភូមិជាមនុស្សស្មោះត្រង់ ប៉ុន្តែមិនសូវវៀសវៃប៉ុន្មានទេក្នុងការទាក់ទងជាមួយអាជ្ញាធរថ្នាក់លើ ឯមេឃុំព្យាយាមខ្លះខ្លែងក្នុងការទាក់ទងជាមួយថ្នាក់លើ ប៉ុន្តែគាត់គិតថាគាត់គ្មានអំណាចនោះទេ ។

## *ថ្នាក់ឃុំ និងថ្នាក់លើចុះទៅភូមិ*

*ភូមិជ្រែង: គេមកទារពន្ធ ហើយក៏មកហូបចាយដែរ*

- អ្នកភូមិមិនបានដឹងជាមុនថា នៅពេលណាខាងរដ្ឋអំណាចនឹងមកជួបពួកគេទេ ។
- នៅពេលដែលខាងរដ្ឋអំណាចចុះមក ជាទូទៅអ្នកភូមិមិនដឹងច្បាស់ថាពួកគេជាអ្នកណានោះទេ ប៉ុន្តែអ្នកភូមិតែងតែធ្វើតាមបញ្ជាថ្នាក់លើហើយបង់ពន្ធ និងកំរៃដែលថ្នាក់លើទាមទារអោយបង់ ។

*ភូមិគោកដូង: ជាស៊ីប្រចាំថ្ងៃដែលត្រូវបង់អោយអ្នកធំ*

- អ្នកភូមិបង់ថ្លៃប័ណ្ណគ្រួសារ ដូចនៅភូមិជ្រែងដែរ ទោះជាគេមិនដឹងច្បាស់ថាធ្វើប័ណ្ណទាំងនេះដើម្បីអ្វី ហើយទោះជាគេគិតថា គេនឹងបង់លុយធ្វើប័ណ្ណថ្មីក៏ដោយ ។
- ម្ចាស់តៀមបង់ជាស៊ីជារៀងរាល់ថ្ងៃ ហើយមេឃុំនិយាយថា គាត់មិនអោយម្ចាស់តៀមបង់ទេ ប៉ុន្តែគាត់មិនអាចជួយបាន ។

## *អ្នកភូមិទៅជួបថ្នាក់ឃុំនិងថ្នាក់លើ*

*ជ្រែង: ទំនាក់ទំនងទៅតាមខ្សែបណ្តោយ*

- អ្នកភូមិដឹងថា ពួកគេមិនអាចរំលងមេភូមិដើម្បីទៅជួបថ្នាក់លើតែម្តងនោះទេ ។
- មូលហេតុសំខាន់ដែលអ្នកភូមិទៅជួបអាជ្ញាធរថ្នាក់លើ គឺការដោះស្រាយជំលោះ ប៉ុន្តែវាត្រូវចំណាយលុយច្រើន ។ ដូច្នេះ អ្នកភូមិភាគច្រើនលែងចង់ទៅរកអាជ្ញាធរទាំងនោះអោយជួយទៀតហើយ ។
- អ្នកបិតស្រាក្នុងភូមិបានទទួលជោគជ័យក្នុងការតវ៉ាជាមួយអាជ្ញាធរដែល "ហាម" បិតស្រានៅក្នុងភូមិ ។

*ភូមិគោកដូង: មិនមានកិច្ចការដែលត្រូវទៅ*

- អ្នកភូមិអាចទៅជួបអាជ្ញាធរថ្នាក់លើដោយមិនបាច់ឆ្លងកាត់មេភូមិជាមុនទេ ប៉ុន្តែ ពួកគេមិនសូវមានកិច្ចការទៅជួបថ្នាក់លើទេ ។

- មិនដូចនៅភូមិជ្រែងទេ អ្នកភូមិជាច្រើនទៅឃុំដើម្បីធ្វើសំបុត្ររៀបអាពាហ៍ពិពាហ៍ ប៉ុន្តែអ្នកភូមិកម្រយករឿងជំលោះទៅដោះស្រាយនៅថ្នាក់លើណាស់ ។
- អ្នកភូមិភាគច្រើន បានចុះហត្ថលេខាលើលិខិតតវ៉ា ដើម្បីទាមទារសិទ្ធិនេសាទត្រីនៅក្នុងបឹងមួយចំនួន ហើយអ្នកភូមិមួយចំនួនតូចបានចូលរួមធ្វើបាតុកម្មដែលហាក់ដូចជាបានទទួលជោគជ័យ ។

## សេចក្តីសន្និដ្ឋាន

### ទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន

- ទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន និងបុគ្គលិកលក្ខណៈប៉ះពាល់យ៉ាងខ្លាំងដល់ការគ្រប់គ្រងនៅក្នុងភូមិ ។
- ភាពមិនច្បាស់លាស់ពីបញ្ហាគ្រប់គ្រង និងប្រភពនៃអំណាច ធ្វើអោយមានការលំបាកក្នុងការទទួលតួនាទីជាអ្នកដឹកនាំ និងកាត់បន្ថយភាពស្របច្បាប់របស់ពួកគេ ។

### ភាពស្ទាក់ស្ទើរ

- ភាពរារែកក្នុងការទទួលតួនាទីជាថ្នាក់ដឹកនាំ ធ្វើអោយប្រជាជនមានការលំបាកក្នុងការទាមទារយកទង្វើដ៏មានប្រសិទ្ធិភាពពីអ្នកដឹកនាំទាំងនោះ ។

### ការទទួលយក

- និន្នាការដ៏ខ្លាំងក្លាមួយរបស់អ្នកភូមិមួយចំនួន ដើម្បីទទួលយកនូវអ្វីដែលអាជ្ញាធរសំរេច ដោយតួបផ្សំជាមួយ ភាពមិនជិតដិត និង កង្វះខាតក្តីរំពឹងផ្សេងៗទៅលើអាជ្ញាធរ មានភាពផ្ទុយនឹងការផ្លាស់ប្តូរការគ្រប់គ្រងនៅតាមមូលដ្ឋាន ។

### បណ្តឹងតវ៉ា

- អ្នកភូមិកំពុងត្រៀមខ្លួនដើម្បីតវ៉ាទាមទារសិទ្ធិរបស់គេ ប្រសិនបើមានការចាំបាច់ និងប្រសិនបើមានអ្នកដឹកនាំធ្វើ ។

## ជំពូក៣: ឥទ្ធិពលសីលានៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន

### ភូមិ

### ភារកិច្ច និងមុខតំណែងថ្មី

*ភូមិជ្រែង ពួកគេជួយភូមិនេះគាំងពីគ្មានអ្វីសោះ*

- មុខតំណែងដែលទាក់ទិននឹងសកម្មភាពអភិវឌ្ឍន៍ត្រូវបានបង្កើតឡើង និងត្រូវបានបំពេញបន្ថែមតាមការចាត់តាំងដោយមេភូមិ ឬបោះឆ្នោតជ្រើសរើសដោយអ្នកភូមិ ។

- បុរសមួយក្រុមតូចដែលមានមុខតំណែងខាងអាជ្ញាធរ បានទទួលមុខតំណែងផ្នែកអភិវឌ្ឍន៍ ប៉ុន្តែក្នុងនោះ ក៏មានស្ត្រីចំនួន ៤នាក់ដែរ ។
- អ្នកភូមិមួយចំនួនធំមិនស្គាល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិជាក្រុមទេ ។ ប៉ុន្តែអ្នកភូមិស្គាល់សមាជិកម្នាក់ៗ ដោយសារការងារពិសេសៗដូចជា លើកផ្លូវ ដំណើរការធនាគារស្រូវ ឬហៅទៅប្រជុំ ។
- អ្នកដែលមានមុខតំណែងផ្នែកអភិវឌ្ឍន៍និយាយថា មិនចង់បានការងារនេះទេ ព្រោះមូលហេតុសំខាន់នោះពួកគេគិតថា អ្នកភូមិដទៃទៀតមិនចូលចិត្តពួកគេ ម្យ៉ាងវិញទៀតមានការប្រជែងគ្នាក្នុងការទៅចូលរួមវគ្គបណ្តុះបណ្តាលនៅពេលដែលមានប្រាក់ឧបត្ថម្ភ ។

*ភូមិគោកដូង: គេហៅទៅប្រជុំ*

- ដូចនៅក្នុងភូមិជ្រែងដែរ មុខតំណែងថ្មីដែលទាក់ទិននឹងសកម្មភាពអភិវឌ្ឍន៍ត្រូវបានធ្វើឡើងតាមរយៈការបោះឆ្នោតជ្រើសរើស ឬការចាត់តាំង ។
- មុខតំណែងទាំងនេះ ត្រូវបានផ្តោតទៅលើតែមនុស្សមួយក្រុមតូចដែលមានតែមនុស្សពីរនាក់ប៉ុណ្ណោះមានមុខតំណែងផ្នែកអាជ្ញាធរ ហើយរួមមានស្ត្រីចំនួន ៤នាក់ផងដែរ ។
- ដូចនៅភូមិជ្រែងដែរ អ្នកភូមិមួយចំនួនធំមិនស្គាល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិជាក្រុមទេ ។ អ្នកភូមិស្គាល់បុរសពីរនាក់ច្បាស់ជាងគេ តាមរយៈសកម្មភាពធនាគារស្រូវ ។ អ្នកភូមិស្គាល់អ្នកមានមុខតំណែងផ្នែកអភិវឌ្ឍន៍សំខាន់នោះ ដោយសារការហៅទៅប្រជុំ ។
- អ្នកដែលមានមុខតំណែងផ្នែកអភិវឌ្ឍន៍និយាយថា ពួកគេរវៃកក្នុងការធ្វើការងារនេះ ដោយសារពួកគេធ្វើការងារច្រើន ប៉ុន្តែគ្មានប្រាក់ឧបត្ថម្ភ។ ប៉ុន្តែពួកគេត្រូវតែធ្វើដោយសារការចាត់តាំង ឬអ្នកភូមិបានបោះឆ្នោតអោយរួចទៅហើយ ។

## ***ការផ្លាស់ប្តូរទំនាស់ផ្នែកអំណាច***

*ភូមិជ្រែង: អំណាចដែលមានសម្រាប់ចាត់ចែងការត្រួតត្រារបស់គេ និងកាន់តែអន់ថយ*

- អន្តរាគមន៍ផ្នែកអភិវឌ្ឍន៍បានធ្វើអោយអ្នកដឹកនាំក្នុងភូមិពីរនាក់ កាន់តែមានអំណាច ប៉ុន្តែ ក៏កាន់តែអន់ថយដែរ ។
- មេភូមិ/ប្រធាន គ.អ.ភ គ្រប់គ្រងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងប្រគល់ការទទួលខុសត្រូវអោយទៅបុរសច្រើនជាងស្ត្រី ។
- មានសមាជិក គ.អ.ភ មួយចំនួនតូច និងអ្នកដទៃទៀត អាចក្លាយជាអ្នកដឹកនាំជំនួសមេភូមិបាន ។
- អន្តរាគមន៍ផ្នែកអភិវឌ្ឍន៍បានប៉ះពាល់ដល់តួនាទីរបស់ព្រះសង្ឃ ដោយពួកគេកំពុងជ្រៀតជ្រែកការងាររបស់ព្រះសង្ឃ និងកំពុងទាក់ទាញព្រះសង្ឃអោយចូលរួមក្នុងការងាររបស់ពួកគេ ។

*ភូមិគោកដូង: យើងមិនដែលភ្លេចគ្នាទេ*

- ការជ្រើសរើសអ្នកដែលមិនមានមុខតំណែងផ្នែកអាជ្ញាធរ អោយមានមុខតំណែងផ្នែកអភិវឌ្ឍន៍នោះ បានធ្វើអោយមេភូមិ និងអ្នកដឹកនាំផ្នែកអភិវឌ្ឍន៍មានការកិច្ចផ្សេងគ្នា និងមានដំណើរការល្អទៀតផង ហេតុដូចនេះហើយទើបបណ្តាលអោយមានរចនាសម្ព័ន្ធដឹកនាំនៅថ្នាក់ភូមិដ៏រឹងមាំ ។
- កូនាទីរបស់មេក្រុម កំពុងឈានទៅរកការបាត់បង់ដោយភ្នាក់ងារអភិវឌ្ឍន៍ធ្វើការងារជំនួសពួកគេ ។
- បុរសពីរនាក់ដែលធ្លាប់មានមុខតំណែងនៅក្នុងភូមិ បានទទួលឋានៈជាអ្នកដឹកនាំដែលអ្នកភូមិទទួលស្គាល់ដោយសារតែការចូលរួមរបស់គេនៅក្នុងសកម្មភាពអភិវឌ្ឍន៍ ហើយបុរសទីបី ក៏កំពុងត្រូវបានអ្នកភូមិទទួលស្គាល់ថា ជាអ្នកដឹកនាំដោយសារការចូលរួមរបស់គាត់ក្នុងសកម្មភាពអភិវឌ្ឍន៍ដែរ ។
- ប៉ុន្តែការប្រមូលផ្តុំការងារ និងការទទួលខុសត្រូវអោយបុរសទាំងពីរនាក់នោះ បណ្តាលអោយអ្នកផ្សេងទៀត ជាពិសេស នារីនឹងគ្មានឱកាសទទួលជំនាញដឹកនាំការងារអភិវឌ្ឍន៍ និងមិនមានអ្នកទទួលស្គាល់ថែមទៀតផង ។

## ឱកាស និងការទទួលខុសត្រូវសំរាប់អ្នកភូមិ

*ភូមិជ្រែង: យើងអាចស្នើសុំ ប៉ុន្តែគេជាអ្នកសំរេច*

- ទោះបីអ្នកភូមិស៊ាំនឹងការទៅចូលរួមប្រជុំ និងស្នើសុំអ្វីៗពីថ្នាក់លើក៏ដោយ ក៏ពួកគេពុំមានការយល់ដឹងពីឥទ្ធិពលទៅលើការសំរេចចិត្តអំពីសកម្មភាពអភិវឌ្ឍន៍ឡើយ ។
- ការចូលរួមដាក់កំលាំងពលកម្ម និងថវិកា ពុំធ្វើអោយអ្នកភូមិយល់ដឹងពីភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ខ្លួនឡើយ ។
- ការគ្រប់គ្រងមិនច្បាស់លាស់ និងភាពអយុត្តិធម៌ដែលទាក់ទិននឹងសកម្មភាពអភិវឌ្ឍន៍ អាចបណ្តាលអោយអ្នកភូមិខឹងសម្បារ និងរៀបចំធ្វើពាក្យបណ្តឹងពីអាជ្ញាធរថ្នាក់ភូមិ ។

*ភូមិគោកដូង: អ្នកភូមិចង់ធ្វើការ ដោយសារមានប្រាក់ឧបត្ថម្ភ*

- វត្តមានរបស់ថ្នាក់ដឹកនាំការងារអភិវឌ្ឍន៍ពុំបានបង្កើតអោយមានការយល់ដឹង (ក្តីពឹង រឺការទាមទារអ្វី) ពីឥទ្ធិពលក្នុងចំណោមអ្នកភូមិទៅលើការសំរេចចិត្តអំពីសកម្មភាពអភិវឌ្ឍន៍ឡើយ ។
- ដូចនៅក្នុងភូមិជ្រែងដែរ ការចូលរួមវិភាគទានពុំធ្វើអោយអ្នកភូមិមានការយល់ដឹងពីភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ខ្លួនទេ ។

## ឃុំ

### *ការផ្លាស់ប្ដូរ ការយល់ឃើញ និងទំនាក់ទំនងរបស់អ្នកភូមិជាមួយថ្នាក់ឃុំ*

*ភូមិជ្រែង: មេឃុំមកទីនេះ នៅពេលដែលយើងលើកផ្លូវថ្មល់*

- មេឃុំកាន់តែមានភាពស្និទ្ធស្នាលបន្តិចម្ដងៗជាមួយអ្នកភូមិមួយចំនួនធំ ។ ប៉ុន្តែពួកគេមិនដឹងច្បាស់ពីតួនាទីរបស់ឃុំនៅក្នុងសកម្មភាពអភិវឌ្ឍន៍ទេ និងនៅតែយល់ថា ឃុំជាកន្លែងដែលនៅឆ្ងាយ ហើយតួនាទីសំខាន់របស់ឃុំ គឺដោះស្រាយពីរឿងសន្តិសុខ និងជំលោះ ។
- សមាជិក គ.អ.ភ មិនដឹងពីតួនាទីរបស់គណៈកម្មាធិការអភិវឌ្ឍន៍ឃុំទេ (គ.អ.ឃ) ពុំមានការយល់ដឹងពីឥទ្ធិពលនៅក្នុងឃុំឡើយ ហើយមានតែប្រធាន គ.អ.ភ (មេភូមិ) ទេ ដែលមានទំនាក់ទំនងជាមួយឃុំ ។
- ជាទូទៅ អ្នកភូមិគិតថា ឃុំជាផ្នែកតូចមួយរបស់ "ថ្នាក់លើ" ។ វត្តមានរបស់អង្គការអភិវឌ្ឍន៍ផ្ដល់ឥទ្ធិពលដ៏សំខាន់បំផុតទៅលើការយល់ដឹង និងទំនាក់ទំនងរបស់អ្នកភូមិជាមួយថ្នាក់លើទាំងនេះ ។

*ភូមិគោកដូង: ខ្ញុំទៅជជែកលេងជាមួយមេឃុំ*

- មេឃុំឧស្សាហ៍ចុះមកភូមិជាងពេលមុន ប៉ុន្តែដូចនៅភូមិជ្រែងដែរ អ្នកភូមិមិនយល់ច្បាស់ពីតួនាទីរបស់ឃុំក្នុងសកម្មភាពអភិវឌ្ឍន៍ទេ ។
- សមាជិក គ.អ.ភ មានភាពស្និទ្ធស្នាលជាមួយឃុំជាងមុន ប៉ុន្តែពួកគេមិនដឹងច្បាស់ថា អ្នកណាខ្លះនៅក្នុងជួរ គ.អ.ឃ ហើយគណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដើម្បីអ្វីនោះទេ ។ ពេលបច្ចុប្បន្ន ប្រធាន គ.អ.ភ និងមេភូមិ ជាអ្នកទំនាក់ទំនងជាមួយឃុំ ។
- ដូចនៅភូមិជ្រែងដែរ ជាទូទៅអ្នកភូមិមិនបានគិតថា ឃុំនៅដាច់ដោយឡែកពី "ថ្នាក់លើ" ដទៃទៀតទេ ហើយកាន់តែមានសារៈសំខាន់ជាងការផ្លាស់ប្ដូរទំនាក់ទំនងរបស់អ្នកភូមិចំពោះថ្នាក់ឃុំ គឺ ដោយសារវត្តមានរបស់អង្គការ ។

## សេចក្ដីសន្និដ្ឋាន

### *ការគ្រប់គ្រងនៅថ្នាក់ភូមិ*

- ឥទ្ធិពលផ្ទាល់របស់សិលាទៅលើការគ្រប់គ្រងនៅថ្នាក់ភូមិ គឺត្រូវបានកំនត់យ៉ាងទូលាយដោយទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន ប៉ុន្តែវាមានលទ្ធភាពដើម្បីបង្កើតឱកាសជាច្រើនទៀតសំរាប់អោយអ្នកដឹកនាំថ្មី ឬជ្រើសរើសអ្នកដឹកនាំបន្ថែមទៀត ។

### *ទំនោររបស់អ្នកភូមិ ក្នុងការទាមទារសិទ្ធិ*

- ឥទ្ធិពលដែលសិលាអាចមានទៅលើទំនោររបស់អ្នកភូមិក្នុងការទាមទារសិទ្ធិរបស់គេ មិនមែនកើតឡើងពីការចូលរួមប្រជុំ ឬវិភាគទាននោះទេ ប៉ុន្តែកើតឡើងដោយសារវត្តមានរបស់ភ្នាក់ងារ រចនាសម្ព័ន្ធភ្នាក់ងារអភិវឌ្ឍន៍ និងអ្នកដឹកនាំថ្មី ។

### ទំនាក់ទំនងរបស់អ្នកភូមិចំពោះឃុំ

- ឥទ្ធិពលរបស់សិលាទៅលើទំនាក់ទំនងរបស់អ្នកភូមិចំពោះឃុំដែលកើតឡើងនោះ ត្រូវបានរាំង

ដោយសារវត្តមានរបស់អង្គការ និងដោយសារអ្នកធ្វើការងារអភិវឌ្ឍន៍មានប្រាក់ឧបត្ថម្ភជាងបុគ្គលិកឃុំ ។

### ជំពូក៤: តើអ្វីទៅដែលជាឥទ្ធិពលពិតប្រាកដរបស់សិលាទៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន?

### សិទ្ធិជាប្រជាពលរដ្ឋ

- សិលាអាចចូលរួមបង្កើនសិទ្ធិជាប្រជាពលរដ្ឋ លុះត្រាតែប្រជាពលរដ្ឋទាំងនោះដឹងពីសិទ្ធិ និងការទទួលខុសត្រូវរបស់គេដែរ ។

### តំណាងភូមិ

- សិលាអាចចូលរួមក្នុងការបង្កើតអ្នកតំណាងដែលទទួលខុសត្រូវនៅក្នុងភូមិ ដោយមានអាណត្តិកំណត់ ប៉ុន្តែវាមិនសង្ឃឹមអោយបានពិតប្រាកដថា សិលាអាចផ្លាស់ប្តូរការគ្រប់គ្រងនៅថ្នាក់ភូមិក្នុងរយៈពេលដ៏ខ្លីនោះទេ ។

### ការគ្រប់គ្រងនៅថ្នាក់ឃុំ

- សិលាអាចពង្រឹងការគ្រប់គ្រងដែលទទួលបន្ទុកនៅថ្នាក់ឃុំ ប៉ុន្តែឥទ្ធិពលរបស់សិលានឹងត្រូវចប់ដំរាបណាភ្នាក់ងារដទៃទៀត ដូចជាអង្គការអភិវឌ្ឍន៍ និងគណបក្សនយោបាយមិនគាំទ្រគោលបំណងនេះ ។

# អក្សរកាត់ និងបទានុក្រម

| | |
|---|---|
| ADRA | Adventist Development and Relief Agency |
| AS | អង្គការអភិវឌ្ឍន៍ស្ត្រី |
| CARERE I | ការចើ្រសមាហរណកម្ម និងការតាំងទីលំនៅឡើងវិញនៅកម្ពុជាពីឆ្នាំ១៩៩២-១៩៩៥ |
| CARERE II | Cambodia Area Rehabilitation and Regeneration; 1996-2000 |
| CDC | គណៈកម្មាធិការអភិវឌ្ឍន៍ឃុំ |
| CFDS | សេវាអភិវឌ្ឍន៍គ្រួសារកម្ពុជា |
| CIAP | តំពេងអូស្ត្រាលី អ៊ីរ៉ កម្ពុជា |
| CRC | កាកបាទក្រហមកម្ពុជា |
| DCC | Danish Cambodian Consortium |
| DFT | ក្រុមសម្របសម្រួលស្រុក |
| IDE | អភិវឌ្ឍន៍បច្ចេកទេសស្នប់ទឹកកសិកម្ម |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IWDA | ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ |
| LCB | មន្ត្រីពង្រឹងសមត្ថភាពមូលដ្ឋាន |
| LDF | ថវិកាអភិវឌ្ឍន៍មូលដ្ឋាន |
| LICADHO | សម្ព័ន្ធផ្សព្វផ្សាយ និងការពារសិទ្ធិមនុស្សនៅកម្ពុជា |
| LPP | ដំណើរការកសាងផែនការមូលដ្ឋាន |
| LWS | អង្គការលូថេរ៉ានបំរើពិភពលោក |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| PDRD | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| PRDC | គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| RDS | រចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ |
| TPO | អង្គការសុខភាពផ្លូវចិត្ត |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNHCR | ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន |

| | |
|---|---|
| UNOPS | ការិយាល័យអង្គការសហប្រជាជាតិ ដើម្បីសេវាកម្មវិធី |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| | |
| *អាចារ្យ* | ចាស់ព្រឹទ្ធាចារ្យដែលអ្នកផងគោរពដោយសារចំណេះដឹងផ្នែកពុទ្ធសាសនារបស់គាត់ និងពិធីបុណ្យ ហើយត្រូវបានចាត់ទុកជាគ្រូផ្លូវនៃជីវិតរបស់ពុទ្ធសាសនិក និងជាអ្នកដែលរៀបចំធ្វើបុណ្យសាសនា ។ |
| *អង្គការ* | ពាក្យដែលអ្នកភូមិប្រើយ៉ាងទូលាយ និងបកប្រែជាទូទៅថា ជាអង្គការអភិវឌ្ឍន៍ ប៉ុន្តែក៏អាចរួមមានរដ្ឋអំណាច និងអ្នកនយោបាយផងដែរ ។ |
| *ចំការ* | ដីកសិកម្មដែលត្រូវបានគេប្រើដើម្បីដាំដំណាំជាងស្រូវ |
| *ក្រមា* | ក្រមាដែលស្លៀក និងប្រើប្រាស់បានទាំងមនុស្សប្រុស និងស្រី |
| *សែន/សែនកូន* | ពិធីរៀបការដែលលឿន និងមិនចាំបាច់ចំណាយថវិកាច្រើន ។ ជាទូទៅត្រូវបានអនុវត្តដោយប្តីប្រពន្ធដែលមិនអាចមានលទ្ធភាពរៀបការ ឬអ្នកដែលប្រញាប់រៀបការដោយសារពួកគេបាននៅជាមួយគ្នាមុន ។ នៅភូមិគោកដូង អ្នកភូមិនិយាយថា ឥឡូវនេះសែនកូនច្រើនជាងរៀបការ ។ |
| *គ្រដោក* | បន្ទះឫស្សីដែលប្រជាជនគោះ ដើម្បីប្រកាសអាសន្នដល់អ្នកដទៃអោយប្រយ័ត្នពីរឿងចោរ ឬបញ្ហាផ្សេងៗ ។ |

# ជំពូក ១

# សេចក្ដីផ្ដើម

## ការចុះចេញពីម៉ាស៊ីនឈូសពង្រាប

*ដើម្បីរំលេចផែ្នកក្នុងការសិក្សានេះ មិត្តភក្ដិថ្មីម្នាក់ដែលមានពាក្យប្រៀបធៀបច្រើន បានអោយពាក្យប្រៀបធៀបមួយឃ្លាសំរាប់ការងារសិក្សាដែលយើងកំពុងស្រាវជ្រាវ ។ គាត់បានធ្វើការប្រៀបធៀបបទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ ទៅនឹងម៉ាស៊ីនឈូសពង្រាបមួយដែលចូលទៅក្នុងភូមិ ឆ្លងកាត់ ហើយចេញទៅវិញ ។ អ្នកធ្វើការខាងអភិវឌ្ឍន៍ និងអ្នកស្រាវជ្រាវភាគច្រើន បានយកចិត្តទុកដាក់ទៅលើម៉ាស៊ីនពង្រាបនោះ ។ យើងអង្គុយនៅលើវា មើលឆ្វេង ស្ដាំ ពីមុខ ពីក្រោយ ពេលនោះទើប យើងអាចនិយាយពីវាជាមួយអ្នកភូមិបាន ។ ប៉ុន្តែនៅពេលដែលម៉ាស៊ីនឈូសពង្រាបនេះទៅបាត់ វាដូចគ្នានឹងភ្នាក់ងារអភិវឌ្ឍន៍ និងអ្នកស្រាវជ្រាវដែលចាកចេញពីភូមិដែរ ។*

*បទអន្តរាគមន៍នៃការសិក្សារបស់យើង គឺដើម្បីជៀសអោយឆ្ងាយពីរូបភាពនៃម៉ាស៊ីនឈូសពង្រាបនោះ . យើងចង់មើលទិដ្ឋភាព និងការរស់នៅរបស់ប្រជាជននៅក្នុងភូមិ២ ព្រមទាំងព្យាយាមស្វែងយល់ថាតើម៉ាស៊ីនឈូសពង្រាបនោះមានន័យដូចម្ដេចចំពោះពួកគេ ។*

របាយការណ៍នេះ គឺជាលទ្ធផលបណ្ដោះអាសន្ននៃការសិក្សាដែលត្រូវបានធ្វើឡើងនៅខែ មិថុនា ឆ្នាំ១៩៩៩ ដល់ខែកក្កដា ឆ្នាំ២០០០ ។ របាយការណ៍នេះ គឺផ្អែកទៅលើពត៌មានមួយចំនួនតូចដែលប្រមូលបាន និងនៅលើការវិភាគជាលើកដំបូង ។ ដំណាក់កាលបន្ទាប់ នឹងផ្ដោតទៅលើពត៌មានដែលប្រមូលបានពីភូមិដើម្បីតភ្ជាប់វាជាមួយទ្រឹស្ដី និងការសិក្សាដទៃទៀត ព្រមទាំងសំរេចថាត្រូវប្រើយ៉ាងម៉េច ដើម្បីអោយវាក្លាយទៅជាការសិក្សាសំរាប់បញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ឬសារណាសំរាប់ថ្នាក់បណ្ឌិត ។

នេះ គឺជាការសិក្សាកម្មវិធីសិលាដែលមួយផ្នែកទៀតផ្ដោតទៅលើបទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ដទៃទៀតនៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជាក្នុងគោលបំណងស្វែងយល់ពីបទអន្តរាគមន៍នោះនៅក្នុងបរិបទ និងពីទស្សនៈរបស់អ្នកភូមិ ។ ដូច្នេះការសិក្សានេះ ផ្ដោតទៅលើប្រធានបទដែលធំទូលាយជាងសកម្មភាពអភិវឌ្ឍន៍ ដោយចង់ដឹង និងពិចារណាពីជីវភាពរស់នៅ ការផ្លាស់ប្ដូរបទពិសោធន៍ពីអតីតកាល បច្ចុប្បន្ន ការយល់ដឹងជាទូទៅ និងក្ដីរំពឹងរបស់ពួកគេសំរាប់អនាគត ។

នៅជំនាន់អាណានិគមនិយមបារាំងអ្នកភូមិមានដីគ្រប់គ្រាន់ ហើយពួកគេធ្វើស្រែ និងដាំបន្លែ ដូចសព្វថ្ងៃនេះដែរ ។ ពួកគេបានបង់ពន្ធជាទឹកប្រាក់ ហើយអ្នកខ្លះទៅលើកថ្នល់ជាតិដែលបានកំរៃជារូបិយប័ណ្ណបារាំង ។

ក្នុងអំឡុងពេល ២ឆ្នាំកងទ័ពឥស្សរៈ[២] បានបង្កភាពភ័យខ្លាចក្នុងចំណោមអ្នកភូមិ ព្រោះពួកគេបានចូលមកភូមិដើម្បីចាប់ប្រជាជនអោយច្បាំងជាមួយបារាំង ហើយចាប់ក្មេងស្រីៗអោយធ្វើជាអ្នករាំរបាំ ។ អ្នកដែលចូលខាងឥស្សរៈ ត្រូវបានបំពាក់ដោយអាវុធ ។ ប៉ុន្តែពុំមានការច្បាំងគ្នានៅក្នុងភូមិទេ ។

ក្នុងជំនាន់សីហនុ ប្រជាជននៅតែមានដីស្រែគ្រប់គ្រាន់ ។ ពួកគេក៏នៅតែបង់ពន្ធដដែល និងត្រូវ បានគេណែនាំទៅជីកទំនប់ដ៏ធំមួយ ហើយលើកផ្លូវសព្វថ្ងៃនេះដោយពុំបានកំរៃឡើយ ។ នៅពេលដែលទំនប់ជិតនោះរួចស្រេចបាច់ ហើយសម្តេចបានយាងមកសម្ពោធទំនប់នោះ ដែលចាស់ៗនៅតែនិយាយពីទំនប់នោះ ។

ក្នុងរបប លន់ នល់ ភូមិនេះគ្មានមានមនុស្សទេ ។ រដ្ឋាភិបាលបានបោះបន្ទាយនៅម្ខាងមកពីកន្លែងដែលពួកគេមកចាប់ទាហាន ហើយខ្មែរក្រហមរស់នៅក្នុងព្រៃម្ខាងទៀត មកពីកន្លែងដែលពួកគេមកបញ្ចុះបញ្ចូលប្រជាជនអោយចូលខាងគេ ។ ដំបូងប្រុសៗរត់គេចខ្លួននៅពេលថ្ងៃ ប៉ុន្តែស្រីៗ និងក្មេងៗ អាចនៅក្នុងភូមិ ហើយប្រុសៗអាចត្រឡប់មកវិញនៅពេលយប់ ។ ប៉ុន្តែដោយសារភូមិនេះស្ថិតនៅចំកណ្តាលសមរភូមិប្រជាជនត្រូវតែចាកចេញ ។ ប្រជាជនភាគច្រើនបានទៅ នៅភូមិដែលគ្រប់គ្រងដោយរដ្ឋាភិបាល អ្នកផ្សេងទៀតទៅខាងខ្មែរក្រហម ។

នៅពេលខ្មែរក្រហមឈ្នះ អ្នកភូមិមួយចំនួន ត្រូវបានគេប្រាប់អោយត្រលប់មកភូមិជ្រែងវិញ ប៉ុន្តែអ្នកភូមិភាគច្រើន បានស្នាក់នៅ និងធ្វើការនៅកន្លែងផ្សេងៗជុំវិញខេត្តក្នុងរបបប៉ុលពត ។

នៅពេលដែលវៀតណាមចូលកាន់តែកៀក មេដឹកនាំខ្មែរក្រហមបង្ខំអ្នកភូមិអោយទៅជាមួយពួកគេ ។ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៧៩ អ្នកភូមិចាប់ផ្តើមត្រលប់ចូលមកភូមិជាបណ្តើរៗ ។ ក្នុងរយៈពេលពីរបីឆ្នាំដំបូងពួកគេមកភូមិតែពេលថ្ងៃទេ ។ វាមានគ្រោះថ្នាក់ណាស់ក្នុងការស្នាក់នៅក្នុងភូមិពេលយប់ ព្រោះនៅមានទាហានខ្មែរក្រហមនៅក្នុងតំបន់នោះ ។ ភូមិនេះត្រូវបានបំផ្លាញទាំងស្រុង ដូច្នេះអ្នកភូមិ ត្រូវកាប់ឆ្ការដីដើម្បីធ្វើស្រែ និងបន្លែ ។ ពួកគេក៏ឡើងត្នោតធ្វើស្ករដែរ ។

ចាប់តាំងពីឆ្នាំ១៩៨៣ ពុំមានបញ្ហារឿងអសន្តិសុខទៀតទេ ហើយប្រជាជនក៏បានមករស់នៅក្នុងភូមិនេះជាអចិន្ត្រៃយ៍ដែរ ដំបូងប្រជាជនរស់នៅក្នុងខ្ទមតូចៗ ហើយនៅពេលដែលគេអាចមានលទ្ធភាពជាបណ្តើរៗ គេសង់ផ្ទះល្អៗ ។ អ្នកដែលបានមកដល់មុន គេយកដី និងក្របីណាក៏បានដែរ អោយតែពួកគេចង់បាន ។ ក្នុងរយៈពេលមួយឆ្នាំឬពីរឆ្នាំប្រជាជនក៏បានធ្វើស្រែរួមគ្នា ។ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៨៣ មេភូមិបានចែកដីស្រែអោយគ្រួសារទាំងអស់ធ្វើជាកម្មសិទ្ធិផ្ទាល់ ។

---

[២] ឥស្សរៈ គឺជាចលនាតស៊ូដណ្តើមយកឯករាជ្យកម្ពុជាក្នុងកំឡុងឆ្នាំ១៩៤០ និង ១៩៥០ ។

ពង្រីកបានទូទាំងប្រទេស ។ ការចូលរួមដ៏ធំធេងកន្លងមកនៅថ្នាក់ភូមិ អំឡុងឆ្នាំ១៩៩៨-១៩៩៩ ត្រូវបានជំនួសដោយការសំរបសំរួលនៅថ្នាក់ឃុំដែលមានបំណងបង្កើតថ្នាក់ឃុំជាភ្នាក់ងារអភិវឌ្ឍន៍ចម្បង ។

## បញ្ហា និងវិធីសាស្ត្រ

### *ចាប់ផ្តើមពីភាពទូលាយ និងការបង្រួមអោយតូច*

ការសិក្សានេះ ត្រូវបានផ្ផែកទៅលើករណីសិក្សា[១] ដែលជាករណីសិក្សានៅក្នុងភូមិនីមួយៗរបស់កម្មវិធីសិលា គឺស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា (សូមមើលផែនទីនៅទំព័រទី៨ និងទំព័រទី១០) ។ ការសិក្សានេះ ត្រូវបានរៀបចំធ្វើដោយក្រុមស្ត្រីខ្មែរ២នាក់ និងជំនាញការស្ត្រីជនជាតិស៊ុយអែតម្នាក់ដែលជាប្រធានក្រុម និងជាអ្នកសរសេររបាយការណ៍នេះ ។ វាក្យស័ព្ទយោង (ឧបសម្ព័ន្ធ២) និយាយពីការងារនៃការវិភាគលើ "*បទពិសោធន៍ និងការយល់ឃើញរបស់អ្នកភូមិដែលទាក់ទិននឹង SEILA/CARERE (និងបទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ដទៃទៀត ដែលត្រូវបានកំពុងអនុវត្តនៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា)*" ។ ដូច្នេះ បញ្ហាចំពោះការសិក្សានេះមិនបានកំណត់ជាមុនទេ ។ គោលបំណងនេះ គឺចាប់ផ្តើមចេញពីទស្សនៈ និងការព្រួយបារម្ភរបស់អ្នកភូមិ ហើយកំណត់ព្រំដែនបញ្ហាដែលទាក់ទិនបន្តិចម្តងៗ ។

ក្រោយពីការស្នាក់នៅលើកទីមួយនៅក្នុងភូមិដំបូង យើងបានរកឃើញបញ្ហាសំខាន់១បី ដើម្បីស្វែងយល់បន្ថែមទៀត និងដើម្បីបង្កើតជាបណ្តាញគ្រោងវិភាគបណ្តោះអាសន្ន ។ បញ្ហាទាំងនោះ មាន *ភាពក្រីក្រ សហគមន៍ និងរដ្ឋអំណាច*[១] ។ ក្នុងដំណាក់កាលដំបូងនៃការស្រាវជ្រាវនេះ (ការសិក្សាពីបទពិសោធន៍ និងការយល់ឃើញរបស់អ្នកភូមិ) យើងបន្តកំណត់ព្រំដែនបន្តិចម្តងៗ និងសិក្សាលំអិតនូវបញ្ហាទាំងនេះ ប៉ុន្តែក៏ព្យាយាមទទួលពត៌មានថ្មីដែលកើតឡើងដែរ ។ គំរោងដ៏ទូលំទូលាយ និងការចាប់ផ្តើមដំបូងនេះ បានធ្វើអោយយើងយល់ពីការព្រួយបារម្ភរបស់អ្នកភូមិ ព្រមទាំងបទពិសោធន៍ និងការយល់ឃើញរបស់ពួកគេតាមកំរិតនៃមូលបទដែលធ្វើអោយយើងអាចត្រៀមខ្លួនសំរាប់ដំណាក់កាលបន្ទាប់ ។

ប៉ុន្តែនៅដំណាក់កាលទី២ (ការសិក្សាពីឥទ្ធិពលរបស់សិលា) យើងត្រូវបង្រួមការផ្តោតនេះអោយកាន់តែតូច ។ នៅពេលនេះ បញ្ហាស្តីពី*រដ្ឋអំណាច/ការគ្រប់គ្រងនៅតាមមូលដ្ឋាន* បានក្លាយជាបញ្ហាដែលគួរអោយចាប់អារម្មណ៍បំផុត ។ ការពិចារណាទៅលើគោលបំណងនៃកម្មវិធីសិលា ការកាត់បន្ថយភាពក្រីក្រតាមរយៈអភិបាលកិច្ចល្អបែបវិមជ្ឈការ និងការពិចារណាទៅលើការកែទំរង់ ដែលទាក់ទិននឹងការងាររដ្ឋាភិបាលនាពេលបច្ចុប្បន្ន រួមទាំងការត្រៀមលក្ខណៈសំរាប់ការបោះឆ្នោតឃុំ ចំណេះដឹងដែលយើងទទួលបានអំពីទស្សនៈរបស់អ្នកភូមិចំពោះរដ្ឋអំណាចមូលដ្ឋាន ហាក់ដូចជាមានប្រយោជន៍ខ្លាំងណាស់ ហើយការសិក្សាស្តីពីអ្វីដែលជាឥទ្ធិពលរបស់សិលាទៅលើការគ្រប់គ្រងតាមមូលដ្ឋានកន្លងមក និងការពិភាក្សាពីអ្វីដែលជាឥទ្ធិពលបន្ថែមទៀត ដែលរំពឹងថាអាចបានទទួលនោះហាក់ដូចជាទាក់ទិនបំផុត ។

---

[១] ដោយសាររបាយការណ៍នេះទាក់ទិនសំខាន់ទៅនឹងបញ្ហាទីបី ខ្ញុំមិននិយាយលំអិតទៅទីនេះពីរបៀប និងមូលហេតុដែលបញ្ហាទាំងបីនេះកើតឡើងដូចមានការទាក់ទិនទេ ។

## *ការស្នាក់នៅទីនោះ និងការត្រឡប់មកវិញ*

ដើម្បីចុះពីលើម៉ាស៊ីនឈូសពង្រាប ចំណាយពេលស្នាក់នៅក្នុងភូមិ គឺជាផ្នែកមួយដ៏សំខាន់សំរាប់វិធីសាស្ត្រនៃការស្រាវជ្រាវ ។ យើងចង់ស្គាល់ទីកន្លែង និងប្រជាជន ហើយចង់អោយពួកគេស៊ាំទៅនឹងវត្តមានរបស់យើង ។

យើងបានទៅស្នាក់នៅក្នុងភូមិនីមួយៗចំនួន ៣ដង (សមាជិកជនជាតិខ្មែរម្នាក់ ឬ ២នាក់ បានទៅស្នាក់នៅក្នុងភូមិបន្ថែមរយៈពេលខ្លី) អស់រយៈពេលប្រហែល២ខែនៅក្នុងភូមិទី១ ក្នុងខែមិថុនា ឆ្នាំ១៩៩៩ ដល់ខែមីនា ឆ្នាំ២០០០ ហើយរយៈពេល២ខែនៅក្នុងភូមិទី២ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ ដល់ខែមេសា ឆ្នាំ២០០០ ។ វិធីសាស្ត្រត្រូវបានធ្វើឡើងតាមបែបដដែលគ្នាធម្មតា ព្រមទាំងមានបែបបទខុសៗគ្នានៃការសម្ភាសន៍ និងការបង្កើតក្រុមផ្ទៀងផ្ទាត់ពត៌មានអោយមានភាពសុក្រិត ។ ប៉ុន្តែក៏មានការខុសប្លែកគ្នាពីរបៀបដំណើរការនៅក្នុងភូមិទាំងពីរនេះដែរ ។

នៅភូមិជ្រៃ ខេត្តពោធិសាត់ បរិយាកាសពោរពេញដោយភាពកក់ក្តៅ និងស្វាគមន៍តាំងពីចាប់ដំណើរការសិក្សាស្រាវជ្រាវដំបូង ។ អ្នកភូមិស្ទើរតែទាំងអស់ហាក់បីដូចជាសប្បាយរីករាយក្នុងការនិយាយជាមួយយើង ហើយផ្ទះដែលយើងស្នាក់នៅ បានក្លាយទៅជាកន្លែងជួបជុំគ្នារបស់អ្នកភូមិទៀតផង ។ ម្ចាស់ផ្ទះព្រមទាំងអ្នកភូមិផ្សេងៗទៀត ដែលមកលេងពួកយើងបានក្លាយជាមនុស្សសំខាន់ដែលយើងអាចផ្ទៀងផ្ទាត់ និងពិភាក្សាលទ្ធផលចុងក្រោយដែលយើងបានទទួលក្នុងការស្នាក់នៅក្នុងភូមិមួយលើកៗជាមួយពួកគេ ។ ភាពកក់ក្តៅនេះបានកើនឡើងបន្ថែមទៀតនៅពេលដែលយើងបានត្រឡប់ទៅស្នាក់នៅភូមិលើកទី២ និងទី៣វិញ ។ ឥឡូវនេះ អ្នកភូមិជាច្រើនហាក់បីដូចជាចាត់ទុកពួកយើងជាមិត្តដែលអាចទុកចិត្តបាន ហើយថែមទាំងនិយាយដោយឥតលាក់លៀមពីបញ្ហាដែលអាចប៉ះពាល់កាន់តែច្រើនឡើងៗ ។ នៅភូមិគោកដូង ខេត្តបាត់ដំបង បរិយាកាសមិនសូវមានភាពសប្បាយប៉ុន្មានទេ ។ អ្នកភូមិជាច្រើនមិនចង់និយាយរកយើងទេ ហើយការស្នាក់នៅលើកទីមួយរបស់យើងមិនសូវមានអ្នកភូមិមកនិយាយលេងជាមួយយើងនៅពេលល្ងាចៗឡើយ ។ ប៉ុន្តែការត្រឡប់ទៅស្នាក់នៅម្តងទៀត បានធ្វើអោយមានការខុសប្លែកគ្នាច្រើនជាងមុន ។ យើងបានស្នាក់នៅជាមួយគ្រួសារមួយផ្សេងទៀត ដែលមិនសូវចុះចារប៉ុន្មានទេ ស្ថិតនៅកណ្តាលភូមិដែលពោរពេញទៅដោយអ្នកភូមិរស់នៅច្រើន និងនៅពេលល្ងាចមិនស្ងាត់ទៀតផង ។

យើងត្រូវបានស្វាគមន៍ដោយអ្នកភូមិ និងចែករំលែកការស្វាគមន៍នេះ អោយមិត្តដែលបានក្លាយជាមនុស្សសំខាន់ និងជាទីប្រឹក្សាដ៏វិសេសបំផុតរបស់យើងផងដែរ ។ ប៉ុន្តែអ្នកដទៃទៀតនៅតែមិនសូវនិយាយស្តី និងកាន់តែងឿងឆ្ងល់ពីវត្តមានរបស់យើងជាងនៅភូមិទី១ (យើងបានដឹងថាហេតុផលមួយនោះគឺពួកគេគិតថា ក្រុមយើងទៅស្នាក់នៅទីនោះ ដើម្បីស៊ើបពីរឿងលេងល្បែងនៅក្នុងភូមិ) អ្នកភូមិភាគច្រើនប្រាប់យើងបន្តិចម្តងៗដោយឥតលាក់លៀម និងដោយពុំមានការដាក់កំហិត ។ វត្តមាន និងសំនួររបស់យើងមានឥទ្ធិពលយ៉ាងច្បាស់ទៅលើអ្វីដែលអ្នកភូមិកំពុងតែគិត និងនិយាយ ហើយការពិតទៅទៀតមានអ្នកភូមិមួយចំនួនសុំចងមិត្តជាមួយយើង ប៉ុន្តែអ្នកផ្សេងទៀតដែលមិនបានចងមិត្តជាមួយយើងនោះ បានជះឥទ្ធិពលយ៉ាងច្បាស់ទៅលើពត៌មានដែលយើងទទួលបាន ។ ប៉ុន្តែទំនាក់ទំនងខុសៗគ្នានេះបានបំពេញអោយគ្នាទៅវិញទៅមកដូចជាការជជែកគ្នាលេងរវាងអ្នកភូមិ និងក្រុមយើងនៅពេលល្ងាចៗ បានធ្វើឱ្យយើងមានការយល់ដឹងកាន់តែស៊ីជំរៅ ហើយយើងអាចលើកជាឧទាហរណ៍នូវពត៌មានដែលយើងទទួលបានពីអ្នកផ្សេងទៀតនៅក្នុងការសម្ភាសន៍នៅពេលថ្ងៃដើម្បីអោយច្បាស់ជាងមុន ។

## ការបង្កើតក្រុមដើម្បីផ្ទៀងផ្ទាត់ពត៌មានអោយសុក្រិត

ការស្នាក់នៅក្នុងភូមិ និងការត្រឡប់ទៅម្តងទៀត អាចធ្វើអោយលទ្ធផល និងការវិភាគរបស់យើងកាន់តែមានសុពលភាពជាបន្តបន្ទាប់ ។ ការជជែកគ្នាក្រៅផ្លូវការ ព្រមទាំងការនិយាយគ្នាដោយសម្ងាត់ដែលកើតឡើងជាមួយអ្នកដែលយើងបានបង្កើតមិត្តភាពពិសេសវិសាលនោះ បានផ្តល់ឱកាសដ៏មានតំលៃដើម្បីត្រួតពិនិត្យពត៌មាន និងការយល់ដឹងរបស់យើង ។ យើងក៏បានត្រួតពិនិត្យរកពត៌មានដែលពិតប្រាកដតាមវិធីមួយដែលកាន់តែមានបែបបទទៀតផង ។ នៅក្នុងភូមិនីមួយៗ យើងបានបង្កើត *ក្រុមផ្តល់យោបល់* ដោយមានមនុស្សពី៧-១០នាក់ ។ យើងបានពិភាក្សាជាមួយពួកគេនៅដើមដំបូងនៃការស្នាក់នៅមួយលើកៗ ដោយបង្ហាញ ពិភាក្សាពីទិសដៅនៃការស្រាវជ្រាវថ្មីៗ និងចុងបញ្ចប់នៃការស្នាក់នៅមួយលើកៗដោយបង្ហាញពីលទ្ធផល និងទទួលការផ្ទៀងផ្ទាត់ពត៌មាន ។ ក្នុងរយៈពេលស្នាក់នៅលើកទីបី យើងបានបង្កើត *ដំណើរទស្សនកិច្ចសិក្សា*[៣] នៅក្នុងភូមិទាំងពីរ ។ ស្ត្រី២នាក់ និងបុរស២នាក់ មកពីភូមិគោកដូងបានទៅស្នាក់នៅភូមិជ្រែងជាមួយពួកយើង ហើយក្រោយមកអ្នកភូមិជ្រែងដែលអោយអ្នកភូមិគោកដូងស្នាក់នៅក្នុងផ្ទះរបស់ខ្លួននោះបានទៅ និងស្នាក់នៅផ្ទះ អ្នកភូមិគោកដូងវិញម្តង ។ ដំណើរទស្សនកិច្ចសិក្សារវាងភូមិទាំងពីរ បានជួយអោយយើងទទួលលទ្ធផលច្បាស់លាស់ដែលយើងបានប្រៀបធៀប និងបង្កើនការចូលរួមរបស់អ្នកភូមិក្នុងការវិភាគពត៌មាន ។ វិធីទាំងពីរនេះ គឺជាវិធីថ្មី និងប្រកបដោយជោគជ័យ ។

## ការពិភាក្សា ការសម្ភាសន៍ និងការប្រមូលពត៌មាន

ការស្នាក់នៅលើកទី១ ក្នុងភូមិនីមួយមានលក្ខណៈស្រាវជ្រាវ និងបើកចំហខ្លាំង ។ ការប្រមូលពត៌មានត្រូវបានរៀបចំអោយមានបែបបទត្រឹមត្រូវបន្តិចម្តងៗ និងផ្តោតចំទិសដៅនៃការសិក្សា ។ ការសិក្សានេះមានប្រសិទ្ធិភាពទៅលើចំណេះដឹងដែលយើងបានទទួលពីភូមិទាំងពីរនេះនៅដំណាក់កាលខុសៗគ្នានៃការស្រាវជ្រាវ ។ ការបើកទូលាយរបស់យើង (និងការបើកទូលាយរបស់អ្នកភូមិ) បានធ្វើអោយយើងមានការយល់ដឹងដ៏ទូលាយពីភូមិទីមួយ ប៉ុន្តែការបង្កើតបណ្តាញគំរោងអាចធ្វើអោយទទួលបានពត៌មានដែលត្រូវបានរៀបចំជាជំពូកៗអំពីភូមិទីពីរក្នុងរយៈពេលខ្លីជាងភូមិទីមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំជឿជាក់ថា នៅចុងបញ្ចប់យើងបានឈានទៅដល់កំរិតនៃការយល់ដឹងអំពីភូមិទាំងពីរដែលមានលក្ខណៈស្រដៀងគ្នា ។

នៅពេលដែលបញ្ហាទាំងឡាយកាន់តែត្រូវបានបង្រួញ ហើយសំនួររបស់យើងកាន់តែមានលក្ខណៈត្រឹមត្រូវតាមបែបបទនៃការសម្ភាសន៍ ភាគច្រើននៅតែមានលក្ខណៈក្រៅផ្លូវការដដែល ។ ទន្ទឹមនឹងនេះដែរ ក៏មានការពិភាក្សាជាក្រុមតូចៗហើយអ្នកភូមិចូលរួមស្រេចតែចិត្ត ។ ការបង្កើតអោយមានក្រុមពិភាក្សានេះ ហាក់ដូចជាធ្វើអោយអ្នកភូមិមានអារម្មណ៍ធូរស្រាល ហើយបញ្ហាជាច្រើនបានលេចចេញពីការពិភាក្សាជាក្រុម ។ ប៉ុន្តែយើងក៏បានសម្ភាសន៍ជាលក្ខណៈបុគ្គល ដែលបានបញ្ចេញការបារម្ភយ៉ាងពន់ពេក ឬសម្ភាសន៍ជាមួយអ្នកដែលមានបទពិសោធន៍ដ៏ពិសេស ជូនកាលបញ្ចេញបញ្ហាដែលមានការប៉ះពាល់យ៉ាងខ្លាំង និងជាមួយអ្នកដែលយើងបានចងមិត្តជាមួយ ។ យើងក៏បានជ្រើសរើសពីរ-បីគ្រួសារ ដើម្បីសិក្សាអោយបានស៊ីជំរៅ ដោយផ្តោតលើសកម្មភាពសេដ្ឋកិច្ច និងទំនាក់ទំនងសង្គម ។ ការចែករំលែកការងារដ៏ធំធេង ក៏មានការបញ្ជាក់ និងការតាមដានករណីដែលបានបង្ហាញដែរ ដូចជា

[៣] សមាជិកខ្មែរម្នាក់នឹងសរសេររបាយការណ៍មួយផ្សេងទៀតស្តីពីទស្សនកិច្ចផ្លាស់ប្តូរទាំងនេះ ។

អ្នកភូមិដែលក្លាយពីក្រុមកមាន ឬពីជំលោះដែលត្រូវបានបញ្ជូនទៅដោះស្រាយនៅតុលាការ និងការតវ៉ាដែលត្រូវបានរៀបចំ ។

លក្ខណៈវិនិច្ឆ័យរបស់យើងតែមួយគត់ សំរាប់អ្នកដែលយើងចង់និយាយជាមួយ គឺថាគេក៏ចង់និយាយជាមួយយើងដែរ ។ ប៉ុន្តែបើគេមិនស្វាគមន៍យើងៗក៏មិនហ៊ានសុំគេសម្ភាសន៍ដែរ ព្រោះខ្លាចរំខានដល់ការប្រកបមុខរបររបស់ពួកគេ ។ ក្រៅពីនេះ ជាទូទៅយើងបានស្វែងយល់ពីតំបន់ ភូមិសាស្ត្រ និងប្រជាជនដែលមានប្រភេទខុសៗគ្នា ។ គោលបំណងនេះ មិនមែនចង់បានតំរូតំណាងស្ថិតិនោះទេ ប៉ុន្តែចង់ដឹងពីប្រជាជនដែលមានប្រវត្តិ និងការយល់ដឹងខុសៗគ្នា ។ ក្រៅពីប្រភេទទូទៅដូចជា អាយុ ភេទ ការីតវប្បធម៌ និងទ្រព្យសម្បត្តិ នៅមានមូលបទមួយទៀត ដែលទាក់ទងទៅនឹងមូលបទជាច្រើនដូចជា "ការទទួលផលប្រយោជន៍ពីប្រឡាយឬទេ" ហើយ "នៅខាងមេភូមិឬទេ" ។ យើងនិយាយជាមួយស្ត្រីច្រើនជាងបុរស ព្រោះយើងមិនសូវបានទទួលពត៌មានពីស្ត្រីអោយបានច្រើនដូចបុរសទេ ។ ក្នុងរយៈពេលនៃការស្រាវជ្រាវ យើងក៏បានបង្កើតទំនាក់ទំនងជាមួយ រដ្ឋអំណាចភូមិ និងមេឃុំ ដោយជួបសំណេះសំណាលបន្តិចបន្តួច ព្រមទាំងធ្វើការសម្ភាសន៍ជាមួយពួកគាត់ផងដែរ ។

ការស្នាក់នៅក្នុងភូមិទាំងពីរនៅលើកទី៣ គឺផ្តោតយ៉ាងខ្លាំងទៅលើការសម្ភាសន៍ដែលបានរៀបចំទុក ។ មូលហេតុសំខាន់ គឺដោយសារនៅដំណាក់កាលនេះ យើងផ្តោតលើប្រធានបទដែលតូចជាងមុនទៅទៀត គឺបទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍និងឥទ្ធិពលរបស់សិលាទៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន ដែលធ្វើអោយការងារមានភាពងាយស្រួលជាងមុនច្រើន ។ ការចុះទៅភូមិលើកនេះ រួមមានការសម្ភាសន៍ជាក្រុមជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ អ្នកភូមិ សមាជិក គ.អ.ភ ទាំងអស់ និងអ្នកផ្សេងទៀត ដែលមានមុខតំណែងផ្នែកការងារអភិវឌ្ឍន៍ និងរដ្ឋអំណាច ។ លើកនេះយើង ក៏បានសម្ភាសន៍ជាមួយមន្ត្រីសំរបសំរួលស្រុក ព្រមទាំងសមាជិកម្នាក់នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តនៃគណៈកម្មាធិការប្រតិបត្តិ និងប្រធានកម្មវិធី CARERE ខេត្ត ដែរ ។ មុននឹងចុះទៅភូមិលើក ទី៣ យើងបានសម្ភាសន៍ជាមួយប្រធានកម្មវិធី CARERE នៅភ្នំពេញ ។

### *គំរោងរបាយការណ៍*

នៅក្នុងរបាយការណ៍នេះ ឈ្មោះអ្នកដែលបានសម្ភាសន៍ត្រូវបានលុបចេញ ឬផ្លាស់ប្តូរលើកលែងតែមន្ត្រីថ្នាក់ភូមិ ឃុំ និងភ្នាក់ងារអភិវឌ្ឍន៍មួយចំនួនតូចតែប៉ុណ្ណោះ ដែលមិនបាច់និយាយឈ្មោះក៏គេស្គាល់ដែរ ដោយសារមុខតំណែងរបស់គេ ។

សេចក្តីផ្តើមនេះបញ្ចប់ដោយការបង្ហាញពីករណីសិក្សានៅភូមិទាំង២ (មាននៅក្នុងឧបសម្ព័ន្ធ១) ។ ជំពូកទី២ *ការយល់ដឹងរបស់អ្នកភូមិចំពោះការគ្រប់គ្រងនៅតាមមូលដ្ឋាន* បង្ហាញអំពីការពិពណ៌នាលើតួនាទី និងទំនាក់ទំនងនៃការដឹកនាំនៅថ្នាក់ភូមិ និងឃុំទាំង២ ដោយមានសេចក្តីសន្និដ្ឋានខ្លីៗមួយចំនួន (*នៅទំព័រ៥៨-៦៣*) ។ ជំពូកទី៣ *ឥទ្ធិពលរបស់សិលាទៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន* គឺជាគំនិត និងការវិភាគទៅលើការផ្លាស់ប្តូរដែលមាននៅក្នុងសេចក្តីផ្តើមស្តីពីសិលា និងបទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ដោយរួមមានសេចក្តីសន្និដ្ឋាន (នៅទំព័រ៩១-៩៥) ។ ជំពូកទី៤ និយាយអំពីសេចក្តីសន្និដ្ឋានលើការពិភាក្សា *តើអ្វីដែលជាឥទ្ធិពលពិតប្រាកដរបស់សិលាទៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន?*

រាល់ចំនុចលំអិតសំខាន់ៗ ត្រូវបានសរសេរជាអក្សរទ្រេត ។ ដើម្បីអោយប្រិយមិត្តអ្នកអានអាចយល់ពីទិដ្ឋភាពទូទៅនៃរបាយការណ៍ និងដោយផ្អែកលើការសំរេចថាអានផ្នែកណាមួយអោយបានពេញលេញ ចំនុចសំខាន់ៗទាំងនេះ ត្រូវបានបង្ហាញនៅក្នុងសេចក្តីសង្ខេប(នៅទំព័រទី v-xii) .

## *ការជ្រើសរើស និងលក្ខណៈពិសេសរបស់ភូមិសំរាប់ករណីសិក្សា*[៥]

ការជ្រើសរើសភូមិសំរាប់ធ្វើការសិក្សាត្រូវបានធ្វើឡើងដោយសហការជាមួយបុគ្គលិក CARERE ខេត្ត ។ គោលបំណងនៃការជ្រើសរើសភូមិ គឺមិនមែនត្រឹមតែជ្រើសរើសរកភូមិ "ដែលជាតំណាង" ប៉ុន្តែជាករណីដែលអាចពន្យល់ហេតុផលបានដែរ ។

ភូមិទីមួយ គឺជាភូមិដែលមានប្រជាជនរស់នៅច្រើនជំនាន់ក្នុងគោលបំណងស្វែងយល់ថា តើលក្ខខ័ណ្ឌសេដ្ឋកិច្ច ទំនាក់ទំនងផ្នែកសង្គមផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះ និងជាកន្លែងដែល SEILA/CARERE ធ្វើការច្រើនឆ្នាំដើម្បីស្វែងយល់ពីឥទ្ធិពលរបស់វា ។

ភូមិទីពីរ គឺជាភូមិដែលមានទំហំ និងធនធានប្រហាក់ប្រហែលគ្នាទៅនឹងភូមិទីមួយ ប៉ុន្តែជាកន្លែងដែលចំនួនប្រជាជនភាគច្រើនមានការប្រែប្រួល ដើម្បីស្វែងយល់ថាតើប្រការនេះប៉ះពាល់ទំនាក់ទំនងផ្នែកសង្គមដូម្តេចខ្លះ (ដែលជាបញ្ហាសំខាន់មាននៅក្នុងតំរោងវិភាគ) និងកន្លែងដែលអង្គការអភិវឌ្ឍន៍ផ្សេងៗ មកធ្វើការ ប៉ុន្តែ SEILA/CARERE ទើបតែចាប់ផ្តើមកម្មវិធីនៅពេលថ្មី ដើម្បីសិក្សាពីឥទ្ធិពលដែលពួកគេអាចមានចំពោះគ្នាទៅវិញទៅមក ។ លក្ខណៈវិនិច្ឆ័យទីមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងនេះ គឺមួយផ្នែកត្រូវបានឆ្លើយតបដោយសារចំនួនប្រជាជនភាគច្រើននៅក្នុងភូមិដែលបានជ្រើសរើសនេះ មិនមានការផ្លាស់ប្តូរ លើកលែងតែជនមាតុភូមិនិវត្តន៍ដែលមានការប្រែប្រួលនៅត្រឹម ២៩គ្រួសារ ។ ភាគច្រើននៃអ្នកទាំងនោះមិនមានទំនាក់ទំនងជាមួយភូមិចាស់នៅពេលដែលពួកគេមកតាំងទីលំនៅក្នុងភូមិនៅឆ្នាំ១៩៩២ ។ ប៉ុន្តែយើងសំរេចធ្វើការងារនៅក្នុងភូមិនេះបន្តទៀតព្រោះវាបានបង្ហាញពីទស្សនៈផ្សេងទៀតយ៉ាងហោចណាស់ ក៏មានការទាក់ទិនទៅនឹងការដឹកនាំនៅក្នុងភូមិ និងតួនាទីរបស់ឃុំក្នុងការងារអភិវឌ្ឍន៍ ។

ដូច្នេះ ភូមិទាំងពីរដែលបានជ្រើសរើសនេះ គឺជាភូមិក្រីក្រ និងដាច់ស្រយាលជាងគេនៅក្នុងឃុំ ។ ភូមិទាំង២នេះ គឺជាភូមិដែលមានវ័យចំណាស់មានអ្នកភូមិរស់នៅច្រើនជំនាន់ ឬរៀបការជាមួយអ្នកភូមិគ្នាឯង ដូច្នេះហើយអ្នកភូមិទាំងអស់ជាសាច់ញាតិនឹងគ្នា ប៉ុន្តែគ្រាន់តែជាសាច់ញាតិជិត ឬឆ្ងាយប៉ុណ្ណោះ ។

ភូមិតុំផង (សូមមើលផែនទីនៅទំព័រទី៨) គឺភូមិមួយក្នុងចំណោមភូមិទាំង១៣ នៅឃុំស្វាយលូង ស្រុកកណ្តៀងមានចំងាយ១២គីឡូម៉ែត្រ ពីទីរួមខេត្តពោធិសាត់ ។ មាន ១៣៤គ្រួសារ និងចំនួនប្រជាជនសរុបមាន ៦៥៥នាក់ (ស្ត្រី៣៦៤នាក់ បុរស២៩១នាក់) ។ ភូមិនេះមាន ៦កន្លែងដាច់ដោយឡែកពីគ្នា ។ កន្លែងដែលឆ្ងាយជាងគេប្រហែលជា ៣គីឡូម៉ែត្រ ។ អ្នកក្រ និងអ្នកមានរស់នៅដាច់ដោយឡែកពីគ្នា ។ ប្រជាជនដែលរស់នៅក្នុង

---

[៥] ចំពោះការបង្ហាញពីភូមិដែលជាករណីសិក្សាដែលពេញលេញជាងនេះ សូមអានឧបសម្ព័ន្ធ ១

កន្លែងមួយក្នុងចំណោមកន្លែងទាំង៦ ជាគ្រួសារធូរធារ ហើយកន្លែងមួយទៀតជាកន្លែងដែលអ្នកក្រីក្របំផុតរស់នៅ ប៉ុន្តែកន្លែងដែលធំ និងនៅកណ្តាលគេនោះ អ្នកក្រ និងអ្នកធូរធារ រស់នៅលាយឡំគ្នា ។

ប្រជាជននៅភូមិជ្រែងប្រកបរបររកស៊ី ចាប់ពីរដូវវស្សា គឺធ្វើស្រែ និងដាំបន្លែបន្ថែម ។ ពួកគេក៏រកត្រីដែរ ប៉ុន្តែ រកសំរាប់តែហូបប៉ុណ្ណោះ ។ ការចិញ្ចឹមជ្រូក គឺជាប្រាក់ចំណូលដ៏សំខាន់បំផុត ហើយ ក៏ជាមុខរបរមួយដែលអ្នកភូមិយល់ថា អាចក្លាយជាអ្នកធូរធារបានដែរ ។

ក្នុងរយៈពេលសង្គ្រាមនៅពាក់កណ្តាលទសវត្ស ១៩៧០ ភូមិនេះគឺជាសមរភូមិមុខ ។ ដំបូងប្រុស១គេចពីការជ្រើសរើសទ័ពរបស់រដ្ឋាភិបាល លន់ នល់ ឬខ្មែរក្រហម ។ បន្ទាប់មកអ្នកភូមិទាំងអស់ ត្រូវបានគេជម្លៀសចេញពីភូមិ ។ នៅពេលដែលខ្មែរក្រហមឈ្នះ អ្នកភូមិមួយចំនួនត្រូវគេបញ្ជាអោយត្រឡប់មកភូមិជ្រែងវិញ ប៉ុន្តែអ្នកភូមិភាគច្រើនបានរស់នៅ និងធ្វើការនៅកន្លែងផ្សេង១ជុំវិញខេត្តរហូតដល់ចប់ជំនាន់ប៉ុលពត ។



*Pursat Province*




*Chraeng Village*

ចាប់តាំងពីឆ្នាំ១៩៧៩ ប្រជាជនបានត្រឡប់មកភូមិវិញជាបណ្តើរ១ ។ នៅលើកដំបូង ពួកគេចូលមកភូមិតែពេលថ្ងៃទេ ព្រោះក្នុងភូមិនៅតែមានទាហានខ្មែរក្រហម ។ ចាប់តាំងពីឆ្នាំ១៩៨៣ ពុំមានបញ្ហាអសន្តិសុខទៀតទេ ហើយប្រជាជនក៏បានមកតាំងទីលំនៅជារៀងរហូតមក ប៉ុន្តែអ្នកភូមិនៅតែរត់គេចពីការចាប់ទាហាន និងពលករ ។

CARERE ១[៥] ចាប់ ផ្តើមដំណើរការនៅភូមិជ្រែងនៅឆ្នាំ១៩៩៣ ដោយសហការជាមួយកាកបាទក្រហមអូស្ត្រាលីបានផ្តល់ថវិកាសំរាប់ធ្វើអណ្តូងលូចំនួន ៥ និងសហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក ផ្តល់ស្បៀងពលកម្មអោយអ្នកភូមិជីកស្រះរួមបី និងបង្កើតធនាគារស្រូវ ។ កម្មវិធីស្បៀងអាហារពិភពលោក បានផ្តល់ស្បៀងពលកម្មសំរាប់លើកផ្លូវមួយខ្សែមានប្រវែង ៣៥០០ម៉ែត្រពីភូមិទៅកាន់ទីរួមខេត្ត ។

នៅឆ្នាំ១៩៩៦ កម្មវិធីសិលាចាប់ផ្តើមដំណើរការ និងបោះឆ្នោតជ្រើសរើសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។ នៅឆ្នាំទីមួយនៃដំណើរការកសាងផែនការមូលដ្ឋាន បានផ្តល់ផ្លូវមួយខ្សែពីភូមិឆ្ពោះទៅវត្តដែលនៅជិតភូមិ ។ នៅឆ្នាំទីពីរ បានដាក់លូកាត់ថ្នល់ពីរកន្លែងនៅលើផ្លូវដដែល ហើយនៅឆ្នាំទីបី ក្រាលគ្រួសក្រហមនៅលើផ្លូវនោះ ។ នៅឆ្នាំទី១ អ្នកភូមិត្រូវបានទទួលរបបពលកម្មអត់ជំនាញ ។ នៅឆ្នាំទី២ ពួកគេចូលរួមដាក់លំាងពលកម្ម និងនៅឆ្នាំទី៣ ពួកគេចូលរួមជាសាច់ប្រាក់ តែប្រមូលមិនទាន់បានគ្រប់នៅឡើយទេ ។

មានអង្គការអភិវឌ្ឍន៍មួយចំនួនតូចតែប៉ុណ្ណោះដែលធ្វើការនៅក្នុងភូមិជ្រែង ។ នៅឆ្នាំ១៩៩៧ CARERE បានផ្តល់ថវិកាសំរាប់ថ្នាក់អក្ខរកម្មដែលមានរយៈពេល ៦ខែ រៀបចំឡើងដោយអង្គការក្នុងស្រុកឈ្មោះសាមគ្គីធម៌ ហើយនៅឆ្នាំ១៩៩៩ អង្គការ TPO បានបើកវគ្គបណ្តុះបណ្តាលស្តីពីសុខភាពផ្លូវចិត្ត ។ ឆ្នាំនេះកម្មវិធីស្បៀងអាហារពិភពលោក បានផ្តល់ស្បៀងពលកម្មដើម្បីជួសជុលផ្លូវនេះឡើងវិញ ។

ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ត្រូវបានកើតឡើង ២ដងនៅភូមិជ្រែង គឺបន្ទាប់ពីទឹកជំនន់នៅក្នុងអំឡុងឆ្នាំ ១៩៩៥-១៩៩៦ ។ ដំបូង CARERE បានចុះមកមើលស្ថានការណ៍នៅក្នុងភូមិជាមុន និងបន្ទាប់ពីទឹកជំនន់នៅឆ្នាំ១៩៩៩ គណៈកម្មាធិការសង្គ្រោះបន្ទាន់ខេត្ត (ដោយរួមទាំង CARERE ផងដែរ) បានចុះមកស្រង់ស្ថិតិគ្រួសាររងគ្រោះ ។ បន្ទាប់មកកម្មវិធីស្បៀងអាហារពិភពលោក សហការជាមួយកាកបាទក្រហម អូស្ត្រាលី បានផ្តល់ "ប័ណ្ណ" អោយអ្នកភូមិជ្រែងចំនួន ៧០គ្រួសារ ។ អង្គការ ADRA បានផ្តល់កៅស៊ូតង់អោយអ្នកភូមិចំនួន ១៧គ្រួសារ ហើយ កាកបាទក្រហមកម្ពុជាបានចែកអំណោយជាសំភារៈជួសជុល និងរបស់របរសំរាប់ប្រើប្រាស់ក្នុងផ្ទះ ។

ភូមិគោកជ្វេ គឺជាភូមិមួយក្នុងចំណោមភូមិទាំង៨ ក្នុងឃុំពាមឯក ស្រុកឯកភ្នំ មានចំងាយ១៥គីឡូម៉ែត្រនៅភាគខាងជើងនៃទីរួមខេត្តបាត់ដំបង ។ មាន ១៧១គ្រួសារ និងប្រជាជនសរុបមាន ៨៥៤នាក់ (ស្ត្រី ៤៣១ នាក់ បុរស៤២៣នាក់) ។

អ្នកភូមិនិយាយពីភូមិ "ចាស់" និងភូមិ "ថ្មី" ។ នៅពេលដែលជនមាតុភូមិនិវត្តន៍មកដល់នៅឆ្នាំ១៩៩២ (ដែលពីដំបូងមាន ៧៤គ្រួសារ) ពួកគេបានទទួលដីឡូត៍តាមបណ្តោយដងផ្លូវដែលឆ្ងាយពីភូមិចាស់២គីឡូម៉ែត្រ

---

[៥] CARERE ។ (ការតាំងទីលំនៅនិងការធ្វើសមាហរណកម្មឡើងវិញរបស់ប្រទេសកម្ពុជានៅឆ្នាំ១៩៩២-១៩៩៦) គោលបំណងសំខាន់របស់កម្មវិធី គឺសំរបសំរួលការវិលត្រឡប់មកវិញរបស់ជនមាតុភូមិនិវត្តន៍និងជនភៀសសឹក ដើម្បីបញ្ចូលពួកគេទៅក្នុងសហគមន៍ដែលគេបានតាំងទីលំនៅ ។ ក្រោយពីមានឥទ្ធិពលយ៉ាងលឿនក្នុងរយៈពេលពីរបីឆ្នាំ អន្តរាគមន៍សង្គ្រោះឆ្ពោះទៅមុខយ៉ាងរហ័ស ទៅរកការអភិវឌ្ឍដែលមានស្ថិរភាព និងភាពជាដៃគូរយ៉ាងជិតស្និទជាមួយរដ្ឋាភិបាលកម្ពុជាដែលឈានទៅរកកម្មវិធីសិលាដែលគាំទ្រដោយ UNDP/CARERE ។

ហើយជាប់នឹងភូមិជិតខាង ។ ចាប់តាំងពីពេលនោះមកអ្នកភូមិចាស់មួយចំនួនបានទិញដី ហើយមករស់នៅកន្លែងនោះដែរ ។ នៅក្នុងភូមិចាស់អ្នកដែលមានជីវភាពធូរធាររស់នៅម្តុំ ប៉ុន្តែ អ្នកក្រមួយចំនួនរស់នៅដាច់ឆ្ងាយពីផ្នែកកណ្តាលនៃភូមិ ។ ប្រជាជនប្រកបរបរចិញ្ចឹមជីវិតសំខាន់នៅរដូវវស្សាដោយការធ្វើស្រែ និងនេសាទត្រី ។ ការខ្វះខាតទឹកបានធ្វើអោយអ្នកភូមិពិបាកក្នុងការដាំបន្លែ ។ អ្នកភូមិភាគច្រើនប្រកបរបរចិញ្ចឹមជីវិតដោយការជញ្ជូនកន្ទេលសឡង់ផងដែរ ។ ឈ្មួញ ច្រើនមក ទិញត្រី កន្ទេលសឡង់ កន្ទេល និងទំនិញដទៃទៀតដល់ភូមិ ។ អ្នកភូមិជាច្រើន ទៅធ្វើការបណ្តោះអាសន្ននៅខាងក្រៅភូមិ ។




*Kook Doung Village*

ពីឆ្នាំ១៩៧២ មានការច្បាំងគ្នាយ៉ាងខ្លាំងនៅក្នុងភូមិនេះ អ្នកភូមិគេចខ្លួននៅពេលយប់ ហើយ ត្រឡប់មកស្នាក់នៅក្នុងភូមិវិញពេលថ្ងៃ ។ ពេលនោះគោកដូង គឺជាភូមិមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ហើយខ្មែរក្រហម ក៏បានចូលមកដុតផ្ទះរបស់ប្រជាជនចំនួនពីរបីដងដែរ ។

ជំនាន់ ប៉ុល ពត អ្នកភូមិភាគច្រើនរស់នៅក្នុងភូមិ (ឬរស់នៅតាមវាលស្រែជុំវិញភូមិ) ប៉ុន្តែអ្នកដែលមកពីភ្នំពេញ និងកន្លែងដទៃទៀតត្រូវគេជម្លៀសអោយមកនៅទីនេះ ។

នៅដើមឆ្នាំ១៩៨០ ការច្បាំងគ្នាកើតឡើងជាញឹកញាប់ ។ ទ័ពខ្មែរក្រហមបានចូលមកភូមិ ដើម្បីបញ្ចុះបញ្ចូលអ្នកភូមិអោយចូលធ្វើទាហានខាងខ្លួន ហើយមកសុំអង្ករ និងថ្នាំជក់ ។ ផ្ទះរបស់អ្នកភូមិ ត្រូវបានដុតបំផ្លាញជាច្រើនដង ។ ដំបូងអ្នកភូមិរត់គេចនៅពេលយប់ ពួកគេមកស្នាក់នៅក្នុងភូមិវិញពេលថ្ងៃ ប៉ុន្តែត្រូវត្រៀមអង្ករ និងថ្នាំជក់សំរាប់អោយទាហានខ្មែរក្រហម ។ នៅឯស្រុក មានបន្ទាយទាហានវៀតណាម ហើយពួកគេក៏មកសុំស្បៀងពីប្រជាជនដែរ ។ ក្រៅពីការជ្រើសរើសទ័ព និងពលករ អ្នកភូមិត្រូវទៅជាមួយទាហានរដ្ឋាភិបាលដើម្បីសែងអាវុធ គ្រាប់រំសេវ និងស្បៀង ។

តាំងពីឆ្នាំ១៩៩២ ទាហានខ្មែរក្រហមលែងចូលមកភូមិទៀតហើយ ប៉ុន្តែអ្នកភូមិនៅតែខ្លាច និងមិនអាចធ្វើស្រែនៅឆ្ងាយៗដដែល ។ ចាប់តាំងពីឆ្នាំ១៩៩៧ ខ្មែរក្រហមមិនបានបង្កអោយមានបញ្ហាអសន្តិសុខទៀតឡើយ តាំងពីពួកគេត្រូវបានធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលរួចមក ។

អង្គការអភិវឌ្ឍន៍ជាច្រើនមានដំណើរការនៅភូមិគោកដូង ។ បច្ចុប្បន្ននេះ មានអង្គការក្នុងស្រុក និងអន្តរជាតិចំនួន២០ ដែលមានសកម្មភាពនៅក្នុងឃុំ ។

អង្គការដែលមកធ្វើការដំបូងនៅភូមិគោកដូង គឺ Ofxam UK/Ireland ។ ពីឆ្នាំ១៩៩១ គេបានបង្កើតកម្មវិធីអភិវឌ្ឍន៍សហគមន៍ ហើយនៅឆ្នាំ១៩៩៦ គេបានប្រគល់ការងារនេះអោយអង្គការក្នុងស្រុកមួយឈ្មោះ អភិវឌ្ឍន៍ស្ត្រី ។ សកម្មភាពសំខាន់ៗមានធនាគារស្រូវ ឥណទាន និងកម្មវិធីចិញ្ចឹមគោមេ ។ សកម្មភាពទាំងអស់នេះត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការដែលបានបោះឆ្នោតជ្រើសរើសដោយអ្នកភូមិ ។ Oxfam ក៏បានផ្តល់អណ្តូងលូ២និងក្រាលគ្រួសលើផ្លូវនៅក្នុងភូមិ "ចាស់" ដែលអ្នកភូមិជាអ្នកលើក ។ ក្រៅពីនេះ អង្គការអភិវឌ្ឍន៍ស្ត្រីដំណើរការកម្មវិធីដោយផ្តោតលើតែគ្រួសារជនមាតុភូមិនិវត្តន៍ ដូចជា ការផ្តល់វគ្គបណ្តុះបណ្តាល ផ្តល់គ្រាប់ពូជបន្លែ និងការដាំកូន ឈើហូបផ្លែ ។

នៅពេលថ្មីៗនេះ គេបានទិញដីស្រែ៨ហិកតា អោយជនមាតុភូមិនិវត្តន៍ចំនួន៨គ្រួសារ ដើម្បីធ្វើស្រែ និងបង់ប្រាក់រំលោះ ។

ចាប់តាំងពីជនមាតុភូមិនិវត្តន៍បានមកតាំងទីលំនៅក្នុងភូមិនៅឆ្នាំ១៩៩២-១៩៩៣ ភ្នាក់ងារដទៃទៀតក៏បានអនុវត្តសកម្មភាពសង្គ្រោះបន្ទាន់ និងកម្មវិធីអភិវឌ្ឍន៍នានា ។ ILO បានលើកផ្លូវមួយខ្សែ ហើយ CARERE សហការជាមួយ UNHCR សង់សាលារៀនមួយខ្នង ។ គ្រួសារជនមាតុភូមិនិវត្តន៍បានទទួលដី សំភារៈសំរាប់សង់ផ្ទះ និងអង្ករនៅឆ្នាំទីមួយ ។ Oxfam បានផ្តល់ស្បៀងពលកម្មសំរាប់ជីកស្រះជាលក្ខណៈគ្រួសារ និងប្រឡាយ ។ ចាប់តាំងពីពេលនោះមក មានគំរោងផ្តល់ស្បៀងពលកម្មនានានៅក្នុងផ្នែកផ្សេងៗរបស់ភូមិ ។

នៅចុងឆ្នាំ១៩៩៧ មានការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ហើយកម្មវិធីសិលាបានចាប់ដំណើរការនៅក្នុងភូមិ ។ នៅឆ្នាំទីមួយនៃដំណើរការកសាងមូលដ្ឋាន គេបានផ្តល់ថវិកាសំរាប់ស្តារប្រឡាយ ។ គ.អ.ភ បានប្រើថវិកាអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីផ្តល់របបអោយអ្នកភូមិស្តារប្រឡាយនេះ ប៉ុន្តែអ្នកភូមិក៏ត្រូវចូលរួម

ជាកំលាំងពលកម្មដែរ ។ រយៈពេល២ឆ្នាំក្រោយមក ភូមិគោកដូងមិនបានទទួលអ្វីពីថវិកាអភិវឌ្ឍន៍មូលដ្ឋាន ។ ប៉ុន្តែនៅពេលថ្មីៗនេះ កម្មវិធីស្បៀងអាហារពិភពលោកបានផ្តល់ស្បៀងពលកម្ម ដើម្បីលើកផ្លូវថ្នល់មួយខ្សែតាមរយៈកម្មវិធីសិលា ហើយនេះជាលើកទី១ ដែលអ្នកភូមិ នឹងត្រូវចូលរួមវិភាគទានជាស្រូវ ។

CARERE ក៏បានផ្តល់ថវិកាតាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្តដើម្បីសង់បង្គន់អនាម័យ ដំណាំហូបផ្លែ និងការពិសោធន៍ពូជស្រូវ ។ អង្គការផ្សេងៗទៀត បានបើកថ្នាក់អក្ខរកម្ម វគ្គបណ្តុះបណ្តាលសិទ្ធិមនុស្ស អប់រំសុខភាព និងសុខភាពផ្លូវចិត្ត ហើយនៅពេលថ្មីៗនេះសប្បុរសជនមកពីសហរដ្ឋដែលមានស្រុកកំណើតនៅឃុំនេះ បានផ្តល់ថវិកាសំរាប់ធ្វើអណ្តូងឈ្នាន់ចំនួន ៩ ។

អង្គការនានាបានផ្តល់អំណោយជាច្រើនលើក ។ ក្រៅពីការសាងសង់ផ្ទះ និងបង្គន់អនាម័យ អង្គការ HelpAge បានផ្តល់សំភារៈប្រើប្រាស់ផ្សេងៗទៀតដូចជា ចាន ឆ្នាំង អង្ករ និងលុយ ។ អង្គការសេវាអភិវឌ្ឍន៍សំរាប់គ្រួសារកម្ពុជា (CFDS) បានចែកអង្ករនិងឯកសណ្ឋានសិស្សដល់កូនស្រីមេម៉ាយនៃគ្រួសារជនមាតុភូមិនិវត្តន៍ ។ ក្រោយពីមានខ្យល់ព្យុះនៅឆ្នាំ១៩៩៥ CFDS បានចែកភួយ មុង សារ៉ុង អង្ករ និងតង់ ហើយ LWS បានផ្តល់ជាគ្រាប់ពូជដំណាំ ។ អង្គការអភិវឌ្ឍន៍ស្ត្រី បានចែកថ្នាំពេទ្យ និងមុង ហើយចាប់តាំងពីឆ្នាំ១៩៩៦ គេបានប្រារព្ធធ្វើពិធីបុណ្យសិទ្ធិនារីអន្តរជាតិ ដោយមានសំណួរចម្លើយ និងរង្វាន់សំរាប់អ្នកឆ្លើយសំនួរស្តីពីនារីត្រូវ ។

# ជំពូក ២

# ការយល់ឃើញរបស់អ្នកភូមិ ចំពោះការគ្រប់គ្រងនៅតាមមូលដ្ឋាន

## ភូមិ

### *តួនាទី និងកិត្តិស័ព្ទរបស់ថ្នាក់អំណាចមូលដ្ឋាន*

*ភូមិជ្រៃង: ឪពុកស្លូត និងបុរសខ្លាំងដែលគួរអោយខ្លាច*

- មេភូមិជាមនុស្សស្លូត អ្នកភូមិជាទូទៅចូលចិត្តគាត់ ។ អ្នកភូមិមានទំនាក់ទំនងជាមួយមេភូមិតាមបែបជារៀមច្បង ។
- មានប្រធានជីវពលដ៏តឹងរឹងម្នាក់ដែលអ្នកភូមិមានការខ្លាចរអា និងគួរអោយស្អប់ ។ ដោយសារអត្តចរិក និងបុគ្គលិកលក្ខណៈរបស់គាត់ គាត់ត្រួតត្រាការងារនៅក្នុងភូមិនេះ ហើយមានអំណាចជាងមេភូមិ ព្រោះគាត់ស្គាល់អ្នកធ្វើការនៅថ្នាក់លើ ។

នៅភូមិជ្រៃង មេភូមិ និងប្រធានជីវពលជាអ្នកដឹកនាំ ដែលអ្នកភូមិភាគច្រើននិយាយថា ជីវពលរូបនេះ ជានគរបាលភូមិ និងអនុប្រធានភូមិ ប៉ុន្តែពួកគេនៅតែមិនដឹងច្បាស់ថា គាត់មានមុខងារអ្វីជាផ្លូវការអោយបានពិតប្រាកដនៅឡើយទេ (សូមអានប្រវត្តិនៃការដឹកនាំភូមិ) ។

ជាទូទៅ អ្នកភូមិចូលចិត្តមេភូមិ ។ ពួកគេនិយាយថា គាត់ជាមនុស្សស្លូត ចិត្តល្អ កម្រប្រើពាក្យមិនសមរម្យ ឬបង្ខំអ្នកភូមិអោយធ្វើអ្វីឡើយ ។ ទំនាក់ទំនងរវាងអ្នកភូមិ និងមេភូមិ ហាក់ដូចជាមានលក្ខណៈបុគ្គល ។ អ្នកភូមិចាត់ទុកមេភូមិជា "ឪពុក" របស់ពួកគេ ហើយជួនកាលគាត់និយាយថា អ្នកភូមិជា "កូន" របស់គាត់ ។

ជាទូទៅ អ្នកភូមិនិយាយថា ពួកគេអាចទៅរកមេភូមិនៅពេលណាដែលពួកគេមានបញ្ហា។ ទំនាក់ទំនងតាមសិទ្ធិរៀមច្បងនេះ ហាក់ដូចជាមានន័យថា ពួកគេធ្វើតាមតែគាត់ប្រាប់។ ជាទូទៅ ពួកគេនិយាយថា ការងារ

របស់មេភូមិ គឺ "គ្រប់គ្រង" ។ គាត់ទទួលផែនការពីថ្នាក់លើ[១] និង ហៅប្រជាជនទៅប្រជុំ ។ គាត់រាយការណ៍អោយថ្នាក់លើ សំខាន់ គឺស្ថិតិប្រជាជន ។ គាត់ដោះស្រាយជម្លោះនៅក្នុងភូមិ និងទូន្មានប្រជាជនកុំអោយធ្វើខុស ។

*តួនាទីរបស់មេភូមិ គឺប្រាប់អ្នកភូមិកុំអោយឈ្លោះគ្នា ប្រាប់អ្នកភូមិអោយប្រឹងរកស៊ី ជួយអ្នកក្រអោយមាន ។ គាត់ដោះស្រាយជម្លោះនៅក្នុងភូមិ ការពារសន្តិសុខ ប្រាប់អ្នកភូមិ អោយយាមយប់ ហើយគាត់ដើរល្បាតមើលអ្នកយាម (ក្រុមក្មេងប្រុស ខែតុលា ឆ្នាំ១៩៩៩) ។*

*មេភូមិជាមនុស្សល្អណាស់! គាត់ស្មោះត្រង់ ចិត្តល្អ ។ មេភូមិណែនាំនៅពេលអ្នកណាម្នាក់ធ្វើអ្វីខុស ។ នៅពេលសុខា[២] ស្រវឹង ហើយអ្នកដទៃមិនចូលចិត្ត មេភូមិណែនាំគាត់ (ក្រុមស្ត្រីក្រីក្រ ខែតុលា ឆ្នាំ១៩៩៩) ។*

ក្រៅពីមេភូមិជាមនុស្សស្លូត និងមានសមត្ថភាពទាបនោះ មានមនុស្សម្នាក់ទៀតដែលគ្រប់គ្រងស្ថានការ និងការយល់ឃើញរបស់អ្នកភូមិចំពោះអាជ្ញាធរថ្នាក់ភូមិ ។ អ្នកភូមិភាគច្រើនខ្លាច និងស្អប់ប្រធានជីវពលនេះ ប៉ុន្តែក៏មានមនុស្សមួយក្រុមគាំទ្រគាត់ដែរ ។ អ្នកភូមិនិយាយថា មនុស្សនេះទទួលបន្ទុកផ្នែកសន្តិសុខ ប៉ុន្តែក៏មានភារកិច្ចផ្សេងៗទៀតដូចជា ការដោះស្រាយជម្លោះ។ មូលហេតុដែលធ្វើអោយអ្នកភូមិមិនសប្បាយចិត្ត គឺថាគាត់ "ខ្លាំង" ហើយប្រើពាក្យគំរោះគំរើយ ។ ជូនកាលគាត់ស្ពាយកាំភ្លើង និងជាញឹកញាប់ គាត់តែងផឹកស៊ី ហើយថែមទាំងសំឡុតធ្វើអោយប្រជាជនកាន់តែខ្លាចថែមទៀត ។

*ប្រជាជនខ្លាចអាជ្ញាធរនៅក្នុងភូមិ (មិនមែនមេភូមិទេ) ប៉ុន្តែអ្នកផ្សេងទៀត ដូចជាអនុប្រធានរបស់គាត់ (សមាជិក គ.អ.ភ ខែមិថុនា ឆ្នាំ១៩៩៩) ។*

*អាហ្នឹងវាឡូយណាស់ វាចង់អោយអ្នកភូមិខ្លាចវា ។ ដោយសារមេភូមិតែងតាំងវា វាឡូយ ។ ប្រហែលជា វាគិតថា ច្បាប់នៅក្នុងខ្លួនវាហើយមើលទៅ (ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

វត្តមានរបស់ "បុរសខ្លាំង" ប្រចាំភូមិនេះ បានជះឥទ្ធិពលយ៉ាងធ្ងន់ទៅលើតួនាទី និងកិត្តិស័ព្ទរបស់មេភូមិ ។ នៅខាងក្រោយសម្ព័ន្ធភាពរបស់គាត់ គាត់ជាមនុស្សម្នាក់ដែលអ្នកភូមិសំដែងអោយឃើញនូវឧទាហរណ៍ទីមួយដែលការមិនសប្បាយចិត្ត ហាក់ដូចជាកាន់តែច្រើន ហើយអ្នកភូមិនិយាយដោយឥតលាក់លៀមកាន់តែខ្លាំងឡើងៗ នៅពេលដែលការស្រាវជ្រាវបានបន្ត (ខែមិថុនា ឆ្នាំ១៩៩៩ដល់ខែមិនា ឆ្នាំ២០០០) ។ ការព្រួយបារម្ភមួយនោះគឺថា មេភូមិមិនប្រគល់ការងារអោយទៅអ្នកដទៃ ប៉ុន្តែគាត់ក៏មិនធ្វើការងារដោយខ្លួនឯងដែរ ។

*មេភូមិខ្លាំង គាត់ធ្វើសព្វគ្រប់ ។ ប៉ុន្តែគាត់ក៏ខ្សោយដែរ (គាត់មានមុខតំណែងច្រើន ប៉ុន្តែគាត់មិនសូវសកម្ម) (ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

---

[១] ប្រជាជននៅភូមិទាំងពីរនិយាយយ៉ាងទូលំទូលាយអំពីថ្នាក់លើដោយយោងទៅលើបញ្ហាជាផ្លូវការទាំងអស់ពីលើភូមិ ។

[២] សុខា គឺជាអ្នកក្រប់ផុតម្នាក់ក្នុងចំណោមអ្នកក្រប់ផុតទាំងអស់នៅក្នុងភូមិ ។ គាត់គ្មានដីស្រែទេ ហើយនៅក្នុងក្រុមពិភាក្សានៅពេលនេះ បានអោយដឹងថា គាត់គ្មានផ្ទះផ្ទាល់ខ្លួនទេ ប៉ុន្តែគាត់ស្នាក់នៅផ្ទះអ្នកផ្សេង ។ គាត់ស្រវឹងជាញឹកញាប់ ។

ការរអ៊ូរទាំមួយទៀតគឺ មេភូមិនិយមតែសាច់ញាតិ និងគ្នាគាត់តែប៉ុណ្ណោះ ប៉ុន្តែអ្នកដែលមិនបានទទួលផលប្រយោជន៍ពីគាត់ មិនពេញចិត្តគាត់ទេ ។ បុរសម្នាក់ដែលខ្ទបខ្ទាចមេភូមិ និងជីវពល បានប្រាប់ក្រុមស្រាវជ្រាវក្រោយពីការប្រជុំលើកទីមួយរបស់យើងជាមួយក្រុមផ្តល់យោបល់ (សូមអានអត្ថបទស្តីពីបញ្ហា និង វិធីសាស្ត្រ) ក្នុងនាមគាត់ជាសមាជិកក្រុមផ្តល់យោបល់ថា:

*មនុស្សបីនាក់ក្នុងក្រុម នៅខាងមេភូមិ អញ្ចឹងហើយ បានជាអ្នកដទៃមិនហ៊ាននិយាយ (បុរសម្នាក់ ខែតុលា ឆ្នាំ១៩៩៩) ។*

ប៉ុន្តែការត្អូញត្អែរភាគច្រើន និយាយតែពីរឿងទំនាក់ទំនងមេភូមិនិងជីវពលម្នាក់នោះ ឬពីអសមត្ថភាពរបស់គាត់ក្នុងការបង្រ្កាបទង្វើរបស់ជីវពលនេះបាន ។ គាត់ជាជីវពលដែលអ្នកភូមិភាគច្រើនមិនចូលចិត្ត និងចង់ដកចេញ ។ ប៉ុន្តែពួកគេមានការខកចិត្តណាស់នៅពេលដែលមេភូមិអនុញ្ញាតអោយមនុស្សនេះគ្រប់គ្រងពួកគាត់ និងភូមិខ្លាំងពេក ហើយមេភូមិក៏ដឹងដែរថាអ្នកភូមិគិតពីអ្វី ។ នៅលើកដំបូងនៃការស្រាវជ្រាវ ពេលដែលអ្នកទាំងពីរធ្វើការជាមួយគ្នាយ៉ាងល្អកល្អឹន មេភូមិបានបដិសេធថាជីវពលនេះ មិនគ្រប់គ្រងភូមិទេ ហើយគាត់ក៏បាននិយាយដែរថា គាត់គឺជាអ្នកអោយមនុស្សនេះធ្វើជាជីវពល ព្រោះគាត់ចង់បង្ហាញពីភាពខ្លាំង និងការគ្រប់គ្រងរបស់គាត់ ។ ប៉ុន្តែបន្ទាប់មកដោយសារទំនាក់ទំនងរវាងអ្នកទាំងពីរកាន់តែយ៉ាប់ទៅៗ ហើយនៅពេលដែលអ្នកភូមិរអ៊ូរទាំ កាន់តែខ្លាំងឡើងៗ មេភូមិហាក់ដូចជាយល់ស្របតាមអ្នកភូមិទាំងស្រុងដែរ ។ ប៉ុន្តែគាត់មិនហ៊ានសំរេច ឬមានអំណាចអ្វីដើម្បីគាត់បន្ថយឥទ្ធិពលរបស់ជីវពលម្នាក់នេះទេ ដូច្នេះហើយអ្នកភូមិហាក់ដូចជាមានបំណងព្យាយាមទំលាក់មេភូមិកាន់តែខ្លាំងឡើងៗ ។

*មេភូមិអោយ ហ៊ន (ជីវពល) ទទួលខុសត្រូវការងារជាច្រើន អញ្ចឹងទៅមេភូមិក្លាយជាអនុប្រធាន ហើយអនុប្រធានក្លាយជាមេភូមិ (សមាជិក គ.អ.ភ ខែតុលា ឆ្នាំ១៩៩៩) ។*

*ខ្ញុំប្រាប់មេភូមិថា កុំអោយមនុស្សនេះធ្វើអ្វីស្រេចតែចិត្ត ។ ប្រជាជនមិនស្អប់មេភូមិទេ គេស្អប់តែហ៊ន (សមាជិក គ.អ.ភ ក្នុងក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

*គាត់ (ជីវពលនេះ) ទទួលខុសត្រូវផ្នែកសន្តិសុខក្នុងភូមិ ។ គាត់មិនពាក់ព័ន្ធក្នុងរឿងដោះស្រាយជម្លោះ ឬចេញសំបុត្ររៀបអាពាហ៍ពិពាហ៍នោះទេ ។ ប្រជាជនមករកតែខ្ញុំអោយដោះស្រាយរឿងទាស់ទែងគ្នា ។ បើខ្ញុំមិននៅ ខ្ញុំផ្ញើរការងារនេះអោយអនុប្រធាន ។ ហើយបើអនុប្រធានមិនអាចដោះស្រាយបាន ខ្ញុំជាអ្នកដោះស្រាយនៅពេលដែលខ្ញុំត្រឡប់មកវិញ ។ នៅពេលខ្ញុំទៅណាឆាត់ អ្នកភូមិរាយការណ៍ប្រាប់ខ្ញុំថា គាត់យកលុយពីពួកគេ ។ ប៉ុន្តែគាត់ធ្វើដូចជាមិនដឹងអីសោះ ហើយខ្ញុំជាមនុស្សគោរពច្បាប់ ។ គាត់មិនមែនជាអនុប្រធានភូមិទេ ប៉ុន្តែអ្នកភូមិចេះតែហៅគាត់ថា អនុប្រធាន[៣] ។ យកល្អ លោកស្រីគួរតែសួរពួកគេថា ម៉េចបានអញ្ចឹង... គាត់កំពុងតែធ្វើហួសពីតួនាទីរបស់គាត់ ។ អ្នកភូមិប្រាប់ខ្ញុំថា ជីវពល*

[៣] មេភូមិផ្ទាល់ក៏ឧស្សាហ៍និយាយអំពី "អនុប្រធានភូមិ" ។ ពេលមួយដែលនិយាយលេងតទល់នឹងបញ្ហានេះ គាត់មានការអៀនខ្មាស ហើយប្រញាប់កែយ៉ាងរហ័សដោយខ្លួនគាត់ថា "ទេ! ខ្ញុំចង់និយាយថា ជាប្រធានជីវពល" ។

*នេះ កំពុងតែក្លាយជាមេរបស់ខ្ញុំហើយ មានការពិកខ្លះដែលអ្នកភូមិនិយាយ ប៉ុន្តែខ្ញុំអោយគាត់ធ្វើ ។ ការងារខ្ញុំនៅតែជាការងារខ្ញុំដដែល (មេភូមិ ខែមិនា ឆ្នាំ២០០០) ។*

នៅមានការលំបាកបន្តិចដើម្បីយល់អោយបានច្បាស់ថាជីវពលនេះបានអំណាចមកពីណា ។ ការពន្យល់ជារួមអំពីអត្តចរិកក្រអើតក្រទមរបស់គាត់ (ដែលបានផ្តល់ដោយអ្នកភូមិ មេភូមិ ជីវពលខ្លួនគាត់ផ្ទាល់ ព្រមទាំងមេឃុំនោះ)គឺតាមរយៈនៃការប្រើប្រាស់ពាក្យសំដីរបស់គាត់។ ប្រភពមួយទៀតនៃអំណាច និងមូលហេតុដែលអ្នកភូមិខ្លាចគឺជីវពលម្នាក់នេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយថ្នាក់លើ។ មេភូមិរារែកមិនហ៊ានសារភាពថា ថ្នាក់លើគាំទ្រជីវពលនេះទេ។ ប៉ុន្តែជីវពលនេះស្គាល់អ្នកធ្វើការនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលគាត់និយាយថា ពួកគេចូលចិត្តគាត់ និងអ្នកដែលគាត់ប្រាប់ពីបញ្ហារបស់គាត់នៅក្នុងភូមិ។ អ្នកធ្វើការនៅថ្នាក់ស្រុក ឧស្សាហ៍មកជិតស៊ីនៅផ្ទះគាត់ណាស់ មេឃុំដែលបានដឹងពីការត្អូញត្អែររបស់អ្នកភូមិដែរនោះ ដឹងច្បាស់ថាគាត់គាំទ្រអ្នកណា ។ នៅពេលដែលក្រុមសិក្សាសម្ភាសន៍ជាមួយមេឃុំ មន្ត្រីថ្នាក់ឃុំដទៃទៀតជាច្រើន បានសរសើរហ៊ានគ្រប់ៗគ្នា ប៉ុន្តែសមាជិក គ.អ.ឃ ម្នាក់ទៀតកាន់តែយល់ និងព្រួយបារម្ភពីបញ្ហាជាមួយរដ្ឋអំណាចថ្នាក់ភូមិនៅភូមិជ្រៃង ។

*ហ៊ន មានអំណាច ព្រោះគាត់មានទំនាក់ទំនងច្រើនជាមួយអ្នកធ្វើការនៅថ្នាក់ឃុំ និងថ្នាក់ស្រុក ។ នៅពេលមន្ត្រីថ្នាក់លើចុះមកភូមិ ភាគច្រើនគេទៅតែផ្ទះគាត់ ។ គេឃើញថា គាត់ពូកែនិយាយ ហើយគាត់អាចគ្រប់គ្រងអ្នកដែលមានតួនាទីនៅក្នុងភូមិ ។ អនុប្រធានភូមិត្រូវបានបង្កើតឡើងដើម្បីធ្វើការងារជាមួយមេភូមិ ។ អញ្ចឹងហើយបានជាគាត់ខ្លាំងជាងមេភូមិ ។ វាក៏ជាកំហុសរបស់អ្នកភូមិដែរ បើមេភូមិបញ្ជូនពួកគេទៅអោយអនុប្រធានភូមិ ពួកគេគួរតែទៅរកមេឃុំជំនួសវិញ។ ប៉ុន្តែថ្នាក់លើគាំទ្រគាត់ ពួកគេតែងតែស្តាប់ហ៊ន ។ មេឃុំគាំទ្រគាត់ខ្លាំងមែនទែន (បុរសម្នាក់ក្នុងកិច្ចសម្ភាសន៍ផ្ទាល់ និងក្នុងក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

*គាត់ជាមនុស្សល្អ ក្លាហ៊ាន និងពូកែនិយាយ ។ មេភូមិស្លូតពេក ប្រជាជនមិនស្តាប់គាត់ទេ ។ ប៉ុន្តែពេលមានហ៊ននៅជាមួយ ពួកគេស្តាប់ ។ ប្រជាជននិយាយថា បើខ្ញុំចង់ឈ្នះការបោះឆ្នោតឃុំ ខ្ញុំត្រូវតែទំលាក់គាត់ចោល ។ ប៉ុន្តែគាត់មិនដែលធ្វើអីខុសផង គាត់មិនដែលធ្វើអោយអ្នកណាមានរបួសផង ។ ដូច្នេះខ្ញុំមិនហ៊ានទំលាក់គាត់ទេ ។ បើខ្ញុំធ្វើ ខ្ញុំនឹងបាត់បង់គាត់ (មេឃុំ ខែមិនា ឆ្នាំ២០០០) ។*

*មេភូមិប្រគល់សិទ្ធិអោយហ៊នធ្វើអ្វីៗគ្រប់យ៉ាង ។ នៅពេលដែលខ្ញុំទៅជ្រៃង ហ៊ន ស្តីអោយខ្ញុំថា ខ្ញុំកាន់គណបក្សផ្សេង ប៉ុន្តែគាត់មិនអាចទាលុយពីខ្ញុំបានទេ ។ មេឃុំ និងគាត់ត្រូវគ្នាណាស់ ព្រោះគេកាន់គណបក្សដូចគ្នា ។ មេឃុំដឹងច្បាស់ថា អ្នកភូមិគិតយ៉ាងម៉េចចំពោះហ៊ន ហើយនៅភូមិជ្រៃង អ្នកភូមិមិនចូលចិត្តគាត់ ហើយគាត់ក៏មិនប្រកាន់នូវអ្វីដែលហ៊នធ្វើដែរ ។ ហ៊នប្រហែលជារាយការណ៍អោយគាត់ អញ្ចឹងហើយបានជាគាត់ដឹងច្បាស់ម្លេះ (សមាជិក គ.អ.ឃ ដែលមកពីភូមិផ្សេង ខែមិនា ឆ្នាំ២០០០) ។*

*អ្នកភូមិស្អប់គាត់ (ជីវពល) ។ សូម្បីតែឃុំក៏ខ្លាចគាត់ដែរ (មេក្រុម ខែមិនា ឆ្នាំ២០០០) ។*

*ខ្ញុំមានមិត្តភក្តិពីរនាក់ ម្នាក់ធ្វើការនៅមន្ទីរខេត្ត ម្នាក់ទៀតធ្វើទាហ៊ានទៅភ្នំពេញ ។ ពួកគេហៅអោយខ្ញុំទៅធ្វើការ ប៉ុន្តែខ្ញុំមិនព្រម ។ ខ្ញុំស្គាល់ លី សុខ និង សៅ វាសនា (មន្ត្រីខេត្ត ហើយបានដូរឈ្មោះ ។ នៅជំនាន់ប៉ុលពត យើងរស់ជាមួយគ្នា យើងជាប់ឃុំឃាំងជាមួយគ្នា (ជីវពល ខែតុលា ឆ្នាំ២០០០) ។*

## ភូមិគោកដូង ប្រធានស្លូត ហើយអនុប្រធានចេះអក្សរ

- ការដឹកនាំនៅក្នុងភូមិមិនសូវមានលក្ខណៈបុគ្គល និងមានលក្ខណៈការងារជាងនៅក្នុងភូមិជ្រែង ។
- មេភូមិស្លូត និងស្មោះត្រង់ ទោះគាត់ជាមនុស្សអសកម្មបន្តិចក៏ដោយ អ្នកភូមិនៅតែចូលចិត្តគាត់ដែរ ។
- អនុប្រធានភូមិចេះអក្សរ និងសកម្មជាងមេភូមិ ហើយអ្នកភូមិក៏គោរពគាត់ដែរ ។
- ជនមាតុភូមិនិវត្តន៍មិនសូវស្គាល់មេភូមិទេ ប៉ុន្តែពួកគេស្គាល់អនុប្រធានភូមិច្រើនជាង ។

នៅភូមិគោកដូងក៏អញ្ចឹងដែរ អ្នកភូមិយល់ថា មេភូមិ និងអនុប្រធានភូមិជាអ្នកដឹកនាំដ៏សំខាន់ ។ ប៉ុន្តែមានមនុស្សពីរនាក់ផ្សេងទៀតដែលជាតំណាងអតីតសមាគមយុវជន ហើយសព្វថ្ងៃនេះជាសមាជិកអង្គការអភិវឌ្ឍន៍ស្ត្រី និងជាសមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ដែលអ្នកភូមិក៏ចាត់ទុកជាអ្នកដឹកនាំភូមិមួយផ្នែកដែរ ។

ជាទូទៅ ប្រជាជននៅភូមិគោកដូងនិយាយថា ពួកគេចូលចិត្តមេភូមិគេខ្លាំងណាស់ ។ ប៉ុន្តែទំនាក់ទំនងរបស់ពួកគេជាមួយមេភូមិហាក់ដូចជាមិនសូវមានលក្ខណៈជាបុគ្គលទេ និងមានលក្ខណៈការងារជាងនៅភូមិជ្រែង-នៅក្នុងន័យថា ក្នុងនាមជាមេភូមិដែលមានភារកិច្ចពិតប្រាកដ ។ ភារកិច្ចរបស់មេភូមិដែលប្រជាជននិយាយគឺ មានលក្ខណៈទូលាយដូចនៅភូមិជ្រែងដែរ សំខាន់គឺទទួលផែនការពីថ្នាក់លើ និងរាយការណ៍អោយគេ ចេញសំបុត្ររៀបអាពាហ៍ពិពាហ៍ "ដឹកនាំ" ប្រជាជន និងសម្រុះសម្រួលក្នុងរឿងជម្លោះប្ដីប្រពន្ធ ។ អ្នកភូមិយល់ច្បាស់ថា មេភូមិជាមនុស្សស្មោះត្រង់ យុត្តិធម៌ និងមិនអាត្មានិយម ប៉ុន្តែគួរអោយសោកស្ដាយ ព្រោះគាត់មិនសូវចេះអក្សរ ហើយហាក់ដូចជាទ្បើយឈាយ និងអសកម្មបន្តិច ។

*មេភូមិទៅរៀនទៅឃុំ ។ ៤-៥ ថ្ងៃគាត់ទៅម្ដង ប៉ុន្តែខ្ញុំមិនដឹងថា គាត់ទៅរៀនពីអ្វីទេ ។ គាត់ក៏ហៅប្រជាជនមកប្រជុំដែរពីរឿងធ្វើស្រែ និងការថែរក្សាផ្លូវ ហើយគាត់ប្រាប់អ្នកភូមិកុំអោយចងគោនៅតាមផ្លូវនេះ (បុរសម្នាក់ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*គាត់ទទួលផែនការពីថ្នាក់លើ ហើយប្រកាសប្រាប់អ្នកភូមិ ។ គាត់អោយពួកគេធ្វើការ ដូចជា ជីកប្រឡាយ រីលើកផ្លូវថ្នល់ ។ បើអ្នកភូមិមានបញ្ហា ពួកគេទៅជួបគាត់ ហើយពួកគេ ក៏ទៅរកគាត់អោយចេញសំបុត្រអាពាពិពាហ៍ដែរ ។ គាត់មិនដែលធ្វើអោយប្រជាជនខកចិត្តទេ ។ គាត់ពិភាក្សាជាមួយប្រជាជន មុននឹងគាត់សំរេចធ្វើអ្វីមួយ (ស្ត្រីម្នាក់ ខែមករា ឆ្នាំ២០០០) ។*

*តួនាទីរបស់គាត់ គឺគ្រប់គ្រងប្រជាជន ធ្វើស្ថិតិប្រជាជន និងដោះស្រាយបញ្ហា ។ គាត់ជាមេភូមិល្អ គាត់មិនដែលកេងប្រវ័ញ្ចអ្នកភូមិនាម្នាក់ទេ ។ ឧទាហរណ៍ គាត់ទៅរកត្រីដោយខ្លួនឯង ហើយគាត់មិនដែលសុំត្រីពីអ្នកណាទេ (ប្រធាន គ.អ.ភ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

អ្នកភូមិក៏គោរពអនុប្រធានភូមិណាស់ដែរ ប៉ុន្តែគេគោរពដោយហេតុផលខុសគ្នាពីមេភូមិ ។ គាត់ចេះអក្សរ និងមានសមត្ថភាព ។ ប្រជាជន ជាទូទៅហៅគាត់ជានគរបាលភូមិ បាននិយាយថាតួនាទីជាស់ខាន់របស់គាត់ គឺដោះស្រាយជម្លោះ ចុះហត្ថលេខាលើការដោះដូរដី និងជួយសរសេរលិខិតស្នាមអោយអ្នកភូមិ ។ គាត់ច្រើនរវល់ការងារនៅវត្ត អ្នកភូមិមួយចំនួនចាត់ទុកគាត់ជា*អាចារ្យ* ។ ពួកគេសរសើរចំណេះដឹង និងជំនាញរបស់គាត់ ប៉ុន្តែពួកគេក៏រអ៊ូរដែរថា គាត់គិតពីការងារផ្ទាល់ខ្លួនខ្លាំងពេក ហើយយកលុយនូវរាល់ការងារដែលគាត់ធ្វើ ។

*គង់ជានគរបាលភូមិ ធ្វើការជាមួយមេភូមិ ។ តួនាទីគាត់ គឺដោះស្រាយជម្លោះនិងធ្វើសំបុត្របញ្ជាក់កម្មសិទ្ធិដី ។ អ្នកភូមិហាក់ដូចជាអោយលុយគាត់ច្រើនជាងមេភូមិ (បុរសម្នាក់ ខែមករា ឆ្នាំ២០០០) ។*

ដោយសារមេភូមិកាន់តែចាស់ និងទៀយហត់ ហើយអនុប្រធានកាន់តែសកម្មនិងចេះអក្សរ ។ ជួនកាលអនុប្រធានភូមិធ្វើការជំនួសមេភូមិ និងដឹងនូវរឿងរ៉ាវទាំងឡាយ ដែលកើតឡើងនៅក្នុងភូមិ ។ ស្ថានការណ៍នេះហាក់ដូចជាសក្តិសមសំរាប់អ្នកទាំងពីរ ហើយពួកគាត់មានទំនាក់ទំនងជាមួយគ្នាយ៉ាងប្រសើរ ឯការងារក៏មានការបែងចែកល្អ ប៉ុន្តែមេភូមិបដិសេធថា អនុប្រធានគាត់សកម្មជាង ។ អ្នកភូមិចូលចិត្តមេភូមិជាង ប៉ុន្តែពួកគេត្រូវទៅពិភាក្សាជាមួយអនុប្រធានច្រើនជាងមេភូមិ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលនៃការស្នាក់នៅចុងក្រោយរបស់ក្រុមសិក្សានៅខែមេសា ឆ្នាំ២០០០ អ្នកភូមិកាន់តែមិនសប្បាយចិត្តជាមួយអនុប្រធានភូមិ និងប្រពន្ធរបស់គាត់ ព្រោះពួកគេនិយាយថា ប្តីប្រពន្ធពីរនាក់នេះ គិតតែពីរឿងប្រាក់ចំណូលផ្ទាល់ខ្លួន ។ អ្នកភូមិបានអោយដឹងថា អនុប្រធានភូមិដឹងពីរឿងនេះច្បាស់ ហេតុដូច្នេះហើយទើបគាត់ "ដក" ខ្លួនចេញពីការងារភូមិ ហើយទៅធ្វើការនៅវត្តជំនួសវិញ (ព្រោះគាត់បានចំណូលពីការងារនេះជាង) ។

*ខ្ញុំដឹងពីការលំបាករបស់អ្នកភូមិ ហើយរាយការណ៍អោយឃុំ ។ ខ្ញុំរាយការណ៍ពីការបង្កបង្កើនផលពីការខូចដំណាំស្រូវ ។ ដូចជារឿងទាស់គ្នា អ្នកភូមិមកជួបខ្ញុំ ឬអនុប្រធាន ជួនកាលយើងពិភាក្សាគ្នា ។ បើខ្ញុំមិននៅ ខ្ញុំឱ្យអនុប្រធានទទួលខុសត្រូវ ដូច្នេះគាត់អាចទៅឃុំជំនួសខ្ញុំ (មេភូមិ ខែមករា ឆ្នាំ២០០៧) ។*

*មេភូមិធំជាងខ្ញុំ ខាងស្រុក និងឃុំទៅផ្ទះមេភូមិ ហើយបន្ទាប់មកមេភូមិប្រាប់ខ្ញុំ ។ ប៉ុន្តែខ្ញុំមិនមែនជាអ្នកដែលអាចសរសេររបាយការណ៍តែម្នាក់ឯងទេ ។ ក្នុងនាមជាអនុប្រធានភូមិ ខ្ញុំសរសេររបាយការណ៍ផ្នែកសន្តិសុខ មានជីវពលប៉ុន្មាននាក់ សល់ប៉ុន្មាន ឈប់ប៉ុន្មាន និងរាយការណ៍ ពីទិន្នផលស្រូវ ទឹកជំនន់ បំផ្លាញអស់ប៉ុន្មាន ។ល។ ប្រជាជនមកប្តឹងខ្ញុំជាងមេភូមិ ។ គាត់មិនសូវចេះអក្សរ គាត់មិនអាចដោះស្រាយបាន ដូច្នេះពួកគេមករកខ្ញុំ ។ បើសិនជាបញ្ហាធំ ខ្ញុំពិភាក្សាជាមួយមេភូមិ ប៉ុន្តែបើរឿងតូចតាចខ្ញុំចេះតែដោះស្រាយទៅ ។ មេភូមិមិនថាអីទេ គាត់ចង់អោយខ្ញុំដោះស្រាយជម្លោះ ។ ពេលគេទៅរកគាត់ គាត់បញ្ជូនមកអោយខ្ញុំ (អនុប្រធានភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*អ្នកទាំងពីរគ្មានអ្នកណាខ្លាំងជាងអ្នកណាទេ ។ អ្នកភូមិអាចទៅជួបអ្នកណាក៏បានដែរ ។ ប៉ុន្តែគង់ [អនុប្រធានភូមិ] ចេះអក្សរ ។ ពេលគេត្រូវធ្វើសំបុត្រស្នាម គេទៅជួបគាត់ ។ ហៀន [មេភូមិ] មិនសូវចេះអក្សរទេ គាត់ដឹងតែចុះហត្ថលេខាតែប៉ុណ្ណោះ (ក្រុមផ្តល់យោបល់ ខែកុម្ភៈ ឆ្នាំ២០០០) ។*

*នៅពេលដែលលក់ ទិញដី ត្រូវទៅជួបគង់ ហើយអោយលុយគាត់ ១០០បាតទៅ ។ ខ្ញុំធ្វើអញ្ចឹង ពេលខ្ញុំទិញដីនេះ ។ មេភូមិ និងប្រពន្ធគាត់ស្លូត តែបើអត់អោយលុយគង់ ប្រពន្ធគាត់នឹងមកយកលុយ ដល់ផ្ទះ ។ ហ្សេនដឹងថា គង់យកលុយ ប៉ុន្តែគាត់នៅស្ងៀម ។ អ្នកទាំងពីរសហការគ្នាល្អណាស់ (ស្ត្រីម្នាក់ ខែមករា ឆ្នាំ២០០០) ។*

*ជួនកាល គង់ ធ្វើការងារដោយមិនប្រាប់មេភូមិ (អ្នកភូមិមួយក្រុមតូចដែលមានស្រី និងប្រុស ខែមករា ឆ្នាំ២០០០) ។*

ជនមាតុភូមិនិវត្តន៍ដែលនៅឆ្ងាយពីភូមិចាស់ មានបទពិសោធន៍ និងយល់អំពីរដ្ឋអំណាចភូមិខុសពីអ្នកភូមិចាស់ ។ ពួកគេមិនសូវស្គាល់មេភូមិទេ ហើយមេភូមិក៏មិនសូវស្គាល់ពួកគេដែរ ។ ភាគច្រើននៃអ្នកទាំងនោះនិយាយថា អនុប្រធានភូមិ គឺជាមេភូមិ ហើយគេមិនដែលអោយលុយគាត់ទេ ក្រៅពីការបង់បន្តិចបន្តួចថ្លៃក្រដាសស្នាម ។ ជនមាតុភូមិនិវត្តន៍ជាច្រើនបានចាត់ទុកអ្នកធ្វើការម្នាក់ខាងអភិវឌ្ឍន៍ស្ត្រី និងសមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិជាអ្នកដឹកនាំនៅក្នុងភូមិដែរ ។

*ខ្ញុំមិនដឹងថា អ្នកណាជាមេភូមិទេ គាត់មិនដែលមកទីនេះទេ (បុរសជនមាតុភូមិនិវត្តន៍ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*ចំពោះការលក់ដី និងទិញដីត្រូវទៅជួបគង់ ដោយមិនបាច់អោយអីទេ (ស្ត្រីជនមាតុភូមិនិវត្តន៍ ខែមករា ឆ្នាំ២០០០) ។*

មេឃុំយល់ព្រមនឹងសំណើរបស់មេភូមិ និងទទួលស្គាល់ប្រជាប្រិយភាពរបស់គាត់ទាំងស្រុង ប៉ុន្តែគាត់មិនមានភាពស្និទ្ធស្នាលជាមួយ ឬមានការពេញចិត្តនឹងអនុប្រធានភូមិទេ ។ គាត់ចាត់ទុកអ្នកដែលធ្វើការខាងអភិវឌ្ឍន៍ស្ត្រី និងសមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិជា "អ្នកដឹកនាំទីពីរ" នៅភូមិគោកដូង ។

*នៅភូមិគោកដូងមានមេភូមិល្អ ។ អ្នកភូមិស្រលាញ់គាត់ ។ គាត់គឺជាអ្នកដឹកនាំដ៏ល្អ ។ គាត់មិនសូវចេះអក្សរមែន ប៉ុន្តែអនុប្រធានរបស់គាត់ជួយធ្វើបញ្ជី ។ តាមពិតទៅប្រជាជនគួរតែទៅរកមេភូមិ ប៉ុន្តែអ្នកខ្លះចូលចិត្តទៅរកអនុប្រធានទៅវិញ ។ នៅពេលគេចង់ប្តឹង គេទៅរកអនុប្រធាន ។ គាត់ចេះអក្សរ ហើយគាត់ដឹងការងារមួយចំនួនជាងមេភូមិ ។ ប៉ុន្តែមេភូមិយុត្តិធម៌ និងត្រឹមត្រូវជាង (មេឃុំ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និង កុម្ភៈ ឆ្នាំ២០០០) ។*

## ប្រវត្តិនៃការដឹកនាំនៅថ្នាក់ភូមិពេលបច្ចុប្បន្ន

*ភូមិជ្រែង: ការផ្លាស់ប្តូរ ភាពមិនច្បាស់លាស់ និងភាពស្ទាក់ស្ទើរ*

- មានការផ្លាស់ប្តូរសមាសភាពថ្នាក់ដឹកនាំភូមិជាច្រើនដងក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ ។ គ្មាននរណាម្នាក់ដឹងច្បាស់ទេថា ការផ្លាស់ប្តូរនេះកើតឡើងយ៉ាងម៉េច និងនៅពេលណា ហើយនៅមិនដឹងច្បាស់ថាអ្នកណាមានមុខងារធ្វើអ្វីខ្លះនោះឡើយ ។
- មានភាពស្ទាក់ស្ទើរដោយមិនចង់បានតំណែងអាជ្ញាធរ ។
- អ្នកភូមិគោរពព្រះសង្ឃ អាចារ្យ ចាស់ទុំ និងអោយតំលៃពួកគាត់ជាអ្នកដឹកនាំក្រៅផ្លូវការ ។

នៅភូមិជ្រែង មានការផ្លាស់ប្តូរសមាសភាព និងតួនាទីថ្នាក់ដឹកនាំភូមិជាច្រើនដងក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ។ ប្រការនេះ ធ្វើអោយកាន់តែមានភាពមិនច្បាស់លាស់ (រវាងអ្នកភូមិ និងអ្នកដឹកនាំ) ថាតើអ្នកណាមានតួនាទី និងភារកិច្ចអ្វីខ្លះ ។ គេគ្មានមន្ទិលសង្ស័យអ្វីចំពោះមេភូមិថ្មីទេ ព្រោះគាត់មានមុខតំណែង នេះតាំងពីដើមឬពាក់កណ្តាលឆ្នាំ១៩៨០មកម្លេះ ។ មេភូមិចាស់ បានចាប់ផ្តើមធ្វើជាមេភូមិក្នុងចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៨១ ។ ប៉ុន្តែអ្នកទាំងពីរព្រមទាំងអ្នកដទៃទៀត បានបញ្ជាក់ពីកាលបរិច្ឆេទ និងមូលហេតុពីការផ្លាស់ប្តូរនេះផ្សេងៗគ្នា ហើយក៏បាននិយាយពីអ្នកឯទៀតដែលមានតួនាទីថ្នាក់ដឹកនាំនៅពេលខុសៗគ្នាដែរ ។

បច្ចុប្បន្ននេះ ភាពមិនច្បាស់លាស់ និងការព្រួយបារម្ភជាចម្បង គឺតួនាទីរបស់ជីវពលដែលអាចធ្វើជាជំនួយការ និងអនុប្រធានភូមិ ។ ដោយសារមេឃុំនិងមេភូមិនិយាយខុសៗគ្នាយ៉ាងមុតមាំ និងដដែលៗអំពីការតែងតាំងនេះ វានៅមិនទាន់ដឹងច្បាស់ថា គាត់ទទួលមុខងារនេះដោយរបៀបណានោះទេ ។ ជាងនេះទៀត អតីតអនុប្រធានភូមិ ហាក់ដូចជាបន្តចាត់ទុកខ្លួនឯង (និងដោយសារអ្នកភូមិជាច្រើនចាត់ទុកគាត់) ជាអនុប្រធានភូមិ ហើយគាត់មានការអៀនខ្មាសយ៉ាងខ្លាំងរហូតដល់គាត់ប្តូរចិត្តនៅពេលសម្ភាសន៍ថា គាត់មិនមែនជាអនុប្រធានភូមិទៀតទេ ។

*ហ៊ន ជាជីវពលឃុំប្រចាំនៅភូមិនេះ ។ ប្រធានយោធាស្រុកអោយកាំភ្លើងទៅគាត់ទុកការពារភូមិ ប៉ុន្តែគាត់មិនមែនជាយោធាស្រុកទេ ។ គាត់គ្រាន់តែកាន់កាំភ្លើងនេះក្នុងនាមជាជីវពលឃុំប៉ុណ្ណោះ ។ នៅពេលដែលគាត់មិនបានជាប់ឆ្នោតជា គ.អ.ភ គាត់មានការខកចិត្ត ហើយមិនចង់ធ្វើអ្វីទាំងអស់ ។ អញ្ចឹងខ្ញុំអោយគាត់ធ្វើជាជំនួយការរបស់មេភូមិ ។ មេភូមិស្លូតពេក ហើយនៅដាច់ឆ្ងាយពីផ្ទៃកណ្តាលភូមិ ។ ហ៊នធ្លាប់ប្រឡូកក្នុងសមរភូមិ ។ អញ្ចឹងហើយបានជាខ្ញុំអោយគាត់ធ្វើជាជំនួយការរបស់មេភូមិ ។ ខ្ញុំតែងតាំងអោយគាត់ធ្វើជាជំនួយការនៅថ្ងៃបោះឆ្នោតកាលពីឆ្នាំទៅ[៤] (មេឃុំ ខែមិនា ឆ្នាំ២០០០) ។*

*នៅចុងឆ្នាំ១៩៩៦ គេបានកំណត់ថា ភូមិជ្រែងគឺជាតំបន់ឆ្ងាយដាច់ស្រយាល ដូច្នេះមេឃុំអោយខ្ញុំរើសប្រធានជីវពលនៅក្នុងភូមិនេះ ។ ដល់តែខ្ញុំរើសបានមនុស្សល្អ មេឃុំឯកភាព ។ ប៉ុន្តែខ្ញុំអាចរើសអ្នកផ្សេងទៀតក៏បាន ហើយគាត់ក៏យល់ព្រមដែរ (មេភូមិ ខែមិនា ឆ្នាំ២០០០) ។*

[៤] ការបោះឆ្នោត គ.អ.ភ លើកទី២ ដែលមេឃុំនិយាយថា ត្រូវបានធ្វើឡើងនៅខែធ្នូ ឆ្នាំ១៩៩៨ ។

*ទេ ទេ ទេ ខ្ញុំសុំទោស ឥឡូវនេះខ្ញុំមិនមែនជាអនុប្រធានភូមិទេ ។ ខ្ញុំភ្លេច! ខ្ញុំឈប់ពីតំណែង ដោយខ្លួនឯង ព្រោះដឹងថាគ្មានអ្នកណាខ្វល់ពីខ្ញុំ ។ ហ៊ន ជាអនុប្រធានភូមិ ធ្វើការតាំងពីឆ្នាំ១៩៩៤ ។ មេភូមិប្រជុំជាមួយមនុស្ស ២-៣នាក់ គាត់និយាយថា គាត់ត្រូវការអនុប្រធានម្នាក់ ហើយមនុស្សដែលគាត់ចង់បាននោះគឺហ៊ន ខ្ញុំនៅទីនោះ ក៏បានឯកភាពដែរ ខ្ញុំដឹងថា ពួកគេអន់ចិត្តនឹងខ្ញុំ (បុរសម្នាក់ដែលជាសមាជិក គ.អ.ភ ខែតុលា ឆ្នាំ១៩៩៨) ។*

ក្នុងអំឡុងឆ្នាំ១៩៨០ មានមេក្រុមចំនួន៨នាក់ដែលជាបុរស ត្រូវបានចាត់តាំងនៅក្នុងភូមិ ។ ភារកិច្ចសំខាន់របស់ពួកគេ គឺជួយក្នុងការបែងចែកដីស្រែ ការជ្រើសរើសទ័ពនិងពលករទៅកាប់ព្រៃ និងអង្គៀសលុយពីអ្នកភូមិ ។ នៅពេលភារកិច្ចទាំងនេះចប់អស់ទៅ មានតែការផ្សព្វផ្សាយពត៌មាន និងហៅអ្នកភូមិមកប្រជុំតែប៉ុណ្ណោះ ។ ឥឡូវនេះ គេមិនត្រូវការមេក្រុមអោយដើរប្រាប់ប្រជាជនទៀតទេ ព្រោះការធ្វើសេចក្តីប្រកាស គឺត្រូវបានធ្វើឡើងតាមមេក្រូ។ មេភូមិនិងមេក្រុមជាច្រើនបានអោយដឹងថារចនាសម្ព័ន្ធមេក្រុមត្រូវលុបចោលជាផ្លូវការនៅឆ្នាំ១៩៩៣ ហើយអ្នកភូមិមួយចំនួននិយាយថារចនាសម្ព័ន្ធមេក្រុមថ្មី ត្រូវបានបង្កើតឡើងម្តងទៀតនៅឆ្នាំ១៩៩៧ ដោយមានអ្នកចាស់ខ្លះ និងអ្នកថ្មីខ្លះកាន់តួនាទី ។ ដូច្នេះ ឥឡូវនេះគេនៅមិនទាន់ច្បាស់លាស់ថា នៅមានមេក្រុមក្នុងភូមិទៀតឬទេ បើមាន តើមានអ្នកណាខ្លះ ហើយពួកគេមានការងារអ្វីខ្លះ ។

*មេក្រុមត្រូវហៅប្រជាជនទៅប្រជុំ និងរើសទ័ព ។ នៅពេលនោះគ្មានអ្នកណាហ៊ានតវ៉ានឹងផែនការថ្នាក់លើទេ ។ មេក្រុមសកម្ម ព្រោះកាលនោះជាជំនាន់កុម្មុយនីស្ត ។ បញ្ជាមកពីថ្នាក់លើ ថ្នាក់ក្រោមត្រូវតែធ្វើតាម ។ ប៉ុន្តែឥឡូវនេះ វាជាលទ្ធិប្រជាធិបតេយ្យ ដូច្នេះពួកគេមិនសូវសកម្មទេ ។ ក្រោយពី UNTAC ពួកគេមិនចូលចិត្តការងារនេះទេ ពួកគេមិនអាចប្រមូលអ្នកភូមិ ដូច្នេះគេឈប់ដោយខ្លួនឯង ។ ក្នុងរបបកុម្មុយនីស្តការងារពិបាក ។ ឥឡូវមេភូមិអាចធ្វើម្នាក់ឯងបាន ព្រោះវាមិនសូវពិបាក (ក្រុមផ្តល់យោបល់ទាំងស្ត្រី និងបុរស ខែតុលា ឆ្នាំ១៩៩៨) ។*

*នៅពេល ហ៊ន បានដំណើងពីថ្នាក់លើ គាត់ប្រកាសមេក្រូប្រាប់អ្នកភូមិ ។ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាគាត់ធ្វើអញ្ចឹង ។ នៅពេលគាត់ធ្វើបែបនេះ មេក្រុមអត់មានការងារធ្វើទេ ។ អញ្ចឹងចាំបាច់អោយមានមេក្រុមធ្វើអី? នៅក្នុងភូមិនេះ មានតែមនុស្សពីរនាក់ធ្វើការងារគ្រប់បែបយ៉ាង គឺហ៊ន និង ហ៊ន់ (បុរសម្នាក់ ខែមិនា ឆ្នាំ ២០០១ ។*

ក្នុងអំឡុងឆ្នាំ១៩៨០ អ្នកភូមិមួយចំនួនតូច (គឺម្តងជ្រើសរើសយកក្នុងនោះ២នាក់) ស្រី៣នាក់ និងបុរស ១នាក់ ត្រូវបានតែងតាំងជាតំណាងសមាគមនារី និងយុវជន[៥] ។ គេរាយការណ៍អោយឃុំ អង្គៀសប្រាក់ និងសំភារៈសាងសង់ពីអ្នកភូមិព្រមទាំងដឹកនាំប្រជាជនស្តារប្រឡាយពីរខ្សែ ។ ចាប់តាំងពីមានការបោះឆ្នោតដែលរៀបចំឡើងដោយ UNTAC គេពុំឃើញមានតំណាងសមាគមនារី ឬយុវជនទៀតនេះទេ ។

[៥] នៅភូមិថ្មី ការតែងតាំងទាំងនេះហាក់ដូចជាមានសមាគមពីរផ្សេងគ្នា ប៉ុន្តែនៅភូមិគោកដូង សមាគមទាំងនេះ ត្រូវបានរួមបញ្ចូលគ្នា ។

ដូច្នេះ មុខតំណែងនៅក្នុងភូមិ និងភារកិច្ច ត្រូវបានផ្លាស់ប្តូរ ។ ប៉ុន្តែការកកើតឡើងវិញពីរឿងមុខតំណែង ទាក់ទិនទៅនឹងការអនុវត្ត ការសំរេចចិត្តដែលមិនមានលក្ខណៈប្រជាធិបតេយ្យ ពីរដ្ឋអំណាចថ្នាក់លើ ហើយអ្នកដែលធ្លាប់មានតួនាទីខាងអាជ្ញាធរថ្នាក់ភូមិនៅឆ្នាំ១៩៨០ និង ១៩៩០ និយាយថា ពួកគេ ចង់ឈប់ពីតួនាទីនេះ ។

*កាលនោះធ្វើជាមេភូមិពិបាកណាស់ ធ្វើការចែកដីស្រែ ជ្រើសរើសទ័ព ហើយយើងត្រូវអង្គាសប្រាក់សំរាប់អោយទ័ព ។ ការទទួលខុសត្រូវដ៏សំខាន់ គឺត្រូវរើសយុវជនពេញកំលាំងអោយធ្វើជាទ័ព និងទៅ "ក៥"[៦] ទៅកាប់ព្រៃ ដើម្បីកុំអោយមានខ្មែរក្រហម ។ ស្រុក និងឃុំ ឧទាហរណ៍ តំរូវចុះយកឈ្មោះ ៥នាក់ទៅក៥ យើងអោយឈ្មោះទៅគេ ប៉ុន្តែគ្មានអ្នកណាទៅទេ ។ ហេតុនេះ ឃុំ ឬស្រុកមកយកឈ្មោះអ្នកទាំងប្រាំនោះ ប៉ុន្តែពួកគេគេចខ្លួនបាត់ ។ ខ្ញុំក៏ទៅធ្វើជាពលករ ។ នៅពេលដែលខ្ញុំត្រឡប់មកវិញ ពួកគេនិយាយថា ខ្ញុំចាស់ហើយ មិនអាចធ្វើមេភូមិបានទៀតទេ ។ ខ្ញុំសប្បាយចិត្តក្នុងការលាឈប់ ។ ហ៊ាន់ [មេភូមិ] ឥឡូវនេះស្រួលហើយ នៅពេលគាត់ធ្វើមេភូមិ អ្វីៗធ្វើរួចអស់ហើយ អត់មានការបែងចែកដីស្រែទៀតទេ ។ សព្វថ្ងៃនេះ ធ្វើមេភូមិ មិនពិបាកអី ។ គាត់ទៅប្រជុំ គាត់បានលុយ ហើយទៅរៀនក៏បានលុយ (បុរសម្នាក់ ខែមិថុនា ឆ្នាំ១៩៩៨) ។*

*ខ្ញុំធ្លាប់មានមុខតំណែងនៅក្នុងភូមិ[៧] ។ ខ្ញុំទទួលខុសត្រូវខាងជ្រើសរើសទ័ព និងពលករទៅកាប់ព្រៃ ។ ខ្ញុំទៅប្រជុំនៅឃុំ ហើយពេលត្រឡប់មកវិញ ប្រាប់អ្នកភូមិអោយរត់មួយរយៈ ។ ឃុំរអ៊ូថា យើងមិនអាចរើសទ័ពបាន ។ ខ្ញុំចំណាយកំលាំង ប៉ុន្តែខ្ញុំមិនបានអីទាំងអស់ ។ ដូច្នេះខ្ញុំឈប់ហើយ ខ្ញុំចំណាយពេលធ្វើស្រែរបស់ខ្ញុំវិញ (អាចារ្យ ខែមិថុនា ឆ្នាំ១៩៩៩និង ខែមិនា ឆ្នាំ២០០០) ។*

*ខ្ញុំធ្វើជាតំណាងសមាគមនារីពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៥ ។ ខ្ញុំត្រូវទៅប្រជុំនៅឃុំរៀងរាល់ថ្ងៃ ប្រជុំគ្រប់កិច្ចការទាំងអស់ ។ ដើរទៅទីនោះពិបាកខ្លាំងណាស់ ហើយខ្ញុំត្រូវដើរកាត់ទឹកត្រឹម១ទ្រូង ។ ថ្ងៃមួយខ្ញុំស្មានថា មានក្រពើនៅក្នុងទឹកនោះ ខ្ញុំខ្លាចខ្លាំងណាស់ ។ គេអោយខ្ញុំប្រមូលស្លឹកត្នោត និងអង្គាសលុយពីអ្នកភូមិ ពិបាកណាស់ ។ ខ្ញុំមិនដឹងថា គេយកទៅធ្វើអីទេ ជួនកាល ខ្ញុំចេញលុយខ្លួនឯង ។ ខ្ញុំខ្លាចគេហៅខ្ញុំ រឺកូនប្រុសខ្ញុំទៅពលករ រឺធ្វើទ័ព ។ អញ្ចឹង ខ្ញុំមិនហ៊ានរអ៊ូទេ ។ ប៉ុន្តែបើគេអោយខ្ញុំធ្វើជាតំណាងទៀត ខ្ញុំមិនចង់ធ្វើទៀតទេ ។ អ្នកផ្សេងធ្វើជំនួសខ្ញុំ ប៉ុន្តែគាត់ចេញពីភូមិហើយ ។ អញ្ចឹងអត់មានតំណាងសមាគមនារីទៀតទេ ។ ឥឡូវនេះ មានតែមេភូមិ អនុប្រធានភូមិ និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (ស្ត្រីម្នាក់ ខែតុលា ឆ្នាំ១៩៩៨) ។*

មេភូមិនេះ លើកដំបូង ក៏និយាយយ៉ាងដាច់ខាតដែរថា គាត់ចង់ឈប់ មិនមែនដោយសារអ្នកភូមិដេរគាត់ទេ ប៉ុន្តែ ដោយសារគាត់មានការងារច្រើនពេក ។ ទោះជាយ៉ាងណាក្តី គាត់និយាយថាអ្នកភូមិមិនអោយគាត់ឈប់ទេ ។

សូម្បីតែជីវពលដែលខ្លាំង និងតឹងតែងក៏និយាយដែរថា គាត់មិនចង់ទទួលការងារនេះទេ ប៉ុន្តែគាត់ក៏បាននិយាយផងដែរថា គាត់ខិតខំប្រឹងប្រែងធ្វើការ និងបូជាកំលាំងកាយចិត្ត ដើម្បីដោះស្រាយបញ្ហាច្បាប់ និងបទបញ្ហា

[៦] ក ៥ គឺជាសមរភូមិមុខមួយនៅតាមព្រំដែនកម្ពុជា-ថៃ ។

[៧] បុរសម្នាក់នេះ ជាអនុប្រធានភូមិកាលពីដើមឆ្នាំ១៩៨០ ។

នៅក្នុងភូមិដែលគាត់គិតថា មេភូមិមិនធ្វើអោយបានជោគជ័យ ។ ឥឡូវនេះគាត់មានការអន់ចិត្ត ដោយសារអ្នកភូមិមិនបានសសើរគាត់ ។

*ដំបូងនៅពេលដែលខ្ញុំធ្វើជាអនុប្រធានភូមិ ខ្ញុំមិនចង់ធ្វើទេ ។ ខ្ញុំមិនជឿលើសមត្ថភាពខ្ញុំ ។ ប៉ុន្តែថ្នាក់លើបានចាត់តាំងខ្ញុំរួចហើយ ដូច្នេះខ្ញុំចង់សាកល្បង ។ តួនាទីរបស់ខ្ញុំឥឡូវនេះត្រូវធ្វើអោយភូមិជ្រែងមានសន្តិសុខល្អ ។ ប៉ុន្តែខ្ញុំមិនចង់ធ្វើទៀតទេ បើសិនខ្ញុំធ្វើត្រូវវាមិនអីទេ តែបើខ្ញុំធ្វើអ្វីដែលប្រជាជនមិនពេញចិត្ត គេជេរខ្ញុំ ។ ប៉ុន្តែខ្ញុំមានផែនការសំរាប់ឆ្នាំ២០០០ ខ្ញុំចង់លុបបំបាត់អំពើលួចប្លន់ អំពើហឹង្សា និងអំពើអសកម្មផ្សេងៗ ។ បន្ទាប់ពីនោះ ខ្ញុំចង់រកការងារផ្សេងធ្វើវិញ ប្រហែលធ្វើជាប៉ូលីស ឬយោធា ឬធ្វើអ្វីនៅឃុំ ។ បើសិនជាគ្មានបញ្ហានៅក្នុងឆ្នាំ២០០០ ទេ មានគេនិយាយថា មិនបាច់ត្រូវការខ្ញុំទៀតទេ (ជីវពល ខែតុលា ឆ្នាំ១៩៩៨) ។*

ក្រៅពីមន្ត្រីនានា នៅក្នុងភូមិជ្រែង ក៏មានឆ្មបម្នាក់ដែលអ្នកភូមិចូលចិត្តមកពិគ្រោះយោបល់ជាមួយ ។ ថ្មីៗនេះ នាយកសាលាបានជ្រើសរើសគាត់ធ្វើប្រធានសមាគមមាតាបិតាសិស្ស ហើយ *អាចារ្យ* និងព្រះសង្ឃ បានជ្រើសរើសគាត់អោយធ្វើជាប្រធានសមាគមចានឆ្នាំង[៨] ។

ព្រះសង្ឃ *អាចារ្យ* និងចាស់ទុំមានតួនាទីដឹកនាំយ៉ាងសំខាន់នៅក្នុងភូមិជ្រែង ព្រោះអ្នកភូមិគោរព និងអោយតំលៃយ៉ាងជ្រាលជ្រៅ ។ ព្រះសង្ឃដែលគង់នៅវត្តក្បែរភូមិ និមន្តចូលភូមិមួយអាទិត្យម្តង ហើយអ្នកភូមិភាគច្រើនបានដាក់បាត្រលោកជាម្ហូប ឬជាលុយ ។ *អាចារ្យ* ៤នាក់ (សុទ្ធតែចាស់ៗ) ដែលរស់នៅភូមិនេះ ហើយអ្នកខ្លះដែលជាសមាជិកគណៈកម្មាការវត្ត គឺជាសម្ព័ន្ធភាពរវាងភូមិ និងវត្ត ។ ពួកគាត់ប្រមូលបច្ច័យពីអ្នកភូមិ ដើម្បីធ្វើបុណ្យ ហើយពួកគាត់ជំរាបដំណឹងទៅព្រះសង្ឃ ។ តួនាទីជាក់លាក់ និងសំខាន់របស់ពួកគាត់អាចថយចុះបន្តិច ព្រោះក្មេងៗមិនសូវដឹងច្បាស់ ដូចជាមនុស្សចាស់ៗថា អ្នកណាខ្លះជាអាចារ្យ ហើយពួកគាត់ធ្វើអ្វីខ្លះទេ ។ ឥឡូវនេះអាចារ្យជាច្រើន មិនសូវសកម្មទេ ព្រោះពួកគាត់កាន់តែចាស់ មានការនឿយហត់ និងមានជំងឺ ។ ចាស់ទុំផ្សេងទៀតក៏ត្រូវបានគេស្គាល់ និងគោរពយ៉ាងខ្លាំងផងដែរ។ ចាស់ៗប្រហែល១៥នាក់ ទៅវត្តស្ទើររាល់ថ្ងៃសីល ។ ព្រះសង្ឃ *អាចារ្យ* និងចាស់ទុំ សុទ្ធតែមានប្រយោជន៍ខុសៗគ្នា ហើយអ្នកភូមិសង្ឃឹមលើពួកគាត់ ដើម្បីដឹកនាំអ្នកភូមិធ្វើបុណ្យផ្សេងៗ (ប៉ុន្តែបើនិយាយទៅដល់ការដឹកនាំធ្វើបុណ្យទាននេះកំពុងតែថយចុះ) ផ្តើមគំនិត និងហៅប្រជាជនអោយមកធ្វើការងាររួម ។

*បន្ទាប់ពីព្រះសង្ឃ អាចារ្យជាមនុស្សដែលគេគោរព ។ ពួកគាត់គិតតែពីរឿងវត្តប៉ុណ្ណោះ ។ បើពួកគាត់ដើរតាមផ្លូវ ហើយឃើញផ្លូវខូច ពួកគាត់ជំរាបព្រះសង្ឃ ។ រួចទៅព្រះសង្ឃយកមេក្រូ ហើយអាចារ្យប្រកូកប្រកាសប្រជាជនអោយចូលរួមជួសជុលផ្លូវ (ស្ត្រីម្នាក់ ខែមិថុនា ឆ្នាំ១៩៩៩) ។*

[៨] គោលបំណងបង្កើតសមាគមចានឆ្នាំង គឺថាប្រជាជនអាចប្រើចានឆ្នាំង និងប្រដាប់ប្រដាផ្សេងៗទៀតនៅពេលមានពិធីផ្សេងៗដែលមានមនុស្សច្រើនត្រូវបំរើ ។ អ្នកភូមិជាច្រើននាក់បានរួមវិភាគទានជាគ្រឿងប្រើប្រាស់ឬលុយគាត់ ហើយអ្នកភូមិទាំងអស់អាចប្រើប្រាស់របស់ទាំងនោះដោយមិនគិតកំរៃ ។

*ពេលអ្នកណាម្នាក់ហៀបនឹងស្លាប់ អាចារ្យទាំងបីត្រូវទៅទីនោះ ដើម្បីសូត្រធម៌រហូតដល់អ្នកនោះស្លាប់ ។ ជួនកាលយូរ អ្នកខ្លះរហូតដល់ ១៥ថ្ងៃទើបស្លាប់! អាចារ្យត្រូវនៅចាំរហូត ពួកគាត់គ្មានពេលធ្វើការងារទេ ដូច្នេះគ្មានអ្នកណាចង់ធ្វើអាចារ្យទេ(អាចារ្យ មិថុនា ១៩៩៩) ។*

*ភូមិគោកដូង: ស្ថិរភាព ប្រត្យក្សភាព និងភាពស្ទាក់ស្ទើរ*

- ការដឹកនាំនៅក្នុងភូមិមានស្ថិរភាព និងច្បាស់លាស់ជាងនៅភូមិជ្រៃង ។
- ដូចនៅភូមិជ្រៃងដែរ មានការស្ទាក់ស្ទើរខ្លាំងក្នុងការទទួលមុខតំណែងអាជ្ញាធរ ។
- ព្រះសង្ឃ អាចារ្យ និងចាស់ទុំ មិនបានទទួលការគោរព និងចូលរួមក្នុងការដឹកនាំ ដូចនៅភូមិជ្រៃងទេ ។

ភូមិគោកដូង ការដឹកនាំនៅក្នុងភូមិមានស្ថិរភាពច្រើនជាងនៅភូមិជ្រៃង ហើយអ្នកភូមិដឹងច្បាស់ថា អ្នកណាមានមុខតំណែងអ្វី និងមានភារកិច្ចអ្វីខ្លះ ។

ភូមិគោកដូង ជាភូមិតែមួយគត់នៅក្នុងឃុំដែលមានមេភូមិ និងអនុប្រធានភូមិដដែលតាំងពីឆ្នាំ១៩៧៩ ។ លុះដល់២ឆ្នាំក្រោយមក ក៏មានសមាជិកទីបីម្នាក់ទៀត ។ ពួកគេត្រូវបានបោះឆ្នោតជ្រើសរើសក្នុងចំណោមបេក្ខជនដែលត្រូវបានតែងតាំង ហើយមេភូមិ និងអនុប្រធានភូមិនិយាយថា ពួកគាត់ឈ្នះ ។ ការបរិយាយនេះអាចបង្ហាញពីបំណងរបស់អ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងពីរថា ម្នាក់ៗហាក់ដូចជាខ្លាំងជាងបេក្ខជនទាំងនោះយ៉ាងប្រាកដ ។

*នៅពេលវៀតណាមចូលមក គេអោយអ្នកភូមិបោះឆ្នោតជ្រើសរើសមេភូមិ ។ ខ្ញុំបានសំលេងឆ្នោតច្រើនជាងគេ ប៉ុន្តែខ្ញុំមិនចង់ធ្វើទេ ។ ខ្ញុំមិនចង់បានមុខតំណែងនេះទេ ។ ខ្ញុំប្រគល់អោយទៅអ្នកហៀវ ។ គាត់ជាប់លេខ២ ហើយគាត់ចាស់ជាងខ្ញុំ ។ វាមិនសមទេដែលថាមេភូមិក្មេងជាងអនុប្រធាន (អនុប្រធានភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ក្នុងអំឡុងឆ្នាំ១៩៨០ ពួកគេមានការមមាញឹកក្នុងការបែងចែកដីស្រែ ដែលអ្នកភូមិភាគច្រើននិយាយយ៉ាងមុតមាំថា ត្រឹមត្រូវ និងយុត្តិធម៌ ហើយការជ្រើសរើសទ័ព និងពលករជាភារកិច្ចសំខាន់របស់មេក្រុម និងតំណាងសមាគមនារី និងយុវជន ។ សព្វថ្ងៃនេះ ពួកគេមានការងារផ្សេងដែលស្រួលជាងមុន ។

*ក្នុងអំឡុងឆ្នាំ១៩៨០ ភារកិច្ចរបស់មេភូមិ គឺដឹកនាំអ្នកភូមិអោយធ្វើស្រែ និងការពារភូមិ ។ ខ្ញុំប្រាប់មេក្រុមអោយប្រាប់កូនក្រុមរបស់គេអោយការពារគ្រួសាររបស់គេ ។ ឥឡូវនេះ ការទទួលខុសត្រូវរបស់ខ្ញុំជាមេភូមិ គឺគ្រប់គ្រង និងដឹកនាំអ្នកភូមិទាំងអស់ខាងរដ្ឋបាល ដូចជាហៅមកប្រជុំ ។ មេភូមិដឹងពីការលំបាករបស់អ្នកភូមិ និងរាយការណ៍អោយឃុំ ។ ខ្ញុំរាយការណ៍ពីការបង្កើនផលអំពីស្រូវដែលខូចខាត ។ ឧទាហរណ៍ ខ្ញុំក៏អាចទទួលផែនការពីឃុំដើម្បីរកគ្រួសារក្រដែលអត់មានអីហូប ។ អញ្ចឹងខ្ញុំកត់ឈ្មោះ ហើយយកទៅឃុំ និងគ្រួសារទាំងនោះបានអំណោយ(មេភូមិ ខែមករា ឆ្នាំ២០០០) ។*

នៅភូមិគោកដូង ប្រព័ន្ធមេក្រុមមើលទៅហាក់ដូចជានៅតែរៀបចំនិងដំណើរការបានល្អ ហើយអ្នកភូមិស្គាល់ច្បាស់ជាងនៅភូមិជ្រៃង ។ ក្នុងអំឡុងឆ្នាំ១៩៨០ មេក្រុមមានចំនួន៨នាក់ ហើយនៅទីនេះក៏អញ្ចឹងដែរ ភារកិច្ច

សំខាន់របស់ពួកគេគឺជ្រើសរើសទ័ព និងពលករ ។ សព្វថ្ងៃនេះ មេក្រុមមិនសូវមានការងារធ្វើទេ ប៉ុន្តែអ្នកភូមិនៅតែស្គាល់ និងទៅពិភាក្សាជាមួយមេក្រុមទាំងនោះជាងនៅភូមិជ្រៃង ។ លុះដល់ឆ្នាំ១៩៩៣ ទើបមានតំណាងសមាគម[៥] នារី និងយុវជន២រូបទៀត ។

*ក្នុងអំឡុងឆ្នាំ១៩៨០ មេភូមិ និងមេក្រុម មានការងារច្រើនមែនទែន ។ ពួកគេទទួលការណែនាំពីថ្នាក់ឃុំដូចជាជ្រើសរើសទ័ព និងពលករ អង្កេវស្រប្រាក់អោយទ័ព និងពលករ ។ ឥឡូវនេះ មិនសូវមានការងារច្រើនទេ មេភូមិអាចធ្វើខ្នាក់ឯងបាន ។ នៅពេលខ្ញុំខឹង ខ្ញុំអោយមេភូមិដើរ អង្កេវស្រប្រាក់ដោយខ្លួនឯង ។ មេភូមិមានប្រាក់ខែ ៣០.០០០រៀលក្នុងមួយខែ ។ ខ្ញុំអត់មានប្រាក់ខែទេ ប៉ុន្តែអ្នកភូមិស្ដីអោយខ្ញុំ ហើយស្អប់ខ្ញុំ(មេក្រុម ខែមករា ឆ្នាំ២០០០) ។*

*ក្នុងនាមជាតំណាងយុវជន ភារកិច្ចរបស់ខ្ញុំ គឺអូសទាញយុវជនអោយស្ម័គ្រចិត្តចូលទ័ព ។ ខ្ញុំធ្វើស្ថិតិអោយឃុំអំពីអ្នកនៅលីវប៉ុន្មាននាក់ដែលមានអាយុក្រោម ២០ឆ្នាំ ក្រោម ៣០ឆ្នាំ ។ នៅពេលដែលឃុំដឹងនោះ គេស្រួលជ្រើសរើសទ័ព ។ ខ្ញុំក៏មានភារកិច្ចបញ្ចុះបញ្ចូលអ្នកដែលមិនបានចូលទ័ព អោយជួយធ្វើស្រែឪពុកម្ដាយ និងប្រពន្ធរបស់អ្នកចូលធ្វើទ័ពដែរ ។ ប៉ុន្តែពួកគេមិនសូវជាជួយណាស់ណាទេ ។ គេគ្រាន់តែជួយភ្ជួរដីបន្តិចបន្តួចប៉ុណ្ណោះ ។ ក្រៅពីនេះ នៅពេលដែលមានផែនការពីថ្នាក់លើអោយជីកប្រឡាយខ្ញុំនាំយុវជន យុវនារីទៅលើកតាមបញ្ជាពីថ្នាក់លើ ។ បើសិនជាត្រូវការជួសជុលផ្លូវ ខ្ញុំនឹងដឹកនាំក្មេងៗទៅធ្វើ ហើយដាក់អំពូលម៉ែត្រ ហើយធ្វើការនៅពេលយប់ ប្រហែលជា ៤ ឬ ៥យប់ ។ ក្មេងៗសប្បាយនឹងធ្វើការងារនេះ ។ អ្នកដែលមកលេងពីភូមិផ្សេង ក៏ជួយធ្វើការងារនេះដែរ (ប្រធាន គ.អ.ភ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ការជ្រើសរើសទ័ពហាក់ដូចជាមានលក្ខណៈធំដុំ ប៉ុន្តែផ្នែកខ្លះក៏ស្រួលជាងនៅភូមិជ្រៃងដែរ ។ អ្នកភូមិអន់ចិត្តយ៉ាងខ្លាំង ហើយនៅតែមិនសប្បាយចិត្តព្រោះគ្រួសារយោធា និងពលករ មិនបានទទួលការជួយជ្រោមជ្រែងតាមពាក្យសន្យា ។ ដូច្នេះអ្នកដែលអាចរំលទ្ធភាពត្រូវតែសូកបាន់ ដើម្បីគេចពីការចាប់ទាហាន ។

*គោកដូងគឺជាភូមិគំរូ ពីព្រោះប្រជាជនល្ងង់ ។ នៅក្នុងភូមិដែលប្រជាជនមានការចេះដឹង ពិបាកជ្រើសរើសទាហាន ។ ឥឡូវលែងមានការចាប់ទាហានទៀតហើយ ព្រោះប្រជាជនដឹងពីសិទ្ធិរបស់ពួកគេ ។ ឥឡូវនេះ ពិបាកបង្ខំមនុស្សអោយធ្វើការណាស់(ក្រុមផ្ដល់យោបល់ស្រី និងប្រុស ខែកុម្ភៈ ឆ្នាំ២០០០) ។*

*នៅពេលប្ដីអ្នកផ្សេងទៅ "ក៥" ប្ដីខ្ញុំធ្លាប់ចូលទ័ព ។ មេភូមិបានសន្យាជួយធ្វើស្រែអោយខ្ញុំ ប៉ុន្តែគាត់មិនបានជួយទេ ។ ក្រោយមក ប្ដីខ្ញុំចង់ឈប់ធ្វើទ័ព ហើយខ្ញុំត្រូវបង់លុយអោយទាហាននៅឃុំ ។ ខ្ញុំបង់ ៣០០.០០០រៀល ខ្ញុំលក់គោ និងស្រូវ ទើបអាចបង់អោយគ្រប់ ។ គេព្រមព្រៀងនៅសាលាឃុំដោយមានផ្ដិតមេដៃ និងបោះត្រាលើក្រដាសស្នាម ។ ប៉ុន្តែក្រោយមកគេនៅតែ មកចាប់ប្ដីខ្ញុំដដែល ។ គាត់ត្រូវគេសចខ្លួនរហូតដល់លែងចាប់ទាហាន(ស្ត្រីម្នាក់ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

---

[៥] នៅភូមិគោកដូងនេះ មានសមាគមដែលត្រូវបានរួមបញ្ចូលគ្នា ផ្ទុយពីភូមិជ្រៃង ដែលហាក់ដូចជាមានសមាគមមួយសំរាប់នារី និងសមាគមមួយសំរាប់យុវជន ។

ដូចនៅភូមិជ្រែងដែរ មេក្រុម និងតំណាងសមាគមនារី និងយុវជនភាគច្រើន ហាក់ដូចជាមិនចង់ធ្វើការងាររបស់ខ្លួនទេ ។ ការជ្រើសរើសទាហាន និងពលករ ហើយការអង្កៀសប្រាក់មិនធ្វើអោយពួកគេមានប្រជាប្រិយភាពទេ ហើយពួកគេឧស្សាហ៍ទៅពលករដើម្បីធ្វើជាតំរូល ។ ប៉ុន្តែពួកគេទាំងអស់គ្នាមានការយល់ដឹងយ៉ាងមុតមាំថា ពួកគេមិនអាចប្រកែកបាន ។

*ខ្ញុំមិនចង់ធ្វើជាមេក្រុមទេ ។ ប៉ុន្តែគេហៅខ្ញុំទៅប្រជុំនៅឃុំ ហើយមិនអាចប្រកែកបាន ។ ធ្វើជាមេក្រុម ខ្ញុំមិនកាចទេ ខ្ញុំចិត្តល្អ ។ ប៉ុន្តែអ្នកភូមិនៅតែជេរខ្ញុំទៀត ខ្ញុំខំប្រឹងរើសទាហាននិងពលករ ។ ខ្ញុំទៅតែខ្លួនឯង ប្រសិនបើអ្នកណាឈឺ ។ បន្ទាប់មក មេភូមិចង់អោយខ្ញុំធ្វើជាជីវពលឃុំដែរ ប៉ុន្តែខ្ញុំមិនចង់ធ្វើទេ ។ បងប្អូនខ្ញុំ ខឹងខ្ញុំខ្លាំងណាស់ ។ គេចង់អោយខ្ញុំធ្វើធំ ។ ប៉ុន្តែខ្ញុំមិនចង់ធ្វើ ព្រោះអាណិតប្រពន្ធ និងកូនរបស់ខ្ញុំ ហើយបើសិនជាខ្ញុំធ្វើធំ អ្នកភូមិនឹងស្អប់ខ្ញុំ ។ សព្វថ្ងៃនេះ មិនសូវមានការងារច្រើនសំរាប់មេក្រុមទេ ។ជួនកាលគេហៅខ្ញុំទៅរៀន ។មេឃុំប្រាប់មេភូមិ ហើយមេភូមិប្រាប់មេក្រុម "មានរៀនសូត្រនៅឃុំរយៈពេល ២-៣ម៉ោង ហើយឯងត្រូវតែទៅ" ប៉ុន្តែខ្ញុំមិនទៅ ។ ជួនកាលខាងស្រុកមកប្រជុំនៅភូមិ អញ្ចឹងទៅខ្ញុំត្រូវប្រាប់កូនក្រុមអោយមកចូលរួម និងកត់ឈ្មោះក្នុងបញ្ជី(មេក្រុម ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ទោះជាពួកគេមានភារកិច្ចស្រួលជាងមុនក៏ដោយ មេភូមិ និងអនុប្រធាននិយាយថា ពួកគេចង់ឈប់ ។

*គាត់ [មេភូមិ] ចង់ឈប់ ប៉ុន្តែអ្នកភូមិមិនអោយគាត់ឈប់ ។ គាត់គិតថា គាត់ចាស់ ហើយភ្នែកគាត់មើលមិនសូវច្បាស់ ប៉ុន្តែអ្នកភូមិគិតថា គាត់ល្អ(ស្ត្រីម្នាក់ ខែមករា ឆ្នាំ២០០០) ។*

*ខ្ញុំចង់ទៅនៅវត្ត! ខ្ញុំចង់គេចពីការងារនេះ ខ្ញុំមិនចង់ធ្វើទេ ។ ខ្ញុំធុញនឹងការងារនេះហើយ ។ នៅពេលមានការទាស់ទែងគ្នា ខ្ញុំជាអ្នកកាត់ក្តី គាត់អោយភាគីម្ខាងឈ្នះ ភាគីម្ខាងទៀតខឹងនឹងខ្ញុំ ។ ជួនកាលមានផែនការមកពីថ្នាក់លើ ខ្ញុំប្រកាសមេក្រុ អ្នកដែលមិនឯកភាពនូវអ្វីដែលខ្ញុំនិយាយ គេអន់ចិត្ត ។ ជួនកាល ខ្ញុំប្រាប់អោយអ្នកភូមិទំលាក់ខ្ញុំ បើសិនមិនឯកភាព សូមទំលាក់ខ្ញុំទៅ ។ ប៉ុន្តែគេមិនព្រមធ្វើអញ្ចឹងទេ(អនុប្រធានភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ក្នុងចំណោមជនមាតុភូមិនិវត្តន៍ មានប្រធានភូមិស្តីទី ឬអនុប្រធានភូមិជួយមេភូមិមួយរយៈ ។ ប៉ុន្តែគាត់បានចាកចេញពីភូមិ ។ នៅពេលមាតុភូមិនិវត្តន៍មកតាំងទីលំនៅ មានការបង្កើតក្រុមថ្មីចំនួន ៣ ឬ ៤ ហើយមេក្រុមទាំងនោះត្រូវបានតែងតាំង ។ ប៉ុន្តែមេភូមិចាំតែមេក្រុមទាំង៨នៅក្នុងភូមិចាស់ និងមិនស្គាល់ឈ្មោះមេក្រុមណាម្នាក់ក្នុងចំណោមជនមាតុភូមិនិវត្តន៍ទេ ហើយពួកគេហាក់ដូចជាលាឈប់ ឬបោះបង់មុខតំណែងនេះទៅហើយ ។

*ក្រោយមក [ក្រោយឆ្នាំ១៩៩៣] ខ្ញុំមិនបានគ្រប់គ្រងទីនោះអោយបានច្បាស់លាស់ទេ ព្រោះគេមានអ្នកដឹកនាំនៅទីនោះហើយ ។ គាត់រត់បាត់ពីរបីឆ្នាំហើយ ដូច្នេះខ្ញុំជាអ្នកដឹកនាំម្តងទៀតជាមួយអភិវឌ្ឍន៍ស្ត្រី ។ ក្រុមទាំងនោះហាក់ដូចជាបាត់មុខ ព្រោះអ្នកថ្មីចេញទៅរកស៊ី (មេភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងខែមករា ឆ្នាំ២០០០) ។*

*ប្ដីខ្ញុំធ្លាប់ធ្វើជាមេក្រុម ។ ប៉ុន្តែគាត់ឈប់ហើយ ព្រោះធ្វើជាមេក្រុមអត់មានប្រយោជន៍ទេ ។ គាត់គ្មានប្រាក់ខែ ប៉ុន្តែអ្នកភូមិជេរគាត់ ។ គេចោទគាត់ថាបានស្រូវពីថ្នាក់លើ ។ អញ្ចឹងគាត់ក៏ឈប់ទៅ ហើយគ្មានអ្នកណាស្ដីអោយគាត់ទេ (ជនមាតុភូមិទីវត្តន៍ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

នៅភូមិគោកដូង ព្រះសង្ឃ អាចារ្យ និងចាស់ព្រឹទ្ធាចារ្យ មិនមានតួនាទីសំខាន់ក្នុងការដឹកនាំដូចនៅភូមិជ្រែងទេ ។ អ្នកភូមិបានអោយដឹងថា ព្រះសង្ឃពីរព្រះអង្គដែលនិមន្តមកពីវត្តនៅក្បែរភូមិ និមន្តចូលមកភូមិរាល់ព្រឹក ដើម្បីបិណ្ឌបាត្រ[១០] ។ ប៉ុន្តែអ្នកភូមិមួយចំនួនតូចតែប៉ុណ្ណោះដែលដាក់បាតប្រគេនព្រះសង្ឃ ។ នៅពេលមានបុណ្យទាននៅក្នុងភូមិ ព្រះសង្ឃពីរព្រះអង្គត្រូវបាននិមន្តមកចូលរួម ប៉ុន្តែព្រះសង្ឃមិនបានចូលរួមក្នុងសកម្មភាពផ្សេងៗណាមួយនៅក្នុងភូមិទេ ។

គេឃើញមានបុរសម្នាក់អាយុ ៣៦ឆ្នាំ ដែលបានធ្វើជាអាចារ្យតាំងពីគាត់មានអាយុ ២២ឆ្នាំម្លេះ ។ គាត់និយាយថា គាត់ជាអាចារ្យវ័យក្មេង ទៅភូមិនេះអត់មានចាស់ទុំដែលមានចំណេះដឹងខាងការធ្វើបុណ្យទានបែបព្រះពុទ្ធសាសនាច្បាស់គ្រប់គ្រាន់ទេ ដើម្បីធ្វើជាអាចារ្យបាន ។ អ្នកភូមិស្គាល់គាត់ច្បាស់ និងចូលចិត្តគាត់ ហើយគាត់ទទួលបន្ទុកខាងសមាគមចានឆ្នាំង ដែលគាត់បានផ្ដើមធ្វើឡើងរយៈពេល២ឆ្នាំកន្លងទៅនេះ ។ ប៉ុន្តែគាត់មិនបានទៅវត្តរាល់ថ្ងៃសិលទេ ព្រោះគាត់រវល់ការងារ ។ គាត់ហាក់ដូចជាមិនបាន ទទួលការគោរពជាពិសេសថា ជាអាចារ្យចាស់ជាងគេ ដូចនៅភូមិជ្រែងឡើយ ។

មានតែចាស់ទុំ ៤ ឬ ៥នាក់ប៉ុណ្ណោះ ទៅវត្តស្ទើររាល់ថ្ងៃសីល ។ ពួកគាត់ហាក់ដូចជាមិនដើរតួក្នុងការប្រមូលប្រជាជនដើម្បីធ្វើបុណ្យទាន និងធ្វើការងារទេ ។

*ក្មេងៗទៅធ្វើការនៅឯកាល អញ្ចឹងគេមិនបានដាក់បាត្រទេ ។ មានតែចាស់ៗដែលមិនអាចដើរឆ្ងាយ បានទៅត្រៀមម្ហូបអាហារប្រគេនព្រះសង្ឃ (អាចារ្យ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*ភារកិច្ចរបស់ព្រះសង្ឃមានតែនិមន្តមកភូមិដើម្បីស្វូត្រធម៌ (មេភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

### *ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ភូមិ*

*ជ្រែងៈ ម្នាក់មិននៅ ម្នាក់ទៀត មិនយុត្តិធម៌ និងថ្លៃ*

- អ្នកភូមិមានការរារែកក្នុងការពិគ្រោះជាមួយអាជ្ញាធរថ្នាក់ភូមិ ព្រោះមេភូមិមិនដែលនៅផ្ទះ ហើយគេមិនទុកចិត្តជីវពលទេ ម្យ៉ាងទៀតគាត់ទាររុយរាល់ការងារណាដែលគាត់ជួយ ។
- ការដោះស្រាយជម្លោះ គឺជាមូលហេតុសំខាន់ដែលអ្នកភូមិទៅរកអាជ្ញាធរភូមិ ហើយមូលហេតុផ្សេងទៀតដែលអ្នកភូមិទៅរកអាជ្ញាធរថ្នាក់ភូមិនោះ គឺការធ្វើលិខិតរៀបអាពាហ៍ពិពាហ៍ រឺការលែងលះគ្នា ។

---

[១០] ប៉ុន្តែក្នុងរយៈពេល២ខែដែលយើងបានស្នាក់នៅក្នុងភូមិនេះ ភាគច្រើន ព្រះសង្ឃមិនទនិមន្តមកទេ ហើយអ្នកភូមិនិយាយថា ព្រះសង្ឃរវល់ការងារនៅវត្ត ។

- ជីវពលកំពុងបន្តធ្វើកិច្ចការរបស់មេភូមិ ។

នៅជ្រែង មេភូមិរស់នៅកន្លែងដែលដាច់ស្រយាលជាងគេនៅក្នុងភូមិ ។ លទ្ធផលបានអោយដឹងថា អស់រយៈពេលដ៏យូរដែលអ្នកភូមិជាច្រើនមិនបានជួបគាត់ទាល់តែសោះ ។ ក្នុងអំឡុងពេលស្នាក់នៅលើកទី១របស់ក្រុមសិក្សា គាត់និយាយថា គាត់ដើរល្បាតជុំវិញភូមិរាល់យប់កុំអោយមានចោរ ។ ប៉ុន្តែជាក់ស្តែង វាមិនមែនជាការពិតទេ ហើយក្នុងអំឡុងពេលស្នាក់នៅលើកចុងក្រោយរបស់ក្រុមសិក្សា រយៈពេល១០ខែក្រោយមក គាត់ហាក់ដូចជាមិនសូវមកក្នុងភូមិដែលមិនមែនជាកន្លែងគាត់រស់នៅទេ ។ នៅពេលដែលគាត់មកកណ្តាលភូមិ គាត់ឧស្សាហ៍អោយគេធ្វើម្ហូបអោយគាត់ និងភ្ញៀវដែលគាត់នាំមក ។

អ្នកភូមិច្រើនឃើញជីវពលជាង ហើយឮសំលេងគាត់ពេញភូមិ នៅពេលគាត់ប្រកាសតាមមេក្រូ រៀបចំកិច្ចការផ្សេងៗ ឬដើរជុំវិញភូមិត្រួតពិនិត្យមើលមានអ្វីថ្មីកើតឡើង ។

ទោះជាមានការពណ៌នាថា មេភូមិជាឪពុកដែលគេអាចទៅរកនៅពេលដែលគេមានបញ្ហាក៏ដោយ ក៏ប៉ុន្តែអ្នកភូមិភាគច្រើន កម្រទៅរកគាត់ណាស់ ។ ជាទូទៅមានមូលហេតុតែមួយគត់ដែលអ្នកភូមិទៅជួបមេភូមិ គឺនៅពេលមានជម្លោះ ។ ប៉ុន្តែគេនៅតែរារែកមិនចង់ទៅរកមេភូមិ ព្រោះគាត់មិនសូវយកចិត្តទុកដាក់ក្នុងការជួយដោះស្រាយទេ តែគាត់បែរជាប្រគល់រឿងនេះអោយជីវពលជាអ្នកដោះស្រាយទៅវិញ ។ នៅពេលគាត់ធ្វើដូច្នេះ អ្នកភូមិភាគច្រើនសុខចិត្តព្យាយាមដោះស្រាយបញ្ហា និងជម្លោះដោយខ្លួនឯង ប៉ុន្តែមេភូមិនិយាយថា គេឧស្សាហ៍ពិគ្រោះជាមួយគាត់ពីរឿងដោះស្រាយជម្លោះ ។

*ជម្លោះមានច្រើនប្រភេទដូចជាក្របីស៊ីស្រូវ ជ្រូកចូលស៊ីដំណាំរបស់អ្នកផ្សេង ជម្លោះរឿងដី... ខ្ញុំដោះស្រាយទៅតាមច្បាប់ ។ ខ្ញុំត្រូវទៅមើលការពិត តើក្របីស៊ីស្រូវអស់ប៉ុន្មាន ។ អញ្ចឹងខ្ញុំអាចប្រាប់ម្ចាស់ក្របីអោយបង់ ។ កាលពីថ្ងៃអាទិត្យមុន ក្របីមួយចំនួនបានស៊ីស្រូវរបស់អ្នកភូមិ ។ ម្ចាស់ស្រែចាប់ក្របី ហើយយកមកអោយខ្ញុំ ។ ខ្ញុំឃាមក្របីហ្នឹងមួយយប់ បន្ទាប់មកម្ចាស់ក្របីមកសុំយកក្របីគេវិញ ។ ខ្ញុំក៏ហៅម្ចាស់ស្រែមកនិយាយគ្នា ។ ម្ចាស់ស្រែទារ ៥០.០០០រៀល ។ ខ្ញុំអោយនគរបាលភូមិ (ជីវពល) ទៅវាស់ស្រែដែលក្របីស៊ី វាអស់បួនម៉ែត្រ ។ ម្ចាស់ក្របីសុំបង់តែ ១០.០០០រៀលទេ ហើយខ្ញុំនិយាយថា "ចុះអោយគ្នាបន្តិចទៅ.." ដល់ចុងក្រោយ គេព្រមនៅត្រឹម ២០.០០០រៀល ។ ការដោះស្រាយជម្លោះនៅភូមិនេះអត់មានអស់អីទេ ។ ខ្ញុំបានត្រឹមតែបារីមួយកញ្ចប់ប៉ុណ្ណោះពីអ្នកដែលបានទទួលប្រាក់សងជំងឺចិត្ត ហើយយើងចែកគ្នាជក់ (មេភូមិ ខែតុលា ឆ្នាំ១៩៩៩) ។*

ជីវពលងាយស្រួលជួបជាងមេភូមិ ព្រោះគាត់រស់នៅផ្នែកកណ្តាលនៃក្នុងភូមិ ។ គាត់ចង់ដឹងថាអ្វីខ្លះដែលកំពុងកើតឡើង ហើយគាត់ចូលចិត្ត ធ្វើជាអ្នកពិគ្រោះយោបល់ ទោះជាខ្លួនគាត់និយាយថា គាត់មិនចូលចិត្តដោះស្រាយជំលោះក៏ដោយ ។ ប៉ុន្តែអ្នកភូមិភាគច្រើន នៅតែរារែកក្នុងការពិភាក្សាជាមួយគាត់ ព្រោះគេមិនចូលចិត្ត ឬទុកចិត្តគាត់ ហើយដោយសារគេដឹងទាំងអស់គ្នាថា គាត់ទារលុយពីអ្នកដែលសុំអោយគាត់ជួយ ។

*គេទៅរកហ៊ានពេលមានរឿងជម្លោះ ។ គាត់ហៅភាគីជម្លោះមកជួបគ្នា ហើយភាគីណាអោយលុយគាត់គឺឈ្នះ ។ មេភូមិមិនចង់យកលុយទេ ។ ប្រសិនបើអ្នកភូមិឈ្លោះគ្នា ហើយទៅរកមេភូមិ គាត់ប្រគល់ការងារនោះអោយទៅហ៊ាន (សមាជិក គ.អ.ភ ខែតុលា ១៩៩៩និង ខែមិនា ឆ្នាំ២០០០) ។*

*អ្នកដឹកនាំគួរតែស្មោះត្រង់ និងយុត្តិធម៌ គេគួរតែគិតគូរអ្នកក្រ និងដោះស្រាយបញ្ហាអោយអ្នកភូមិ ។ គេមិនគួរគិតពីរឿងលុយទេ ហើយគេគួរតែនិយាយអោយត្រង់មកថាគេចង់បានអ្វី ឧទាហរណ៍ ចារីមួយកញ្ចប់ ។ អ្នកដឹកនាំមិនគួរយកលុយពីភាគីជម្លោះទាំងសងខាងទេ ។ ច្បាប់មានចែងថា គេគួរបង់ប៉ុន្មានៗ ប៉ុន្តែអ្នកដឹកនាំនេះមិនធ្វើតាមច្បាប់ទេ ។ អ្នកណាអោយលុយច្រើន អ្នកនោះឈ្នះ (ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

ចោរ ពិសេសចោរលួចគោ ក្របី គឺជាការបារម្ភដ៏ធំរបស់អ្នកភូមិ និងជារឿងដែលមេភូមិ និងជីវពលនិយាយថា ពួកគេប្តេជ្ញាយ៉ាងខ្លាំងក្លាដើម្បីដោះស្រាយបញ្ហានេះ ។

*មាន់ និងទា ចោរធ្លាប់លួចរៀងរាល់ខែ ។ ឥឡូវនេះមិនសូវមានចោរដូចពីមុនទេ ។ ខ្ញុំចាប់បានចោរម្នាក់ ហើយណែនាំគេ ។ ធ្លាប់មានចោរ ៤នាក់ ប៉ុន្តែឥឡូវគេឈប់លួចហើយ គេក្លាយជាមនុស្សល្អក្រោយពីខ្ញុំណែនាំពួកគេ ។ យើងធ្វើកិច្ចសន្យាដោយផ្តិតមេដៃ ។ គេសន្យាថាឈប់ធ្វើអំពើអាក្រក់ទៀតហើយ "បើខ្ញុំធ្វើអំពើអាក្រក់ សូមចាប់ខ្ញុំទៅ" ។ នៅឆ្នាំ១៩៩៨ មានចោរពីរនាក់បានផ្តិតមេដៃលើកិច្ចសន្យានោះ ហើយនៅឆ្នាំ១៩៩៩ពីរនាក់ទៀត (មេភូមិ ខែតុលា ឆ្នាំ១៩៩៩) ។*

និយាយពីរឿងជម្លោះនៅក្នុងគ្រួសារដែលជាបញ្ហាសំខាន់ និងជាជម្លោះទូទៅបំផុតនោះ. ជាធម្មតាអ្នកភូមិកម្រទៅរកមេភូមិឬជីវពលណាស់ ។ ស្ត្រី១ដែលប្តីតែងតែវាយធ្វើបាបមិនចង់រាយការណ៍ពីរឿងនេះទេ ព្រោះពួកគេមិនចង់លែងលះគ្នា ។ សូម្បីតែអ្នកជិតខាងក៏មិនហ៊ានចូលធ្វើអន្តរាគមន៍ក្នុងរឿងជម្លោះគ្រួសារនេះដែរ ។

ដើម្បីរៀបការ ឬលែងលះគ្នាត្រូវមានការដឹងលឺពីមេភូមិ និងឃុំ ។ ជាទូទៅ មេភូមិគិតគូរទាំងពីរនាក់ តែអ្នកភូមិមួយចំនួនមិនខ្វល់ពីគ្នាទេ ។ ប៉ុន្តែសូម្បីតែអ្នកភូមិមកសុំច្បាប់រៀបការ ជីវពលក៏សំរេចជំនួសមេភូមិខ្លះៗដែរ ។ ក្នុងអំឡុងពេលទស្សនកិច្ចចុងក្រោយរបស់យើង ឪពុកម្តាយរបស់កូនប្រុសម្នាក់ដែលនៅភូមិជិតនោះបានមកស្តីដណ្តឹងកូនស្រីនៅក្នុងភូមិជ្រែង ពួកគេបានប្រាប់ និងសួរមេភូមិពីរឿងនេះ ។ ដោយសារមេភូមិមិននៅផ្ទះ បុរសនោះទៅជួបជីវពលជំនួសវិញ ហើយជីវពលរីករាយនឹងធ្វើកិច្ចការនេះដោយជប់លាងជាមួយសាច់ញាតិកូនកំលោះ និងកូនក្រមុំនៅពេលរសៀលទៀតផង ។

*នៅពេលខ្ញុំរៀបចំការកូនស្រី ខ្ញុំទៅជួបតែមេភូមិ ហើយគាត់រត់ការអោយខ្ញុំ ។ ខ្ញុំត្រូវជូនគាត់ ១៥.០០០រៀល ព្រោះគាត់ត្រូវទៅជួបមេឃុំ ។ ម្នាក់ៗត្រូវបង់ ១៥.០០០រៀល ។ គេមិនខ្វល់ថា អ្នកខ្លះក្រនោះទេ គេនិយាយថា បើអ្នកក្រ គេមិនរៀបការទេ ។ ប្រសិនអ្នកភូមិសែនកូន គេប្រាប់ត្រឹមតែមេភូមិ ។ ប៉ុន្តែបើគេទៅជួបហ៊ាន គេត្រូវតែអោយលុយ (ស្ត្រីម្នាក់ ខែមិនា ឆ្នាំ២០០០) ។*

ខួងជាមនុស្សចាស់ម្នាក់ ដែលគ្មានដីស្រែក្នុងចំណោមអ្នកក្រីក្របំផុតនៅក្នុងភូមិនេះ ។ គាត់រស់នៅជាមួយកូនស្រីម្នាក់ដែលមានអាយុ ១៧ឆ្នាំ និងកូនប្រសារ ។ ប្តីរបស់គាត់បានបាត់បង់ជីវិតអស់រយៈពេល ១០ឆ្នាំកន្លងទៅហើយ ។ នៅពេលថ្មីៗកន្លងទៅនេះ ការតភ្ជាប់របស់គាត់ជាមួយមេភូមិ និងជីវពល បានបង្ហាញពីអ្វី ដែលអ្នកដទៃបានជួបប្រទះ។

នៅពេលដែលកូនស្រីរៀបការ ខួងបានទៅជួបមេភូមិដើម្បីជំរាបគាត់ ។ ក្រោយពីធ្វើដំណើរទៅផ្ទះមេភូមិដែលមានចំងាយប្រហែលបីគីឡូម៉ែត្រជាច្រើនដង ហើយមិនបានជួប ខួងក៏ឈប់ទៅ ។

ក្រោយមកអ្នកជិតខាងម្នាក់បានចោទកូនប្រសាររបស់គាត់ថា លួចស្រូវ ។ លើកនេះ ខួងបានទៅជួបជីវពលដែលរស់នៅក្បែរនោះ ។ ប៉ុន្តែជីវពលនោះមិនជួយគាត់ទេ ប្រសិនបើគាត់មិនអោយលុយទៅជីវពលនោះ ៥០.០០០រៀល ។

*គោកដូង: ម្នាក់ត្រឹមត្រូវ ប៉ុន្តែយឺតយ៉ាវ ម្នាក់ទៀតមានប្រសិទ្ធិភាព ប៉ុន្តែថ្លៃ*

- រដ្ឋអំណាចនៅថ្នាក់ភូមិមានពេលវេលាអោយអ្នកភូមិទៅជួប និងទុកចិត្តជាងនៅភូមិជ្រែង ហើយអ្នកភូមិឧស្សាហ៍ទៅពិគ្រោះជាមួយរដ្ឋអំណាចនៅថ្នាក់ភូមិច្រើនជាង ។ ប៉ុន្តែជនមាតុភូមិនិវត្តន៍ដែលរស់នៅឆ្ងាយពីភូមិចាស់មានឱកាសពិភាក្សាជាមួយរដ្ឋអំណាចនៅថ្នាក់ភូមិ តិចជាងអ្នកភូមិចាស់ ។
- ដូចនៅភូមិជ្រែងដែរ ការដោះស្រាយជម្លោះ គឺជាមូលហេតុសំខាន់ដែលអ្នកភូមិទៅពិគ្រោះជាមួយអាជ្ញាធរថ្នាក់ភូមិ និងមូលហេតុផ្សេងទៀតដូចជា ធ្វើលិខិតរៀបអាពាហ៍ពិពាហ៍ ឬការលែងលះគ្នា ។
- អនុប្រធានភូមិមានប្រសិទ្ធិភាពជាង ប៉ុន្តែមេភូមិត្រឹមត្រូវជាង ហើយមិនយកលុយពីអ្នកភូមិ ដែលមកអោយគាត់ជួយនោះទេ ។

នៅភូមិគោកដូង រដ្ឋអំណាចមានពេលវេលាអោយអ្នកភូមិទៅជួប និងទុកចិត្តជាងនៅភូមិជ្រែង ។ អ្នកភូមិភាគច្រើន (លើកលែងជនមាតុភូមិនិវត្តន៍ដែលរស់នៅឆ្ងាយពីភូមិចាស់) ជួប ឬយ៉ាងហោចណាស់ ក៏ឃើញមេភូមិ និងអនុប្រធាន នៅពេលពួកគាត់ដើរក្នុងភូមិ រឺចេញក្រៅភូមិដែរ ។

*ខ្ញុំមិនសូវចូលទៅក្នុងភូមិទេ ប៉ុន្តែខ្ញុំឃើញមេភូមិ និងគង់ (អនុប្រធានភូមិ) ជិះកង់កាត់តាមនេះ (ស្ត្រីម្នាក់ ខែមករា ឆ្នាំ២០០០) ។*

អ្នកភូមិមួយចំនួនប្រហែលជាពេញចិត្ត ពេលដែលរដ្ឋអំណាចមិនសូវដឹងថាអ្វីដែលកំពុងតែកើតមានឡើងនៅកន្លែងកំបាំងនៅក្នុងភូមិ ។ ភូមិគោកដូង ជាកន្លែងលេងល្បែងស៊ីសងដែលអ្នកមកពីភូមិផ្សេង ក៏មកលេងដែរ ហើយមេភូមិ និងអនុប្រធានហាក់ដូចជាមិនអាចបំបាត់ល្បែងស៊ីសងនេះបានសោះ ។

*នៅពេលដែលមេភូមិប្រាប់អោយគេបន្ថយការលេងល្បែងគេមិនស្តាប់ទេ ។ គេប្រាប់គាត់ថា មិនមែនជារឿងរបស់គាត់ គេមិនយកលុយ ឬសុំបាយគាត់ហូបទេ (មេក្រុម ខែមករា ឆ្នាំ២០០០) ។*

*ក្នុងមួយឆ្នាំ ប្រធាន និងអនុប្រធានយក ៤០០០រៀល ទៅ ៥០០០រៀលពីអ្នកលេងល្បែងគ្រប់រូប ហើយយកច្រើនជាងនេះទៀតពីអ្នកដែលរៀបចំលេងល្បែង (ក្រុមផ្តល់យោបល់ ស្ត្រី និងបុរស ខែកុម្ភៈ ឆ្នាំ២០០០) ។*

ដូចនៅភូមិជ្រែងដែរ ការយល់ឃើញសំខាន់គឺថា ជម្លោះ គឺជាមូលហេតុតែមួយគត់ដែលអ្នកភូមិទៅរក មេភូមិ ឬអនុប្រធាន ។ ដោយសារពួកគាត់មានពេលច្រើន មានការយកចិត្តទុកដាក់ខ្ពស់ និងមានឆន្ទៈជួយអ្នកភូមិ បានមកពិភាក្សាបញ្ហាតូច ឬធំក្តីជាមួយពួកគាត់ជាងនៅភូមិជ្រែង ។ ប៉ុន្តែអ្នកភូមិមានទស្សនៈខុសៗគ្នាថាតើក្នុង ចំណោមអ្នកទាំងពីរ គេត្រូវទៅរកអ្នកណាល្អជាង ។ ចំពោះការទិញដូរដី ជាធម្មតាអ្នកភូមិទៅជួបអនុប្រធានភូមិ ។ ដើម្បីអោយជួយដោះស្រាយជម្លោះ ឬធ្វើកិច្ចព្រមព្រៀង គេអាចទៅជួបអ្នកណាក៏បានដែរ ។ អនុប្រធានមាន ប្រសិទ្ធិភាពជាង ប៉ុន្តែមិនសូវត្រឹមត្រូវទេ ហើយគាត់ទារលុយ ។ មេភូមិនិងអនុប្រធាននិយាយថា គាត់ទាំងពីរ សហការគ្នា ប្រហែលការនិយាយនេះច្រើនជាងការអនុវត្តជាក់ស្តែង ។

*នៅពេលគាត់ក្តីមេភូមិមិនសំរេចលឿនដូចគង់(អនុប្រធានភូមិ) ទេ ។ មេភូមិស្មោះត្រង់ គាត់តែង តែនិយាយពីច្បាប់ មុននឹងសំរេច គាត់ប្រើច្បាប់ដើម្បីសំរេច ។ គង់ សំរេចលឿនជាង ប្រសិនបើភាគី ណាមួយអោយលុយ គាត់អាចធ្វើអោយអ្នកត្រូវទៅជាខុស (មេក្រុម ខែមករា ឆ្នាំ២០០០) ។*

*អ្នកដែលមានជម្លោះមកប្តឹងខ្ញុំ ឬមេភូមិ ។ មេភូមិនិងខ្ញុំធ្វើការសម្រុះសម្រួល ។ បើត្រូវ ខ្ញុំថាត្រូវ បើជាខុស ខ្ញុំថាខុស ។ ខ្ញុំណែនាំ ឧទាហរណ៍បើគេស្រវឹងហើយជេរគ្នា ខ្ញុំប្រាប់គេថា "អ្នកឯងធ្វើហ្នឹងមិន ត្រឹមត្រូវទេ នៅក្នុងភូមិ យើងដូចជាសាច់ញាតិនឹងគ្នា អ្នកឯងមិនគួរជេរគ្នាទេ" ។ ជម្លោះភាគច្រើនអាច ដោះស្រាយនៅក្នុងភូមិបាន (អនុប្រធានភូមិខែវិច្ឆិកា ឆ្នាំ១៩៩៨) ។*

ដូចនៅភូមិជ្រែងដែរ មូលហេតុជម្លោះជាទូទៅក្នុងចំណោមអ្នកភូមិ គឺបណ្តាលមកពីសត្វពាហនៈស៊ីដំណាំ ។ តួនាទីសំខាន់របស់មេភូមិ គឺជំរុញប្រជាជនអោយមើលសត្វរបស់ខ្លួន និងធ្វើអោយប្រជាជនអត់អោនអោយគ្នា ប៉ុន្តែជូនកាលគាត់ ឬអនុប្រធានត្រូវដោះស្រាយដើម្បីអោយភាគីទាំងសងខាងព្រមព្រៀងគ្នាអំពីការសងជំងឺចិត្ត ។

*មេភូមិប្រកាសតាមមេក្រូ "កុំបណ្តោយគោអោយស៊ីស្រូវ" ។ នៅពេលដែលម្ចាស់ស្រែចាប់ គោដែលកំពុងស៊ីស្រូវបានគាត់ដឹកទៅផ្ទះគណៈកម្មាការ (មេភូមិ) ។ បន្ទាប់មក គាត់ប្រកាសមេក្រូ "គោអ្នកណា? មកយកទៅវិញ! "នៅពេលនោះ គាត់ណែនាំម្ចាស់គោ" ថ្ងៃក្រោយកុំបណ្តោយ គោអោយស៊ីស្រូវគេអញ្ចឹងទៀត" ប៉ុន្តែអត់មានបង់លុយទេ ហើយម្ចាស់គោក៏ដឹងពីកំហុសដែរ ហើយក៏ លែងធ្វើអញ្ចឹងទៀត (ស្ត្រីម្នាក់ ខែវិច្ឆិកា ឆ្នាំ១៩៩៨) ។*

ដូចនៅភូមិជ្រែងដែរ អ្នកភូមិមានការព្រួយបារម្ភយ៉ាងខ្លាំងពីបញ្ហាចោរលួចគោ ហើយចោរដែលគេចាប់បាន ត្រូវគេអោយធ្វើកិច្ចសន្យា ដើម្បីធានាការទទួលខុសត្រូវនៅថ្ងៃមុខ ។ រឿងរ៉ាវដែលកើតឡើងមុន ពេលរៀបការ និងបញ្ហាជិតក្បែរនៅភូមិគោកដូង មានកើតជាទូទៅជាងនៅភូមិជ្រែងដែលរដ្ឋអំណាចនៅថ្នាក់ភូមិត្រូវដោះស្រាយ ។

*ខ្ញុំអោយគង់ (អនុប្រធានភូមិ) ដោះស្រាយបញ្ហារឿងកូនស្រីរបស់ខ្ញុំជាមួយ សំ ។ ខ្ញុំទៅប្តឹង គង់ ប៉ុន្តែខ្ញុំមិនចង់អោយរឿងនេះក្លាយជារឿងធំទេ ។ ខ្ញុំគ្រាន់តែចង់ដឹងថា គេទទួលស្គាល់កូននៅក្នុងផ្ទៃជាកូនរបស់គេ ឬអត់ ។ នៅពេលដែលគង់ហៅ សំ មកសួរ គេព្រមទទួលស្គាល់កូននោះ ហើយខ្ញុំទារគេអោយបង់ ៥.០០០បាត ដើម្បីចិញ្ចឹមកូន អញ្ចឹងទៅយើងបានបញ្ចប់រឿងនេះ ។ ខ្ញុំអោយគង់ ១០០បាត សំរាប់ការជួយសម្រុះសម្រួលរបស់គាត់(សមាជិក គ.អ.ភ ស្ត្រី ខែមករា ឆ្នាំ២០០០) ។*

ដូចនៅភូមិជ្រៃងដែរ ទោះជាស្ត្រីរាវែរកក្នុងការប្តឹងពីប្តីរបស់ខ្លួន ហើយអ្នកជិតខាងរាវែរកមិនហ៊ានចូលជួយក៏ដោយ អ្នកភូមិច្រើនមកពិគ្រោះពីរឿងជម្លោះនៅក្នុងគ្រួសារជាមួយមេភូមិ និងអនុប្រធានភូមិជាងនៅភូមិជ្រៃង។ តួនាទីសំខានគាត់ គឺព្យាយាមធ្វើអោយប្រជាជនអធ្យាស្រ័យអោយគ្នាទៅវិញមក ។

មូលហេតុដែលត្រូវជួបមេភូមិចំពោះអ្នកដែលគ្មានការឈ្លោះទាស់ទែងគ្នា គឺការទិញ/លក់ដី ឬនៅពេលដែលគេមានកូនរៀបការ ឬលែងលះលែងគ្នាត្រូវជំរាប និងទទួលការយល់ព្រមពីគាត់ ។ ប៉ុន្តែប្រហែលជាមានមនុស្សតិចជាងនៅភូមិជ្រៃងដែលមិនទៅរកមេភូមិ ពីព្រោះគេមិនចង់បង់ថ្លៃច្បាប់រៀបអាពាហ៍ពិពាហ៍ ឬដោយសារពួកគេមានការធុញទ្រាន់នឹងទៅជួបអាជ្ញាធរថ្នាក់ភូមិ ។ នៅពេលដែលអ្នកភូមិលែងលះគ្នា អាជ្ញាធរថ្នាក់ភូមិក៏ព្យាយាមអោយពួកគេត្រូវគ្នាវិញដែរ ។

*កាលពេលដែលប្តីខ្ញុំវៃ ខ្ញុំរត់ទៅអោយមេភូមិជួយ ។ បន្ទាប់មកមេភូមិធ្វើការសម្រុះសម្រួល ។ គាត់ព្រមានគេ (អតីតប្តី) ដោយអោយគេធ្វើកិច្ចសន្យាផ្តិតមេដៃ ដោយនិយាយថា គេឈប់ធ្វើអញ្ចឹងទៀតហើយ ។ ប៉ុន្តែពេលដែលគេវៃធ្វើបាបខ្ញុំ ខ្ញុំក៏រលូតកូន មេភូមិលែងសម្រុះសម្រួលទៀតហើយ ព្រោះប្តីរបស់ខ្ញុំមិនគោរពពាក្យសន្យា ។ ខ្ញុំបានប្តឹងមេភូមិអោយជួយធ្វើការលែងលះអោយខ្ញុំ (ស្ត្រី ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*គេ (ប្តីប្រពន្ធមួយគូទៀត) លែងលះគ្នាច្រើនដងហើយ ។ គេនៅជាមួយគ្នា ហើយលែងគ្នា... ខ្ញុំព្យាយាមណែនាំពួកគេ ប៉ុន្តែគេមិនស្តាប់ទេ ។ មេភូមិព្យាយាមសំរបសំរួល ប៉ុន្តែពួកគេមិនឯកភាពជាមួយគាត់ទេ តែគេលែងលះតែគ្នាគេ ។ គេមិនដែលទៅរកមេភូមិ ឬមេឃុំទេ គេព្រមព្រៀងតែគ្នាគេ (មេក្រុម ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ជនមាតុភូមិនិវត្តន៍ដែលរស់នៅឆ្ងាយពីភូមិចាស់ មានទំនាក់ទំនង និងឱកាសជួបជាមួយមេភូមិ និងអនុប្រធានភូមិតិចជាងអ្នកភូមិចាស់ ។ ដូចដែលបានកត់សំគាល់ហើយថា ពួកគេជិតដិតជាមួយអនុប្រធានជាងជាមួយមេភូមិ ។ ពួកគេជួបគាត់ដោយសាររឿងដោះដូរដី ប៉ុន្តែរឿងជម្លោះ ជាទូទៅគេព្យាយាមដោះស្រាយដោយខ្លួនឯង ។

*អ្នកមកថ្មី មិនសូវមកទេ ។ គេមិនសូវមានរឿងឈ្លោះគ្នា ហើយគេនៅឆ្ងាយពីភូមិចាស់ ។ អញ្ចឹងពេលដែលគេមានជម្លោះបន្តិចបន្តួច គេគិតថា មិនចាំបាច់មករកខ្ញុំទេ (មេភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ឃុំ

*ការយល់ដឹងចំពោះថ្នាក់ឃុំ*

*ជ្រែង: ពួកគេនិយាយអ្វី យើងធ្វើហ្នឹង*

- ការយល់ដឹងរបស់អ្នកភូមិចំពោះថ្នាក់ឃុំមានភាពស្រពិចស្រពិលដោយពួកគេគ្រាន់តែដឹងថា "ថ្នាក់លើ" តែប៉ុណ្ណោះ ។
- អ្នកភូមិមិនសូវស្គាល់មុខ និងឈ្មោះមន្ត្រីថ្នាក់ឃុំ ស្រុក និងខេត្តទេ ប៉ុន្តែពួកគេគាន់តែដឹងថា ថ្នាក់លើជាកន្លែងមួយដែលនៅឆ្ងាយពីភូមិ និងមិនអាចាន់នឱកាសចូលជួបបាន ។
- មេភូមិ និងមេឃុំមិនសូវជិតដិតជាមួយអាជ្ញាធរថ្នាក់លើ និងមានឋានៈទាបជាងថ្នាក់លើទាំងនោះ ។

នៅភូមិជ្រែង ប្រជាជនភាគច្រើនដឹងពីអ្វីដែលគេហៅថា "ខ្សែបណ្តោយ" ខាងលើភូមិគឺឃុំ ខាងលើឃុំគឺស្រុក ខាងលើស្រុក គឺខេត្ត ។ អ្នកភូមិយល់ឃើញថាអ្នកទាំងនោះនៅឆ្ងាយសែនឆ្ងាយ និងមិនអាចាន់នឱកាសចូលជួបបាន ហើយអ្នកភូមិហៅអ្នកដែលមកពីខាងហ្នឹងថា "អ្នកធំ" ។ ចំពោះភ្នំពេញ ឬហ៊ុន សែន អ្នកភូមិហាក់ដូចជាគិតថាឆ្ងាយពេក និងធំពេកដែលធ្វើអោយពួកគេស្ទើរតែនឹកមិនឃើញ ។

ជាទូទៅ អ្នកភូមិហាក់ដូចជាមិនចែកអោយដាច់រវាងថ្នាក់រដ្ឋអំណាចផ្សេងៗ ប៉ុន្តែពួកគេយល់ទាំងស្រពិចស្រពិលថា ថ្នាក់រដ្ឋអំណាចទាំងនេះជា "ថ្នាក់លើ" ។ ក្រៅពីដឹងថាថ្នាក់ក្រោម "ទទួលផែនការ" ពីថ្នាក់លើ "ផ្ញើផែនការ" ពីថ្នាក់ក្រោម និងការដោះស្រាយជម្លោះដែលថ្នាក់ក្រោមមិនអាចដោះស្រាយបាន អ្នកភូមិភាគច្រើននៅតែមិនដឹងច្បាស់ពីតួនាទី និងអំណាចរបស់ថ្នាក់លើ និងមន្ត្រីនានាទេ ។ អ្នកភូមិហាក់ដូចជាមិនចង់ដឹងពីអ្វីដែលរដ្ឋអំណាចថ្នាក់លើធ្វើ ឬស្វែងយល់ថា ហេតុអ្វីបានជាគេធ្វើអញ្ចឹងនោះទេ ។ អ្នកភូមិមិនគិតថា ពួកគេអាចាន់នឥទ្ធិពលចំពោះថ្នាក់លើនោះឡើយ ។ ប៉ុន្តែជាទូទៅ អ្នកភូមិមិនបានបង្ហាញអោយឃើញពីការភ័យខ្លាចណាមួយពិតប្រាកដចំពោះរដ្ឋអំណាចនោះទេ ឥរិយាបទគ្រប់គ្រងយ៉ាងខ្លាំងមិនមែនជាបញ្ហាដែលមកពី "ថ្នាក់លើ" នោះទេ ប៉ុន្តែអ្នកភូមិចូលចិត្តធ្វើតាមនិងគោរពអ្វីដែលថ្នាក់លើនិយាយ ។

*គេអោយយើងធ្វើអ្វី យើងធ្វើហ្នឹងទៅ ។ បើគេអោយចូលគុក ក៏ចូលទៅ (អ្នកភូមិ ស្ត្រី ខែតុលា ឆ្នាំ១៩៩៩) ។*

*ថ្នាក់លើចេះច្បាប់ ។ ថ្នាក់ក្រោមមិនហ៊ាននិយាយអ្វីទេ ។ អ្នកភូមិជាច្រើនមិនហ៊ានទៅជិតអ្នកធំដោយគេខ្លាចថា គេនឹងនិយាយអ្វីខុស ហើយត្រូវគេដាក់ទោស (ស្ត្រី ខែតុលា ឆ្នាំ១៩៩៩) ។*

*អ្វីដែលថ្នាក់លើធ្វើសុទ្ធតែស្របច្បាប់ទាំងអស់ ឧទាហរណ៍បើគេចង់លើកផ្លូវកាត់វាលស្រែ ក៏មិនអីដែរ ។ ថ្នាក់លើជាអ្នកច្បាប់ (បុរសដែលជាសមាជិក គ.អ.ភ ខែតុលា ឆ្នាំ១៩៩៩) ។*

*ខ្ញុំដឹងថាអ្វីកើតឡើងនៅក្នុងភូមិ ប៉ុន្តែខ្ញុំមិនដឹងថាថ្នាក់លើធ្វើយ៉ាងម៉េចនោះទេ ។ ថ្នាក់លើមិនដឹងថាអ្វីកើតឡើងនៅក្នុងភូមិនោះឡើយ ។ ថ្នាក់ក្រោមរាយការណ៍ ព្រោះថ្នាក់ក្រោមមិនដឹងថា ថ្នាក់លើធ្វើអ្វីនោះទេ ។ ថ្នាក់លើណែនាំ ឧទាហរណ៍អោយលើកដីបំពេញផ្លូវថ្នល់ ។ មានផែនការពីថ្នាក់លើអញ្ចឹង*

*ថ្នាក់ក្រោមដឹងថា ចាប់ផ្តើមនៅពេលណា ។ ឧទាហរណ៍ បើអ្នកណាម្នាក់ចង់កាប់ឆ្ការដីធ្វើចំការថ្នាក់ក្រោម សុំយោបល់ពីថ្នាក់លើ ហើយថ្នាក់លើជាអ្នកសម្រេច (សមាជិក គ.អ.ភ ប្រុសម្នាក់ ខែតុលា ឆ្នាំ១៩៩៨) ។*

*រដ្ឋអំណាចនានាមិនយល់ពីអារម្មណ៍របស់អ្នកភូមិទេ ។ គេប្រើពាក្យដែលអ្នកភូមិមិនយល់ ។ អ្នកភូមិទាំងអស់ ធ្វើតាមអ្វីដែលរដ្ឋអំណាចនិយាយ ទោះគេមិនយល់ក៏ដោយ (បុរស ខែតុលា ឆ្នាំ១៩៩៨) ។*

ជាទូទៅ ទោះជាអ្នកភូមិមិនអាចចែកថ្នាក់ឃុំអោយដាច់ពីថ្នាក់លើក៏ដោយ ពួកគេនៅតែគិតថា ឃុំជាកន្លែងដែលនៅឆ្ងាយដាច់ស្រយាលពីពួកគេដដែល ។ ប៉ុន្តែអ្នកភូមិភាគច្រើននៅភូមិជ្រែង ស្គាល់ឈ្មោះមេឃុំ ព្រោះគាត់ធ្វើការនៅឃុំតាំងពីឆ្នាំ១៩៧៩ ហើយធ្វើជាមេឃុំតាំងពីឆ្នាំ១៩៨៦ ។ អ្នកភូមិភាគច្រើនឃើញគាត់ម្តងម្កាលនៅក្នុងភូមិ ។ ប៉ុន្តែអ្នកភូមិភាគតិចណាស់ដែលអាចអោយឧទាហរណ៍ច្បាស់ពីអ្វីដែលឃុំ ឬមេឃុំធ្វើ ។ ការយល់ឃើញជាទូទៅ គឺការដាក់ផែន និងការដោះស្រាយជម្លោះ ។

*យើងឃើញមេឃុំម្តង ពេលគាត់យកសំបុត្រអោយមេភូមិ (ប្តីប្រពន្ធ ខែមិនា ឆ្នាំ២០០០) ។*

ទោះជាអ្នកភូមិមានការស្រពិចស្រពិលយ៉ាងខ្លាំងចំពោះរដ្ឋអំណាចថ្នាក់ស្រុកក៏ដោយ អ្នកភូមិជាច្រើនដឹងថានៅពេលថ្មីៗនេះមានការផ្លាស់ប្តូរអភិបាលស្រុកពីស្រុកមួយទៅស្រុកមួយ ។ អ្នកភូមិស្គាល់អភិបាលស្រុកថ្មី និងចូលចិត្តជាងអភិបាលស្រុកចាស់ ព្រោះគាត់ចុះមកភូមិនៅពេលលើកផ្លូវថ្នល់ និងនៅពេលដែលគាត់ណែនាំមិនអោយប្រជាជនកាប់ឈើ និងនេសាទត្រីខុសច្បាប់ ។

*មេស្រុកថ្មី គាត់ផ្លាស់មកពីស្រុកក្រវ៉ាញ ។ ខ្ញុំមិនដឹងថាហេតុអីនោះទេ ប្រហែលជាអភិបាលស្រុកចាស់ មិនគិតពីរឿងព្រៃឈើ ដោយចេះតែអោយប្រជាជនកាប់ព្រៃហើយមើលទៅ ។ អញ្ចឹងហើយបានជាគេផ្លាស់គាត់ទៅកន្លែងផ្សេង ។ អភិបាលស្រុកចាស់ យើងមិនដែលឃើញទេ ។ ប៉ុន្តែកាលពីមុនលើកថ្នល់ អភិបាលស្រុកថ្មីមកប្រជុំនៅក្នុងភូមិម្តង ។ គាត់ប្រាប់ឈ្មោះ និងអាយុ អោយអ្នកភូមិដឹង ហើយគាត់ប្រាប់អ្នកភូមិមិនអោយកាប់ឈើ ព្រោះខ្លាចបាត់បង់ព្រៃឈើ ។ មេស្រុកថ្មីសុភាពរាក់ទាក់ និងសាមញ្ញ ។ គាត់មិនគិតថា គាត់ជាអ្នកណានោះទេ ជួនកាលគាត់ស្លៀកពាក់ធម្មតា ហើយដើរតាមភូមិ អ្នកខ្លះមើលគាត់ស្ទើរតែមិនស្គាល់ (ក្រុមស្ត្រីក្រីក្រ ខែតុលា ឆ្នាំ១៩៩៨) ។*

គេអាចទស្សន៍ទាយបានថា អ្នកភូមិមិនគិតថាអាចទាក់ទងជាមួយមន្ត្រីថ្នាក់ខេត្តណាមួយបានទេ ។ ប៉ុន្តែអភិបាលថ្មី ក៏បានធ្វើការចាប់អារម្មណ៍យ៉ាងខ្លាំងជាងអភិបាលចាស់ដែរ ។ អ្នកភូមិភាគច្រើន មិនបានឃើញគាត់ទេ ប៉ុន្តែគេដឹងថា គាត់ជាមនុស្សម្នាក់ដែលណែនាំអោយគ្រួសារនីមួយៗ ត្រូវតែមានត្រដោកនៅតាមផ្ទះ ។ អ្នកភូមិបានស្គាល់អភិបាលរងទីបីនៅពេលថ្មីៗ ព្រោះគាត់បានចុះមកបើកអំណោយនៅភូមិ បន្ទាប់ពីមានទឹកជំនន់នៅចុងឆ្នាំ១៩៩៩ ។ ជាទូទៅ "អ្នកធំ" ត្រូវបានគេស្គាល់ដោយសារការចែកអំណោយ ។

*យើងមិនអាចជួបអ្នកធ្វើការនៅខេត្តបានទេ ។ ខ្ញុំមិនដឹងថាគេនៅកន្លែងណា ។ នៅខេត្តពោធិសាត់មានផ្ទះធំៗច្រើនណាស់ អញ្ចឹងយើងមិនអាចរកគេឃើញទេ (ក្រុមស្ត្រីក្រីក្រ ខែតុលា ឆ្នាំ១៩៩៨) ។*

គួរអោយភ្ញាក់ផ្អើលជាងការដែលដឹងថា អ្នកភូមិមានគំនិតស្រពិចស្រពិលនោះមេភូមិមានការខ្វះខាតភាពជិតដិតជាមួយថ្នាក់លើ ។ គាត់ទៅប្រជុំនៅឃុំ (ប៉ុន្តែមិនសូវញឹកញាប់ទេ ទោះជាឃើញអ្នកភូមិទៅឃុំ និងថ្នាក់លើក៏ដោយ) ហើយអ្នកមកពីស្រុក និងមន្ទីរខេត្តមករកគាត់ដល់ផ្ទះ ។ គាត់មិនដឹងច្បាស់ថា អ្វីខ្លះកើតឡើងនៅក្នុងឃុំ សូម្បីតែឈ្មោះអភិបាលខេត្ត ក៏មិនចាំផង ហើយប្រការសំខាន់នោះគឺថា គាត់ហាក់ដូចជារង់ចាំ "អ្នកធំ" មកប្រាប់ឬណែនាំ ។ ម្យ៉ាងទៀតអ្នកភូមិបានទទួលពត៌មានបន្តពីជីវពលច្រើនជាងមេភូមិ ហើយគាត់មានភាពជិតដិតជាមួយថ្នាក់លើ ។

*ខ្ញុំមិនស្គាល់ឃុំទេ! ខ្ញុំស្គាល់តែភូមិ ។ មេឃុំត្រួតពិនិត្យ និងគ្រប់គ្រងមេភូមិទាំងអស់ ។ រាល់ថ្ងៃពុធ គាត់ទៅស្រុកដើម្បីទទួលផែនការ ហើយរាល់ថ្ងៃច័ន្ទ គាត់រាយការណ៍អោយមេភូមិ ។ នៅពេលប្រជុំទាំងនេះ គឺជាទំនាក់ទំនងដែលខ្ញុំមានជាមួយមេឃុំ ។ ខ្ញុំមិនដឹងថាអភិបាលស្រុកធ្វើអ្វីខ្លះនោះទេ ។ ប៉ុន្តែខ្ញុំស្គាល់គាត់ ខ្ញុំបានជជែកលេងជាមួយគាត់ម្តង ។ គាត់មកពីស្រុកក្រវ៉ាញ ។ គេដូរអភិបាលស្រុកពីស្រុកមួយទៅស្រុកមួយដោយសារ មានផែនការមកពីខេត្ត គេចង់អោយស្រុកនីមួយៗមានការរីកចំរើនការងាររបស់ស្រុក គឺសំរាប់តែកិច្ចការរដ្ឋអំណាច ដូចជាដោះស្រាយជម្លោះ និងបង្ក្រាបអំពើឆក់ប្លន់ ។ ខ្ញុំមិនស្គាល់ខេត្តទេ! គេធំណាស់!!! ខ្ញុំមិនដឹងថា អភិបាលខេត្តធ្វើអ្វីខ្លះនោះទេ ។ គាត់មកថ្មីមកពីខេត្តបាត់ដំបង ។ នៅពេលមានមន្ត្រីថ្នាក់ខេត្តចុះមកឃុំ នោះគឺជាពេលដែលខ្ញុំឃើញអ្នកមកពីខេត្ត (មេភូមិ ខែតុលា ឆ្នាំ១៩៩៩ និងខែមិនា ឆ្នាំ២០០០) ។*

អត្ថន័យនៃឋានៈទាបជាងនេះ មិនមែនកើតឡើងតែនៅក្នុងភូមិនេះទេ ។ មេឃុំ ហាក់ដូចជាមិនមានភាពកក់ក្តៅ និងភ័យខ្លាច "អ្នកធំ" ។ នៅពេលដែលក្រុមសិក្សាស្រាវជ្រាវកំពុងហូបបាយថ្ងៃត្រង់ជាមួយមេឃុំ ប្រធានមន្ទីរកិច្ចការនារីខេត្តនៅផ្ទះ សមាជិកគ.អ.ឃ យើងឃើញច្បាស់ថា មេឃុំមានអារម្មណ៍មិនសូវស្រួល ហើយគាត់បានប្រាប់សមាជិកខ្មែរម្នាក់ថា គាត់មិនចង់ទៅជិត "អ្នកធំ" ទេ ។

*ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ស្រុក ។ ផ្នែកលំបាកបំផុតនៃការងាររបស់ខ្ញុំ គឺរដ្ឋអំណាច ជាពិសេសបញ្ហាសន្តិសុខ ។ ប្រសិនបើខ្ញុំមិនអាចបង្ក្រាបអំពើឆក់ប្លន់បានទេ នោះគេចាត់ទុកថា ខ្ញុំជាមេឃុំមិនសូវពូកែ ។ ប្រសិនបើមានអំពើឆក់ប្លន់ ថ្នាក់លើនឹងបន្ទោសខ្ញុំ ដូច្នេះខ្ញុំត្រូវតែប្រុងប្រយ័ត្ន ។ មេឃុំខ្លះបានសុំការអនុញ្ញាតពីមេស្រុក មិនអោយដាក់ឈ្មោះខ្លួនទៅក្នុងបញ្ជីបេក្ខជនសំរាប់បោះឆ្នោតឃុំទេ ។ ប៉ុន្តែមេស្រុកមិនព្រម គាត់អោយពួកគេឈរឈ្មោះ ។ អភិបាលស្រុកបានអោយកូនចៅគាត់ ចុះមកធ្វើការស្ទាបស្ទង់មតិថា អ្នកណាគួរតែឈរឈ្មោះជាបេក្ខជន ។ មេឃុំទាំងអស់សុទ្ធតែជាបេក្ខជនល្អៗ ។ ដូច្នេះខ្ញុំមិនហ៊ានសួរគាត់ថាតើខ្ញុំមានឈ្មោះនៅក្នុងបញ្ជីបេក្ខជនដែរឬអត់ ។ ខ្ញុំមិនដែលជួបនិយាយផ្ទាល់ជាមួយអភិបាលខេត្តទេ ។ នៅពេលដែលខ្ញុំទៅសន្និបាទ ទើបខ្ញុំបានឃើញគាត់ ។ ខ្ញុំ និងខាងស្រុក បានទៅរាយការណ៍អំពីទឹកជំនន់ជូនអភិបាលខេត្តមុនផ្ទាល់ ។ ប៉ុន្តែពេលទឹកជំនន់ក្រោយនេះ យើងមិនបានទៅជួបអភិបាលផ្ទាល់ទេ ដោយសារគាត់មកថ្មី (មេឃុំ ខែមិនា ឆ្នាំ២០០០) ។*

*គោកដូង: ខ្ញុំគ្រាន់តែជាអ្នកនៅថ្នាក់ក្រោម ខ្ញុំត្រូវស្ដាប់គេ*

- ដូចនៅភូមិជ្រែងដែរ ជាទូទៅ អ្នកភូមិមិនអាចចែកថ្នាក់ឃុំអោយដាច់ពី "ថ្នាក់លើ" បានទេ ។
- អ្នកភូមិមានភាពជិតដិតជាមួយមន្ត្រីថ្នាក់លើដោយលក្ខណៈបុគ្គលតិចជាងភូមិជ្រែង ប៉ុន្តែប្រសិនបើគេមានការ គេមានទំនោរទៅរកថ្នាក់លើអោយជួយច្រើនជាងអ្នកភូមិជ្រែង ។
- មេភូមិជាមនុស្សស្មោះត្រង់ ប៉ុន្តែមិនសូវឈ្លាសវៃប៉ុន្មានទេក្នុងការទាក់ទងជាមួយអាជ្ញាធរថ្នាក់លើ ឯមេឃុំកំពុងតែខ្នះខ្នែងក្នុងការទាក់ទងជាមួយថ្នាក់លើ ប៉ុន្តែចេះតែគិតខ្លួនឯងថា គាត់គ្មានអំណាច ។

នៅភូមិគោកដូងក៏អញ្ចឹងដែរ អ្នកភូមិដឹងពីគំរិតនៃរដ្ឋអំណាចនៅពីលើថ្នាក់ភូមិ ។ ប៉ុន្តែដូចនៅភូមិជ្រែងដែរ គំនិតដែលថា "ថ្នាក់លើ" ទាំងនេះធ្វើអ្វីខ្លះនោះ នៅមានការស្រពិចស្រពិលដោយមានការយល់ដឹងជាទូទៅថា "ធ្វើផែនការ" "ហៅទៅប្រជុំ" "ដោះស្រាយជម្លោះ" និងរង់ចាំទទួលយកអ្វីដែលបានមកពី "ថ្នាក់លើ" ។

អ្នកភូមិមិនសូវស្គាល់មេឃុំ ជាលក្ខណៈបុគ្គលដូចនៅភូមិជ្រែងទេ ព្រោះមានការផ្លាស់ប្ដូរមេឃុំច្រើនដងពេក ។ អ្នកភូមិភាគច្រើនដឹងរឿងមេឃុំចាស់ ។ គាត់ចេញ ដោយសារគាត់មានប្រពន្ធចុង ហើយពួកគេនៅមិនទាន់ស្គាល់មេឃុំថ្មីដែលឡើងធ្វើជាមេឃុំនៅឆ្នាំ១៩៩៧ អ្នកមុនៗនៅឡើយទេ ។ ប៉ុន្តែគេឧស្សាហ៍ឃើញមេឃុំជិះម៉ូតូមកភូមិ ។ អ្នកភូមិស្គាល់មន្ត្រីថ្នាក់ស្រុក និងថ្នាក់លើដោយផ្ទាល់ តិចជាងនៅខេត្តពោធិសាត់ ហើយប្រហែលជាតិចជាងពីមុន ។ សព្វថ្ងៃនេះ សូម្បីតែមេភូមិ ក៏មិនស្គាល់ឈ្មោះអភិបាលស្រុកថ្មីដែរ ។ ប៉ុន្តែឃុំហាក់ដូចជាដក់ជាប់ទៅនឹងផ្នត់គំនិតរបស់ប្រជាជនជាងនៅភូមិជ្រែងដដែល ព្រោះពួកគេអាចទៅជួបឃុំ បើសិនជាមានកិច្ចការចាំបាច់ដែលត្រូវទៅ ។

*អ្វីក៏ដោយអោយតែថ្នាក់លើចង់អោយមេភូមិធ្វើ គាត់ត្រូវតែធ្វើ ។ មេក្រុមតូច ហើយនៅថ្នាក់ក្រោមទៀត បន្ទាប់មក គឺមេភូមិ មេឃុំ មេស្រុក និងចៅហ្វាយខេត្ត ។ ខ្ញុំមិនដឹងថាឃុំធ្វើអ្វីខ្លះនោះទេ ។ ខ្ញុំថ្នាក់ទាប ខ្ញុំគ្រាន់តែស្ដាប់គេប៉ុណ្ណោះ ខ្ញុំមិនស្គាល់មេឃុំថ្មី ។ ខ្ញុំស្គាល់មេឃុំចាស់ដែលរត់ចាក់ ពីព្រោះខ្ញុំធ្លាប់ទៅរៀន ។ ឥឡូវនេះខ្ញុំអត់ទៅទេ ។ ខ្ញុំមិនស្គាល់ខាងស្រុកទេ ប្រសិនអ្នកចង់ដឹង ទៅសួរមេភូមិទៅ (មេក្រុម ខែវិច្ឆិកា ឆ្នាំ១៩៩៨) ។*

*ខ្ញុំមិនស្គាល់ឈ្មោះមេឃុំទេ ។ ខ្ញុំគ្រាន់តែឃើញគាត់ជិះម៉ូតូតាមផ្លូវនេះ (អ្នកភូមិស្ត្រី ខែមករា ឆ្នាំ២០០០) ។*

*ជួនកាលមានសំបុត្រមកពីគេ ហើយជួនកាលគេមកទីនេះ ។ ខ្ញុំមិនដឹងថា ពួកគេជាអ្នកណានោះទេ មកពីថ្នាក់ណា លោកនេះ លោកនោះ (ស្ត្រី ខែវិច្ឆិកា ឆ្នាំ១៩៩៨) ។*

*កាលពីដើម អ្នកភូមិបានទទួលការប្រជុំរៀនសូត្រទៀងទាត់ ។ សូម្បីតែក្មេងៗក៏ស្គាល់មេឃុំ និងអភិបាលស្រុកដែរ ។ ឥឡូវនេះជាលទ្ធិប្រជាធិបតេយ្យ ដូច្នេះប្រជាជនមិនស្គាល់អ្នកដឹកនាំទេ (ក្រុមផ្ដល់យោបល់ ស្ត្រី/បុរស ខែកុម្ភៈ ឆ្នាំ២០០០) ។*

*នៅពេលដែលខាងស្រុកចុះមកសុំអ្នកភូមិអោយដីមួយចំនួនរបស់ពួកគេ ទៅជនមាតុភូមិនិវត្តន៍ អ្នកភូមិនិយាយថា ចាស់/បាទ ព្រោះគ្នាគិតថា មិនអាចឆ្លើយថាទេជាមួយស្រុកបានទេ ព្រោះពួកគេខ្លាច (អនុប្រធានភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ជនមាតុភូមិនិវត្តន៍មានទំនាក់ទំនងជាមួយឃុំ និងថ្នាក់លើច្រើនជាងអ្នកភូមិចាស់ ហើយមានភាពជិតដិតជាមួយមេឃុំជាងមេភូមិ ។ នេះឆ្លុះបញ្ចាំងអោយឃើញថា មេភូមិមិនដែលមានការចាប់អារម្មណ៍ណាមួយចំពោះជនមាតុភូមិនិវត្តន៍ទេ ប៉ុន្តែមេឃុំថ្មីមានការព្រួយបារម្ភយ៉ាងខ្លាំង ហើយខិតខំរកដីស្រែអោយពួកគេ ប៉ុន្តែគាត់មិនសូវមានការអាណិតអ្នកភូមិចាស់ដែលបានលក់ដីស្រែរបស់ពួកគេបានទទួលនៅឆ្នាំ១៩៨០នោះទេ ។ ទោះជាយ៉ាងនេះក្តី ជនមាតុភូមិនិវត្តន៍អន់ចិត្តជាមួយថ្នាក់លើ ព្រោះគេសន្យាថា អោយដីស្រែ ប៉ុន្តែមិនទាន់បាននៅឡើយទេ ។

មេភូមិមានការជិតដិតជាមួយមេឃុំព្រោះឧស្សាហ៍ឃើញគ្នានៅពេលប្រជុំថ្នាក់ឃុំ និងភូមិ ។ ក្នុងការទាក់ទងជាមួយរដ្ឋអំណាចថ្នាក់លើ មេភូមិស្មោះត្រង់ និងជាអ្នកមានភារកិច្ច ប៉ុន្តែគាត់មិនសូវចេះអក្សរ ឬមាត់ករទេ ។

*ខ្ញុំនៅក្រោមរដ្ឋអំណាចថ្នាក់លើ ខ្ញុំទៅទទួលផែនការនៅឃុំ ។ គោកដូង គឺជាតំបន់មួយនៅដាច់ស្រយាលពីគេ ហេតុនេះហើយបានជាគ្មានអ្នកណាចង់ឈរឈ្មោះបោះឆ្នោតឃុំទេ ។ ខ្ញុំឧស្សាហ៍ជួបអភិបាលចាស់ អ៊ុង សាមី ។ គាត់ចុះមកឃុំ ឬស្រុក មើលអ្នកភូមិលើកថ្នល់ជាដើម ឬមកចែកអំណោយអោយជនរងគ្រោះ ។ ឥឡូវនេះគាត់នៅខេត្តពោធិសាត់ ។ ខ្ញុំភ្លេចឈ្មោះអភិបាលថ្មី ហើយគាត់មកពីខេត្តសៀមរាប គាត់មិនដែលមក (ភូមិ) ទេ អត់មានអំណោយអោយជនរងគ្រោះទេ (មេភូមិ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

មេឃុំនៅក្មេង និងប្រឹងប្រែងធ្វើការងារ ។ គាត់ចង់អោយអ្នកភូមិដឹងពីសិទ្ធិរបស់ពួកគេ និងឃើញវាជាតួនាទីរបស់ឃុំ ដើម្បីលើកកំពស់ជីវភាពរបស់គេ ។ ប៉ុន្តែគាត់ឧស្សាហ៍គិតថាគាត់គ្មានអំណាច ចំពោះរដ្ឋអំណាចថ្នាក់លើទេ ។

*ឥឡូវនេះ មេឃុំមិនមានសិទ្ធិធ្វើអ្វីនោះទេ យើងនៅក្រោមថ្នាក់ស្រុក ។ ឃុំគ្មានវិធីទាក់ទងជាមួយរដ្ឋាភិបាលទេ ។ មូលហេតុទីមួយ គឺឃុំគ្មានលុយ មូលហេតុទីពីរ គឺគេមិនដែលទាក់ទងជាមួយរដ្ឋាភិបាល ។ ខ្ញុំខ្លាចថ្នាក់លើមិនយកចិត្តទុកដាក់ ព្រោះខ្ញុំគ្រាន់តែជាអ្នកថ្នាក់ក្រោម គេកម្រយកចិត្តទុកដាក់ជាមួយយើងណាស់ (មេឃុំខែវិច្ឆិកា ឆ្នាំ១៩៩៩ និងខែកុម្ភះ ឆ្នាំ២០០០) ។*

### *ថ្នាក់ឃុំ និងថ្នាក់លើចុះទៅភូមិ*

*ជ្រែង: នៅពេលគេមកទារពន្ធ គេក៏មកហូបបាយដែរ*

- អ្នកភូមិមិនដឹងជាមុនថា នៅពេលណាខាងរដ្ឋអំណាចនឹងមកជួបពួកគេ ។

- នៅពេលដែលខាងរដ្ឋអំណាចចុះមក ជាទូទៅអ្នកភូមិមិនដឹងច្បាស់ថា ពួកនោះជាអ្នកណាទេ ប៉ុន្តែអ្នកភូមិតែងតែធ្វើតាមបញ្ជាថ្នាក់លើ ហើយបង់ពន្ធ និងជាស៊ីដែលថ្នាក់លើទាមទារអោយបង់ ។

ក្រៅពីមេឃុំ និងមេស្រុកដែលអ្នកភូមិបានឃើញនៅពេលប្រជុំពិភាក្សាផ្លូវផ្ទាល់ អ្នកផ្សេងទៀតដែលមកពីថ្នាក់លើជួនកាលក៏មកភូមិដែរដែរ ។ នាយកសាលាអាចទទួលមន្ត្រីផ្នែកអប់រំជាច្រើនផ្សេងទៀតនៅផ្ទះរបស់គាត់ ប៉ុន្តែជីវពលឧស្សាហ៍មានភ្ញៀវដែលជាអ្នកមកពីឃុំ និងស្រុក មកស៊ីផឹកនៅផ្ទះរបស់គាត់ ។

អ្នកដែលមកពីរដ្ឋអំណាចថ្នាក់លើក៏ចុះមកមើលអ្នកភូមិដែរ ។ អ្នកភូមិកម្រដឹងជាមុនថា ពួកគេមកនៅពេលណា ប៉ុន្តែនៅពេលដែលថ្នាក់លើនាំយកការងារណាមួយមក អ្នកភូមិត្រូវតែប្រញាប់ចូលរួមការងារនោះ ឬបង់ថ្លៃដែលថ្នាក់លើសុំអោយបង់ ឬគេចខ្លួនបាត់ ។

បុគ្គលិកពេទ្យស្រុក ជួនកាលចុះមកចែក និងចាក់ថ្នាំអោយកុមារ ។ ពួកគេធ្វើការនៅផ្ទះជីវពលភូមិ ហើយគាត់ជាអ្នកប្រាប់អ្នកភូមិ ។ ថ្ងៃមួយបុរសវ័យក្មេងម្នាក់មានការធូរស្រាលដោយសារប្រពន្ធគាត់នៅផ្ទះចំពេលដែលគេចុះមកធ្វើការ ។

> *ហ៊ីន ទើបតែជិះកង់គាត់នេះហើយស្រែកថា "បើចង់យកកូនទៅចាក់ថ្នាំ ទៅឥឡូវនេះភ្លាម!" ប្រពន្ធរបស់ខ្ញុំក៏ប្រញាប់យកកូនទៅ (បុរសម្នាក់ ខែមិនា ឆ្នាំ២០០០) ។*

ថ្ងៃមួយទៀត អ្នកភូមិអន់ចិត្តយ៉ាងខ្លាំងជាមួយអ្នកដែលមកពីខាងស្រុកអោយពួកគេបង់ ១០.០០០រៀល ដើម្បីធ្វើប័ណ្ណគ្រួសារ ។ ប្រជាជនមិនដឹងច្បាស់ថា ប័ណ្ណទាំងនេះសំរាប់ធ្វើអ្វីទេ ប៉ុន្តែគ្មានអ្នកណាហ៊ានថា មិនធ្វើនោះទេ ។ អ្នកភូមិម្នាក់បានឃើញតាមទូរទស្សន៍ថា ប័ណ្ណមួយថ្លៃតែ ៦.០០០រៀលប៉ុណ្ណោះ ប៉ុន្តែគ្មានអ្នកណាតវ៉ា ឬរអ៊ូឡើយ ។ អ្នកភូមិត្រូវគេបញ្ចុះបញ្ចូលថា ប្រសិនបើពួកគេរង់ចាំ តំលៃនឹងកើនឡើង ។ ដូច្នេះអ្នកណាដែលមានលទ្ធភាពគួរប្រញាប់ប្រញាល់យកលុយទៅបង់អោយទាន់ពេល អ្នកខ្លះខ្ចីលុយគេ អ្នកផ្សេងទៀតប្រើលុយដែលបំរុងទុកសំរាប់ទិញជី ។

> *នៅឆ្នាំ១៩៨៤ យើងធ្វើប័ណ្ណគ្រួសារម្តង ព្រោះរដ្ឋអំណាចត្រូវការចាប់ទាហាន ។ បើគ្រួសារណាព្យាយាមលាក់កូន រដ្ឋអំណាចដឹង គេនឹងរឹបអូសយកដីស្រែ ។ (ឥឡូវនេះ) អ្នកភូមិប្រឹងរកលុយដើម្បីធ្វើប័ណ្ណគ្រួសារនេះ ទោះជាខ្ចីលុយគេក៏ដោយ ។ បើគេមិនបង់ថ្លៃប័ណ្ណគ្រួសារឥឡូវនេះទេ លើកក្រោយថ្លៃជាងនេះ ហើយបើអ្នកមកពីស្រុកចុះមកគេនឹងយកប្រហែល ១៥.០០០រៀល ។ លើកក្រោយទៀត អ្នកភូមិត្រូវទៅធ្វើនៅឃុំតំលៃ ២៥.០០០រៀល ហើយលើកក្រោយៗអាចច្រើនជាងនេះទៀត (សមាជិក គ.អ.ភ ម្នាក់ស្រី ខែមិថុនា ឆ្នាំ១៩៩៩) ។*

> *ប្រសិនជាអ្នកគ្មានប័ណ្ណទេ គេមិនអោយអ្នកនៅក្នុងក្រុម ភូមិ ឬឃុំទេ ។ អ្នកទាំងនោះនឹងនៅក្រៅសង្គម ។ ជាមួយអភិបាលចាស់ យើងធ្វើប័ណ្ណគ្រួសារមួយហើយ ។ ជាមួយអភិបាលថ្មី យើងធ្វើប័ណ្ណថ្មីទៀត ។ ជាមួយអភិបាលលើកក្រោយ យើងប្រហែលធ្វើប័ណ្ណថ្មីទៀតហើយ (អ្នកភូមិមួយក្រុមតូច ស្ត្រី/បុរស ខែតុលា ឆ្នាំ១៩៩៩) ។*

គេក៏ចុះមកទារពន្ធ និងថ្លៃអាជីវកម្មផ្សេងៗ ។ ម្ចាស់រោងវីដេអូពីរនាក់ បានបង់ពន្ធដូចម្ចាស់ម៉ាស៊ីនកិនស្រូវ និងអ្នកបិតស្រាដែរ ។ អ្នកភូមិហាក់ដូចជាមិនបានយល់ដឹងពីគោលបំណងនៃការទារពន្ធនេះទេ ។ អ្នកភូមិភាគច្រើនមិនដឹងច្បាស់ថា អ្នកទារពន្ធជាអ្នកណានោះទេ ហើយតំលៃ និងច្បាប់ហាក់ដូចជា មានការខុសគ្នា និងប្រែប្រួល ។

អ្នកភូមិនិយាយថា ម្ចាស់ម៉ាស៊ីនស្រូវបង់ ៨.០០០រៀល (២ដុល្លារ) ក្នុងមួយខែ ប៉ុន្តែថ្លៃធ្វើច្បាប់អាជីវកម្មដំបូង គឺ ១៥០ដុល្លារសំរាប់ម៉ាស៊ីនធំ ហើយ ២០ម៉ឺន (៥៣ដុល្លារ) សំរាប់ម៉ាស៊ីនតូច ។ អ្នកភូមិអន្ទះសារចង់ប្រាប់ក្រុមសិក្សាពីរបៀបដែលអ្នក "មកពីក្រសួង" មកទារពន្ធថ្លៃម៉ាស៊ីនស្រូវ ។

> *មានពេលមួយក្រុមសិក្សា បានឃើញមនុស្ស៧នាក់ជិះម៉ូតូមក ។ គេមកតាំងពីម៉ោង ៧ព្រឹករហូតដល់ម៉ោង ៦ល្ងាច! គេទៅផ្ទះម្ចាស់ម៉ាស៊ីនស្រូវពីមួយទៅមួយទៀត ។ គេដឹងថាអ្នកណាខ្លះមានម៉ាស៊ីនកិនស្រូវ ព្រោះគេអាចឮសំលេង ។ ប៉ុន្តែទោះគ្មានស្រូវកិនក៏ដោយ គេត្រូវតែបង់ដែរ ។ អ្នកភូមិរត់ពួន! (អ្នកភូមិមួយក្រុមតូច ស្ត្រី/បុរស ខែតុលា ឆ្នាំ១៩៩៨) ។*

អ្នកផ្សេងទៀត មកទារពន្ធពីអ្នកបិតស្រា ។ អ្នកភូមិនិយាយថា តំលៃមានចាប់ពី ១៥.០០០ ទៅ ២៥.០០០រៀល (៤-៦.៥ដុល្លារ) ក្នុងមួយខែ ប៉ុន្តែមន្ត្រីមកពីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និយាយពីពន្ធសំរាប់អាជីវកម្មខ្នាតតូច គឺ ៥ពាន់-៦ពាន់រៀល (១.៣-១.៦ដុល្លារ) ក្នុងមួយខែ ។

ថ្ងៃមួយ នៅពេលដែលមនុស្សបីនាក់មកទារពន្ធថ្លៃបិតស្រា អ្នកបិតស្រាម្នាក់ក្នុងចំណោមអ្នកបិតស្រាធំៗ អត់នៅផ្ទះ ហើយនៅថ្ងៃបន្ទាប់មកទៀត គាត់មិនដឹងថា គេមកទីនេះទេ ។ ស្ត្រីម្នាក់នេះខំរកស៊ីតាំងពីក្រហូតដល់មានជីវភាពធូរធារដោយសារការចិញ្ចឹមជ្រូក និងបិតស្រា ។ គាត់ពឹងផ្អែកទាំងស្រុងលើប្រាក់ចំណូលទាំងនេះ ប៉ុន្តែគាត់ហាក់ដូចជាយល់ស្របក្នុងការបង់ពន្ធ និងធ្វើតាមច្បាប់ដែលណែនាំ ។

> *កាលមុនពន្ធថ្លៃ ១៥.០០០ពាន់រៀល (៤ដុល្លារ) ក្នុងមួយឆ្នាំ ។ ឥឡូវនេះ ១៥.០០០ពាន់រៀលក្នុងមួយខែ ។ ឃុំមកយកពន្ធរាល់ខែ ។ ប្រហែលជាគេមកពីខេត្ត... ឬមកពីស្រុក... ខ្ញុំមិនដឹងថាអ្នកដែលមកទារពន្ធនោះជាអ្នកណាទេ ។ ចាប់តាំងពីខែសីហាឆ្នាំនេះ កាលមួយខែមុន គេមកហ្នឹងដែរ អញ្ចឹងជិតដល់ថ្ងៃគេមកទៀត ហើយខ្ញុំនឹងបង់ ១៥.០០០រៀល ។ កាលពីខែច្រូត គេចុះមកប្រាប់អ្នកភូមិមិនអោយបិតស្រា ។ គេនិយាយថា គេនឹងមកមើល ហើយផាក ៣០ម៉ឺនរៀល (៨០ដុល្លារ) បើសិនជាអ្នកណានៅតែបិតស្រា ។ ខ្ញុំគ្មានលុយអោយគេផាកទេ អញ្ចឹងខ្ញុំឈប់ អ្នកផ្សេងក៏ឈប់គ្រប់គ្នា ។ ប៉ុន្តែបានតែមួយអាទិត្យ ឬជាងមួយអាទិត្យប៉ុណ្ណោះ បន្ទាប់មកគេប្តូរចិត្ត ហើយទារពន្ធជំនួសវិញ ។ គេត្រឡប់មកប្រាប់ថា "បិតចុះតែត្រូវបង់ពន្ធ" ។ នៅខេត្តពោធិសាត់ មានកុងស៊ីបិតស្រា ។ គេលក់មិនសូវដាច់ទេ ព្រោះស្រានោះមិនសូវល្អ ។ ស្រាធ្វើនៅភូមិល្អជាង ។ គ្មានអ្នកណាទិញស្រាពីកុងស៊ីនោះទេ ។ អញ្ចឹងគេអោយអ្នកភូមិបិតស្រាវិញ (ស្ត្រី ខែតុលា ឆ្នាំ១៩៩៨) ។*

ប្រាំខែក្រោយមកស្ត្រីម្នាក់នេះក៏បង់ច្បាប់អនុញ្ញាតធ្វើអាជីវកម្ម ។ មន្ត្រីម្នាក់ដែលមកពីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល បានប្រាប់យើងថា ម្ចាស់ម៉ាស៊ីនស្រូវ និងអ្នកបិតស្រាត្រូវបង់ ១៨ម៉ឺន (៥០ដុល្លារ) អោយមន្ទីរខេត្ត

បន្ទាប់មក គេនឹងរត់ការអោយឃុំ ស្រុក និងខេត្តចុះហត្ថលេខា ។ រៀងរាល់ឆ្នាំ គេត្រូវបង់ ៨០.០០០រៀល ដើម្បីធ្វើច្បាប់អាជីវកម្មថ្មី ។ ស្ត្រីម្នាក់នេះមិនដឹងច្បាស់ពីតំលៃ និងច្បាប់ទាំងនេះទេ ។

*គេមកហ្នឹងកាលពីពីរបីថ្ងៃមុន ហើយបានប្រាប់ខ្ញុំថា ខ្ញុំត្រូវការធ្វើច្បាប់បិតស្រា ។ ខ្ញុំមិនដឹងថា គេមកពីឃុំ ឬស្រុកទេ ។ គេមកពីរដងហើយថ្មីៗនេះ ប៉ុន្តែខ្ញុំបានជួបគេតែម្តងទេ ។ ខ្ញុំមិនបានបង់ទេ ព្រោះខ្ញុំគ្មានលុយ ។ ដូច្នេះគេអាចរករឿងខ្ញុំ! ខ្ញុំចាំមើល ។ ប្រហែលជាគេត្រឡប់មកវិញ អោយខ្ញុំធ្វើច្បាប់ ។ គេនិយាយថា ខ្ញុំត្រូវបង់ ១៨ម៉ឺនរៀល ។ អ៊ីៗក៏លុយដែរ! ខ្ញុំមិនដឹងថា ខ្ញុំត្រូវបង់រាល់ឆ្នាំ ឬបង់តែម្តងនោះទេ ។ ខ្ញុំធ្វើតាមតែគេប្រាប់(ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

នៅក្នុងភូមិ មានមនុស្សមួយចំនួនតូច ដែលមានការចេះដឹង និងមានជីវភាពធូរធារ មិនបានគោរពដូចស្ត្រីនេះទេ ។ អ្នកដែលមានការយល់ដឹងច្រើនជាងបំផុតនៅក្នុងភូមិដែលជាអ្នកបិតស្រាចំដែរនោះ មានការយល់ដឹងច្បាស់ពីច្បាប់ទាំងនោះ ។ ប៉ុន្តែគាត់នៅតែរារែកក្នុងការបង់ប្រាក់ដើម្បីធ្វើច្បាប់អាជីវកម្ម និងមិនដូចអ្នកភូមិជាច្រើននោះទេ គាត់ចង់ដឹងអោយបានច្បាស់សិន មុននឹងគាត់ធ្វើតាមអ្នកខេត្តអោយគាត់ធ្វើ ។ អ្នកដែលមានជីវភាពធូរធារជាងគេបំផុតនៅក្នុងភូមិដែលដឹកនាំអ្នកបិតស្រា និងម្ចាស់ម៉ាស៊ីនកិនស្រូវបានឮថា អ្នកអាចបង់តិចជាងនេះអោយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែអ្នកត្រូវរត់ការរឿងចុះហត្ថលេខាដោយខ្លួនឯង ដែលអ្នកត្រូវការចំណាយលុយ និងការទាក់ទង ។

*នៅថ្ងៃទី០៩ ខែមិនា មានបញ្ហាថ្មីៗពីរឿងបិតស្រា ។ ឥឡូវគេចង់អោយអ្នកភូមិធ្វើច្បាប់អាជីវកម្មបិតស្រា ។ យើងនឹងបង់ ១៨ម៉ឺនរៀងរាល់ឆ្នាំ ។ ខ្ញុំមិយាយថាទេ ប៉ុន្តែគេនឹងត្រលប់មកម្តងទៀតនៅថ្ងៃទី១៦ ហើយខ្ញុំត្រូវតែបង់ ។ គេមកពីខេត្ត អ្នកទាំងនោះហើយដែលជាអ្នកធ្វើច្បាប់សំរាប់ការរកស៊ី ។ ខ្ញុំនៅតែមិនទាន់ច្បាស់ ខ្ញុំចាំសួរអ្នកបិតស្រាឯទៀតៗដែលរស់នៅជិតទីរួមខេត្ត ថាតើគេបង់ថ្លៃធ្វើច្បាប់អាជីវកម្ម ឬអត់ ។ បើសិនគេបង់ ខ្ញុំនឹងបង់ដែរ ។ ប៉ុន្តែខ្ញុំខ្លាចគេយកលុយទុកខ្លួនគេ ហើយមិនបង់អោយរដ្ឋ ។ ខ្ញុំបង់ ២០.០០០រៀលរួចហើយក្នុងមួយខែៗ ប៉ុន្តែអ្នកដែលមក ខុសពីអ្នកដែលមកពីការិយាល័យពន្ធដាខេត្ត(បុរសម្នាក់ ខែមិនា ឆ្នាំ២០០០) ។*

*អ្នកអាចបង់ ១៨ម៉ឺនរៀល អោយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល នោះអ្នកនឹងបានច្បាប់ពីគេ ឬអ្នកអាចបង់តែ ៨០.០០០រៀល ប៉ុន្តែអ្នកត្រូវយកទៅអោយអភិបាលស្រុក និងខេត្តចុះហត្ថលេខាដោយខ្លួនឯង ។ យើងមិនអាចធ្វើអញ្ចឹងបានទេ ព្រោះយើងមិនស្គាល់អ្នកណានៅទីនោះ (ប្តីប្រពន្ធ ខែមិនា ឆ្នាំ២០០០) ។*

យើងក៏បានជួបម្ចាស់ម៉ាស៊ីនកិនស្រូវម្នាក់ដែលនិយាយថា គាត់មិនដែលបង់ពន្ធទេ ព្រោះមេឃុំអោយជីវពលមើលការខុសត្រូវ ។ ប៉ុន្តែមេឃុំបញ្ជាក់ថា ឃុំមិនបានទទួលផលប្រយោជន៍ពីការយកពន្ធ ឬច្បាប់អាជីវកម្មទេ ក្រៅពីថ្លៃចុះហត្ថលេខារបស់គាត់ ។

*អ្នកចាំបាច់ត្រូវមានច្បាប់អនុញ្ញាតដើម្បីមានម៉ាស៊ីនកិនស្រូវ ហើយអ្នកត្រូវបង់លុយ ដើម្បីបានច្បាប់អនុញ្ញាត ។ បន្ទាប់មក អ្នកក៏ត្រូវបង់ពន្ធអោយបានទៀងទាត់ដែរ ។ ប៉ុន្តែខ្ញុំមិនដែលបង់ពន្ធទេ ។*

*ខ្ញុំអោយតែលុយខ្លះទៅនគរបាលភូមិ ហ៊ន (ជីវពល) បានចាត់ទៅហើយ ។ ឃុំ និងនគរបាលភូមិចែកសិទ្ធគ្នាក្នុងការយកពន្ធ ។ ឧទាហរណ៍បើឃុំយកពន្ធពីម៉ាស៊ីនស្រូវទាំង៨ ក្នុងនោះឃុំផ្តល់សិទ្ធអោយ ហ៊ន យក២ ។ ខ្ញុំអោយលុយទៅ ហ៊ន តិចជាង បើខ្ញុំបង់អោយឃុំ ។ អ្នកយកពន្ធដែលមកយកពន្ធពីម្ចាស់ម៉ាស៊ីនស្រូវផ្សេងទៀតមកហូបចាយថ្ងៃត្រង់ ឬល្ងាច គេកាប់មាន់ហូប (បុរសម្នាក់ ខែកុម្ភៈ ឆ្នាំ២០០០) ។*

*ប្រជាជនបង់ពន្ធថ្លៃម៉ាស៊ីនស្រូវ និងបិតស្រាអោយមន្ទីរពន្ធដាខេត្ត ។ ប៉ុន្តែឃុំអត់បានអីទេ ។ ប្រជាជនបានច្បាប់បើកអាជីវកម្មនោះ ជាការទទួលខុសត្រូវរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ។ គេចុះមកភូមិដើម្បីអោយដឹងថា កន្លែងណាខ្លះមានម៉ាស៊ីនស្រូវ ហើយអ្នកណាជាម្ចាស់ម៉ាស៊ីនស្រូវទាំងអស់នេះ ។ បន្ទាប់មក គេអោយក្រដាសទៅម្ចាស់ម៉ាស៊ីនស្រូវ យកទៅអោយមេឃុំ និងអភិបាលស្រុកចុះហត្ថលេខា ។ អ្នកភូមិទៅឃុំ ហើយបង់ពី ៥.០០០ ទៅ ១០.០០០រៀលថ្លៃហត្ថលេខា រួចទៅស្រុក និងបង់ថ្លៃហត្ថលេខា បន្ទាប់មកទៅខេត្ត ហើយបង់ថ្លៃហត្ថលេខាទៀត ។ ក្នុងអំឡុងរដ្ឋកម្ពុជា ឃុំទារយកស្រូវទៅអោយទាហាន និងពលករ ។ ប៉ុន្តែឥឡូវនេះឃុំមិនពាក់ព័ន្ធក្នុងការយកអង្ករពីម្ចាស់ម៉ាស៊ីនកិនស្រូវទេ (មេឃុំ ខែមិនា ឆ្នាំ២០០០) ។*

*គោកដូង: ជាស៊ីប្រចាំថ្ងៃដែលត្រូវបង់អោយអ្នកធំ*

- អ្នកភូមិបង់ថ្លៃប័ណ្ណគ្រួសារ ដូចនៅភូមិជ្រែងដែរ ទោះជាគេមិនដឹងច្បាស់ថា ធ្វើប័ណ្ណទាំងនេះដើម្បីអ្វី ហើយទោះជាគេគិតថា គេនឹងបង់លុយដើម្បីធ្វើប័ណ្ណថ្មីក៏ដោយ ។
- ម្ចាស់តៀមបង់ជាស៊ីប្រចាំថ្ងៃ ហើយមេឃុំថា គាត់មិនឱ្យម្ចាស់តៀមបង់ទេ តែគាត់មិនអាចជួយបាន ។

នៅភូមិគោកដូង មន្ត្រីថ្នាក់លើពីរនាក់មានទីលំនៅក្នុងភូមិ ម្នាក់គឺជាប្រធានយោធាស្រុក ម្នាក់ទៀតជានគរបាលខេត្ត ។ ប៉ុន្តែដូចដែលបានជំរាបជូនហើយថា មេឃុំឧស្សាហ៍មកជួបមេភូមិ រឺប្រធានគ.អ.ភ មន្ត្រីផ្សេងទៀតមិនសូវបានចុះមកទេ ។ បុគ្គលិកពេទ្យស្រុកដែលចុះមកចែកថ្នាំ និងចាក់ថ្នាំបង្ការអោយកុមារ និងនគរបាលដែលមកចេញប័ណ្ណគ្រួសារ និងយកថ្លៃផ្សេងៗក្រៅផ្លូវការ ។

អ្នកភូមិរាយការណ៍ខុសៗគ្នាពីសៀវភៅ និងប័ណ្ណគ្រួសារ ។ គេបានទទួលសៀវភៅគ្រួសារ និងប័ណ្ណទាំងនោះនៅពេលខុសៗគ្នា និងបង់ថ្លៃខុសៗគ្នាដែរ ។ ជាទូទៅជនមាតុភូមិនិវត្តន៍បង់តិចជាងអ្នកភូមិចាស់ឆ្ងាយណាស់ ។ ដូចនៅភូមិជ្រែងដែរ បើមិនរួសរាន់ធ្វើ ត់លៃក៏កាន់តែកើនឡើង ហើយអ្នកភូមិក៏គិតថា រដ្ឋអំណាចនឹងណែនាំអោយធ្វើប័ណ្ណថ្មីដែរ ។ ប្រជាជននឹងមិនច្បាស់ទេថា ធ្វើប័ណ្ណនេះដើម្បីអ្វី ប៉ុន្តែគ្មានអ្នកណាហ៊ានតវ៉ានោះទេ ។ អ្នកដែលអត់មានដីស្រែជាច្រើនគ្រួសារមានអារម្មណ៍ថា ត្រូវបានគេបោកប្រាស់ ព្រោះគេទទួលបាននូវការចាប់អារម្មណ៍ថា ពេលណាគេមានប័ណ្ណ គេនឹងបានទទួលដីស្រែ ។

*នគរបាលឃុំចុះមក ហៀន និង គង់ (មេភូមិ និងអនុប្រធាន) បានហៅប្រជាជនអោយទៅកន្លែងប្រជុំ ហើយគេបានប្រាប់អ្នកភូមិថា ត្រូវតែមានប័ណ្ណ ។ ខ្ញុំមិនដឹងថា ប័ណ្ណនេះសំរាប់អីទេ ។ ប៉ុន្តែយើងត្រូវតែមានទាំងពីរសៀវភៅគ្រួសារ និងប័ណ្ណពណ៌លឿង ។ នៅពេលនោះ ខ្ញុំបានលុយពីការត្បាញកន្ទេល ។ យើងធ្វើអ្វីតាមតែគេអោយ យើងធ្វើចេះតែទុកទៅ (ឯកសារទាំងនេះ) ព្រោះយើងនៅក្រោម*

*អំណាចគេ ។ អ្នកដែលមិនអាចបង់នៅលើកទីមួយ ពេលក្រោយនឹងបង់ច្រើនជាងនេះប្រហែលមួយជាពីរ ។ អ្នកខ្លះនៅមិនទាន់មានប័ណ្ណគ្រួសារទេ ។ គេនិយាយថា អ្នកដែលមានសៀវភៅគ្រួសារ នឹងបានដីស្រែ ប៉ុន្តែយើងមិនទាន់បានអ្វីទាំងអស់ (ប្តីប្រពន្ធ ជនមាតុភូមិនិវត្តន៍ ខែមករា ឆ្នាំ២០០០) ។*

*ខ្ញុំបានប័ណ្ណនេះ តាំងពីមុនបោះឆ្នោត១៩៩៨ ពីគង់ (អនុប្រធានភូមិ) ដោយមិនអស់លុយ ព្រោះខ្ញុំក្រ ។ បើអ្នកអត់មានឯកសារគ្រួសារទេ អ្នកនឹងមិនអាចមានឱកាសបានទទួលដីស្រែទេ (ជនមាតុភូមិនិវត្តន៍ ស្ត្រី ខែមករា ឆ្នាំ២០០០) ។*

*នគរបាលឃុំដើរពីផ្ទះមួយទៅផ្ទះមួយ ហើយឡើងថ្លៃ ។ ខ្ញុំបង់ ៨ពាន់ថ្លៃប័ណ្ណគ្រួសារមួយ កាលមុនថ្លៃតែ ៥.០០០រៀលទេ សំរាប់អ្នកដែលបង់ភ្លាមៗ ។ ខ្ញុំមិនដឹងថាគេធ្វើប័ណ្ណគ្រួសារធ្វើអីទេ ។ ប៉ុន្តែអ្វីដែលមេភូមអោយអ្នកភូមិធ្វើ អ្នកភូមិត្រូវតែធ្វើតាម ព្រោះឃុំ ឬស្រុកប្រាប់មេភូមិ (ស្ត្រី ខែមករា ឆ្នាំ២០០០) ។*

*គោលបំណងនៃការធ្វើសៀវភៅគ្រួសារ និងប័ណ្ណពណ៌លឿងគឺចង់ដឹងថា មានគ្នាប៉ុន្មាននាក់នៅក្នុងគ្រួសារ ហើយនៅពេលកូនរៀបការ អ្នកយកប័ណ្ណនេះទៅបង្ហាញមេភូមិ និងមេឃុំ ។ នៅពេលដែលខ្ញុំបានសៀវភៅ និងប័ណ្ណនេះ គេប្រាប់ខ្ញុំថាអាចប្រើការបានរយៈពេល១០ឆ្នាំប៉ុន្តែខ្ញុំគិតថា ប្រើបានតែពីរ ឬបីឆ្នាំប៉ុណ្ណោះ នឹងដូរដូចអាចាស់ទៀតហើយ (បុរស ខែមករា ឆ្នាំ២០០០) ។*

នៅភូមិគោកដូង មានតែម្ចាស់រ៉ឺម៉កអូទេ ដែលបង់ពន្ធទៀងទាត់ ។ ប៉ុន្តែម្ចាស់តៀមជាច្រើនបង់ផាសុីប្រចាំថ្ងៃអោយអ្នកម៉ៅការផ្សារនៅឃុំដែលមកទារ ឬអោយគ្នាគេពីរនាក់ចុះមកទារ ជួនកាលមកទាររាល់ថ្ងៃ ជួនកាលមួយអាទិត្យមកទារម្តង ។ អ្នកណាក៏ដឹងពីរឿងនេះដែរ ជាទូទៅគ្មានអ្នកណាជំទាស់ទេ ។

*ម្ចាស់តៀមបង់ ១០០រៀលក្នុងមួយថ្ងៃ ។ វាជាផាសុីប្រចាំថ្ងៃអោយអ្នកជំ ។ កាលពីដើមមានតែអ្នកលក់នៅផ្សារទេ ទើបបង់ (ស្ត្រីមួយក្រុមតូច ខែមករា ឆ្នាំ២០០០) ។*

ដោយសារនៅភូមិគោកដូង ជាកន្លែងលេងល្បែង ដូច្នេះអ្នកដែលធ្វើការនៅស្រុក ក៏បានមកយកសំណូកពីអ្នកលេងល្បែងដែរ ។

*អ្នកភូមិដែលបង្កើតកន្លែងលេងល្បែងបង់ ១០.០០០រៀលអោយនគរបាលរាល់ឆ្នាំ ។ នគរបាលយកតាំងពីមាន់ ឬរបស់របរផ្សេងៗទៀត ឬប្រហែលជា ៥.០០០រៀលពីអ្នកលេងល្បែង (បុរស ខែមករា ឆ្នាំ២០០០) ។*

ទាំងប្រាក់បង់ថ្លៃតៀម និងការលេងល្បែង គឺជាបញ្ហាដែលមេឃុំនិយាយថា គាត់ចង់ធ្វើអ្វីមួយចំពោះរឿងនេះ ប៉ុន្តែគាត់និយាយថា ឃុំមិនអាចធ្វើអ្វីបានទេ ព្រោះមានថ្នាក់លើនៅពីក្រោយ ។

*អ្នកម៉ៅការផ្សារបានទិញ ជួល ផ្សារពីស្រុក ។ គេបង់ ៥លានរៀល (១.៣០០ដុល្លារ) ក្នុងមួយឆ្នាំ ។ ប៉ុន្តែ ឃុំមិនដែលបានទេ... ទើបតែពីរឆ្នាំនេះទេ ស្រុកអោយ ៥០០.០០០រៀល ។ អ្នកម៉ៅការ*

*ផ្សារ មិនគួរយកជាស៊ីពីម្ចាស់តៀមទេ ។ វាមិនត្រូវច្បាប់ ។ ខ្ញុំបានហៅអ្នកម៉ៅការផ្សារ ហើយប្រាប់គាត់ថា គាត់មិនគួរយកជាស៊ីទេ ។ ប៉ុន្តែគាត់មិនស្តាប់ ។ ខ្ញុំប្រាប់អ្នកភូមិថា "បើគេមកទារ ២០០រៀល អោយគេតែ ១០០រៀលបានហើយ" ។ ប្រសិនវាក្លាយជាការទទួលខុសត្រូវរបស់ឃុំ យើងនឹងចុះថ្លៃនៅត្រឹម ៤លាន ព្រោះអ្នកភូមិពិបាករកលុយបង់ ។ ប៉ុន្តែឥឡូវ ខ្ញុំមិនអាចធ្វើអីបានទេ ព្រោះឃុំនៅក្រោមស្រុក ហើយស្រុកគាំទ្រអ្នកម៉ៅការផ្សារ ។ គេមិនគួរស្រលាញ់លុយជាងប្រជាជនទេ ។ ខ្ញុំមិនចង់អោយអ្នកភូមិលេងល្បែងទេ ។ ប៉ុន្តែខ្ញុំមិនអាចធ្វើអីបាន ខ្ញុំមិនអាចបញ្ឈប់វាបាន ។ មានតែនៅពេលដែលខ្ញុំមានប្រជុំ ខ្ញុំអោយប្រជាជនឈប់ ឬកាត់បន្ថយការលេងល្បែង ។ នេះមិនមែនជាកំហុសរបស់ខ្ញុំទេ ។ វាជាកំហុសពីថ្នាក់លើ វាចាប់ផ្តើមតាំងពីខេត្តមកម្លេះ ។ នៅតាមផ្សារ មានចាក់គន្លុយលេខ ហើយមេគន្លុយលេខប្រើវិទ្យុទាក់ទងប្រាប់ពីលទ្ធផល ។ ក្នុងអំឡុងឆ្នាំ១៩៨០ មន្ត្រីអាចលួចចាំន់ជាដើម ។ ឥឡូវប្រជាជនដឹងពីសិទ្ធិរបស់គេ គេមិនអោយអ្នកណាលួចរបស់គេទៀតទេ ។ ប៉ុន្តែនៅពេលដែលនគរបាល ឬអ្នកមកពីថ្នាក់លើចុះមកចាប់អ្នកលេងល្បែង ប្រជាជននិយាយថា "សូមយកអានេះទៅ" (មេឃុំ ខែកុម្ភះ ឆ្នាំ២០០០) ។*

## *អ្នកភូមិទៅជួបថ្នាក់ឃុំ និងថ្នាក់លើ*

*ជ្រែង: ទៅតាមខ្សែបណ្តោយ*

- អ្នកភូមិដឹងថា ពួកគេមិនអាចរំលងមេភូមិ ដើម្បីទៅជួបថ្នាក់លើតែម្តងបានទេ ។
- មូលហេតុសំខាន់ដែលអ្នកភូមិទៅជួបអាជ្ញាធរថ្នាក់លើ គឺការដោះស្រាយជម្លោះ ប៉ុន្តែត្រូវចំណាយលុយច្រើន ។ ដូច្នេះអ្នកភូមិភាគច្រើនលែងចង់ទៅរកអាជ្ញាធរទាំងនោះអោយជួយទៀតហើយ ។
- អ្នកបិតស្រានៅក្នុងភូមិបានទទួលជោគជ័យក្នុងការតវ៉ាជាមួយអាជ្ញាធរដែល "ហាម" បិតស្រាក្នុងភូមិ ។

មតិភាគច្រើននៅក្នុងភូមិជ្រែង រឺថ្នាក់ភូមិ មិនអាចទៅជួបថ្នាក់ឃុំ ឬថ្នាក់លើដោយខ្លួនឯងទេ ។ អ្នកភូមិមួយចំនួនតូចដឹងយ៉ាងពិតប្រាកដថា សាលាឃុំនៅឯណា[១១] ។ ជាទូទៅ អ្នកភូមិនិយាយថា គេតែងតែ "ទៅតាមរយៈខ្សែបណ្តោយ" ដែលមានន័យថា គេទៅជួបមេភូមិ មេឃុំ និងមេស្រុក ។

ភាគច្រើនការដោះស្រាយជម្លោះត្រូវបានគេនិយាយថា ជាមូលហេតុដែលអ្នកភូមិទៅជួបថ្នាក់លើ ប៉ុន្តែចំពោះអ្នកភូមិមួយចំនួនធំ វានៅតែជារឿងមួយដែលពួកគេគ្រាន់តែបានលឺ ដោយមួយចំណែកទាក់ទងទៅនឹងការចំណាយ ។ ដើម្បីរៀបការ ឬលែងលះគ្នា និងធ្វើពិធីបុណ្យផ្សេងៗ គេត្រូវការការយល់ព្រមពីមេឃុំ ។ ប៉ុន្តែអ្នកភូមិហាក់ដូចជាមិនគិតពីរឿងទៅរកមេឃុំដោយខ្លួនឯងទេ បែរជាអោយមេភូមិទៅជំនួសវិញ ។ មេឃុំក៏ចូលចិត្តបែបនេះដែរ ប៉ុន្តែគាត់ក៏ជឿជាក់ថា អ្នកភូមិមិនរារែកមកជួបគាត់ ប្រសិនបើគេមានបញ្ហា ។

---

[១១] អ្នកភូមិមួយចំនួនត្រូវបានផ្តល់អំណោយនៅទីស្នាក់ការឃុំក្រោយពីមានទឹកជំនន់នៅចុងឆ្នាំ១៩៩៩ ។ នេះគឺជាលើកទី១ ហើយដែលពួកគេស្ទើរតែទាំងអស់បានទៅទីនោះ ហើយចង់និយាយថា ពួកគេបើកអំណោយនៅមន្ទីរពេទ្យសាលាដែលស្ថិតនៅជាប់នឹងមជ្ឈមណ្ឌលធនធានឃុំថ្មី ដែលប្រើប្រាស់ជាទីស្នាក់ការឃុំ ប៉ុន្តែស្នាក់ការឃុំចាស់ហាក់ដូចជាត្រូវបានគេទុកចោល ។

*នៅពេលដែលអ្នកណាម្នាក់ចង់បានច្បាប់ការ គេត្រូវទៅជួបមេភូមិ ហើយបង់ ១០.០០០រៀល ព្រោះគាត់ត្រូវយកទៅឃុំ និងលឿនជាងរត់ការខ្លួនឯង ។ មេភូមិដឹងកន្លែងត្រូវទៅចុះហត្ថលេខា (មេក្រុម ខែមិនា ឆ្នាំ២០០០) ។*

*បើមានការឈ្លោះគ្នាដែលខ្ញុំមិនអាចដោះស្រាយបាន ខ្ញុំបញ្ជូនឯកសារនេះទៅឃុំ ។ អ្នកខ្លះមកជួបខ្ញុំមុន អ្នកខ្លះទៅឃុំតែម្តង ។ អ្នកដែលមកជួបខ្ញុំមុន តែងតែបានជោគជ័យ ។ ប៉ុន្តែអ្នកដែលទៅផ្ទាល់ច្រើនជួបគ្រោះថ្នាក់ ។ នៅពេលដែលមេឃុំឃើញថា គេអត់មានការចុះហត្ថលេខារបស់ខ្ញុំ គាត់បញ្ជូនត្រឡប់មកខ្ញុំវិញ (មេភូមិ ខែមិនា ឆ្នាំ២០០០) ។*

*ប្រជាជនទៅឃុំ ដើម្បីសុំការអនុញ្ញាតធ្វើបុណ្យទាន ។ ប៉ុន្តែគេមិនភ្លេចមេភូមិទេ ត្រូវតែឆ្លងគាត់គាត់មុន បើមិនអញ្ចឹងទេ ខ្ញុំបញ្ជូនមកអោយមេភូមិអនុញ្ញាតសិន ។ ឥឡូវអ្នកភូមិហ៊ានមកឃុំហើយ ។ ប្រសិនបើមានបញ្ហាជាមួយមេភូមិ គេមករកខ្ញុំតែម្តង ។ ឥឡូវរដ្ឋអំណាចមិនអាចធ្វើ អ្វីខុសនោះទេ ។ ប្រជាជនដឹងពីសិទ្ធិរបស់គេច្បាស់ណាស់ (មេឃុំ ខែមិនា ឆ្នាំ២០០០) ។*

ប៉ុន្តែអ្នកភូមិពឹងតែលើមេភូមិ ហើយជឿថា គាត់មានទំនាក់ទំនងល្អជាមួយថ្នាក់លើ ។ នេះហាក់ដូចជាមិនមែនជាបញ្ហាទេ ។ មេភូមិនិយាយថា គាត់ទៅប្រជុំប្រចាំសប្តាហ៍នៅឃុំ ។ ប៉ុន្តែជាក់ស្តែង គាត់តែងតែអវត្តមាន ហើយគាត់មិនសូវអោយអ្នកផ្សេងទៅជំនួសគាត់ទេ ។ ប៉ុន្តែគាត់បញ្ជាក់ប្រាប់ក្រុមសិក្សាស្រាវជ្រាវពីមូលហេតុដែលគាត់មិនបានទៅប្រជុំកាលពីថ្ងៃច័ន្ទមុន ឬអាទិត្យមុននេះ អ្នកភូមិផ្សេងទៀត រួមទាំងសមាជិក គ.អ.ភ និងជីវពលជឿថា គាត់បានទៅប្រជុំ ។ ដូចដែលបានបង្ហាញជូនរួចមកហើយថា ជីវពលមានទំនាក់ទំនងល្អជាងជាមួយថ្នាក់លើ ។ គាត់ឧស្សាហ៍ចូលរួមប្រជុំនៅឃុំ និងនៅស្រុក ។

*មេភូមិអត់មានម៉ូតូ ដូច្នេះគាត់ត្រូវការជំនួយការរបស់គាត់ម្នាក់ (ជីវពល) ដើម្បីទៅប្រជុំនៅឃុំ ។ ពត៌មានទាំងអស់ដែលបានមកពីការប្រជុំម្នាក់នោះក៏ដឹងដែរ ។ ជួនកាលគាត់ដឹងច្រើនជាងមេភូមិទៀត (បុរសម្នាក់ក្នុងក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

ដូចដែលបានជំរាបជូនរួចមកហើយថា ហេតុផលតែមួយគត់ដែលអ្នកភូមិភាគច្រើនអាចគិតថា ទៅជួបថ្នាក់លើ គឺបើមានជម្លោះដែលមិនអាចដោះស្រាយបាននៅក្នុងភូមិ ។ គ្រប់គ្នាឯកភាពថា ទង្វើនេះចំណាយថវិកាច្រើន ហើយរឿងប្តឹងផ្តល់ជាច្រើនដែលឡើងដល់ថ្នាក់លើ មានតែគ្រួសារអ្នកមានជីវភាពធូរធារ និងគ្រួសារដែលជាសាច់ញាតិមួយចំនួនតូចប៉ុណ្ណោះ ។

ខាងក្រោមនេះ គឺជារឿងប្តឹងផ្តល់ស្តីពីការលែងលះរបស់ សុភី និងអតីតប្តីរបស់នាងដែលចង់រៀបការជាមួយអ្នកថ្មី ។ រឿងនេះហាក់បីដូចជាត្រូវបានដោះស្រាយនៅក្នុងភូមិរួចហើយ ប៉ុន្តែវាត្រូវបានបញ្ជូនទៅតុលាការខេត្តរយៈពេលបីឆ្នាំកន្លងទៅហើយ ។ ឪពុកម្តាយសុភី គឺជាអ្នកមានគួរសមដូចគ្រួសាររបស់អតីតប្តីរបស់នាងដែរ ។ រឿងនេះបង្ហាញអោយឃើញថា អ្នកភូមិម្នាក់នេះមានអារម្មណ៍ភ័យខ្លាច ដោយសាររដ្ឋអំណាចថ្នាក់ភូមិ និងថ្នាក់លើដែលនាងមិនយល់ពីច្បាប់ និងបែបបទរបស់ពួកគេ ។ ដូច្នេះមានការសង្ស័យថា ភាគីម្ខាងទៀតឈ្នះ ដោយសារគាត់

សូកលុយ ហើយនាងអត់ ។ រឿងនេះ ក៏បានបង្ហាញអោយឃើញពីភាពមិនច្បាស់លាស់នៅក្នុងករណីលែងលះយ៉ាង សាមញ្ញមួយដែលធ្វើអោយរឿងរ៉ាវកាន់តែស្មុគស្មាញ ។

- ខ្ញុំរៀបការបានតែមួយឆ្នាំប៉ុណ្ណោះ ។

សុភីបានរស់នៅក្នុងកន្លែងដែលមានជាងគេនៅក្នុងភូមិជ្រៃង ។ នៅពេលដែលនាងមានអាយុ ២៤ឆ្នាំ នាងបានរៀបការជាមួយបុរសម្នាក់ដែលរស់នៅភូមិជាមួយគ្នា ។ ប៉ុន្តែមួយឆ្នាំក្រោយមក នាងក៏រលូតកូន ហើយមិនអាចធ្វើការបាន ពួកគេក៏សំរេចចិត្តលែងលះគ្នា ។

- នាងនិយាយថា ខ្ញុំមិនដឹងថាហេតុអ្វីបានជាគេចង់លែង ប្រហែលដោយសារខ្ញុំឈឺហើយមើលទៅ ។ ប៉ុន្តែខ្ញុំបានដឹងថា គេមិនបានមើលថែខ្ញុំទេ អញ្ចឹងខ្ញុំក៏យល់ព្រម ។

បុរសនោះបានទៅប្រាប់មេភូមិ ហើយក្រោយមកមេភូមិអោយពួកគេទៅជួបគាត់ទាំងអស់គ្នា ។

- ប្តីឧបប្រពន្ធទៅជួបមេភូមិ មេភូមិហៅមកម្តងទៀតដើម្បីសម្រុះសម្រួល ។ ខ្ញុំអាចឃើញថា ពួកគេមិនមានការទាស់ទែងគ្នាទេ ។ បញ្ហានោះគឺថាម្តាយមិនអោយរស់នៅជាមួយគ្នា ។

ដូច្នេះ មេភូមិព្យាយាមបញ្ចុះបញ្ចូលសុភី និងប្តីរបស់នាងអោយនៅជាមួយគ្នាវិញ ។ ប៉ុន្តែម្តាយខាងប្រុសមិនព្រម ។

- សុភីនិយាយថា គាត់ប្រាប់មេភូមិអោយធ្វើយ៉ាងម៉េចក៏បានដែរអោយតែបានលែងគ្នា ។ ប្រសិនណាបើមេភូមិធ្វើបាន គាត់នឹងអោយមេភូមិ ២០.០០០រៀល ។

មេភូមិហៅអ្នកទាំងពីរមកជាលើកទីពីរ និងទីបី នៅពេលនោះ ម្តាយរបស់ភាគីទាំងសងខាង ក៏នៅទីនោះដែរ ពួកគេនៅតែថា ចង់លែងលះគ្នា ។

- មេភូមិនិយាយថា ខ្ញុំមិនអាចបង្ខំអោយពួកគេនៅជាមួយគ្នាបានទេ ដូច្នេះ ខ្ញុំក៏យល់ព្រមអោយលែងលះគ្នា ។ សាមីជនខាងប្រុស និងខាងស្រី ហើយម្តាយទាំងសងខាងបានផ្តិតមេដៃទាំងអស់គ្នា ។ ប៉ុន្តែខ្ញុំមិនបានពាក់ព័ន្ធក្នុងរឿងបែងចែកទ្រព្យសម្បត្តិទេ ។ ខ្ញុំគ្រាន់តែទៅធ្វើបញ្ជីស្តីពីរឿងទ្រព្យសម្បត្តិដែលគេចុះហត្ថលេខា ។

៣ឆ្នាំក្រោយមក បុរសនោះចង់រៀបការជាមួយសាច់ញាតិរបស់សុភី តែ សុភី មិនព្រម ។

- ខ្ញុំមិនចង់អោយគេរៀបការជាមួយសាច់ញាតិរបស់ខ្ញុំទេ ហើយខ្ញុំចង់ធ្វើអោយគេអាម៉ាស ។ ដូច្នេះ ខ្ញុំក៏ទៅឃុំ ហើយសួរថា មានច្បាប់ដែរទេ ប្រសិនបើខ្ញុំចង់រស់នៅជាមួយគេវិញ ។ ពួកគេនិយាយថា មានបើសិនជាប្តីចង់លែង ប៉ុន្តែប្រពន្ធមិនព្រមលែង អញ្ចឹងខាងប្រុសត្រូវតែបង់ជំងឺចិត្ត ។

សុភីនិយាយថា ជីវពលអោយនាងធ្វើពាក្យបណ្តឹងពីរឿងប្តីរបស់នាងដែលរៀបការជាមួយស្រីផ្សេង ព្រោះគាត់សង្ឃឹមថា នឹងបានផលប្រយោជន៍ពីរឿងនេះ ។ នៅឃុំនាងនិយាយថា នាងនិងប្តីរបស់នាងមិនទាន់លែងគ្នាដាច់ទេ ។ ចំពោះរឿងនេះ អ្នកទាំងពីរត្រូវទៅឃុំ ដើម្បីយកលិខិតលែងលះគ្នា ប៉ុន្តែនាងមិនបានធ្វើទេ ។ ដូច្នេះនៅពេលដែលភាគីខាងប្រុសមកឃុំ ដើម្បីសុំច្បាប់រៀបការ មន្ត្រីឃុំមិនហ៊ានចេញអោយ ។

- សុភីនិយាយថា គេអោយលុយទៅឃុំ ដើម្បីសុំច្បាប់រៀបការ ប៉ុន្តែគេនៅតែមិនហ៊ានចេញអោយទេ ។ ឃុំមិនហ៊ាននិយាយថាអោយគេនៅជាមួយខ្ញុំ ឬគេគួរតែបានច្បាប់រៀបការនោះ ។

ឃុំ បានហៅភាគីខាងប្រុសអោយសងជំងឺចិត្តនាងជំនួសវិញ ។

- សុភីនិយាយថា ប៉ុន្តែគេចង់អោយលុយទៅឃុំវិញ ។ គេអោយលុយទៅមេឃុំដើម្បីធ្វើអោយរឿងនេះស្ងាត់ ។ គេអោយលុយទៅឃុំ ហើយឃុំក៏ដូរចិត្ត ។ ឥឡូវនេះ ពួកគេនិយាយថាគ្មានច្បាប់ទេ ។
- មេឃុំនិយាយថា យើងអោយភាគីខាងប្រុសសងជំងឺចិត្តដើម្បីអោយនាងអស់ចិត្ត ។ ប៉ុន្តែខាងប្រុស គ្នាអត់មានលុយ ដូច្នេះយើងមិនអាចដោះស្រាយរឿងនេះបានទេ ។ ប្រសិនបើភាគីណាមួយមិនយល់ព្រម ឃុំ មិនអាចសំរេចអោយលែងលះបានទេ ។

ដូច្នេះ ឃុំក៏បញ្ជូនរឿងនេះទៅតុលាការខេត្ត ដោយភ្ជាប់សំនើរបស់សុភីដែលចង់រស់នៅជាមួយប្តីរបស់នាង និងការស្នើរបស់អតីតប្តីរបស់នាងដែលចង់រៀបការជាមួយស្រីផ្សេង ។ អ្នកទាំងពីរត្រូវបានកោះហៅទៅតុលាការបីដង ។ លើកទីមួយ គេឱ្យភាគីខាងប្រុសសងជំងឺចិត្តអោយសុភី ប៉ុន្តែគាត់មិនព្រម ។ លើកទីពីរ គេអោយនាងយល់ព្រមលើការលែងលះអោយដាច់ស្រេច ប៉ុន្តែនាងនៅតែមិនព្រម ។ លើកទីបី គេក៏ហៅមេភូមិទៅដែរ ។

- មេភូមិនិយាយថា នាងមិនបានប្រាប់ខ្ញុំទេ បែរជាឡើងមកតុលាការតែម្តង ។ នាងធ្វើអោយតុលាការមានការលំបាក ។ ប៉ុន្តែនៅពេលដែលខ្ញុំយកកិច្ចព្រមព្រៀងស្តីពីការលែងលះដែលមានផ្តិតមេដៃ និងបញ្ជីស្តីពីរឿងបែងចែកទ្រព្យសម្បត្តិដែលមានស្នាមមេដៃទៅជាមួយ តុលាការនិយាយថា "ល្អ" ។

សព្វថ្ងៃនេះ បុរសនោះរៀបការជាមួយសាច់ញាតិរបស់សុភី ហើយសុភីនិយាយថា គាត់ឈ្នះដោយសារគាត់មានលុយ និងដោយសារនាងមិនបានដឹងថា អ្វីដែលបានកើតឡើង ។

- ដំបូងមេភូមិនិយាយថា ខ្ញុំត្រូវហើយ "ឯងត្រូវធ្វើអញ្ចឹងហើយ" ។ លើកក្រោយទៀតគាត់ដូរចិត្ត ។ ប្រសិនខ្ញុំអោយលុយគាត់ដែរ គាត់ប្រហែលជាដូរចិត្តវិញទៀត ។ ប៉ុន្តែខ្ញុំអោយបារីតែមួយកញ្ចប់នៅពេលដែលខ្ញុំទៅជួបមេភូមិ និងមេឃុំ ហើយតុលាការបានបោកប្រាសខ្ញុំ ។ ពួកគេចង់អោយយើងលែងគ្នា ហើយនិយាយថា បើភាគីណាមិនយល់ព្រមទេ សូមទៅតុលាការភ្នំពេញ ។ ខ្ញុំមិនយល់ព្រមទេ ហើយចង់ទៅភ្នំពេញ ។ ប៉ុន្តែគេអោយខ្ញុំផ្តិតមេដៃលើក្រដាស ។ ខ្ញុំស្មានថាជាក្រដាសដែលត្រូវឡើងទៅភ្នំពេញ ។ ប៉ុន្តែវាបែរជាក្រដាសស្តីពីការយល់ព្រមលែងលះគ្នាទៅវិញ ។ ខ្ញុំពិបាកយល់ណាស់ វានៅក្នុងកណ្តាប់ដៃគេទាំងអស់ ។

មេភូមិ ក៏បាននិយាយពីជម្លោះដីធ្លីរបស់បងប្អូនពីរនាក់ ដែលរស់នៅផ្នែកដែលមានជាងគេនៅក្នុងភូមិ ដែលគាត់បញ្ជូនដល់ស្រុក:

- រឿងជម្លោះដីធ្លី ខ្ញុំមិនអាចដោះស្រាយនៅក្នុងភូមិបានទេ ។ បុរសម្នាក់បានសុំដីរបស់បងប្រុសនៅបណ្តោះអាសន្ន និងធ្វើជង្រុកស្រូវនៅលើដីនោះ ។ បន្ទាប់មកបងប្រុសចង់បានដីនោះមកវិញ ហើយ

អោយប្អូនរើជង្រុកនោះចេញ ។ ប៉ុន្តែប្អូនប្រុសនោះមិនព្រមហើយបែរជាធ្វើរបងព័ទ្ធជុំវិញជង្រុកនោះទៅវិញ ។ ដូច្នេះបងប្រុសនោះក៏មកជួបខ្ញុំ ហើយខ្ញុំក៏ហៅប្អូនប្រុសនោះមកសម្រុះសម្រួល ។

- ប៉ុន្តែប្អូនប្រុសនោះមិនព្រម អញ្ចឹងគាត់ធ្វើពាក្យបណ្តឹងបញ្ជូនទៅខាងយុត្តិធម៌ស្រុក ។ ខ្ញុំសរសេរលិខិតមួយបញ្ជូនទៅស្រុក និងភ្ជាប់ពាក្យបណ្តឹងទាំងពីរទៅជាមួយដែរ ។
- បន្ទាប់មក គណៈកម្មាធិការស្រុកបានចុះមកមើលការពិត ។ ពួកគេមកពីខាងនគរបាលស្រុក យុត្តិធម៌ស្រុក យោធាស្រុក និងខាងសុរិយោដីមួយចំនួនទៀត ។ គេអត់មាននិយាយថាម៉េចទេ គ្រាន់តែត្រឡប់ទៅការិយាល័យស្រុកវិញ ។ ក្រោយមកគេក៏បានហៅអ្នកដែលមកទីនេះទាំងអស់មកពិភាក្សា ។ គេសំរេចថាប្អូនប្រុសខុស ហើយអោយគាត់រើជង្រុកចេញក្នុងរយៈពេល១៥ថ្ងៃ ។ បើមិនអញ្ចឹងទេ ខាងស្រុកនឹងចុះមកម្តងទៀត ហើយអោយគាត់បង់លុយអោយពួកគេ ។
- ប៉ុន្តែប្អូនប្រុសមិនរើជង្រុកទេ ហើយអ្នកខាងស្រុក ក៏មិនឃើញមក អញ្ចឹងជង្រុកនៅទីនោះដដែល ។

មេភូមិនិយាយបន្តពីរឿងប្តឹងផ្តល់មួយករណីនៅក្នុងភូមិដែលឡើងដល់តុលាការនៅភ្នំពេញ ។ រឿងនេះកើតឡើងអស់រយៈពីឆ្នាំកន្លងផុតទៅ ហើយជារឿងរបស់បងប្អូនពីរនាក់នេះដដែល ។

- *ប្អូនប្រុសនេះ ធ្លាប់បានប្រើប្រាស់ផ្លូវបរទេះនេះតាំងពីឆ្នាំ១៩៧៩ ។ ឥឡូវ បងប្រុសនេះមិនអោយចេញចូលផ្លូវនេះទៀតទេ ។ ខ្ញុំហៅភាគីទាំងពីរមកសម្រុះសម្រួល ប៉ុន្តែពួកគេមិនព្រមទេ ។ ដូច្នេះខ្ញុំបញ្ជូនរបាយការណ៍នេះទៅយុត្តិធម៌ស្រុក ។ នគរបាលស្រុក និងខាងសុរិយោដី ចុះមកមើលម្តងទៀត ។ អ្វីដែលគេឃើញនោះ គឺថាបងប្រុសនោះបិទផ្លូវចូល ។ មួយអាទិត្យក្រោយមកគេហៅភាគីទាំងពីរទៅសម្រុះសម្រួលនៅសាលាស្រុក ។ ខាងស្រុកអោយបងប្រុសបើករបង ។ ពួកគេក៏ព្រម និងផ្តិតមេដៃ ។*
- *ពេលដែលឈ្លោះគ្នា បងប្រុសបានដឹកអន្លង់លើផ្លូវចូល ហើយប្អូនប្រុសបានលុបអន្លុងនោះវិញ ។ ឥឡូវនេះបងប្រុសនោះមិនបានបើករបងដូចដែលបានព្រមព្រៀងគ្នានោះទេ ដូច្នេះ ខាងស្រុកដែលបានមកទីនេះម្តងរួចមកហើយនោះ ចុះមកបើករបង ។*
- *បន្ទាប់មកបងប្រុសបានប្តឹងដល់តុលាការខេត្ត ហើយតុលាការខេត្តបានហៅភាគីទាំងពីរហូតដល់បីដង ។ ពីរលើកដំបូង គេហៅភាគីទាំងពីរទៅសម្រុះសម្រួល ប៉ុន្តែពួកគេមិនព្រម ។ លើកទីបី គេហៅខ្ញុំទៅដែរ ហើយគេអោយខ្ញុំបកស្រាយពីរឿងនោះ ។ ខ្ញុំនិយាយការពិតថា ប្អូនប្រុសនេះធ្លាប់បានប្រើប្រាស់ផ្លូវនេះតាំងពីឆ្នាំ១៩៧៩ ហើយបងប្រុសមកនៅភូមិនេះក្រោយទេ ។ តុលាការសំរេចថា ខាងប្អូនប្រុសត្រូវ ។*
- *បន្ទាប់មកបងប្រុសបានប្តឹងដល់តុលាការនៅភ្នំពេញ ។ គេហៅភាគីទាំងសងខាងទៅ ប៉ុន្តែគេមិនហៅខ្ញុំទៅទេ ។ គេបញ្ជូនឯកសារទៅភ្នំពេញ ហើយគេឃើញឯកសារទាំងនោះមកពីស្រុក និងខេត្ត មកពីអ្នកដែលចុះមក មើលការពិតនៅទីនេះ ។ តុលាការនៅភ្នំពេញក៏កាត់ក្តីអោយខាងប្អូនត្រូវ ហើយឥឡូវនេះបងប្រុសក៏បានយល់ព្រមដែរ ។*

ទោះជាអ្នកនៅភូមិជ្រែង ជាទូទៅព្រមទទួលនូវអ្វីដែលអាជ្ញាធរនិយាយនិងធ្វើ ហើយទោះជាពួកគេមិនគិតពីរឿងទៅជួបថ្នាក់លើក៏ដោយ យ៉ាងហោចណាស់ក៏មានឧទាហរណ៍មួយស្តីពីអ្នកភូមិមួយចំនួន ដែលបានចូលរួម

តវ៉ាពីរឿងការសំរេចរបស់ថ្នាក់លើ ។ ប៉ុន្តែការតវ៉ានេះ ត្រូវបានផ្តួចផ្តើមធ្វើឡើងដោយអ្នកដែលមានជីវភាពធូរធារ និងមានការជិតដិតជាមួយថ្នាក់លើ ។ រឿងនេះបានកើតឡើងកាលពីឆ្នាំទៅ នៅពេលដែលគេប្រាប់អ្នកភូមិមិនអោយបិតស្រា ។ ភាព គឺជាមនុស្សម្នាក់ដែលចេះដឹងជាងគេនៅក្នុងភូមិ និងជាអ្នកបិតស្រាធំដែរ ។

- ភាពបាននិយាយថា ក្រុមហ៊ុនឯកជនបានបង្កើតរោងចក្រនៅក្នុងខេត្តពោធិសាត់ ហើយគេមិនចង់អោយអ្នកផ្សេងបិតស្រាទេ ។ អញ្ចឹងគេបង់ ១.០០០ដុល្លារអោយរដ្ឋដើម្បីមានសិទ្ធិបិតស្រា ។

នៅក្នុងភូមិជ្រែងមានប្រហែលជា ១០គ្រួសារ ដែលជាអ្នកបិតស្រា ។ អ្នកខ្លះឈប់បិត ប៉ុន្តែនៅពេលដែលគេឃើញអ្នកផ្សេងបិតបន្ត គេក៏ចាប់ផ្តើមបិតទៀត ។

បន្ទាប់មក ថ្ងៃមួយ ភាពបានទទួលលិខិតមួយច្បាប់ពីអ្នកបិតស្រានៅស្រុកកណ្តៀង ។ គាត់ផ្ញើបណ្តឹងតវ៉ាជាលាយល័ក្ខណ៍អក្សរស្តីពីការហាមបិតស្រា ហើយគាត់អោយអ្នកបិតស្រាទាំងអស់នៅភូមិជ្រែងចុះហត្ថលេខានៅលើពាក្យបណ្តឹងនោះ ។ ភាពក៏យកពាក្យបណ្តឹងនេះអោយអ្នកផ្សេងទៀត រួមទាំងបងប្អូនរបស់គាត់ឈ្មោះសាន ដែលបានឈប់បិតស្រា ព្រោះគាត់មិនចង់អោយគេជាក ៣០ម៉ឺនរៀល ។ ភាពក៏បានទទួលការផ្តិតមេដៃទាំងអស់ នៅលើពាក្យបណ្តឹងនេះ ។

- សាននិយាយថា ភាពបានផ្តិតមេដៃ និងដាក់ឈ្មោះអោយខ្ញុំ ។ ខ្ញុំព្រមអោយវាធ្វើ ព្រោះវាជួយខ្ញុំ ។ បើខ្ញុំមិនអាចបិតស្រា ខ្ញុំគ្មានប្រាក់ចំណូលទេ ។

ភាព ក៏បានយកពាក្យបណ្តឹងទៅអោយបុរសនោះនៅស្រុកកណ្តៀងវិញ ដែលជាតំណាងអោយអ្នកបិតស្រានៅតាមភូមិទូទាំងស្រុក និងដែលជាអ្នកយកពាក្យបណ្តឹងនេះទៅថ្នាក់ខេត្ត ។

- ភាពនិយាយថា ខ្ញុំមិនដឹងច្បាស់ថាគាត់យកទៅអោយអ្នកណានោះទេ ។ ប៉ុន្តែវាបានឆ្លងកាត់ផ្នែករដ្ឋបាលទៅអភិបាលរងទីបី ទៅអភិបាលរងទីពីរ ដល់អភិបាលរងទីមួយហើយ ។

ការតវ៉ានេះទទួលជោគជ័យយ៉ាងសមហេតុផល ។ បំរាមបិតស្រាត្រូវបានលុបចោល ប៉ុន្តែមានការបង់ពន្ធយ៉ាងធ្ងន់ធ្ងរដែលយ៉ាងហោចណាស់ធ្វើអោយស្ត្រីម្នាក់នៅភូមិជ្រែងឈប់បិតស្រា ។

- ភាពនិយាយថា អ្នកភូមិបានសំណូមពរបង់ពន្ធតិចជាងនេះ ។ រដ្ឋបានគិតគូរពីរឿងនេះ ហើយប្រកាសថាគេអាចរកបានច្រើនជាង ១.០០០ដុល្លារដែលក្រុមហ៊ុនបង់អោយ ។

*គោកដូង: មិនមានកិច្ចការដែលត្រូវទៅ*

- *អ្នកភូមិអាចទៅជួបអាជ្ញាធរថ្នាក់លើដោយមិនបាច់ឆ្លងកាត់មេភូមិទេ តែពួកគេមិនសូវមានកិច្ចការទៅជួបថ្នាក់លើទេ ។*
- *មិនដូចនៅភូមិជ្រែងទេ អ្នកភូមិជាច្រើនទៅឃុំដើម្បីធ្វើសំបុត្ររៀបអាពាហ៍ពិពាហ៍ ប៉ុន្តែអ្នកភូមិកម្រយករឿងជម្លោះទៅដោះស្រាយនៅថ្នាក់លើណាស់ ។*
- *អ្នកភូមិភាគច្រើនបានចុះហត្ថលេខាលើលិខិតតវ៉ា ដើម្បីទាមទារសិទ្ធិនេសាទត្រីនៅក្នុងបឹងមួយចំនួន ហើយអ្នកភូមិមួយចំនួនតូចបានចូលរួមធ្វើបាតុកម្មដែលទំនងជាបានទទួលជោគជ័យ ។*

នៅភូមិគោកដូង អ្នកភូមិនិយាយថា គេមិនមានកិច្ចការទៅឃុំ ឬថ្នាក់លើទេ ។ អ្នកភូមិនៅតែស្គាល់សាលាឃុំច្រើនជាងអ្នកភូមិជ្រែង ហើយដឹងពីទីកន្លែងដែលត្រូវទៅជាងអ្នកភូមិជ្រែង និងដឹងថា គេប្រាកដជាអាចទៅបើគេត្រូវការ ។ ប្រាក់បង់នៅថ្នាក់ឃុំមិនមែនជាឧបសគ្គសំខាន់នោះទេ ប៉ុន្តែទៅលើទៀតវាក្លាយជាបញ្ហា ។ អ្នកភូមិអាចទៅថ្នាក់លើដោយខ្លួនឯង ហើយបើគេមិនចង់ទៅជួបអាជ្ញាធរថ្នាក់ភូមិជាមុន គេនៅតែអាចទៅជួបថ្នាក់លើតែម្តងក៏បានដែរ ។ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែងសព្វថ្ងៃនេះ ក្រៅពីមេភូមិ អនុប្រធានភូមិ និងប្រធានគ.អ.ភ ជាទូទៅមានតែអ្នកភូមិមួយចំនួនតូចទេដែលទៅឃុំ ឬថ្នាក់លើ ។

*កាលពីមុន ឃុំហៅអ្នកភូមិទៅប្រជុំ ។ ឥឡូវគេហៅតែមេភូមិទេ (ស្ត្រី ខែកុម្ភៈ ឆ្នាំ២០០០) ។*

ឱកាសមួយដែលប្រជាជននៅភូមិគោកដូងពិគ្រោះជាមួយឃុំ គឺនៅពេលគេ ឬកូនរបស់គេរៀបការ ។ មិនដូចនៅភូមិជ្រែងទេ អ្នកភូមិភាគច្រើនទៅដោយខ្លួនគេ តែមេភូមិនឹងទៅជំនួស ប្រសិនបើគេស្នើអោយគាត់ទៅ ។

*ដើម្បីបានច្បាប់រៀបការកូន ខ្ញុំបានសុំការយល់ព្រមពីមេភូមិ មេឃុំ និងមេស្រុក ។ ប៉ុន្តែម្នាក់ដែលនៅឃុំជាអ្នកយកច្បាប់នោះ ដើម្បីសុំការយល់ព្រមពីមេស្រុក ។ អ្នកធ្វើការនៅឃុំមិនយកលុយពីខ្ញុំទេ ប៉ុន្តែពេលខ្លះអ្នកភូមិ ជូនចាំមួយកញ្ចប់ដើម្បីជាការដឹងគុណ (ស្ត្រីម្នាក់ ខែវិច្ឆិកា ១៩៩៩) ។*

មេឃុំបានអោយដឹងថា ការលែងលះគ្នាត្រូវតែមានការយល់ព្រម និងចុះហត្ថលេខាពីឃុំផងដែរ ប៉ុន្តែករណីនេះមិនសូវកើតឡើងទេ ។ ស្ត្រីយក្មេងម្នាក់ដែលប្តីរបស់នាងធ្លាប់ធ្វើបាប ដឹងពីអ្វីដែលនាងធ្វើនៅពេលដែលនាងសំរេចចិត្តលែងលះជាលើកចុងក្រោយ ។ ប៉ុន្តែប្តីប្រពន្ធមួយគូរទៀតដែលក្រជាងគេ និងលែងគ្នាហើយ មករស់នៅជាមួយគ្នាវិញច្រើនលើក ជាទូទៅមិនដែលប្រាប់រដ្ឋអំណាចទេ ដែលអាចបង្កើតជាបញ្ហាសំរាប់អាជ្ញាធរ និងអ្នកភូមិ ។

*ខ្ញុំបានទៅជួបមេភូមិ ឃុំ និងស្រុក ហើយផ្តិតមេដៃ ព្រោះខ្ញុំមិនចង់អោយមានបញ្ហាទៅថ្ងៃក្រោយ (ស្ត្រីម្នាក់ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*នៅពេលដែលប្រជាជនចង់លែងលះគ្នាគេមកឃុំ ។ ប៉ុន្តែនៅពេលដែលគេចង់ជុំគ្នាវិញគេមិនប្រាប់ខ្ញុំទេ ។ ដូច្នេះខ្ញុំមិនដឹង ហើយស្រាប់តែខ្ញុំភ្ញាក់ព្រើតនៅពេលលឺថា ពួកគេមានកូនមួយទៀត ។ ខ្ញុំចង់អោយអ្នកភូមិដឹងពីសិទ្ធិរបស់គេ ។ កាលមុន អ្នកដែលសែនកូនមិនធ្វើច្បាប់ការទេ នោះបង្កើតជាបញ្ហានៅពេលដែលគេចង់លែងលះគ្នា ព្រោះគេអត់មានច្បាប់រៀបការជាកស្តុតាង ។ ឥឡូវ ខ្ញុំជំរុញការអនុវត្ត ។ ទោះជាអ្នកសែនកូនក៏ដោយ ក៏ខ្ញុំអោយពួកគេធ្វើច្បាប់រៀបការដែរ ដូច្នេះគេអាចលែងលះគ្នាបាច់ (មេឃុំ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

មេឃុំក៏បានអោយដឹងដែរថា ការដោះដូរដីត្រូវតែមានការយល់ព្រមនិងចុះហត្ថលេខាពីឃុំ ។ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅភូមិគោកដូង ជាទូទៅមានតែអនុប្រធានភូមិទេដែលចុះហត្ថលេខាក្នុងរឿងនេះ ដែលមេឃុំនិយាយថាវាបង្កើតអោយមានបញ្ហា ។

> *គេរាយការណ៍អោយឃុំដឹងពីរឿងដោះដូរដីតែមួយចំនួនប៉ុណ្ណោះ ។ ប្រជាពលរដ្ឋភាគច្រើនមិនប្រាប់ឃុំទេ ។ មានតែប្រជាពលរដ្ឋដែលដឹងពីច្បាប់ប៉ុណ្ណោះដែលរាយការណ៍ទៅឃុំ ។ អញ្ចឹងបានជាមានបញ្ហានៅពេលគេចាប់វាស់វែង ព្រោះគេគ្មានប្លង់ដី ហើយក៏ឈ្លោះគ្នា (មេឃុំ ខែកុម្ភៈ ឆ្នាំ២០០០) ។*

នៅភូមិគោកដូង មានការតវ៉ាយ៉ាងធំពីរឿងប្រាក់បង់ក្រៅផ្លូវការនៅសាលាឃុំ ហើយមន្ត្រីឃុំនិយាយដោយបើកចំហពីបញ្ហានេះ ។

> *ខ្ញុំប្រើខួរក្បាល និងបញ្ញារបស់ខ្ញុំនៅក្នុងការិយាល័យនេះ ។ ប៉ុន្តែខ្ញុំគ្មានពេលគ្រប់គ្រាន់ ដើម្បីធ្វើការដូចកសិករ ហើយខ្ញុំមិនអាចទៅរកស៊ីនៅខាងក្រៅបានទេ ។ មេឃុំរកបាន ៣០.០០០រៀល (៨ដុល្លារ) ហើយអនុប្រធាន ២០.០០០រៀលក្នុងមួយខែ ។ ជូនកាលយើងមិនដែលបានបើកប្រាក់ខែនៅថ្ងៃទី៣០ទេ ដល់ទៅពីរ ឬបីខែក្រោយឯណោះទើបបើក ។ អញ្ចឹងអោយអ្នកធ្វើការនៅឃុំរស់យ៉ាងម៉េចទៅ? នៅពេលដែលប្រជាពលរដ្ឋ មកធ្វើច្បាប់ការ ឬផ្លាស់ទីលំនៅ ឬផ្ទេរកម្មសិទ្ធដី គេតែងតែអោយខ្លះប្រហែលជា ១០.០០០រៀល ឬ ១០០បាត ។ អត់មានច្បាប់ទេ ហើយមិនទារពីគេទេគេអោយលុយដោយខ្លួនគេ ។ យើងចំណាយផ្ទាល់ខ្លួនខ្លះ ហើយទុកខ្លះទិញសំភារៈការិយាល័យ អ្នកខ្លះអត់មានបារីជក់ មេឃុំត្រូវការចាក់សាំងម៉ូតូ... អ្នកខ្លះធ្វើសំបុត្រការ ដោយមិនបាច់អោយអ្វីទេ ។ ថ្មីៗនេះ មានអនិកជនមកពិសហរដ្ឋ យើងដឹងថា គាត់មានលុយ អញ្ចឹងយើងសុំគ្រួសគាត់មួយឡាន (អនុប្រធានឃុំ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

ទោះជា អ្នកភូមិមិនត្រូវការអោយមេភូមិទៅឃុំជំនួសគេក៏ដោយ ក៏មេភូមិនៅភូមិគោកដូង ឧស្សាហ៍ទៅឃុំច្រើនជាងមេភូមិនៅភូមិជ្រែង ។ ឧស្សាហ៍មានប្រជុំដែលគាត់កម្រខកខាន ប៉ុន្តែគាត់ក៏មិនសូវទៅថ្នាក់លើជាងនេះដែរ ។ ប្រសិនបើមេភូមិមិនអាចទៅប្រជុំនៅឃុំ ជាទូទៅប្រធាន គ.អ.ភ ទៅជំនួស ប៉ុន្តែអនុប្រធានភូមិដែលជា *អាចារ្យ*ផងនោះ ទៅជួបឃុំសំខាន់តែពីបញ្ហាដែលទាក់ទងរឿងវត្ត ។

ដូចនៅភូមិជ្រែងដែរ មូលហេតុដែលអ្នកភូមិភាគច្រើននិយាយថា ទៅជួបថ្នាក់លើ គឺការដោះស្រាយជម្លោះ ប៉ុន្តែអ្នកភូមិក៏បានបង្ហាញដែរថា មានតែពីរបីករណីប៉ុណ្ណោះដែលឡើងដល់ថ្នាក់លើយ៉ាងពិតប្រាកដ ពីព្រោះថា "កាន់តែទៅលើ កាន់តែថ្លៃ" និងជម្លោះខ្លះ អនុប្រធានភូមិអាចដោះស្រាយនៅថ្នាក់ភូមិបាន ដោយអ្នកភូមិគ្រាន់តែចំណាយលុយបន្តិចបន្តួចប៉ុណ្ណោះ ។ មន្ត្រីឃុំក៏អញ្ចឹងដែរ ព្យាយាមជួយដោះស្រាយជម្លោះ ប៉ុន្តែគេដឹងពីព្រំដែនរបស់ខ្លួន ហើយក៏ជួយប្រជាជនអោយទៅតុលាការផងដែរ ប្រសិនបើគេត្រូវការ ។

> *វាជារឿងធម្មតាទេដែលការដោះស្រាយជម្លោះចាប់ផ្តើមពីភូមិទៅឃុំ ទៅស្រុក... ។ ដោយឡែកនៅភូមិគោកដូង គឺពិសេសណាស់ គ្មានជម្លោះណាទៅដល់ថ្នាក់លើទេ ខាងសន្តិសុខ (អនុប្រធានភូមិ) ខំសម្រុះសម្រួល បើមិនអញ្ចឹងទេ គាត់ត្រូវទៅឃុំជាមួយគេដែរ ដូច្នេះគាត់គ្មានពេលធ្វើការងារនៅផ្ទាល់ខ្លួនទេ (ប្តីប្រពន្ធ ខែមករា ឆ្នាំ២០០០) ។*

> *អ្នកធ្វើការនៅឃុំមានចិត្តទូលាយ ។ ទោះជាអ្នកភូមិមានបញ្ហាអ្វីក៏ដោយ ក៏យ៉ាងហោចណាស់មានម្នាក់នៅកន្លែង ចាំទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋដែរ ។ អ្នកភូមិអាចទៅឃុំ "រំលង" មេភូមិបាន*

*ឬគេអាចទៅតុលាការខេត្តតែម្តងក៏បានដែរ ។ អ្នកធ្វើការនៅឃុំ គ្រាន់តែជាអ្នកណែនាំប៉ុណ្ណោះ ប៉ុន្តែគេមិនអាចកាត់ក្តីបានទេ ។ តុលាការឯករាជ្យ ។ ឃុំគ្រាន់តែជាអ្នកសម្រុះសម្រួល ធ្វើកិច្ចសន្យាជាមួយអ្នកដែលធ្វើខុសដោយនិយាយថា "ថ្ងៃក្រោយខ្ញុំមិនធ្វើអញ្ចឹងទៀតទេ" ។ បើភាគីទាំងនេះមិនយល់ព្រម ឃុំត្រូវតែបញ្ជូនទៅតុលាការ ។ យើងមិនត្រូវទុករឿងនេះនៅកន្លែងអោយលើសពី ១៥ថ្ងៃទេ ។ ដើម្បីបញ្ជូនរឿងក្តីទៅតុលាការប្រជាពលរដ្ឋត្រូវតែបង់លុយមិនមែនបង់ជាផ្លូវការទេ ប៉ុន្តែភាគីទាំងសងខាងត្រូវតែបង់អោយអ្នកនៅតុលាការ (អនុប្រធានឃុំ ខែវិច្ឆិកា ឆ្នាំ១៩៩៨) ។*

នៅភូមិគោកដូងជម្លោះរឿងដីធ្លីហាក់ដូចជាទូទៅជាងនៅភូមិជ្រែង ។ ខាងក្រោមនេះគឺជារឿងទំនាស់រវាងសមាជិកនៅក្នុងក្រុមមួយដែលចោទមេក្រុមយកដីស្រែរួមរបស់ពួកគេ យកទៅប្រើប្រាស់ជាកម្មសិទ្ធផ្ទាល់ខ្លួន ហើយអោយប្រគល់អោយពួកគេវិញ ។ រឿងនេះបង្ហាញអោយដឹងថា ដំបូងអ្នកភូមិមានការរារែកយ៉ាងណាក្នុងការប្តឹង ហើយបន្ទាប់មកថាតើម្នាក់នោះអាចប្រមូលសមាជិកផ្សេងទៀតឱ្យបានច្រើនដោយរបៀបណា ព្រោះអ្នកផ្សេងទៀតមិនហ៊ានចូលរួម ។ រឿងនេះក៏បានបង្ហាញថា អ្នកត្រូវការមានលុយដើម្បីមានឱកាសឈ្នះ ប៉ុន្តែការពិតសមាជិកក្រុមនោះបានទទួលជោគជ័យដោយមិនបាច់អស់លុយ ។

នៅឆ្នាំ១៩៨០ មេភូមិបានចែកដីស្រែអោយ៩ក្រុមនៅក្នុងភូមិដើម្បីប្រើរួមគ្នា ។ ណារីជាស្ត្រីម្នាក់ដែលក្រោយមកបានដឹកនាំក្រុមប្តឹងមេក្រុមរបស់គេដោយនិយាយថា ពួកគេមិនដែលធ្វើស្រែរួមទេ ហើយភ្លាមនោះ មេក្រុមបានប្រើដីនោះជារបស់ផ្ទាល់ខ្លួន ។

អស់រយៈពេលជាច្រើនឆ្នាំកូនក្រុមទាំង១១នាក់បានឃ្លាំមើលមេក្រុម ។ ក្នុងរយៈពេលផ្សេង១គ្នា ពួកគេដឹងមិនច្បាស់ថាអ្វីដែលបានកើតឡើងពិតប្រាកដ ចំពោះដីនោះទេ ។ មេក្រុមអាចដោះដូរដីចំនួន ២ហិកតាកន្លះជាមួយដី ១.៨ហិកតានៅកន្លែងផ្សេង គាត់អាចលក់ដីមួយចំនួន ហើយប្រហែលជាជួលមកធ្វើស្រែវិញគាត់អាចអោយដីស្រែខ្លះទៅកូនគាត់ពីរនាក់ពេលដែលរៀបការ[១២] ។ នៅឆ្នាំ១៩៩៨ គេចង់ប្តឹង នៅពេលកូនក្រុមឮថា គាត់បានលក់ដីមួយចំនួនទៀត ។ ប៉ុន្តែដំបូង គេមិនទាន់ហ៊ានធ្វើអោយបានពិតប្រាកដទេ ។

- ណារីនិយាយថា ខ្ញុំអត់ខ្លាចទេ ។ ខ្ញុំទៅរកមេក្រុមហើយសួរគាត់ពីរឿងដីដែលគាត់កាន់កាប់រួម ។ គាត់និយាយថា គាត់មិនដឹងទេ ស្រេចនៅលើមេភូមិ គាត់បានប្រគល់អោយមេភូមិវិញហើយ ។

នៅពេលដែលពួកគេឈរនៅទីនោះ មេភូមិក៏ដើរចូលមក ដូច្នេះណារីបានសួរ គាត់ក៏និយាយថា អត់ដឹងទេ ។

- វាហាក់ដូចជាមេភូមិមានចំណែកក្នុងរឿងនេះដែរ ។ បន្ទាប់មកមេក្រុមនិយាយបញ្ឈឺខ្ញុំ ។ គាត់និយាយថា "បើឯងមិនព្រមទេ ទៅប្តឹងទៅ" ។ គាត់គិតអញ្ចឹងដោយសារគាត់មានលុយគាត់អាចឈ្នះ ។

នៅថ្ងៃដដែលណារី បាននាំសមាជិកទាំងអស់នៅក្នុងក្រុមនេះទៅប្តឹងនៅឃុំ ។

- មេឃុំឱ្យមកម្តងទៀត ដំបូងខ្ញុំនិយាយថា "ពាក្យបណ្តឹងនេះមិនត្រឹមត្រូវទេ សូមយកទៅធ្វើម្តងទៀត" ។ បន្ទាប់មកគេត្រឡប់មកម្តងទៀតដោយយកពាក្យបណ្តឹង និងស្នាមមេដៃត្រឹមត្រូវ ។ ឃុំផ្ញើលិខិតមកហៅមេក្រុម និងមេភូមិ ។

---

[១២] ការប្រគល់ដីស្រែរួមអោយទៅគ្រួសារថ្មីនៅក្នុងក្រុមនោះ គឺជាវិធីទូទៅមួយនៃការចែកចាយនៅពេលដែលគេទុកវាចោល ។

- ណារីនិយាយថា បន្ទាប់មកមេក្រុម និងអ្នកភូមិប្រាប់ខ្ញុំថា កុំអោយធ្វើ ។ គេនិយាយថា ខ្ញុំគ្មានលុយសូក មេក្រុមមាន ។ គេព្យាយាមបញ្ចុះបញ្ចូលកូនក្រុមទាំងអស់មិនអោយទៅ មានតែបីនាក់ទេដែលស្តាប់ ។

ដូច្នេះនៅថ្ងៃបន្ទាប់មកទៀត កូនក្រុមទាំង៨នាក់ មេក្រុម និងមេភូមិទៅឃុំ ។

- មេឃុំថា ខ្ញុំអោយមេភូមិនិយាយពីរឿងដីស្រែរួមនោះ ហើយគាត់ពណ៌នារឿងដីនោះបានច្បាស់ណាស់ ។

កូនក្រុមមិនបានទាមទារអោយសងជំងឺចិត្តសំរាប់រយៈពេលច្រើនឆ្នាំ ដែលមេក្រុមបានប្រើប្រាស់ដីស្រែនោះទេ ពួកគេគ្រាន់តែចង់បានដីនោះមកវិញ ។ មេឃុំនៅខាងគាត់គិតថា មេក្រុមជាមនុស្សល្អ ព្រោះគាត់មិនបានលក់ដីស្រែដូចមេក្រុមផ្សេងទៀតទេ ដូច្នេះហើយគាត់សំណូមពរថា កូនក្រុមទាំង ៨នាក់ គួរយកដីស្រែនេះមួយហិកតា ហើយមេក្រុមយកដីស្រែដែលនៅសល់ ០.៨ហិកតា ។

- ណារីនិយាយថា ដំបូងមេក្រុមមិនយល់ព្រមទេ ហើយយើងនៅតែនិយាយអស់រាប់ម៉ោង ។ ខ្ញុំបានព្យាយាមនិយាយថា បើមេឃុំមិនដោះស្រាយអោយទេ ខ្ញុំនឹងអោយគាត់សរសេរពាក្យបណ្តឹងទៅស្រុក បើសិនជាមេក្រុមមិនព្រម ខ្ញុំនឹងទារយកលុយអោយច្រើន ។ មេឃុំនៅតែពន្យល់ថា គាត់មិនអាចយកទាំងអស់បានទេ ដីស្រែនោះជារបស់សមាជិកទាំងអស់ ។ គាត់អង្វរមេក្រុមថា "ព្រមទៅ តាអើយ" ។ មេក្រុមម្នាក់ឯង សមាជិកច្រើន ។ ដូច្នេះចុងបញ្ចប់ គាត់ សំរេចអោយដីស្រែរួមនោះមកវិញ ។

ពួកគេក៏បានធ្វើកិច្ចសន្យាជាមួយមេក្រុមនៅសាលាឃុំដោយនិយាយថា បើកូនក្រុមណាមួយមានបញ្ហា ឬគ្រោះថ្នាក់ មេក្រុមជាអ្នកទទួលខុសត្រូវ ។ សមាជិកទាំង៨រូប សប្បាយរីករាយជាមួយនឹងដំណោះស្រាយនេះ ហើយឥឡូវនេះ កំពុងរង់ចាំលក់ដីនេះ និងចែកលុយគ្នា ។

- ណារីនិយាយថា យើងអត់មានអោយអ្វីមេឃុំទេ គាត់មានប្រាក់ខែហើយ ។ ខ្ញុំមិនដឹងថា មេក្រុមអោយលុយមេឃុំឬអត់ទេ ។

រឿងជម្លោះមួយករណីទៀត ដែលហាក់ដូចជាជម្លោះតូចតាចរវាងអ្នកជិតខាង បានយកទៅប្តឹងរដ្ឋអំណាចថ្នាក់ភូមិ និងថ្នាក់លើដោយរបៀបណា ដោះស្រាយមានលក្ខណៈជំនុំបែបណា ហើយភាគីទាំងសងខាងចរចាគ្នា និងយល់ព្រមចំពោះការសងជំងឺចិត្តដូចម្តេច ។

វី ដែលមកស្នាក់នៅជាមួយមនុស្សផ្សេងៗគ្នានៅភូមិគោគដូង ត្រូវបានគេចោទថាជាចោរលួច ។ នៅពេលដែលស្ត្រីម្នាក់ឈ្មោះឡាព្រមាន ហើយថា "កុំលួចពីពួកយើងទៀត មានអ្នកមកពីបាត់ដំបងចង់ចាប់ឯង" ។ ពេលនោះ វី ខឹងនឹងឡា ហើយក៏បានមកប្រាប់វីរៈ ដែលជាម្ចាស់ផ្ទះដែលនាងកំពុងស្នាក់នៅជាមួយ ។ វីរៈខឹងខ្លាំងណាស់ហើយក៏ជេរឡាដែលចោទថា វីជាចោរ ។ ឡាក៏ជេរតបទៅវិញ ហើយភ្លាមនោះ ក៏មានការឈ្លោះទាស់ទែងគ្នាយ៉ាងខ្លាំង ។

ក្រោយមកឡាបានទៅប្តឹងអនុប្រធានភូមិពីរឿងវីរៈ ហើយគាត់ក៏ហៅវីរៈទៅផ្ទះគាត់ ។

- អនុប្រធានភូមិនិយាយថា តាមការសង្កេត និងស្តាប់ការនិយាយរបស់ខ្ញុំ គាត់យល់ថា វីរៈជេរឡាមុន ។

ឡាទារសងជំងឺចិត្ត ប៉ុន្តែវីរៈមិនព្រមសងទេ ហើយនៅពេលអនុប្រធានភូមិព្យាយាមបញ្ចុះបញ្ចូល វីរៈ ចាប់ផ្តើមជេរគាត់ដោយនិយាយថា គាត់ល្ងង់ និងមិនចេះច្បាប់ ។

- អនុប្រធានភូមិនិយាយថា អញ្ចឹងខ្ញុំប្រាប់វីរៈអោយទៅផ្ទះ ហើយ "ចាប់ពីថ្ងៃនេះតទៅ យើងមិនចាំបាច់ទាក់ទងគ្នាទៀតទេ" ។ ឯងមិនស្តាប់ខ្ញុំ ឥឡូវនេះបើឯងមានរឿងឯងមិនបាច់មកអោយខ្ញុំជួយទេ ។ ប៉ុន្តែឡានៅតែចង់ទារសងជំងឺចិត្ត ហើយអោយអនុប្រធានភូមិយករឿងនេះទៅឃុំ ។ អនុប្រធានភូមិបានសរសេរលិខិតមួយ ឡាបានផ្តិតមេដៃនៅលើលិខិតនោះ ហើយយកទៅសាលាឃុំជាកន្លែងដែលនាងរាយការណ៍ដោយផ្ទាល់មាត់ ។
- អនុប្រធានភូមិនិយាយថា ឡាត្រូវតែឈ្នះរឿងនេះនៅឃុំ ប៉ុន្តែប្រហែលជាវីរៈអោយលុយខ្លះ ព្រោះពួកគេហាក់ដូចជាស្មើគ្នា ។ អញ្ចឹង ខ្ញុំនិយាយអោយឃុំថា "មេត្តាធ្វើការអោយបានត្រឹមត្រូវ ។"

មេឃុំចុះមកភូមិដើម្បីរកសាក្សី និងចង់ដឹងថា មានរឿងអ្វីកើតឡើង ។ បន្ទាប់មកឃុំហៅវីរៈ និងឡា ទៅជួបម្តងម្នាក់ៗ បន្ទាប់មកទៀត ក៏ហៅអ្នកទាំងពីរមកជួបគ្នា ក្រោយមកក៏ហៅសាក្សីបីនាក់ទៀត ។

លើកនេះឡាទារសងជំងឺចិត្តច្រើនជាងមុនដោយសារវីរៈមិនព្រមបង់នៅពេលដោះស្រាយនៅភូមិ ។

- អនុប្រធានភូមិនិយាយថា មេឃុំសំណូមពរ នាងមិនគួរទារប្រាក់សងជំងឺចិត្តទាំងនោះទេ ព្រោះអ្នកទាំងពីររស់នៅភូមិជាមួយគ្នាទុករាប់អានគ្នាទៅថ្ងៃក្រោយ ។

ប៉ុន្តែឡានៅតែទទូចអោយវីរៈសងតិចជាងមុន ។ ដូច្នេះមេឃុំជួយចរចាពីរឿងប្រាក់សងជំងឺចិត្ត និងព្រមព្រៀងពីរឿងចំនួន ។

ករណីទីបីជារឿងដែលភាគីទាំងពីររស់នៅឃុំផ្សេងគ្នា បង្ហាញបន្ថែមពីរឿងការចរចាយ៉ាងល្អិតល្អន់ និងពន្យា ពេលយូរពីរឿងប្រាក់សងជំងឺចិត្តដែលមូលហេតុសំរេចយកចំនួនតិចជាងនោះ ការបន្តទៅថ្នាក់លើអាចចំណាយច្រើនជាងនេះ ។

ក្មេងប្រុសម្នាក់រស់នៅភូមិគោកដូងបានបើកម៉ូតូទៅបុកក្មេងម្នាក់ដែលនៅឃុំជិតនោះ ហើយនៅស្រុកផ្សេងគ្នាធ្វើអោយជើងក្មេងប្រុសនោះរងរបួសជាទម្ងន់ ។ ឪពុកម្តាយរបស់ក្មេងរងគ្រោះនោះបានប្តឹងទៅឃុំរបស់គេ ហើយគេហៅក្រុមគ្រួសាររបស់ក្មេងដែលបើកម៉ូតូបុកទៅដោះស្រាយនៅខាងឃុំគេ ។ នៅពេលនោះម្តាយរបស់ក្មេងដែលបើកម៉ូតូបានទៅពឹងអោយរឿនដែលជាមេក្រុម និងស្គាល់គ្រួសារក្មេងប្រុសដែលជិះម៉ូតូនោះអោយទៅជួយដោះស្រាយ ពីព្រោះឪពុកក្មេងប្រុសនោះអត់នៅផ្ទះ ។ ការដោះស្រាយនេះ ប្រព្រឹត្តទៅអស់រយៈពេលបីថ្ងៃ ទើបព្រមព្រៀងគ្នា ។

- រឿននិយាយថា ល្មមដល់ពេលហើយ ។ បើនៅតែបន្តទៅទៀត វាអាចអស់ច្រើនជាងនេះ ។

  រឿនថា នៅថ្ងៃដំបូង ខាងជនរងគ្រោះទារសងជំងឺចិត្ត ៨០.០០០បាត (៨លានរៀល/២.១០០ដុល្លារ) ។ ប៉ុន្តែរឿននិយាយថា វាច្រើនពេកហើយ សូម្បីរកមួយជីវិតក៏មិនបានដល់ប៉ុណ្ណឹងដែរ ។ គេនិយាយថាពួកគេអាចបង់អោយតែ ១០.០០០បាតទេ ។ ជើងបាក់តែម្ខាងទៀត ១០.០០០បាតនេះអាចព្យាបាលគ្រប់ហើយ ។

អញ្ចឹងខាងជនរងគ្រោះចុះនៅត្រឹម ៦៥.០០០បាត ប៉ុន្តែរឿននៅតែប្រកែក ហើយអោយពួកគេត្រឡប់ទៅផ្ទះវិញ និងគិតម្តងទៀត ។

លើកក្រោយទារ ២៥.០០០បាត តែម្ខាងទៀតនៅតែនិយាយថា គេមិនអាចបង់លើសពី ១០.០០០បាតទេ ។ ដូច្នេះខាងជនរងគ្រោះសំរេចយក ១៥.០០០បាត ។

- ខ្ញុំនៅតែរឹងថ្លៃ ១០.០០០បាត និងនិយាយបន្ថែមទៀតថា បើគេមិនព្រមហើយចង់ប្តឹងដល់ថ្នាក់លើទៀត ដូចជាស្រុក ឬខេត្តអោយគេទៅ ទៅ ។ ខ្ញុំប្រាប់ពួកគេថា បើសិនគេធ្វើមែនគេអាចបានតិចជាងនេះ ព្រោះលុយយើងត្រូវចាយ នៅពេលដែលយើងទៅពីកន្លែងមួយទៅកន្លែងមួយ ដូច្នេះសល់ប៉ុន្មានអោយប៉ុណ្ណឹង ។

នៅពេលដែលខាងជនរងគ្រោះ ឮអញ្ចឹង គេក៏ព្រមយក ១០.០០០បាត និងធ្វើកិច្ចសន្យា ។

- វៀននិយាយថា ពួកគេខ្លាចអត់បានលុយ ។ បើសិនគេបន្តទៅលើទៀត គេនឹងបានតែ ២.០០០ ឬ ៣.០០០បាតប៉ុណ្ណោះ ។

ដូចដែលបានបង្ហាញជូនរួចហើយថា ជាទូទៅប្រជាជននៅភូមិគោកដូងមិនមានកិច្ចការដែលត្រូវជួបថ្នាក់លើទេ ប៉ុន្តែពួកគេហាក់ដូចជាត្រៀមខ្លួនយ៉ាងសមហេតុផលដើម្បីទៅជួបថ្នាក់លើ ប្រសិនបើចាំបាច់ ។ ទង្វើនេះត្រូវបានអះអាងដោយការតវ៉ាយ៉ាងខ្លាំងនាពេលថ្មីៗនេះក្នុងចំណោមអ្នកភូមិគោកដូង និងអ្នកភូមិផ្សេងទៀតជាច្រើនដែលរួមមានការបញ្ជូនញត្តិអោយរដ្ឋអំណាចផ្សេងៗ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងការធ្វើបាតុកម្មដែលមានមនុស្សរាប់រយនាក់ចូលរួម ហើយបុរសម្នាក់ដែលមកពីភូមិផ្សេង ត្រូវនគរបាលបាញ់អោយរបួស ។ ដូចដែលអ្នកភូមិចង្អុលបង្ហាញថា រឿងនេះ កម្រកើតមានណាស់ក្នុងរយៈពេល៥ ឬ ១០ឆ្នាំកន្លងទៅនេះ ។

*កាលពីដើមប្រជាជនខ្លាចរដ្ឋអំណាច ។ ឥឡូវគេដឹងពីសិទ្ធិរបស់គេ ។ វាជាលទ្ធិប្រជាធិបតេយ្យ ហើយប្រជាជនក្លាហានក្នុងការប្តឹងតវ៉ាផ្ទិតមេដៃ(ក្រុមផ្តល់យោបល់ស្ត្រី /បុរស ខែកុម្ភៈ ឆ្នាំ២០០០) ។*

ករណីនៃការតវ៉ានេះ ដែលអ្នកភូមិ មេឃុំ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយបាននិយាយថា ជាការផ្តួចផ្តើមធ្វើការតវ៉ារបស់ភូមិទាំងស្រុង នេះបង្ហាញថាអ្នកដែលមិនស្គាល់កន្លែងយកពាក្យបណ្តឹងទៅដាក់ ប្រហែលជាឈប់តវ៉ា ឬទទួលបរាជ័យ ប្រសិនបើគ្មានអ្នកផ្សេងស្គាល់ថ្នាក់លើដែលជួយលើកទឹកចិត្តដល់ពួកគេទេ ។ រឿងនេះក៏បានបង្ហាញអោយដឹងថា នៅពេលណាដែលមានអ្នកដឹកនាំនៅទីនោះដែរ វាមិនមែនការលំបាកក្នុងការអូសទាញអ្នកភូមិផ្សេងទៀតអោយចូលរួមនោះទេ ប៉ុន្តែគ្រាន់តែចង់ដឹងថាតើអ្នកដឹកនាំទាំងនោះ មានការចាប់អារម្មណ៍ផ្ទាល់ខ្លួននៅក្នុងបញ្ហានេះ ឬអត់ ។

ក្រៅពីរបរធ្វើស្រែ ការនេសាទត្រី និងជញ្ជូនកន្ត្រកសឡង់ គឺជាមុខរបរសំរាប់រកប្រាក់ចំណូលដ៏សំខាន់បំផុតរបស់អ្នកភូមិនៅគោកដូង ។ អស់រយៈពេលជាច្រើនឆ្នាំ ឈ្មួញបានទិញបឹងនេសាទត្រីមួយចំនួនតូចនៅក្នុងតំបន់នោះ ។ប៉ុន្តែមានបញ្ហាកន្លែងផ្សេងទៀតជាច្រើនដែលអ្នកភូមិអាចនេសាទបាន ពួកគេត្រូវបានអនុញ្ញាតអោយនេសាទក្រោយពេលដែលឈ្មួញរកអស់មួយរដូវៗសិន និងនេសាទដោយលួចលាក់ ។ បញ្ហានេះបានកើតឡើងអស់រយៈពេលពីរបីឆ្នាំហើយ ព្រោះតំបន់ដែលគេបានចែកជាចំណែក ត្រូវបានគេពង្រីកយកបន្តិចម្តងៗ ហើយឈ្មួញបានជួលអ្នកយាមប្រដាប់ដោយអាវុធអោយបញ្ឈប់អ្នកភូមិក្នុងការនេសាទនៅទីនោះទោះនៅពេលណាក៏ដោយក្នុងមួយឆ្នាំៗ ។ នៅពេលដែលយើងជួបពួកគេដំបូងនៅវិច្ឆិកាឆ្នាំទៅ មនុស្សមួយក្រុមនៅក្នុងភូមិគ្មានផ្លូវដោះស្រាយបញ្ហានេះទេ ។

- យើងអត់មានសិទ្ធិរកត្រីនៅក្នុងបឹងទាំងនេះទៀតទេ ព្រោះគេលក់បឹងអោយនាយទុនអស់ហើយ ។ បើយើងទៅរកគេនឹងបាញ់យើង ។ គេជាអ្នកធំ ។

អ្នកភូមិមិនដឹងច្បាស់ថា អ្នកណាជាអ្នកលក់បឹងនេសាទត្រីអោយពិតប្រាកដនោះទេ ប៉ុន្តែភាគច្រើនគេថាស្រុកត្រូវជាមួយនាយទុន ។

- អ្នកភូមិនិយាយថា ដំបូងស្រុកបានលក់បឹងមួយចំនួនទេ ។ បន្ទាប់មកអភិបាលខេត្តថ្មីមិនបានគិត គាត់ចេះតែចុះហត្ថលេខាលក់ថែម ។ បើសិនជាស្រុកមិនធ្វើទេ គេមិនអាចដោះស្រាយបញ្ហាបាន ។ អ្នកឯងសំលាប់ប្រជាជនទៅល្អជាង ។ ក្រៅពីរបរធ្វើស្រែ ការនេសាទត្រី គឺជារបរសំខាន់បំផុតសំរាប់រកប្រាក់ចំណូលរបស់អ្នកភូមិ ។ បើខ្ញុំមានលុយច្រើនខ្ញុំនឹងដឹកនាំ អ្នកភូមិធ្វើបាតុកម្មនៅមុខរដ្ឋសភាជាតិ ។

អ្នកយាមមួយចំនួនក៏បាននិយាយប្រាប់អ្នកភូមិថា គឺស្រុកជាអ្នកអោយពួកគេមកយាមបឹងទាំងនេះ ។ មេឃុំក៏បានស្តីបន្ទោសអោយខាងស្រុកដែរ ប៉ុន្តែគាត់និយាយថា គឺក្រសួងទេដែលលក់បឹងនេសាទទាំងនោះ ហើយឃុំមិនអាចធ្វើអ្វីបានទេចំពោះរឿងនេះ ។

- កាលមុនក្រសួងលក់បឹងតែប្រាំទេ ។ គេចង្អុលបង្ហាញនៅលើផែនទី ដោយមិនបានចុះទៅទីនោះទេ ។ ឥឡូវនេះ គេលក់បឹងទាំង៤៨ ។ ពីខាងលើគេនិយាយពីរមជ្ឈការ ។ ប៉ុន្តែគេមិនអនុវត្តតាមទេ ។ បើគេចង់លក់បឹង គេលក់ ។ ការងាររបស់យើងគឺបំរើអ្នកភូមិ ។ ប៉ុន្តែយើងធ្វើម៉េចទៅ?

នៅពេលដែលសិទ្ធិក្នុងការនេសាទត្រីមានលក្ខណៈកាន់តែតឹងរឹងទៅៗ ប្រជាជនកាន់តែមួម៉ៅ ។ ដំបូងពួកគេនៅស្ងៀមហើយនៅតែព្យាយាមទៅនេសាទ ។ ប៉ុន្តែអ្នកយាមបានយកសំភារៈនេសាទរបស់ពួកគេ ហើយយកកាំភ្លើងមកគំរាមកំហែងពួកគេទៀត ។

ការបាត់បង់សិទ្ធិក្នុងការនេសាទធ្វើឱ្យប៉ះពាល់ដល់អ្នកភូមិទូទាំងឃុំ និងកន្លែងផ្សេងៗទៀតនៅក្នុងស្រុក ។ ព្រែកឆ្មោរគឺជាភូមិមួយដែលធ្វើការតវ៉ាមុនគេ ។ ចំនួនអ្នកចូលរួមធ្វើការតវ៉ាច្រើនជាងចំនួនអ្នកភូមិគោកដូងបឹងង ហើយជាអ្នកដែលមានជីវភាពធូរធារទៀតផង ។ ជីវភាពរស់នៅរបស់ពួកគេ គឺពឹងផ្អែកទៅលើការនេសាទត្រីច្រើនជាងការធ្វើស្រែ ហើយភូមិនេះក៏នៅជិតបឹងទាំងនោះដែរ ។ ដូច្នេះ បុរសម្នាក់ដែលមកពីភូមិនោះបានសរសេរជាញត្តិមួយ ហើយយកទៅខេត្ត ។

នៅភូមិគោកដូង ដារ៉ាក៏ជាអ្នកចូលរួមធ្វើការតវ៉ាដែរ ។

- គាត់និយាយថា គាត់ក៏ចង់ធ្វើពាក្យបណ្តឹងដែរ ប៉ុន្តែខ្ញុំមិនដឹងធ្វើយ៉ាងម៉េចទេ ហើយយើងមិនដឹងច្បាស់ថា ថ្នាក់លើស្តាប់ ឬអត់ ។ នៅព្រែកឆ្មោរ គេមានបងប្អូននៅតុលាការខេត្ត ។ អញ្ចឹងគេដឹងផ្លូវ ។ គោកដូងរៀនតាមគេ ។

ថ្ងៃមួយនៅពេលដារ៉ានៅឃុំ អនុប្រធានឃុំអោយយោបល់ថា គាត់គួរធ្វើពាក្យបណ្តឹង ។

- គាត់និយាយថា បើអភិបាលខេត្តមិនអាចដោះស្រាយបានផង តើឃុំអាចធ្វើយ៉ាងម៉េចទៅ?

  ដារ៉ាសរសេរពាក្យបណ្តឹងមួយច្បាប់ ប៉ុន្តែទុកចោលនៅផ្ទះ ។ គាត់មិនដឹងថា ត្រូវផ្ញើទៅកន្លែងណា ។ គាត់ចង់យកទៅដាក់នៅស្រុក ប៉ុន្តែគាត់ខ្លាច ហើយរវល់នឹងការងារផង ។ បន្ទាប់មកមានពីរនាក់មកពីព្រែកឆ្មោរមកជួប គាត់ និងមេភូមិ ។

- គេក៏បានអោយមេភូមិសរសេរពាក្យបណ្តឹងដែរ ប៉ុន្តែគាត់មិនចេះអក្សរ អញ្ចឹងគាត់អោយខ្ញុំធ្វើ ។ ហើយគេប្រាប់ខ្ញុំអោយទៅខេត្តតែម្តង ។

ដារ៉ាបានអង្កេស្រលុយសំរាប់ទិញក្រដាស និងប៊ិចពីអ្នកដែលធ្លាប់ទៅនេសាទត្រីនៅបឹងទាំងនោះ ។ គាត់សរសេរពាក្យបណ្តឹង ហើយអោយអ្នកភូមិផ្តិតមេដៃលើពាក្យបណ្តឹងនោះ អ្នកភូមិស្ទើរតែទាំងអស់ រួមទាំងអ្នកដែលមិនទៅនេសាទផង ក៏យល់ព្រមផ្តិតមេដៃ ហើយគាត់យកពាក្យបណ្តឹងនោះទៅខេត្ត ។

បន្ទាប់មក ដារ៉ានៅតែបន្តសរសេរពាក្យបណ្តឹងប្រមូលស្នាមមេដៃ ហើយយកពាក្យបណ្តឹងទាំងនោះទៅអោយអាជ្ញាធរនានា និងអង្គការសិទ្ធិមនុស្ស ។

- ខ្ញុំបានជូនពាក្យបណ្តឹងទៅឃុំដែរ ប៉ុន្តែវាយឺតទំរាំដល់ស្រុក អញ្ចឹងខ្ញុំធ្វើមួយច្បាប់ថ្មីទៀតឱ្យខាងស្រុក ។

ព្រែកឆ្ការនៅតែជាភូមិមួយខ្លាំងក្លាជាងគេ ។ ប្រជាជនបាននាំគ្នាទៅស្រុក និងខេត្តម្តងហើយម្តងទៀតដោយចំណាយពេល និងថវិកាអស់ជាច្រើនក្នុងការធ្វើដំណើរ ។ អ្នកភូមិរាប់រយនាក់ដែលមកពីទូទាំងស្រុកបានផ្តិតមេដៃលើញត្តិ ដើម្បីទារយកសិទ្ធិនេសាទត្រីមកវិញ ។ មេឃុំបញ្ជាក់ថាការផ្តួចផ្តើមទាំងអស់នេះចេញមកពីអ្នកភូមិ គេគ្រាន់តែមកឃុំដើម្បីសួរថាត្រូវធ្វើយ៉ាងម៉េច ។

- ខ្ញុំលើកទឹកចិត្តពួកគេ ដោយនិយាយថា ពួកគេគួរតែធ្វើពាក្យបណ្តឹងដើម្បីយកបឹងទាំងនោះមកវិញ ។ បើមិនអញ្ចឹងទេ អនាគតទៅកូនចៅនឹងអត់មានកន្លែងនេសាទ ។ ប៉ុន្តែគំនិតនេះចេញមកពីអ្នកភូមិ ។ មានអ្នកខ្លះទៀតចោទឃុំថា ត្រូវគ្នាជាមួយអ្នកភូមិ ថ្នាក់លើ... អ្នកខ្លះទៀតដែលធ្វើការនៅស្រុក ។

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយឈ្មោះថាអភិវឌ្ឍន៍ស្ត្រី ក៏បានលើកទឹកចិត្តដល់អ្នកភូមិក្នុងការសរសេរពាក្យបណ្តឹង ហើយបុគ្គលិកម្នាក់ បានទៅអង្គការសិទ្ធិមនុស្សជាមួយដារ៉ា ដោយនាំយកពាក្យបណ្តឹងរបស់គាត់ទៅជាមួយដែរ ។ ប៉ុន្តែការគាំទ្រនេះបានកើតឡើងក្រោយពេលដែល អ្នកភូមិបានផ្តួចផ្តើមធ្វើការគ្រាំ ។

- ដារ៉ានិយាយថា ទោះជាគ្មានការគាំទ្រពីពួកគេ ប្រជាជននៅតែធ្វើពាក្យបណ្តឹងដដែល ។

នៅពាក់កណ្តាលខែវិច្ឆិកា ហាក់ដូចជាគ្មានអ្វីកើតឡើងសោះ ប៉ុន្តែមេឃុំគិតថាត្រូវធ្វើយ៉ាងម៉េចបន្តទៀត ។

- អ្នកភូមិមិនទៅស្ងៀមនៅក្នុងភូមិទេ ។ ពួកគេត្រូវតែបង្ខំចិត្តទៅនេសាទត្រី ។ បើនៅផ្ទះក៏ស្លាប់ បើទៅក៏អាចស្លាប់ដែរ ។ នៅពេលដែលពួកគេយកពាក្យបណ្តឹងទៅ ថ្នាក់លើមិនយកចិត្តទុកដាក់ទេ ។ បើសិនជាពួកគេទៅហើយកើតមានអំពើហឹង្សាថ្នាក់លើនឹងយកចិត្តទុកដាក់ ។ បើមិនដោះស្រាយបញ្ហាឆ្នាំក្រោយអ្នកភូមិ នឹងមិនទៅបោះឆ្នោតឃុំ និងបោះឆ្នោតសភាជាតិនៅឆ្នាំ២០០៣ ទេ ។ ពួកគេនឹងនៅផ្ទះ ព្រោះពួកគេមិនស្រលាញ់ ហើយក៏មិនស្អប់អ្នកណាដែរ ។

បុរសម្នាក់នៅភូមិព្រែកឆ្ការបានដឹកនាំប្រជាជនធ្វើបាតុកម្មយ៉ាងធំ ។ ព្រឹកមួយនៅខែមករាឆ្នាំនេះ អ្នកភូមិប្រហែល ២០០ ទៅ ៣០០នាក់ បានទៅនេសាទត្រីនៅបឹងដែលជ្រៅ និងសំបូរត្រីបំផុត ។ អ្នកភូមិគោកដូងបីនាក់ បានចូលរួមដែរ ។ ណាក់គឺជាអ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកទាំងអស់ ។

- ខ្ញុំឮគេថាមានគំរោងទៅទីនោះ ។ នៅពេលដែលគេជួបគ្នានៅតាមវាលស្រែ អ្នកភូមិនិយាយប្រាប់គ្នា ។ យើងណាត់ជួបគ្នា ។ ខ្ញុំគិតថាបើយើងមិនទៅឥឡូវទេ ឆ្នាំក្រោយគេនឹងលក់បឹងទៀត ។ បើយើងមិនតវ៉ា រដ្ឋនឹងបន្តលក់បឹងនេសាទអោយនាយទុននៅឆ្នាំក្រោយ១ទៀត ។

គេប្រមូលគ្នានៅមួយកន្លែងដែលមានចំងាយ២គីឡូម៉ែត្រពីបឹងនោះ ហើយនាំគ្នាដើរពីនោះទៅ ។ នៅម៉ោង ៩ ពួកគេបានទៅដល់បឹងនោះហើយចាប់ផ្តើមនេសាទត្រី ។ ២ម៉ោងក្រោយមកបុរសម្នាក់ដែលមកពីភូមិព្រៃកន្ធោរត្រូវបានប៉ូលីសបាញ់អោយរបួសហើយត្រូវគ្រាចេញពីទីនោះ ។ ដំបូងអ្នកយាមពីរនាក់ដែលយាមនៅបឹងនោះបានអោយប្រជាជនឈប់នេសាទ ប៉ុន្តែនៅពេលដែលពួកគេមិនស្តាប់ ប៉ូលីស ៤នាក់ទៀត ក៏បានមកដល់កន្លែងនោះ ។គេយកមង១របស់អ្នកភូមិ ហើយនៅពេលបុរសដែលមកពីភូមិព្រៃកន្ធោរអោយគេឈប់ធ្វើបែបនេះ ព្រោះអ្នកភូមិមកនេសាទគ្រាន់តែសំរាប់ចិញ្ចឹមគ្រួសារប៉ុណ្ណោះ ។ ប៉ូលីសម្នាក់បាញ់បីគ្រាប់ ។ មួយគ្រាប់ត្រូវជើងរបស់បុរសមកពីព្រៃកន្ធោរ ប៉ុន្តែអ្នកផ្សេងទៀតមិនមានអ្នកណារងរបួសទេ ។

នៅម៉ោង១១ ពួកគេបានត្រឡប់មកកន្លែងដែលបានណាត់ជួបគ្នាវិញ ។ អ្នកមកពីស្រុករួមទាំងមេស្រុក អ្នកធ្វើការនៅអង្គការសិទ្ធិមនុស្សដែលមកសំភាសន៍អ្នកភូមិ និងថតរូប ក៏នៅទីនោះដែរ ។ ណាក់បានអោយដឹងថា អ្នកធ្វើការនៅស្រុកធ្វើជាគាំទ្រអ្នកភូមិ ។ គេបានព្យាយាមអោយបាតុករកត់ឈ្មោះ អ្នកខ្លះកត់ អ្នកខ្លះអត់កត់ ។ ប៉ុន្តែនៅពេលដែលពួកគេ (ខាងស្រុក) ចង់យកសំភារៈនេសាទត្រី អ្នកធ្វើការនៅសិទ្ធិមនុស្សប្រាប់ពួកគេមិនអោយយកទេ ។

- ណាក់និយាយថា អ្នកភូមិដឹងហើយថា មេស្រុកគាំទ្រនាយទុនទេ ។ អញ្ចឹងគេនាំគ្នាគ្រោកឈរជេរមេស្រុកហើយដើរចេញ ។

ថ្ងៃបន្ទាប់មកទៀត អ្នកភូមិនាំគ្នាបន្តនេសាទត្រីជាបន្តបន្ទាប់រហូតមក ។ រយៈពេល ៥ថ្ងៃ ក្រោយពេលធ្វើបាតុកម្ម ឯកឧត្តម ស ខេង ដែលអញ្ជើញមកខេត្តបាត់ដំបង ដើម្បីបិទវគ្គសិក្ខាសាលា បានអញ្ជើញមកឃុំនៅជិតនោះ ដើម្បីនិយាយជាមួយប្រជាជន ដែលមកពីទូទាំងស្រុកពីរឿងជម្លោះបឹងនេសាទ ។ មេភូមិ និងអនុប្រធាននៅភូមិគោកដូងក៏បានចូលរួមដែរ ។

អនុប្រធានភូមិនិយាយថា មន្ត្រីទាំងឡាយនិយាយថា គេត្រូវតែលក់បឹងនេសាទ ព្រោះគេយកលុយនោះទៅអភិវឌ្ឍន៍ប្រទេស ។ នោះជាអ្វីដែល ឯកឧត្តម ស ខេង បានមានប្រសាសន៍ប្រាប់អ្នកភូមិអញ្ចឹងដែរ ។ ប៉ុន្តែអ្នកធំត្រូវតែគិតពីជីវិតរបស់អ្នកភូមិ ។ បើសិនជាគេមិនអាចនេសាទត្រី តើអោយ គេរកស៊ីអ្វី?

មួយខែក្រោយមកជម្លោះនោះមិនទាន់ត្រូវបានដោះស្រាយជាផ្លូវការនៅឡើយទេ ព្រោះមិនទាន់មានការសំរេចថា បឹងណាជារបស់អ្នកណាទេ ។ ប៉ុន្តែចាប់តាំងពីមានបាតុកម្មនោះកើតឡើងមកអត់មានអ្នកយាមប្រដាប់ដោយអាវុធទៀតទេ ហើយក៏គ្មានអ្នកណាបញ្ឈប់អ្នកណាក្នុងការនេសាទត្រីទៀតដែរ ។ ដូចកាលពីដើម មានតែបឹង ៤-៥ប៉ុណ្ណោះ ដែលអ្នកភូមិគ្មានសិទ្ធិនេសាទ ។

- ណាក់និយាយថា យើងធ្វើអញ្ចឹងល្អ ។ បើមិនអញ្ចឹង យើងនៅតែមិនអាចានសិទ្ធិនេសាទបានឡើយ ។ ប៉ុន្តែខ្ញុំខ្លាចថា នាយទុនព្រមចាញ់ឆ្នាំនេះ ដល់ឆ្នាំក្រោយ គេនឹងមានល្បិចខ្លះព្រោះនាយទុនមានលុយ ។

## សេចក្តីសន្និដ្ឋាន

### *ទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន*

- ទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន និងបុគ្គលិកលក្ខណៈប៉ះពាល់យ៉ាងខ្លាំង ដល់ការគ្រប់គ្រងនៅក្នុងភូមិ ។
- ភាពមិនច្បាស់លាស់ពីបញ្ហាអាណត្តិ និងប្រភពអំណាច ធ្វើអោយមានការលំបាកក្នុងការមានតួនាទីជាអ្នកដឹកនាំ និងបន្ថយភាពស្របច្បាប់របស់គេ ។

បទពិសោធន៍និងការយល់ឃើញដែលអ្នកភូមិបញ្ចេញអោយដឹងនោះ ពន្យល់ពីទំនាក់ទំនងផ្នែកអំណាចតាមមូលដ្ឋាន និងផ្នែកបុគ្គលិកលក្ខណៈប៉ះពាល់ទៅលើតួនាទីរបស់ថ្នាក់ដឹកនាំនៅក្នុងភូមិ និងទំនាក់ទំនងរបស់អ្នកភូមិចំពោះពួកគេ ។

នៅភូមិជ្រែង ការដឹកនាំរបស់មេភូមិដែលហាក់ដូចជាមានលក្ខណៈគ្រួសារជាងការធ្វើការងារជាមេភូមិ មិនបានធ្វើអោយអ្នកភូមិចូលចិត្ត ឬធ្វើអោយគាត់ទទួលខុសត្រូវចំពោះទង្វើរបស់គាត់ទេ ហើយមិនអាចធ្វើអោយគាត់មានតួនាទីយូរអង្វែងទៀតទេ ។ តួនាទីរបស់គាត់ដែលដូចជា "ឪពុក" នេះហាក់ដូចជាបានធ្វើអោយគាត់ធ្វើអ្វីស្រេចតែចិត្តដោយមិនបានប្រាប់ ឬបង្ហាញពីភាពសមហេតុផលអោយអ្នកណាដឹងនៅក្នុងភូមិឡើយ ។ រួមទាំងបុគ្គលិកលក្ខណៈរបស់គាត់ ប្រការនេះក៏បានបើកចំហចំពោះភាពលំអៀង គាត់ប្រើប្រាស់មុខងាររបស់គាត់យ៉ាងទូលាយដើម្បីផ្តល់ផលប្រយោជន៍អោយសាច់ញាតិ និងគ្នីគ្នារបស់គាត់ ។ ទោះជាកន្លងមក អ្នកភូមិទទួលយកទង្វើនេះ និងធ្វើតាមដែលគាត់ប្រាប់ក៏ដោយ ការគ្រប់គ្រងដែលមិនច្បាស់លាស់ និងយន្តការដើម្បីធ្វើអោយគាត់ទទួលខុសត្រូវចំពោះមុខងារទាំងពីរនោះ បើកចំហចំពោះភាពតាមអំពើចិត្តរបស់គាត់ និងធ្វើអោយតួនាទីជាមេភូមិអន់ថយ ។

ផ្ទុយទៅវិញ នៅភូមិគោកដូង អ្នកភូមិយល់ឃើញថា មេភូមិប្រកាន់តួនាទីបានល្អ ហើយមានភារកិច្ចជាក់លាក់ និងកំណត់ច្បាស់ជាងមេភូមិជ្រែង ។ មេភូមិហាក់ដូចជាមិនចូលចិត្តពង្រីកឥទ្ធិពលរបស់គាត់នៅក្នុងវិស័យផ្សេងទៀត ឬប្រើមុខតំណែងរបស់គាត់ដើម្បីយកផលប្រយោជន៍ខ្លួនឯង ឬសំរាប់បក្សពួករបស់គាត់ឡើយ ។

អំណាចក្រៅផ្លូវការកាន់តែធ្វើអោយមានភាពមិនច្បាស់លាស់ ។ នៅភូមិជ្រែង ជីវពលអាចធ្វើការហួសពីមុខតំណែងរបស់គាត់ ព្រោះមិនច្បាស់ថាមុខតំណែង និងអំណាចធ្វើអ្វីខ្លះអោយបានពិតប្រាកដទេ ហើយបុគ្គលិកលក្ខណៈរបស់គាត់បានធ្វើអោយអ្នកភូមិខ្លាចគាត់ និងដោយសារគាត់មានទំនាក់ទំនងក្រៅផ្លូវការជាមួយ ថ្នាក់លើ ប៉ុន្តែអ្នកភូមិមិនដឹងច្បាស់ថា ការទំនាក់ទំនងរបស់គាត់មានអ្វីខ្លះនោះទេ ។ ទំនាក់ទំនងដ៏មានឥទ្ធិពល និងការគំរាមកំហែងរបស់គាត់ ហាក់ដូចជាធ្វើអោយគាត់មានអំណាចជាងមេភូមិ ហើយអ្នកភូមិពិបាកទុកចិត្តគាត់ជាងមេភូមិ ។

នៅភូមិគោកដូង អ្នកភូមិដឹងច្បាស់ថា មេភូមិធ្វើអ្វីខ្លះ ហើយអនុប្រធានធ្វើអ្វីខ្លះ ។ កិរិតសកម្មភាព និងឥទ្ធិពលរបស់ពួកគេធ្វើទៅតាមសមត្ថភាពជាងការមានទំនាក់ទំនងក្រៅផ្លូវការ ។ អនុប្រធានក្មេង និងមានការចេះដឹងច្រើនជាងមេភូមិ ហេតុដូច្នេះគាត់ធ្វើកិច្ចការណាដែលមេភូមិមិនអាចធ្វើបាន ឬមិនចង់ធ្វើ ។

ស្ថានភាពនយោបាយតាមមូលដ្ឋាន និងបុគ្គលិកលក្ខណៈរបស់ថ្នាក់ដឹកនាំបានធ្វើអោយអ្នកភូមិមិនសប្បាយចិត្តដែរ ។ ដោយសារអនុប្រធានភូមិនៅគោកដូងត្រូវបានអ្នកភូមិរិះគន់កាន់តែខ្លាំងឡើង ចំពោះទង្វើរបស់គាត់ៗកំពុងតែដកខ្លួនបន្តិចម្តងៗ ពីការងារជំច្រើននៅក្នុងភូមិ ហើយទៅធ្វើការនៅវត្តវិញ ។

ផ្ទុយទៅវិញ នៅភូមិជ្រៃង ជីវពលនេះដឹងច្បាស់ថា អ្នកភូមិខ្លាច និងមិនចូលចិត្តគាត់ទេ ។ ប៉ុន្តែប្រការនេះមិនបានធ្វើអោយគាត់ឈប់ទេ តែគាត់បែជាបន្តធ្វើអោយគេខ្លាច និងមិនចូលចិត្តគាត់ថែមទៀត ។

ការខុសគ្នានេះប្រហែលជាដោយសារទំនាក់ទំនងរបស់អ្នកទាំងពីរជាមួយឃុំមានការខុសគ្នា ហើយការអោយតំលៃ និងតំរូវការរបស់មេឃុំទាំងពីរមានការខុសគ្នាផងដែរ ។ អនុប្រធានភូមិនៅគោកដូងមិនបានទទួលការគាំទ្រដ៏ខ្លាំងក្លាណាមួយពីមេឃុំទេ ហើយមេឃុំនេះចង់អោយអ្នកភូមិ ដឹងពីសិទ្ធិរបស់គេ ។ ផ្ទុយទៅវិញមេឃុំនៅក្នុងខេត្តពោធិសាត់គាំទ្រជីវពលនេះយ៉ាងខ្លាំង ដោយសរសើរគាត់ថា មានការប្តេជ្ញាចិត្តនិយាយ និងធ្វើការម៉ឺងម៉ាត់ផ្ទុយពីមេភូមិដែលជាមនុស្សស្លូត មេឃុំនេះប្រាកដជាផ្តល់សិទ្ធិអោយជីវពលក្នុងការគ្រប់គ្រងភូមិដែលនៅឆ្ងាយដាច់ស្រយាលជាងគេនៅក្នុងឃុំ ហើយមើលទៅ ។

មូលហេតុដែលអ្នកភូមិនៅគោកដូងមានទំលាប់ និងទទួលការពិភាក្សាដែលសមហេតុផល យុត្តិធម៌ និងដំបូន្មានល្អៗពីអាជ្ញាធរនោះធ្វើអោយពួកគេទៅជួបមេភូមិ ឬអនុប្រធានភូមិ ឬថ្នាក់លើជាងនេះ នៅពេលដែលគេមានកិច្ចការដែលត្រូវទៅ ។

ផ្ទុយទៅវិញ នៅភូមិជ្រៃងបទពិសោធន៍របស់អ្នកភូមិមិនបានធ្វើអោយគេគិតថា បានទទួលការជួយជ្រោមជ្រែងដោយយុត្តិធម៌ និងតាមតួនាទីពីសំណាក់រដ្ឋអំណាចនោះទេ ។ ដូច្នេះអ្នកដែលនៅខាងមេភូមិ ឬជីវពលមិនរកការជួយជ្រោមជ្រែងទេ ហើយគេក៏មិនទៅរកថ្នាក់លើផ្ទាល់តែម្តងដែរ ។ បញ្ហាគឺនៅត្រង់ថា អ្នកភូមិគ្មានកន្លែងផ្សេងទៀត ដែលត្រូវទៅពិគ្រោះយោបល់ជាមួយទេក្រៅពីមេភូមិ ឬជីវពល ប៉ុន្តែពួកគេមិនចង់ពិគ្រោះជាមួយអ្នកទាំងពីរនេះទេ ។ ដូច្នេះពាក្យចរចាមអារាម និងការមិនពេញចិត្តរបស់អ្នកភូមិចំពោះអ្នកទាំងពីរក៏បានកើតឡើង ។ ប៉ុន្តែមិនទាន់មានការប្តឹងផ្តល់ជាផ្លូវការ ឬធ្វើសកម្មភាពណាមួយ ដើម្បីផ្លាស់ប្តូរស្ថានការណ៍នៅឡើយទេ ។

ប្រការនេះចង្អុលបង្ហាញទាំងអស់ពីតំរូវការរបស់អ្នកដឹកនាំ ហើយក៏បានបង្ហាញពីអ្នកដឹកនាំប្រភេទណាដែលធ្វើអោយអ្នកភូមិចាប់អារម្មណ៍ ។ មិនមែនជាការគួរអោយភ្ញាក់ផ្អើលទេ ដែលអ្នកភូមិអោយតំលៃទៅលើអ្នកដឹកនាំដែលស្លូត ចិត្តល្អ និងមានការយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកក្រ-អ្នកដឹកនាំដែលអ្នកភូមិអាចានសិទ្ធចូលជួប និងយុត្តិធម៌ មិនស៊ីសំណូក ហើយមិននិយមតែខ្លួនឯង ឬបក្សពួក និងសាច់ញាតិនោះទេ ។ អ្នកភូមិមិនចូលចិត្តអ្នកដឹកនាំដែលតឹងរ៉ឹង និងគិតតែពីទារ ឬអ្នកដែល "សង្កត់សង្កិន" អ្នកភូមិនោះទេ ។ ប៉ុន្តែអ្នកភូមិគោរព "អ្នកធំ" នៅក្នុងភូមិជ្រៃងអ្វីដែលធ្វើអោយអ្នកភូមិចាប់អារម្មណ៍ពីរឿងមេស្រុកថ្មី គឺថាគាត់ជាមនុស្ស "សាមញ្ញ" គាត់ស្លៀកពាក់ដូចប្រជាជនសាមញ្ញ ។

*ភាពស្ទាក់ស្ទើរ*

- *ភាពរារែកក្នុងការទទួលតួនាទីជាថ្នាក់ដឹកនាំ ធ្វើអោយប្រជាជនមានការលំបាកក្នុងការទាមទារយកទង្វើដ៏មានប្រសិទ្ធិភាពពីអ្នកដឹកនាំទាំងនោះ ។*

ការយល់ឃើញ និងបទពិសោធន៍របស់អ្នកភូមិ និងអ្នកដឹកនាំ បង្កើតអោយមានភាពរារែកនៅក្នុងភូមិទាំងពីរក្នុងការមានតួនាទីជាថ្នាក់ដឹកនាំ ប៉ុន្តែវាក៏បានបង្កើតអោយមានការយល់ដឹងផងដែរថា ពួកគេមិនអាចបដិសេធបានក្នុងការទទួលយកតួនាទីទាំងនេះ ។ ភាពរារែកព្រមទាំងការបង្ខិតបង្ខំដែលអ្នកភូមិយល់ឃើញនេះមានទំនាក់ទំនងទៅនឹងការគិតថា តួនាទីបែបនេះផ្តោតទៅលើអ្វី ។ នៅក្នុងករណីខ្លះអាចមានហេតុផលដែលគួរអោយសង្ស័យថា ភាពរារែកដែលអ្នកដឹកនាំសំដែងចេញមកមិនមែនស្មោះត្រង់ទាំងស្រុងនោះទេ ប៉ុន្តែប្រាកដជាមានបំណងបន្ទាបខ្លួន ។ ទោះបីយ៉ាងណា ក៏មានហេតុផលល្អចំពោះការរារែកនេះយ៉ាងពិតប្រាកដដែរ ។

មូលហេតុដែលមេភូមិបច្ចុប្បន្ន និងមេភូមិមុនៗ អនុប្រធាន មេក្រុម តំណាងសមាគមនារី និងយុវជននិយាយពីការដែលមិនចង់បានមុខតំណែង គឺថាអត់មានពេលធ្វើការផ្ទាល់ខ្លួន គ្មានមានប្រាក់ខែ ឬផលប្រយោជន៍អ្វីឡើយ ។ មូលហេតុមួយទៀត គឺថាអ្នកដឹកនាំនៅតាមភូមិ ជួនកាលមិនសប្បាយចិត្តនឹងមុខតំណែងរវាងអ្នកភូមិ និងរដ្ឋអំណាចថ្នាក់លើទេ ។

កាលពីមុន ការមានមុខតំណែងអាចផ្តល់ឋានៈនិងផលប្រយោជន៍មួយចំនួនដូចជាការចាប់យកដីស្រែ ។ ប៉ុន្តែវាក៏ធ្វើអោយអ្នកភូមិមិនចូលចិត្តអ្នកដឹកនាំដែរ ដោយសារអ្នកដឹកនាំទាំងនោះ អនុវត្តតាមការសំរេចចិត្តពីថ្នាក់លើដូចជាការអង្កេស្រូវ លុយ ការជ្រើសរើសពលករ និងទ័ពដោយបង្ខំ ។ នៅពេលជាមួយគ្នានោះដែរ អ្នកដឹកនាំតាមភូមិត្រូវបានគ្រប់គ្រងពីថ្នាក់លើ ឧទាហរណ៍ ប្រសិនបើពួកគេមិនអាចអង្កេស្របានទេ ពួកគេត្រូវចេញរបស់ផ្ទាល់ខ្លួនជំនួស និងទៅធ្វើពលករជំនួសកូនក្រុម ។

និន្នាការដែលមានលក្ខណៈស្រដៀងគ្នា ក៏មាននៅទីនោះដដែល ។ នៅក្នុងការសិក្សានេះ យើងឃើញថាមេភូមិទាំងពីរជាមនុស្សស្លូត ចាស់ និងមានការនឿយណាយនឹងការងារ ហើយប្រហែលជាចង់ចំណាយពេលទៅធ្វើស្រែ និងជួបជុំកូនចៅជាជាងការប្រជុំ ឬដោះស្រាយជម្លោះអោយអ្នកភូមិ ។ អនុប្រធានម្នាក់ក្នុងចំណោមអនុប្រធានទាំងពីរចង់ទៅធ្វើការនៅវត្តដែលអាចរកប្រាក់បាន ប៉ុន្តែម្នាក់ទៀតកំពុងតែគិតពីរឿងមុខរបរអាជីពនៅក្រៅភូមិ ។ ជាទូទៅ ការដោះស្រាយជម្លោះនៅតែបញ្ជាក់ថា យ៉ាងហោចណាស់ភាគីម្ខាងមិនសប្បាយចិត្តនឹងលទ្ធផលទេ ។ ប៉ុន្តែសញ្ញា នឹងការកត់សំគាល់ដែលបង្ហាញអោយដឹងថា អ្នកភូមិកំពុងតែរិះគន់ និងមិនសូវមានការគោរពទេ រដ្ឋអំណាចថ្នាក់លើនៅតែគ្រប់គ្រងរដ្ឋអំណាចថ្នាក់ក្រោមដដែល ។ ប្រសិនបើអ្នកដឹកនាំនៅតាមភូមិម្នាក់ធ្វើអ្វីខុស គាត់មានរឿង ប៉ុន្តែបើគាត់ធ្វើត្រូវគាត់មិនបានទទួលការតបស្នងច្រើនណាស់ណាទេ ។

ដោយសារតែតួនាទីរបស់រដ្ឋអំណាចថ្នាក់ក្រោម នៅតែត្រូវបានគេយល់ថា ចាំតែទទួលការណែនាំ និងបញ្ជូនរបាយការណ៍អោយថ្នាក់លើនោះ ហាក់ដូចជាមិនមានឱកាសច្រើន ដើម្បីក្លាយជាអ្នកនាំពាក្យដ៏សកម្មដែលធ្វើអោយភូមិមានការខុសប្លែកសោះ ។

ដូច្នេះ ភាពរារែកដែលអាចយល់ច្បាស់បានដោយតួបផ្សំនឹងមូលហេតុដែលអ្នកដឹកនាំជាច្រើននៅតាមភូមិ ដែលគិតថា ពួកគេគ្មានការជ្រើសរើសណាផ្សេងក្រៅពីការទទួលយកមុខតំណែងទេ ហើយអាចធ្វើឱ្យកាន់តែពិបាកទុកចិត្ត និងមួយចំណែកអាចពន្យល់ថាហេតុអ្វីបានជាអ្នកភូមិជានិច្ចកាល មិនសង្ឃឹមលើជំនួយដ៏មានប្រសិទ្ធិភាព និងទង្វើដ៏យុត្តិធម៌ពីអ្នកដឹកនាំរបស់ពួកគេ ។ អ្នកទាំងនេះ កំពុងតែចំណាយពេលវេលា និងជួនកាលចំណាយថវិការបស់ពួកគេទៅលើអ្វីដែលពួកគេ ឬគ្មានអ្នកណាចង់ធ្វើ ហើយពួកគេក៏មិនបានទទួលកំរៃចំពោះការងារនេះដែរ ។ ដូច្នេះប្រហែលជាពិបាកបន្ទោសពួកគេថាមិនសកម្ម និងដែលមិនមានពេលអោយអ្នកភូមិចូលជួបបាន ឬចំពោះការទារលុយ ជួនកាលទារលុយច្រើនសំរាប់ជំនួយរបស់ពួកគេ ។

***ការទទួលយក***

- *និន្នាការដ៏ខ្លាំងមួយនៅក្នុងចំណោមអ្នកភូមិ ដើម្បីទទួលយកនូវអ្វីដែលអាជ្ញាធរសំរេច ដោយតួបផ្សំជាមួយនឹងភាពមិនជិតដិត និងកង្វះខាតក្តីរំពឹងផ្សេងៗទៅលើអាជ្ញាធរ ភាពជុំយគ្នានឹងការផ្លាស់ប្តូរនៅក្នុងការគ្រប់គ្រងតាមមូលដ្ឋាន ។*

ការយល់ឃើញរបស់អ្នកភូមិចំពោះឃុំ និងរដ្ឋអំណាចថ្នាក់លើថា ជាកន្លែងមួយដែលនៅឆ្ងាយដាច់ស្រយាលពីគេ ហើយសំបូរទៅដោយ "អ្នកធំ" ស្ទើរតែគ្រប់គ្នាជាមនុស្សរវាយឫក ហើយជាមនុស្សដែលអ្នកភូមិមិនស្គាល់ និងមិនអាចចូលជួបបាន ហើយអ្នកភូមិចូលចិត្តទទួលយកការណែនាំដែលចេញមកពីថ្នាក់លើ ដោយមិនសួរនាំអ្វីទាំងអស់ នោះហាក់ដូចជាមិនបានត្រៀមហេតុផលអោយបានសមរម្យ ដើម្បីធ្វើការផ្លាស់ប្តូរទំនាក់ទំនងណាមួយ រវាងអ្នកភូមិ និងរដ្ឋអំណាចអោយបានឆាប់រហ័សនោះឡើយ ។ នេះហាក់ដូចជាសំរាប់អោយរដ្ឋអំណាចនៅតាមមូលដ្ឋានមានទំនាក់ទំនងជាមួយរដ្ឋអំណាចថ្នាក់លើផងដែរ ។ មេភូមិមិនឆ្ងល់ទេថា មេឃុំធ្វើអ្វីខ្លះ ហើយមេឃុំទទួលយករាល់ផែនការដែលមកពីស្រុក ។

លក្ខណៈពិសេសនៃឥរិយាបទរបស់អ្នកភូមិ ចំពោះរដ្ឋអំណាចថ្នាក់លើ គឺការយល់ឃើញដោយកម្រប់ផុត ។ ប៉ុន្តែភាពមិនជិតដិត និងការទទួលយកហាក់ដូចជាមិនទាក់ទងទៅនឹងការភ័យខ្លាចណាស់ណាទេ ។ អ្នកភូមិហាក់ដូចជាមិនមានការខុសប្លែកអ្វីទេ មិនបានធ្វើអោយថ្នាក់លើគិតអ្វីច្រើនទេ និងមិនយល់ថាអ្វីដែល "ពួកគេ" ធ្វើទាក់ទងអ្វីច្រើនដល់ពួកគេទេ ។ ទោះជាធ្លាប់មានបទពិសោធន៍កន្លងមក ចំពោះការជ្រើសរើសដោយបង្ខំ "គេនិយាយអីយើងធ្វើហ្នឹងទៅ" មិនត្រូវបាននិយាយដោយការភ័យខ្លាច ឬកំហឹងនោះទេ ប៉ុន្តែនិយាយដោយដកដង្ហើមធំដែលហាក់ដូចជាបញ្ជាក់ថា អ្នកភូមិមានបញ្ហាសំខាន់ជាច្រើនដែលត្រូវគិត ហើយអាចផ្តោតទៅលើអ្វីដែលធ្វើអោយ "ពួកគេ" រីករាយកាន់តែឆាប់កាន់តែប្រសើរ ។

ដូច្នេះក្នុងចំណោមអ្នកភូមិ ហាក់ដូចជាមិនគិត ឬមានបំណងស្វែងយល់ថា រដ្ឋអំណាចធ្វើអ្វីខ្លះទេ សូម្បីតែការគិតទុកថានឹងអាចមានឥទ្ធិពលទៅលើការសំរេចចិត្តរបស់ពួកគេ ឬបង្កើតអោយមានទំនាក់ទំនងខុសគ្នាក៏គ្មានដែរ ។ នៅពេលដែលបញ្ហា ឬសកម្មភាពចេញមកពីខាងលើដែលហាក់ដូចជាមិនសមរម្យ និងមិនយុត្តិធម៌ អ្នកភូមិអាចរអ៊ូរទាំតែនៅក្នុងចំណោមពួកគេប៉ុណ្ណោះ ។ ប៉ុន្តែក្នុងករណីជាច្រើន វាហាក់ដូចជាមិនកើតឡើង ចំពោះអ្នកណាដែលពួកគេអាចតវ៉ា ឬយ៉ាងហោចណាស់ ក៏សួរពត៌មានបន្ថែមជាងការអនុវត្តន៍តាម ។

ការពិតទៅ មួយចំណែកដោយសារបទពិសោធន៍នៃបរិយាកាសនយោបាយ ដែលធ្វើអោយមានភាពស្ងប់ស្ងាត់ ។ កង្វះខាតនៃការគិតទុកចំពោះអ្វីដែលខុសប្លែក គឺត្រូវបានបន្ថែមទៅលើភាពមិនជិតដិតរបស់អ្នកភូមិជាមួយថ្នាក់លើ ដែលជាមូលហេតុធ្វើអោយអ្នកភូមិជាទូទៅពុំមានកិច្ចការដើម្បីទៅពិគ្រោះជាមួយថ្នាក់លើ ។ ការគិតទុកជំពេញលេញដែលថា បើពួកគេធ្វើ ពួកគេនឹងត្រូវចំណាយកាន់តែខ្ពស់ កាន់តែអស់លុយច្រើន គឺមិនមែនជាការលើកទឹកចិត្តមួយដ៏ខ្លាំងក្លាទេ ។ ដូច្នេះ អ្នកភូមិកម្រសាកល្បងប្រព័ន្ធនេះណាស់ ។ ពួកគេមិនមានបទពិសោធន៍ និងការយល់ដឹង ឬការគិត ដែលពួកគេអាចត្រូវការ. ចង់អោយមានឥទ្ធិពលទៅលើ និងផ្លាស់ប្តូរទំលាប់នេះ ។

### *បណ្តឹងតវ៉ា*

- *អ្នកភូមិកំពុងត្រៀមខ្លួនតវ៉ាទាមទារសិទ្ធិរបស់ខ្លួន ប្រសិនបើមានការចាំបាច់ ហើយបើមានអ្នកនាំធ្វើ ។*

ទោះជាមានការទទួលយក និងភាពមិនជិតដិតដែលបានពិភាក្សាខាងលើហើយក៏ដោយ ប្រជាជនរាប់រយនាក់នៅភូមិគោកដូង និងភូមិជិតខាងជាច្រើនទៀត បានធ្វើការតវ៉ាយ៉ាងម៉ឺងម៉ាត់ នៅពេលដែលពួកគេត្រូវគេគំរាមកំហែង និងបំបិទសិទ្ធិក្នុងការនេសាទត្រី ហើយនៅភូមិជ្រែង អ្នកបិតស្រាទាំងអស់បានផ្តិតមេដៃនៅលើញត្តិ ដើម្បីធ្វើការតវ៉ាបំរាមបិតស្រានៅតាមភូមិ ។

ហេតុការណ៍នេះធ្វើអោយមានចំងល់ថា មូលហេតុអ្វីដែលបណ្តាលអោយអ្នកភូមិតវ៉ា ។ ការសិក្សានេះបង្ហាញពីសារៈសំខាន់របស់អ្នកដឹកនាំ ការយល់ដឹងពីរដ្ឋអំណាច និងបែបបទក្នុងការធ្វើបណ្តឹងតវ៉ា ។

នៅក្នុងការតវ៉ាទាំង២ករណីនេះ ការផ្តួចផ្តើម និងអ្នកចូលរួមដ៏ច្រើនលើសលប់នេះ បានផុសចេញមកពីភូមិផ្សេងៗទៀត ។ អ្នកផ្តួចផ្តើម និងអ្នកដឹកនាំ គឺជាប្រជាជនដែលមានចំណាប់អារម្មណ៍ខ្លាំងនៅក្នុងបញ្ហានេះ មានទំនាក់ទំនងល្អ មានការយល់ដឹងចំពោះថ្នាក់លើ និងធ្វើការប្តឹងផ្តល់ខ្លាំងជាងអ្នកនៅភូមិគោកដូង ឬនៅជ្រែងទៀតផង ។ នៅក្នុងការតវ៉ាទាំង២ករណីនេះ នៅក្នុងភូមិ អ្នកដែលសកម្មជាងគេ បំផុតនោះក៏ជាមនុស្សដែលមានការចាប់អារម្មណ៍ខ្លាំងនៅក្នុងបញ្ហា មានការយល់ដឹង និងបទពិសោធន៍ចំពោះថ្នាក់លើជាងអ្នកផ្សេងទៀតស្ទើរតែទាំងអស់ ទោះបីនៅភូមិគោកដូងមិនមានសកម្មភាពខ្លាំងជាងគេក៏ដោយ ។

បើសិនជាគ្មានការផ្តួចផ្តើមគំនិតនៅក្នុងភូមិ និងប្រជាជនដែលមកពីភូមិផ្សេងទេការតវ៉ាទាំងនេះ ក៏មិនអាចកើតមានឡើងនៅភូមិគោកដូង ឬជ្រែងដែរ ។ កន្លងមកហាក់ដូចជាគ្មានអ្នកណាម្នាក់ នៅក្នុងភូមិទាំងនេះមានការខិតខំប្រឹងប្រែង យល់ដឹង និងទុកចិត្តនៅក្នុងចំណោមអ្នកភូមដទៃទៀត ដើម្បីអាច និងមានឆន្ទៈផ្តើមដឹកនាំធ្វើការតវ៉ាដែលស្រដៀងនេះ ។ យើងមិនដឹងថាអ្វីដែលបង្កើតអោយមានបុគ្គលិកលក្ខណៈទាំងនេះនៅភូមិដទៃទៀតទេ ។ ប៉ុន្តែមានការលើកទឹកចិត្ត និងមានមនុស្សដែលហ៊ានប្តូរផ្តាច់ជីវិតក្រាំងកាយ ហើយអាចទុកចិត្តបាននៅភូមិគោកដូង និងភូមិជ្រែង ដើម្បីអនុវត្តតាមការផ្តួចផ្តើមដែលមកពីខាងក្រៅ និងអូសទាញអ្នកផ្សេងទៀតអោយចូលរួម ។

ដូចអ្នកភូមិគោកដូងបង្ហាញអោយដឹងថា ការតវ៉ាបែបនេះកម្រកើតមានណាស់នៅក្នុងរយៈពេល ៥ ឬ១០ឆ្នាំកន្លងទៅនេះ ។ ប៉ុន្តែគេគិតថាវាអាចកើតឡើងច្រើនជាងនេះទៀតនៅពេលអនាគត ។ អ្នកភូមិមួយចំនួនទៀត

កំពុងចុះហត្ថលេខាលើញត្តិជាផ្លូវការជូនថ្នាក់លើ ហើយនៅគោកដូងក៏មានការផ្តិតមេដៃប្រមូលប្រជាជនធ្វើបាតុកម្មដែរ ។ អ្នកភូមិទាំងអស់ក៏បានឃើញលទ្ធផលប្រកបដោយជោគជ័យមួយចំណែកដែរ ។ ទង្វើនេះអាចធ្វើអោយអ្នកភូមិ ចាប់ផ្តើមគិតអំពីតួនាទី និងការទទួលខុសត្រូវខុសៗគ្នារបស់អ្នកធ្វើការ និងអំពីរបៀបដោះស្រាយជាយុទ្ធសាស្ត្រជាមួយរដ្ឋអំណាច ។ ដូច្នេះវាមានការងាយស្រួលដើម្បីស្រម៉ៃថា លើកក្រោយនៅពេលដែលមានហេតុផលគំនិតដែលចង់ធ្វើការតវ៉ាជាជាងការអនុវត្តតាម នឹងងាយជ្រាបចូលក្នុងផ្នត់គំនិតរបស់អ្នកណាម្នាក់ ហើយប្រជាជនប្រហែលជាដឹងថា អ្វីដែលត្រូវធ្វើ និងស្គាល់កន្លែងដែលត្រូវទៅ ។

ដោយសារហេតុផល និងការចង់ធ្វើការតវ៉ាប្រហែលជាកំពុងរីកដុះដាល ដូចជា ការដណ្តើមយកដី ការរកស៊ីនេសាទ និងការកាប់ឈើកំពុងតែកើនឡើង ដូច្នេះអ្នកភូមិ កំពុងទទួលបានបទពិសោធន៍ដែលអាចត្រៀមខ្លួន ដើម្បីប្រមូលអ្នកភូមិអោយចូលរួមធ្វើការតវ៉ា នៅពេលអនាគតនៅពេលណាដែលត្រូវគេរំលោភសិទ្ធិ ឬក៏អាជ្ញាធរកំពុងប្រើប្រាស់អំណាចរបស់គេខុសច្បាប់ ។ (សូមអានពត៌មានស្តីពីឱកាស និងការទទួលខុសត្រូវសំរាប់អ្នកភូមិជ្រែង) ។

ជំពូក ៣

# ឥទ្ធិពលសិលានៅលើការគ្រប់គ្រងនៅតាមមូលដ្ឋាន

## ភូមិ

### ***ភារកិច្ច និងមុខតំណែងថ្មី***

*ភូមិជ្រែងៈ គេជួយភូមិនេះតាំងពីគ្មានអ្វីសោះ*

- មុខតំណែងដែលទាក់ទិននឹងសកម្មភាពអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើង និងមានការចាត់តាំងដោយមេភូមិ ឬបោះឆ្នោតជ្រើសរើសដោយអ្នកភូមិ ។
- បុរសមួយក្រុមតូចដែលមានមុខតំណែងខាងអាជ្ញាធរ បានទទួលមុខតំណែងផ្នែកអភិវឌ្ឍន៍ ប៉ុន្តែនៅក្នុងនោះ ក៏មានស្ត្រីចំនួន ៤នាក់ផងដែរ ។
- អ្នកភូមិមួយចំនួនធំមិនស្គាល់គណៈកម្មការអភិវឌ្ឍន៍ភូមិជាក្រុមទេ ។ ប៉ុន្តែអ្នកភូមិស្គាល់សមាជិកម្នាក់ៗ ដោយសារការងារពិសេសៗ ដូចជាលើកផ្លូវ ដំណើរការធនាគារស្រូវ ឬហៅទៅប្រជុំ ។
- អ្នកភូមិជាច្រើនដែលមានមុខតំណែងផ្នែកអភិវឌ្ឍន៍និយាយថា មិនចង់បានការងារនេះទេ ព្រោះគេគិតថា អ្នកភូមិដទៃទៀតមិនចូលចិត្តពួកគេ ហើយម្យ៉ាងទៀតមានការប្រជែងគ្នាក្នុងការទៅចូលរួមវគ្គបណ្តុះបណ្តាលណាដែលមានប្រាក់ឧបត្ថម្ភ ។

នៅភូមិជ្រែង មានការបោះឆ្នោតជ្រើសរើសគណៈកម្មការអភិវឌ្ឍន៍ភូមិ មានសមាជិក ៦រូប ( ស្ត្រី ២នាក់ បុរស ៤នាក់) ស្ត្រីម្នាក់ទៀតឈប់ហើយ ។ ពីរបីឆ្នាំកន្លងទៅនេះ មេភូមិបានជ្រើសរើសសមាជិក ៤រូប (ស្ត្រី ២នាក់ បុរស ២នាក់) អោយទៅចូលរួមវគ្គបណ្តុះបណ្តាលពេទ្យសត្វមានតែ២នាក់ទេ ដែលសកម្មជាងគេ ។ កាលពីឆ្នាំទៅ មានការជ្រើសរើសភ្នាក់ងារសុខភាពភូមិ ២នាក់ (ស្ត្រីម្នាក់ បុរសម្នាក់) ។ មានរបាយការណ៍ផ្សេងៗគ្នាពីរឿងពួកគេត្រូវបានជ្រើសរើស ឬតែងតាំង មេភូមិនិយាយថា គាត់តែងតាំងពួកគេ ។ ចាប់ពីពេលនោះ ភ្នាក់ងារសុខភាពភូមិបានប្រមូលទិន្នន័យប្រជាជន ហើយអ្នកភូមិមិនដឹងថា ពួកគេជាភ្នាក់ងារសុខភាពភូមិទេ ក្នុងនោះមានអ្នកស្ម័គ្រចិត្តកាកបាទក្រហមភេទប្រុសម្នាក់ដែលអ្នកភូមិស្ទើរតែទាំងអស់មិនស្គាល់ ។ នៅឆ្នាំ១៩៩៩ មានវគ្គបណ្តុះបណ្តាលស្តីពីសុខភាពផ្លូវចិត្ត មេភូមិបានជ្រើសរើសមនុស្ស ៦នាក់ (បុរស ៣នាក់ ស្ត្រី ៣នាក់) ទៅទទួលការបណ្តុះបណ្តាលធ្វើជាប្រធានក្រុមផ្លូវចិត្ត ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំងនោះ មិនបានធ្វើជាប្រធានក្រុមទេ ។

| ស្រី/ប្រុស | មុខតំណែងផ្នែកអភិវឌ្ឍន៍ | មុខតំណែងផ្នែកអាជ្ញាធរ |
|---|---|---|
| ប | ប្រធាន គ.អ.ភ. ពេទ្យសត្វភូមិ. ប្រធានក្រុមផ្លូវចិត្ត | មេភូមិ |
| ប | ហិរញ្ញិក គ.អ.ភ. ប្រធានក្រុមផ្លូវចិត្ត | អតីតអនុប្រធានភូមិ. មេក្រុម |
| ប | អនុប្រធាន គ.អ.ភ | មេក្រុម |
| ប | សមាជិក គ.អ.ភ | អតីតប្រធានភូមិ |
| ស | សមាជិក គ.អ.ភ | |
| ស | សមាជិក គ.អ.ភ | |
| ស | ពេទ្យសត្វភូមិ. ភ្នាក់ងារសុខភាពភូមិ. ប្រធានក្រុមផ្លូវចិត្ត | |
| ស | ពេទ្យសត្វភូមិ. ប្រធានក្រុមផ្លូវចិត្ត | អតីតតំណាងសមាគមនារី |
| ប | ពេទ្យសត្វភូមិ. ប្រធានក្រុមផ្លូវចិត្ត | ជីវពល |
| ប | ភ្នាក់ងារសុខភាពភូមិ | |

អ្នកខ្លះដែលមានមុខតំណែងទាក់ទងទៅនឹងសកម្មភាពអភិវឌ្ឍន៍ គឺជាមនុស្សដដែលៗ ហើយមនុស្ស ៥នាក់ក្នុងចំណោមអ្នកទាំងនោះ មានមុខតំណែងខាងរដ្ឋអំណាចក្នុងនោះមានមេភូមិផងដែរ ។ សមាជិកគ.អ.ភ ២នាក់ជាមេក្រុម សមាជិកម្នាក់ទៀតជាអតីតជាអនុប្រធានភូមិ ហើយ២នាក់ទៀតជាមេភូមិ និងជាអតីតមេភូមិ ។ បទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍បានផ្តល់មុខតំណែងជាផ្លូវការដែលមានអាណត្តិវែង ឬខ្លីអោយស្ត្រីចំនួន ៤នាក់នៅក្នុងភូមិ ដោយ ២នាក់ជាសមាជិកគ.អ.ភ ហើយ ២នាក់ទៀត ជាពេទ្យសត្វភូមិ និងជាប្រធានក្រុមផ្លូវចិត្ត ។

អ្នកភូមិភាគច្រើន មិនស្គាល់សមាជិកគ.អ.ភ ឬជាមនុស្សមួយក្រុម ដែលមានការទទួលខុសត្រូវខាងសកម្មភាពអភិវឌ្ឍន៍នៅក្នុងភូមិទេ ។ ប៉ុន្តែអ្នកភូមិស្គាល់សមាជិក គ.អ.ភ ម្នាក់ៗ ដោយសារភារកិច្ច និងសកម្មភាពជាក់លាក់ផ្សេងៗ ហើយជួនកាលអ្នកភូមិហៅអ្នកទាំងនោះថាជា "អ្នកធ្វើការ" ឬ "អ្នកធ្វើការងារអភិវឌ្ឍន៍" ។ វាជាការគួរអោយចាប់អារម្មណ៍ដែរថា អ្នកភូមិជាច្រើនបានចាត់ទុកជីវពលជាអ្នកធ្វើការងារអភិវឌ្ឍន៍ដែរ ទោះគាត់មិនមែនជាសមាជិកគ.អ.ភក៏ដោយ និងនិយាយថាមិនពាក់ព័ន្ធនឹងការងាររបស់ពួកគេទេ ។ សកម្មភាពអភិវឌ្ឍន៍ដែលត្រូវបានអ្នកភូមិស្គាល់ច្បាស់នោះ គឺការងារលើកផ្លូវ និងដំណើរការធនាគារស្រូវដែលសមាជិកគ.អ.ភ កាន់កាប់បន្តពីគណៈកម្មការធនាគារស្រូវមុន ហើយដែលបានប្តូរមកជាការអោយខ្ចីជីទៅវិញ ។ អ្នកភូមិជួបជាមួយអ្នកធ្វើការងារអភិវឌ្ឍន៍ តែនៅពេលប្រជុំប៉ុណ្ណោះ ។

*តួនាទីរបស់ពួកគេ (អ្នកធ្វើការងារអភិវឌ្ឍន៍) គឺប្រជុំគ្នាគេ ។ បន្ទាប់មក គេមានប្រជុំធំជាមួយអ្នកភូមិ ដូចជាប្រជុំពីរឿងថ្នល់ (មេក្រុម ខែមិនា ឆ្នាំ២០០០) ។*

*អ្នកភូមិជួប គ.អ.ភ នៅពេលដែលគេត្រូវការជី ។ ជាការមួយល្អណាស់ក្នុងការមានគ.អ.ភ នៅក្នុងភូមិ ព្រោះគ.អ.ភ អាចជួយតាំងពីគ្មានអ្វីសោះ ដើម្បីជួយអ្នកក្រ ។ ឧទាហរណ៍ គេអោយខ្ចីជី នៅខែស្ទូង ហើយគេអោយប្រជាជនសងវិញ ពេលច្រូតរួច (ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

ដោយសារក្នុងចំណោមអ្នកដែលមាន ឬធ្លាប់មានមុខតំណែងខាងរដ្ឋអំណាច អ្នកដែលមានមុខតំណែងខាងការងារអភិវឌ្ឍន៍ភាគច្រើននិយាយថា ពួកគេមិនចង់បានមុខតំណែងនេះទេ ប៉ុន្តែពួកគេត្រូវតែធ្វើ ព្រោះមេភូមិបានជ្រើសរើស ឬអ្នកភូមិបានបោះឆ្នោតអោយពួកគេរួចទៅហើយ ។ មូលហេតុសំខាន់ដែលក្នុងចំណោមសមាជិក គ.អ.ភ មានការរារែក មិនមែនដោយសារការងារច្រើននោះទេ ប៉ុន្តែដោយសារគេគិតថា អ្នកភូមិមិនចូលចិត្តពួកគេ និងគិតថាពួកគេបានទទួលផលប្រយោជន៍ពីតួនាទីរបស់ខ្លួន ។ ជំនួយសង្គ្រោះបន្ទាន់ដែលមកពីកម្មវិធីស្បៀងអាហារពិភពលោក និងកាកបាទក្រហម ត្រូវបានចែកចាយក្រោយពីទឹកជំនន់ស្រុកកាលពីចុងឆ្នាំកន្លងទៅនេះ បានធ្វើអោយអ្នកភូមិមួយចំនួនមិនសប្បាយចិត្តទាល់តែសោះ ។ ប៉ុន្តែមានការប្រជែងគ្នាក្នុងចំណោមសមាជិកគ.អ.ភ និងអ្នកដែលមិនមែនជាសមាជិកពីរឿងទៅចូលរួមវគ្គបណ្តុះបណ្តាលដែលមានប្រាក់ឧបត្ថម្ភ ។

*គេជេរយើងដោយសារគេគិតថាយើងបានលុយ ។ ខ្ញុំនឹងមិនឈរឈ្មោះទៀតទេ ។ ខ្ញុំធ្វើការអោយប្រជាជន ប៉ុន្តែនៅពេលដែលខ្ញុំសុំអ្វីមួយពីគេ ឬនៅពេលគេឃើញខ្ញុំ គេជេរខ្ញុំ ។ គេនិយាយថា ខ្ញុំមានមាសពាក់ដោយសារលើកផ្លូវ (ស្ត្រីជាសមាជិក គ.អ.ភ ក្រុម គ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

*គេហៅយើងទៅប្រជុំ ។ ឈុនលី [CARERE LCB] មេឃុំ អ្នកសំរបសំរួលស្រុក... អ្នកធំនៅទីនោះ ។ នៅពេលនោះ ខ្ញុំមិនបានដឹងថា មានការអភិវឌ្ឍន៍នៅក្នុងភូមិទេ ។ នៅពេលដែលពួកគេចុះមក ពួកគេរកបេក្ខជន ១២នាក់ គេហៅអ្នកចេះអក្សរមកជួបជុំគ្នា មេភូមិក៏នៅទីនោះដែរ ។ គេហៅឈ្មោះខ្ញុំ ហើយប្រជាជនទះដៃ ។ មេភូមិចុះឈ្មោះខ្ញុំ និងដាក់ឈ្មោះឱ្យកូនប្រសាខ្ញុំ "ឈ្មោះនេះបានទេ?" ហើយអ្នកភូមិឆ្លើយថា "បាន ដាក់ទៅ" ។ បេក្ខជនប្រកែកមិនរួច ។ ការងារមិនជាច្រើនទេ យើងមិនមែនធ្វើការតែម្នាក់ឯងឯណា ។ ប៉ុន្តែយើងខ្លាចប្រជាជនមិនចូលចិត្តយើង ។ ឧទាហរណ៍ គេចែកអំណោយ ខ្ញុំអត់បានដឹងពីរឿងនេះទេ ហើយអ្នកធ្វើការផ្សេងទៀត (សមាជិក គ.អ.ភ) ក៏មិនបានដឹងដែរ រួចទៅគេស្តីអោយយើង ។ គ.អ.ភ អត់មានបានពាក់ព័ន្ធទេ ប៉ុន្តែអ្នកដែលមិនដឹងចេះតែនិយាយអាក្រក់ពីអ្នកធ្វើការទៅ ។ គេយល់ព្រមចូលលុយវិភាគទាន ប៉ុន្តែពេលទឹកជំនន់ ថ្នាក់លើចុះមកចែកអំណោយ ។ អ្នកដែលអត់បានអំណោយខឹងនឹងការងារនេះ ព្រោះគេគិតថា យើងជាអ្នកអោយឈ្មោះទៅគេ ។ ប៉ុន្តែអ្នកដែលធ្វើការនៅខេត្តជាអ្នកចុះមកផ្ទាល់ (ស្ត្រី ដែលជាសមាជិក គ.អ.ភ ក្រុមគ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

មូលហេតុផ្សេងទៀត ដែលអ្នកភូមិមិនចង់បានមុខតំណែងនេះ ប្រហែលជាដោយសារមិនដឹងច្បាស់ថា ជាការងារនោះធ្វើអ្វីខ្លះ ហើយពួកគេមិនមានទំនុកចិត្តលើខ្លួនឯងថា នឹងអាចធ្វើការងារនេះបាន ។

*ខ្ញុំគ្រាន់តែដឹងថាឈ្មោះរបស់ខ្ញុំមាននៅទីនោះ (ក្នុងចំណោមបេក្ខជន) ។ ខ្ញុំប្រាប់អ្នកភូមិថា កុំបោះអោយខ្ញុំ ។ ខ្ញុំមិនចេះដឹងអ្វីទេ ។ ខ្ញុំមិនចង់ធ្វើជាពេទ្យគ្រឡប់ (ភ្នាក់ងារអប់រំសុខភាពភូមិ) ទេ ។ ប៉ុន្តែឥឡូវនៅពេលអ្នកភូមិបោះអោយ ខ្ញុំត្រូវតែធ្វើ ។ មេភូមិអោយខ្ញុំធ្វើការងារនេះ (ប្រមូលទិន្នន័យ*

*ប្រជាជនពីគ្រួសារទីមួយៗ ។ ខ្ញុំមិនដឹងថា ធ្វើដើម្បីអីនោះទេ ។ នៅពេលដែលខ្ញុំចូលទៅតាមផ្ទះនីមួយៗ ម្ចាស់ផ្ទះសួរខ្ញុំថា "ធ្វើជំរឿនអីទៀតហើយ អនិ្នក?" ខ្ញុំឆ្លើយថា "ខ្ញុំអត់ដឹងទេ ខ្ញុំទទួលការងារនេះពីគេ" ខ្ញុំត្រូវចំណាយសៀវភៅ ប៊ិច និងកំលាំងរបស់ខ្ញុំ ហើយខ្ញុំអត់បានអ្វីសោះ ។ កាលមុនមានធ្វើជំរឿននៅក្នុងភូមិដែរ ប៉ុន្តែកាលនោះអ្នកធ្វើជំរឿន ចុះមកភូមិធ្វើខ្លួនគេ ហើយគេពាក់អាវយឺត និងមួកជំរឿន ។ នៅពេលនោះ អ្នកធ្វើជំរឿនបានប្រាប់ខ្ញុំថា "បើសិនអ្នកណាអោយប្អូនធ្វើជំរឿន ហើយប្អូនអត់បានអាវយឺត មួក ប៊ិច សៀវភៅ និងប្រាក់១០ដុល្លារទេ កុំធ្វើ" ។ នៅពេលនេះ មេភូមិអោយខ្ញុំធ្វើជំរឿន ។ ប៉ុន្តែខ្ញុំអត់បានអីសោះ ។ ខ្ញុំនឹងសួរគាត់ពីរឿងនេះ ។ ខ្ញុំទៅប្រជុំបានម្តង ។ មិនទាន់មានវគ្គរៀនសូត្រអីពិតប្រាកដនៅឡើយទេ ។ គ្រូនិយាយថា នៅពេលយើងធ្វើការយូរទៅ យើងនឹងបានទទួលលិខិតបញ្ជាក់ថា យើងជាពេទ្យក្រឡប់ (ភ្នាក់ងារអប់រំសុខភាពភូមិ) ។ ដូច្នេះ នៅពេលខ្ញុំជូនអ្នកណាម្នាក់ទៅពេទ្យដោយកាន់លិខិតនោះទៅជាមួយគេ អត់យកលុយទេ ។ ខ្ញុំមិនទាន់បានជូនអ្នកណាទៅពេទ្យនៅឡើយទេ ។ ប្រសិនបើអ្នកណាម្នាក់មករកខ្ញុំអោយជួយ ខ្ញុំមិនដឹងធ្វើយ៉ាងម៉េចទេ ព្រោះខ្ញុំអត់មានលិខិតស្នាម (ភ្នាក់ងារសុខភាពភូមិ ខែតុលា ឆ្នាំ១៩៩៩ ខែមិនា ឆ្នាំ២០០០) ។*

គោកដូង: គេហៅទៅប្រជុំ

- ដូចនៅក្នុងភូមិជ្រៃងដែរ មុខតំណែងថ្មីដែលទាក់ទិននឹងសកម្មភាពអភិវឌ្ឍន៍ ត្រូវបានបញ្ចូលតាមរយៈការបោះឆ្នោតជ្រើសរើស ឬការចាត់តាំង ។
- មុខតំណែងទាំងនេះត្រូវបានផ្តោតទៅលើតែមនុស្សមួយក្រុមតូចប៉ុណ្ណោះ ដោយរួមមានស្រ្តីចំនួន ៤នាក់ផងដែរ ដោយមានតែមនុស្ស ២នាក់ប៉ុណ្ណោះ ដែលមានមុខតំណែងផ្នែកអាជ្ញាធរ ។
- ដូចនៅភូមិជ្រៃងដែរ អ្នកភូមិមួយចំនួនធំមិនស្គាល់គណៈកម្មការអភិវឌ្ឍន៍ភូមិជាក្រុមទេ ។ អ្នកភូមិស្គាល់បុរស ២នាក់ច្បាស់ជាងគេ ដោយសារការងារនៅធនាគារស្រូវ ។ អ្នកភូមិស្គាល់អ្នកមានមុខតំណែងផ្នែកអភិវឌ្ឍន៍ ដោយសារការហៅទៅប្រជុំ ។
- អ្នកដែលមានមុខតំណែងផ្នែកអភិវឌ្ឍន៍និយាយថា ពួកគេរវល់ក្នុងការធ្វើការងារនេះ ដោយសារពួកគេធ្វើការច្រើន ប៉ុន្តែគ្មានប្រាក់ឧបត្ថម្ភ ។ ទោះជាយ៉ាងណា ពួកគេត្រូវតែធ្វើដោយសារការចាត់តាំង ឬអ្នកភូមិ បានបោះឆ្នោតអោយរួចទៅហើយ ។

នៅភូមិគោកដូង មានការបោះឆ្នោតជ្រើសរើសគណៈកម្មការដែលមានសមាជិក ៤រូប (ដំបូងមាន ៥នាក់ ឥឡូវនៅសល់ស្ត្រី ២នាក់ បុរស ២នាក់) ទទួលខុសត្រូវសកម្មភាពដែលផ្តល់ថវិកាដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកឈ្មោះអភិវឌ្ឍន៍ស្ត្រី និងមានគណៈកម្មការអភិវឌ្ឍន៍ភូមិ[៩] ។ មានសមាជិក ៧រូប បោះឆ្នោតដោយអ្នកភូមិ (ស្ត្រី ៣នាក់ បុរស ៤នាក់) ។ ភ្នាក់ងារអប់រំសុខភាពភូមិ ៥នាក់ (ស្ត្រី៣នាក់ បុរស ២នាក់) ត្រូវបានបោះឆ្នោតជ្រើសរើសដោយអ្នកភូមិនៅឆ្នាំ១៩៩៦ ។ ប៉ុន្តែមានស្ត្រីម្នាក់គត់នៅធ្វើការ ហើយអ្នកភូមិដឹងថា គាត់ធ្វើការងារនេះ ។ ភ្នាក់ងារ

---

[៩] នៅទីនេះ ខ្ញុំហៅមនុស្សមួយក្រុមដែលដំណើរការធនាគារស្រូវ គណទាន និងកម្មវិធីចិញ្ចឹមគោរបស់គណៈកម្មការអភិវឌ្ឍន៍ស្ត្រី ។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងដោយ PDRD ខ្ញុំហៅថា គ.អ.ភ ។ ជាទូទៅអ្នកភូមិនិយាយថា គណៈកម្មការអភិវឌ្ឍន៍ស្ត្រីជា "អ្នកធ្វើការខាងជង្រុកស្រូវ" ប៉ុន្តែសមាជិកទាំងនោះហៅថា "គណៈកម្មការសហគមន៍" អភិវឌ្ឍន៍ស្ត្រី និង "ក្រុមធ្វើប្រឡាយ" ឬ "ក្រុមសិលា" (គ.អ.ភ) ។

អប់រំសុខភាពភូមិដែលជាស្ត្រីម្នាក់ ក៏មានតួនាទីជាភ្នាក់ងារស្ម័គ្រចិត្តកាកបាទក្រហមដែរ ហើយអ្នកភូមិស្ទើរតែទាំងអស់មិនស្គាល់ ។ មានការខិតខំប្រឹងប្រែងក្នុងការបង្កើតអោយ មានពេទ្យសត្វភូមិ ប៉ុន្តែឥឡូវនេះមិនទាន់ដឹងថាអ្នកណានឹងក្លាយជាពេទ្យសត្វនៅឡើយទេ ។

| ស្រី/ប្រុស | មុខតំណែងផ្នែកអភិវឌ្ឍន៍ | មុខតំណែងផ្នែកអាជ្ញាធរ |
|---|---|---|
| ប | ប្រធាន គ.អ.ភ. សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី | អតីតតំណាងសមាគមយុវជន |
| ប | លេខា គ.អ.ភ. ប្រធាន គណៈកម្មការអភិវឌ្ឍន៍ស្ត្រី | អតីតតំណាងសមាគមយុវជន. មេក្រុម |
| ស | សមាជិកគ.អ.ភ. សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី. ភ្នាក់ងារអប់រំសុខភាពភូមិ | |
| ស | អនុប្រធានគ.អ.ភ. ភ្នាក់ងារអប់រំសុខភាពភូមិ ប្រធានក្រុមផ្លូវចិត្ត | |
| ស | សមាជិក គ.អ.ភ. ភ្នាក់ងារអប់រំសុខភាពភូមិ. ភ្នាក់ងារស្ម័គ្រចិត្តកាកបាទក្រហម. ប្រធានក្រុមផ្លូវចិត្ត | |
| ប | សមាជិក គ.អ.ភ. ភ្នាក់ងារអប់រំសុខភាពភូមិ | |
| ប | សមាជិក គ.អ.ភ | |
| ស | សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី | |
| ប | ភ្នាក់ងារអប់រំសុខភាពភូមិ. ប្រធានក្រុមផ្លូវចិត្ត | |
| ប | ប្រធានក្រុមផ្លូវចិត្ត | ប្រធានភូមិ |

អ្នកដែលមានមុខតំណែងទាក់ទងទៅនឹងសកម្មភាពអភិវឌ្ឍន៍មួយផ្នែកធំ គឺជាមនុស្សដដែល។ ។ សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី ៣នាក់ ក្នុងចំណោម ៤នាក់ ក៏ជាសមាជិកគអភដែរ ។ ភ្នាក់ងារអប់រំសុខភាពភូមិ ៤នាក់ក្នុងចំណោម ៥នាក់ ក៏ជាសមាជិក គ.អ.ភ ដែរ ហើយម្នាក់ក្នុងចំណោមអ្នកទាំង៤ ក៏ជាគណៈកម្មការអភិវឌ្ឍន៍ស្ត្រីដែរ ។ ក្នុងចំណោមអ្នកភូមិ ៤នាក់ (បុរស ២នាក់ ស្ត្រី ២នាក់) ដែលត្រូវបានជ្រើសរើសអោយធ្វើជាប្រធានផ្លូវចិត្ត មានបីនាក់ក្នុងចំណោមអ្នកទាំងនោះ មានមុខតំណែងដូចដែលបានរៀបរាប់ខាងលើមួយ ឬច្រើនរួចទៅហើយ ។ ប៉ុន្តែ ២នាក់ក្នុងចំណោមអ្នកទាំងនេះដែលទើបតែមានមុខតំណែងផ្នែកការងារអភិវឌ្ឍន៍ក៏មាន ឬធ្លាប់មានមុខតំណែងផ្នែកអាជ្ញាធរដែរ ។ បុរស ២នាក់ ដែលជាសមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី និងជាសមាជិកគ.អ.ភ ធ្លាប់ជាតំណាងសមាគមយុវជនរហូតដល់ដើមឆ្នាំ១៩៩០ ម្នាក់ក្នុងចំណោមអ្នកទាំង២ ក៏ជាមេក្រុមផងដែរ ។ សកម្មភាពអភិវឌ្ឍន៍បានផ្តល់មុខតំណែងជាផ្លូវការមួយ ឬច្រើន អោយស្ត្រីចំនួន ៤នាក់នៅក្នុងភូមិ ។

អ្នកភូមិចាស់ និងជនមាតុភូមិនិវត្តន៍ភាគច្រើន មិនស្គាល់ គ.អ.ភ ជាក្រុមទេ ។ អ្នកភូមិជ្រើសរើសគណៈកម្មការនេះនៅខែធ្នូ ឆ្នាំ១៩៩៧ ដែលមានបេក្ខជន ១២រូប ។ ប៉ុន្តែតាំងពីពេលនោះមក លទ្ធផលដែលបានឃើញ

ផ្ទាល់ភ្នែក គឺការស្តារប្រឡាយនៅឆ្នាំ១៩៩៨ ដែលអ្នកភូមិមួយចំនួនតូចប៉ុណ្ណោះ បានទទួលផលប្រយោជន៍ពីប្រឡាយនោះ ។ ប៉ុន្តែអ្នកភូមិស្គាល់សមាជិកគ.អ.ភ មួយចំនួនដោយសារភារកិច្ចជាក់លាក់ ជាពិសេសការងារដែលទាក់ទងនឹងសកម្មភាពអភិវឌ្ឍន៍ស្ត្រី និងការថែទាំសុខភាព ។ បុរស ២នាក់ដែលត្រូវបាននិយាយនៅខាងលើជាប្រធាន គ.អភ/សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី និងប្រធានគណៈកម្មការអភិវឌ្ឍន៍ស្ត្រី/លេខាគ.អ.ភ ជាអ្នកសកម្មបំផុត និងត្រូវបានគេស្គាល់ថា ជាអ្នកធ្វើការងារខាងអភិវឌ្ឍន៍នៅក្នុងភូមិ ។ សកម្មភាពអភិវឌ្ឍន៍ដែលត្រូវបានអ្នកភូមិស្គាល់ច្បាស់ជាងគេនោះ គឺដំណើរការធនាគារស្រូវ ។ អ្នកទាំង២ ក៏ត្រូវបានគេស្គាល់ថាជាអ្នកធ្វើការខាងធនាគារស្រូវនេះដែរ ប៉ុន្តែអ្នកភូមិមួយចំនួន និយាយថា ម្នាក់ក្នុងចំណោមអ្នកទាំង២ ក៏ជាអ្នកមើលការខុសត្រូវខាងប្រឡាយដែរ ។

អ្នកភូមិមិនសូវស្គាល់សមាជិកផ្សេងទៀតរបស់គណៈកម្មការទាំង២ទេ ហើយអ្នកទាំងអស់នោះ ក៏មិនសូវសកម្មដូចបុរសទាំង២នេះដែរ ។ សមាជិក២នាក់ផ្សេងទៀតរបស់គណៈកម្មការអភិវឌ្ឍន៍ស្ត្រី ជាទូទៅធ្វើការខាងធនាគារស្រូវ ប៉ុន្តែសមាជិកគ.អ.ភ ផ្សេងទៀត ប្រហែលជាគេស្គាល់ថា ជាអតីត ឬបច្ចុប្បន្នជាភ្នាក់ងារអប់រំសុខភាព ។ ទោះជាការងារពាក់ព័ន្ធនឹងធនាគារស្រូវ ឬឥណទាន ការចិញ្ចឹមគោ ការលើកផ្លូវ ប្រឡាយ ឬការថែទាំសុខភាពក៏ដោយ អ្នកភូមិដឹងពីការងាររបស់អ្នកដែលមានមុខតំណែងផ្នែកការងារអភិវឌ្ឍន៍ច្រើនខ្លះនោះគឺ "ការហៅទៅប្រជុំ" ។

អ្នកដែលមាន ឬធ្លាប់មានមុខតំណែងទាក់ទិននឹងសកម្មភាពអភិវឌ្ឍន៍និយាយថា ពួកគេរវល់ក្នុងការទទួលយកមុខតំណែងនេះ ។ មូលហេតុសំខាន់ គឺមានការងារច្រើន គ្មានប្រាក់ឧបត្ថម្ភ ហើយមនុស្សជាច្រើននិយាយពីអ្នកដែលមានមុខតំណែងផ្នែកការងារអភិវឌ្ឍន៍នេះថា "ធ្លាប់ទៅហើយ" ។ សូម្បីតែការសង្ឃឹមថា បានទទួលប្រាក់ឧបត្ថម្ភនៅពេលចូលរួមវគ្គបណ្តុះបណ្តាល ហាក់ដូចជាមិនមានដូចនៅភូមិជ្រៃងទេ ។ ប៉ុន្តែដូចនៅភូមិជ្រៃងដែរ ប្រជាជនគិតថា ត្រូវតែទទួលយកមុខតំណែងប្រសិនបើគេអោយធ្វើ ។ ជាពិសេស បើសិនជាអ្នកភូមិ បានបោះឆ្នោតអោយអ្នក អ្នកមិនអាចប្រកែកបានទេ ។ ហើយនៅពេលដែលអ្នកចាប់ផ្តើមធ្វើការងារហើយ អ្នកមិនអាចឈប់បានទេ លុះត្រាតែការងារនោះចប់សិន ។ វិធីតែមួយគត់ដែលគេយល់ឃើញថា អាចជៀសផុតពីការមានមុខតំណែងបាន គឺព្យាយាមបញ្ចុះបញ្ចូលអ្នកភូមិអោយបោះឆ្នោតអោយអ្នកផ្សេង ឬកុំនៅក្នុងភូមិពេលបោះឆ្នោត ។

*រិន (បុគ្គលិកអង្គការអភិវឌ្ឍន៍ស្ត្រី) និងមេភូមិអោយខ្ញុំឈរឈ្មោះ (បោះឆ្នោត គ.អ.ភ) ។ ដំបូងខ្ញុំប្រកែក ។ ខ្ញុំថា ខ្ញុំមានមុខតំណែងពីរហើយ ខ្ញុំមិនចង់បានទៀតទេ ។ ប៉ុន្តែពួកគាត់ប្រាប់ខ្ញុំថា "ចេះតែឈរទៅ អ្នកភូមិមិនបោះឆ្នោតអោយទេ ព្រោះឯងមានមុខងារពីរហើយ" ។ ស្រាប់តែអ្នកភូមិបោះឆ្នោតអោយខ្ញុំទៀត (ភ្នាក់ងារអប់រំសុខភាពភូមិ ស្ត្រី ខែមេសា ឆ្នាំ២០០០) ។*

*អ្នកផ្សេងទៀតចង់ឈប់ ។ គេចង់គេច ប៉ុន្តែគេមិនអាចធ្វើទៅបាន ព្រោះថាបើមានការបោះឆ្នោត ជាប់ឆ្នោតទៀតហើយ ។ ផ្លូវតែមួយគត់ គឺគេចនៅពេលបោះឆ្នោត ។ បើយើងនៅតែឈរឈ្មោះអ្នកភូមិនៅតែបោះអោយយើងដដែល (សមាជិកគ.អ.ភប្រុស ខែមេសា ឆ្នាំ២០០០) ។*

*ខ្ញុំក៏មានឈ្មោះជាបេក្ខជន (បោះឆ្នោត គ.អ.ភ ដែរ) ។ ប៉ុន្តែ (នៅថ្ងៃបោះឆ្នោត) ខ្ញុំទៅវាល ព្រោះខ្ញុំមិនចង់ ។ គ្មានអ្នកណាចង់ទេ ប៉ុន្តែអ្នកភូមិបោះអោយ អញ្ចឹងគេត្រូវតែធ្វើ ។ ខ្ញុំធ្វើការតាំងពីឆ្នាំ១៩៧៩ អញ្ចឹងគេស្រួលប្រើខ្ញុំ ។ ប៉ុន្តែឥឡូវខ្ញុំអោយគេធ្វើជំនួសខ្ញុំម្តង ។ ខ្ញុំធ្លាប់ធ្វើជាពេទ្យសត្វភូមិដែរ ។ ខ្ញុំធ្លាប់ចាក់ថ្នាំអោយគោ និងមាន់ ប៉ុន្តែអោយខ្ញុំធ្វើការងារនេះម៉េចទៅ? ខ្ញុំអត់មានប្រាក់ខែ គេអោយតែលុយទិញថ្នាំចាក់ ។ ម៉ាល្ងាច ខ្ញុំដើរចាក់បានតែបីផ្ទះទេ ព្រោះមាន់ច្រើនពេក ។ ខ្ញុំអត់បានលុយ ហើយខ្ញុំទិញចារីជក់ខ្លួនឯង ។ ដូច្នេះចូរនិយាយថា ខ្ញុំមិនមែនជាពេទ្យសត្វភូមិទៀតទេ (មេក្រុម ខែមេសា ឆ្នាំ២០០០) ។*

ប៉ុន្តែយ៉ាងហោចណាស់ក៏មានមនុស្សពីរនាក់ដែលអ្នកភូមិចូលចិត្ត និងគោរព បានលាលែងពីមុខតំណែង ដែលពីមុនជាអាជ្ញាធរ ឬខាងការងារអភិវឌ្ឍន៍ និងដែលត្រូវបានគេសុំអោយឈរឈ្មោះជាបេក្ខជននៅក្នុងការបោះឆ្នោតគ.អ.ភ ប៉ុន្តែជាអ្នកដែលអាចប្រកែកបាន ។ ប៉ុន្តែម្នាក់ក្នុងចំណោមអ្នកទាំង២ កូនចុងរបស់គាត់ត្រូវបានគេបញ្ចុះបញ្ចូលអោយចូលធ្វើការជំនួសសមាជិកគ.អ.ភម្នាក់ ដែលបានលាឈប់ ។

*និយាយពីរឿងបោះឆ្នោតជ្រើសរើសគណៈកម្មការអភិវឌ្ឍន៍ស្ត្រីលើកទី២:*
ខ្ញុំពាក់ផ្លាកលេខ៤ ។ ប៉ុន្តែខ្ញុំដើរប្រាប់ប្រជាជនអោយបោះឆ្នោតអោយលេខ៦ ហើយលេខ៦ ក៏ជាប់ ។

*និយាយពីរឿងបោះឆ្នោតជ្រើសរើសគណៈកម្មការអភិវឌ្ឍន៍ភូមិ:*
គេចង់អោយខ្ញុំឈរឈ្មោះ ប៉ុន្តែខ្ញុំថា ទេ ។ ខ្ញុំមានសិទ្ធិ សូម្បីតែគង់ ក៏គេអោយគាត់ឈរឈ្មោះដែរ ប៉ុន្តែគាត់ប្រកែក ។

*និយាយពីរឿងកូនចុងរបស់គាត់ដែលក្លាយជាសមាជិក គ.អ.ភ ដោយគាត់មិនបានដឹង:*
បើសិនជាខ្ញុំដឹង ខ្ញុំមិនអោយវាធ្វើទេ ។ វាស្រួលប្រើ វាល្អ ប៉ុន្តែល្ងង់ វាធ្វើស្អីតាមតែគេ (មេភូមិ និងអ្នកដឹកនាំការងារអភិវឌ្ឍន៍ពីនាក់ទៀត) ប្រាប់អោយវាធ្វើ ។ គេប្រើវាធ្វើសព្វបែបយ៉ាង ។ ឧទាហរណ៍នៅពេលមេភូមិមិនហ៊ានប្រាប់អ្នកលេងល្បែងអោយឈប់នៅពេលអ្នកទាំង៣ (ក្រុមសិក្សា) នៅទីនេះគាត់ប្រើកូនខ្ញុំអោយទៅប្រាប់ពួកគេជំនួស (មេក្រុម ខែមេសា ឆ្នាំ២០០០) ។

## *ការផ្លាស់ប្តូរចេនាសម្ព័ន្ធផ្នែកអំណាច*

*ជ្រែង អំណាចដែលមានស្រាប់ បានពង្រីកការគ្រប់គ្រងរបស់គេ ហើយកាន់តែអន់ថយ*

- បទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍បានធ្វើអោយអ្នកដឹកនាំក្នុងភូមិពីរនាក់កាន់តែមានអំណាច ប៉ុន្តែក៏កាន់តែអន់ថយដែរ ។
- មេភូមិ/ប្រធាន គ.អ.ភ គ្រប់គ្រងគណៈកម្មការអភិវឌ្ឍន៍ភូមិ និងប្រគល់ការទទួលខុសត្រូវអោយទៅបុរសច្រើនជាងស្ត្រី ។
- មានសមាជិក គ.អ.ភ មួយចំនួនតូច និងអ្នកដទៃទៀតអាចក្លាយជាអ្នកដឹកនាំជំនួសមេភូមិបាន ។

- បទអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ បានប៉ះពាល់ដល់តួនាទីរបស់ព្រះសង្ឃ មួយចំណែកគេកំពុងបន្តការងាររបស់ព្រះសង្ឃ ហើយមួយចំណែកទៀត កំពុងទាក់ទាញព្រះសង្ឃអោយចូលរួមក្នុងការងាររបស់គេ ។

នៅភូមិជ្រៃងមុខតំណែងថ្មីនៃការងារអភិវឌ្ឍន៍ ត្រូវបានទទួលយកដោយអ្នកដែលមានមុខតំណែងផ្នែកអាជ្ញាធររួចហើយ ដែលគ្រប់គ្រងដោយមេភូមិ និងត្រួតពិនិត្យដោយជីវពលម្នាក់ដែលចង់គ្រប់គ្រងសកម្មភាព និងធនធានទាំងឡាយ ។

តាមសំដីរបស់អ្នកភូមិ នៅពេលបោះឆ្នោតគ.អ.ភទាំងពីរលើក ហាក់ដូចជាគ្មានចំងល់ថា មេភូមិមិនគួរជាប្រធានគ.អ.ភទេ ។ ដូចដែលបានបង្ហាញអោយដឹងរួចមកហើយថា គាត់គឺជាមនុស្សម្នាក់ ដែលអ្នកភូមិចាត់ទុកថាជាឪពុករបស់ពួកគេ ។ ប៉ុន្តែឥឡូវនេះហាក់ដូចជាថាអ្នកភូមិ និងមិនបោះឆ្នោតអោយមេភូមិនៅពេលមានការឆ្នោតលើកក្រោយទៀតទេ ។

*ប្រជាជនមិនស្មានថា មានបញ្ហាទេ ។ កាលពីមុន គាត់មានមុខតំណែងតែមួយគត់ ហើយប្រជាជនគិតថា គាត់អាចធ្វើបានមួយទៀត ។ ប៉ុន្តែតាមការពិត... (ភ្នាក់ងារសុខភាពភូមិប្រុស. ក្រុមផ្តល់យោបល់ស្ត្រី/ប្រុស ខែមិនា ឆ្នាំ២០០០) ។*

ទោះអ្នកភូមិមិនបោះឆ្នោតអោយជីវពលនេះនៅក្នុងការបោះឆ្នោត គ.អ.ភ ក៏ដោយ គាត់នៅតែគ្រប់គ្រងសកម្មភាព និងជាអ្នកធ្វើការងារអភិវឌ្ឍន៍ដទៃទៀតដដែល១ ហើយជាទូទៅគាត់ គឺជាមនុស្សតែម្នាក់គត់ដែលប្រកាសដំណឹងតាមមីក្រូ ។

*ទោះជាខ្ញុំឈប់ពីការងារអភិវឌ្ឍន៍ក៏ដោយ ខ្ញុំនៅតែមានសិទ្ធិប្តឹងអ្នកធ្វើការងារអភិវឌ្ឍន៍ ។ ខ្ញុំថា "អ្នកឯងនៅខាងអភិវឌ្ឍន៍ ប៉ុន្តែអ្នកឯងនៅក្រោមរដ្ឋអំណាចរបស់ខ្ញុំ" ។ ប្រសិនបើគ្មានការងាររដ្ឋាភិបាលទេ ការងារអភិវឌ្ឍន៍នឹងពិបាកក្នុងការប្រើកំលាំង ។ ខ្ញុំដាច់ខាតត្រូវតែចូលរួម បើសិនការងារណាមួយត្រូវអនុវត្ត ។ បើសិនជាមានប្រជុំ គ.អ.ភ ហើយខ្ញុំមិនបានចូលរួមទៅមិនរួចទេ ។ ខ្ញុំចូលរួមប្រជុំជាមួយសមាជិកគ.អ.ភ ព្រោះគេអញ្ជើញខ្ញុំ ។ ប្រធានគ.អ.ភ ត្រូវឱ្យខ្ញុំចូលរួម ព្រោះការងារណាក៏ដោយនៅក្នុងភូមិ... បើមានតែការអភិវឌ្ឍន៍ ហើយគ្មានការងាររដ្ឋាភិបាល គ្មានការងាររដ្ឋអំណាចទេ... ខ្ញុំដាច់ខាតត្រូវចូលរួមជាមួយគេ ដើម្បីដោះស្រាយបញ្ហា (ជីវពល ខែមិនា ឆ្នាំ២០០០) ។*

*គាត់ (ជីវពល) ចូលរួមខ្លះ ។ គាត់ជួយប្រកួតប្រកាស ឧទាហរណ៍ អ្នកភូមិចង់លើកផ្លូវ គឺខាងរដ្ឋអំណាច ។ គាត់មិនលូកដៃក្នុងគ.អ.ភទេ ប៉ុន្តែជាមួយរដ្ឋអំណាច ។ គាត់ជួយយើងដែរដូចជាជួយមើលការខុសត្រូវ ។ មានន័យថា គ.អ.ភ មិនមែនធ្វើការងារអភិវឌ្ឍន៍តែម្នាក់ឯងទេ រដ្ឋអំណាចមូលដ្ឋាន ក៏ជួយប្រកាសដែរ ។ ពេលស្នើសុំកំលាំង យើងទាក់ទងជាមួយរដ្ឋអំណាចដើម្បីបានប្រជាជនមកធ្វើការ ។ ដូច្នេះរដ្ឋអំណាចដូច ហ៊ន អនុខ្ញុំត្រូវតែចូលរួមនៅពេលដែលប្រជាជនចង់ធ្វើការ ។ មានន័យថា ហ៊នចូលរួមក្នុងគណៈកម្មការ ប៉ុន្តែគាត់មិនដែលចូលរួមក្នុងការប្រជុំគណៈកម្មការដូចនេះទេ (ក្រុម គ.អ.ភ ស្ត្រី/ប្រុស ខែមិនា ឆ្នាំ២០០០) ។*

មេភូមិប្រើមុខតំណែងនេះ ដើម្បីជ្រើសរើសបេក្ខជនឈរឈ្មោះបោះឆ្នោត និងជ្រើសតាំងមនុស្សអោយមានមុខតំណែង ហើយក៏ដើម្បីបែងចែកផលប្រយោជន៍យ៉ាងច្រើនដែលគាត់ត្រូវការ ។ ដូចដែលបានជំរាបជូនរួចមកហើយថា មានការប្រកួតប្រជែងគ្នាមួយចំនួនក្នុងការទៅចូលរួមវគ្គបណ្តុះបណ្តាលដែលមានប្រាក់ឧបត្ថម្ភ ហើយមេភូមិមិនញញើតក្នុងការត្រៀមយកឱកាសទាំងនេះ ដើម្បីរកលុយក្រៅសំរាប់ខ្លួនគាត់ និងបក្សពួកគាត់ទេ ។ ថ្នាក់អក្ខរកម្មនៅឆ្នាំ១៩៩៧ គឺជាឧទាហរណ៍ដែលគួរអោយចាប់អារម្មណ៍ ។ មេភូមិតែងតាំងខ្លួនឯងធ្វើជាគ្រូ ដោយគាត់បានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ប៉ុន្តែអត់មានសិស្សច្រើនទេ ។

*ខ្ញុំមិនចូលរៀនថ្នាក់អក្ខរកម្មទេ ព្រោះគ្រូមើលទៅមិនចេះជាងខ្ញុំប៉ុន្មានទេ (ភ្នាក់ងារសុខភាពភូមិ ប្រុស ខែមិនា ឆ្នាំ២០០០) ។*

ស្រដៀងគ្នានឹងនេះដែរ សមាជិកគ.អ.ភ ម្នាក់ដែលមិន "នៅខាង" មេភូមិ បានចាប់ផ្តើមទៅចូលរួមវគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិ ។

*គេអោយខ្ញុំទៅរៀន ហើយទៅច្រើនថ្ងៃ ។ អ្នកខេត្តជាអ្នកសំរេចថា ខ្ញុំគួរតែទៅ គេស្គាល់ខ្ញុំតាមរយៈឃុំ ។ ប៉ុន្តែនៅថ្ងៃចុងក្រោយនៅពេលគេចែកសំភារៈ យើងអាចធ្វើជាពេទ្យសត្វភូមិបាន ទោះមិនមែនជាឈ្មោះខ្ញុំក៏ដោយ ។ មេភូមិអោយជីវពលទៅជំនួសខ្ញុំ ។ គាត់បានម្ជុល និងសារាង (សមាជិក គ.អ.ភ ខែតុលា ឆ្នាំ១៩៩៩) ។*

ដូច្នេះ នៅភូមិជ្រែង បទអន្តរាគមន៍ និងធនធានផ្នែកអភិវឌ្ឍន៍ បានបង្កើតការទាក់ទាញអារម្មណ៍ដែលមេភូមិ និងជីវពល មិនអាចទប់ទល់ ឆក់យកឱកាសណាដែលផ្តល់ប្រយោជន៍ដល់ពួកគេបានទេ ។ ដោយការរំលោភបំពានខាងអំណាចរបស់ពួកគេមានលក្ខណៈកាន់តែច្បាស់លាស់ឡើងៗ ពួកគេក៏កំពុងតែទទួលរងនូវការរិះគន់កាន់តែខ្លាំងឡើងៗដែរ ។ ការគ្រប់គ្រងមិនច្បាស់លាស់របស់ពួកគេ និងភាពមិនសប្បាយចិត្តរបស់អ្នកភូមិហាក់ដូចជាបានធ្វើអោយចេទាសម្ព័ន្ធនៃការដឹកនាំទន់ខ្សោយ ។

ការប្រមូលផ្តុំអំណាចរបស់អ្នកដឹកនាំណាម្នាក់ដែលគិតតែផលប្រយោជន៍ផ្ទាល់ខ្លួន បានធ្វើអោយសមាជិក គ.អ.ភ ដទៃទៀតបាក់ទឹកចិត្តយ៉ាងខ្លាំង ដោយសារតែឥទ្ធិពលរបស់ជីវពលម្នាក់នេះ ។ ការសំរេចការងារជាមួយនឹង គ.អ.ភ បានបន្សល់ទុកនូវភាពមិនច្បាស់លាស់ ដែលវាហាក់ដូចជាស្រេចតែលើអ្នកដឹកនាំសំរេច និងប្រគល់ភារកិច្ចដែលគាត់យល់ថាសមរម្យ ។ ស្ត្រីពីរនាក់នេះមិនមានទំនុកចិត្តក្នុងការដឹកនាំរបស់ខ្លួន ហើយមានភារកិច្ចទទួលខុសត្រូវតិចជាងបុរស ។

*មូលហេតុទីមួយ (ដែលខ្ញុំក្លាយប្រធានគ.អ.ភ) ដោយសារខ្ញុំបានសំលេងឆ្នោតច្រើនជាងគេ ។ មូលហេតុទីពីរ គឺដោយមានការសំរេចរបស់រូលពីស្រុក និងលុះន លី (CARERELCB) ឃើញសមត្ថភាពរបស់ខ្ញុំ ។ គេបានសំរេចថា ខ្ញុំគួរធ្វើជាប្រធាន ។ នៅភូមិផ្សេងទៀតអ្នកដែលបានសំលេងឆ្នោតច្រើនជាងគេមិនមាន សមត្ថភាពល្អ គេមិនអោយធ្វើជាប្រធានទេ ។ ប្រធាន គ.អ.ភ ជាអ្នកសំរេចថាអ្នកណាត្រូវមានមុខតំណែងផ្សេងៗនៅក្នុងគ.អ.ភ ។ គាត់អាចឃើញសមត្ថភាពរបស់ពួកគេ ។ វាមិន*

*ផ្តែកលើសំលេងឆ្នោតទេ ។ ឆិល ជាអនុប្រធាន ប៉ុន្តែវណ្ណី មិនអាចកាន់លុយបាន ដូច្នេះខ្ញុំធ្វើការផ្លាស់ប្តូរ (មេភូមិ ប្រធាន គ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

*បើអ្នកមានមុខតំណែងចង់ធ្វើអីល្អ អ្នកផ្សេងទៀត (ជីវពល) ចង់ធ្វើអីផ្សេងវិញ ។ ម្នាក់នេះតែងតែជ្រៀតជ្រែកគេ ។ អ្នកផ្សេងធ្វើការល្អ ប៉ុន្តែគាត់បំផ្លាញគេ (សមាជិកគ.អ.ភ ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

*តួនាទីរបស់ខ្ញុំគឺធ្វើបញ្ជី ឧទាហរណ៍នៅពេលដែលយើងប្រមូលវិភាគទាន ។ ប៉ុន្តែខ្ញុំមិនដែលធ្វើទេ គណៈកម្មការឃុំអោយឆិល (អនុប្រធាន គ.អ.ភ) ជាអ្នកធ្វើ ដូចជាលុយថ្ងៃជី (មេភូមិ. ប្រធាន គ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

*ទេ ស្ត្រីមិនដែលទទួលខុសត្រូវខាងហិរញ្ញវត្ថុទេ ។ អ្នកកាន់លុយត្រូវតែចេះ និងមានសមត្ថភាព (មេភូមិ ប្រធានគ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

សមាជិកដទៃពឹងផ្អែកទៅលើតែប្រធានក្នុងការទទួលពត៌មានពីថ្នាក់លើដែលគាត់មិនសូវបានទទួល ឬផ្សព្វផ្សាយបន្ត ។ ដូច្នេះការគ្រប់គ្រងរបស់ប្រធាន និងការពឹងផ្អែកលើប្រធាន ដោយមួយផ្នែកការពារអ្នកផ្សេងមិនអោយទៅធ្វើការងារណាដែលគេចង់ធ្វើ និងមិនអោយគេបានទទួលបទពិសោធន៍និងចំណេះដឹង ដើម្បីផ្តល់ការដឹកនាំជំនួស ។ ប៉ុន្តែការគ្រប់គ្រងដែលមានលក្ខណៈមិនច្បាស់លាស់របស់មេភូមិ និងជីវពលបន្ថែមទៅលើតួរនាទីការរបស់អ្នកដឹកនាំដទៃទៀត ហើយទោះជាមានឧបសគ្គក៏ដោយ សមាជិកគ.អ.ភមួយចំនួន និងអ្នកដទៃមួយចំនួនតូចទៀតដែលមានមុខតំណែងផ្នែកការងារអភិវឌ្ឍន៍ក្រៅផ្លូវការ ហាក់ដូចជាកំពុងមានការខិតខំប្រឹងប្រែងផ្ទាល់ខ្លួនព្រមទាំងបានទទួលការទុកចិត្តពីអ្នកភូមិ ។ ទោះជាអ្នកដឹកនាំដែលមានសក្តានុពលមិនហ៊ានទទួលយកតួនាទីដឹកនាំ ឬភារកិច្ចណាដែលនៅក្រៅការគ្រប់គ្រងរបស់ពួកគេនៅឡើយក៏ដោយ ពួកគេអាចកំពុងទទួលបាននូវការប្តេជ្ញា និងទំនុកចិត្តរបស់ខ្លួន (សូមអានអត្ថបទស្តីពីការមានឱកាស និងការទទួលខុសត្រូវចំពោះអ្នកភូមិ) ។

*អ្នកខ្លះមករកខ្ញុំអោយដោះស្រាយពីរឿងជម្លោះ ។ ខ្ញុំប្រាប់ពួកគេថា ខ្ញុំមិនមែនធ្វើការខាងរឿងឈ្លោះប្រកែកគ្នាទេ ខ្ញុំធ្វើតែរឿងអណ្តូង និងស្រះ ហើយនិង... អ្នកខ្លះរាយការណ៍ប្រាប់ខ្ញុំទាំងអស់គេ អោយខ្ញុំណែនាំ ប៉ុន្តែខ្ញុំអត់មានជំនាញទេ ។ ខ្ញុំមិនហ៊ានធ្វើអ្វីដែលមិនមែនជាមុខងាររបស់ខ្ញុំទេ ដូចជាជម្លោះជាដើម (សមាជិក គ.អ.ភ ប្រុស ខែមិនា ឆ្នាំ២០០០) ។*

*ខ្ញុំនឹងមិនបោះឆ្នោតអោយអ្នកដឹកនាំចាស់ៗទេ ពួកគេពុករលួយ ។ ប៉ុន្តែមានអ្នកផ្សេង (ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

អន្តរាគមន៍ផ្នែកការងារអភិវឌ្ឍន៍នៅភូមិជ្រែង មួយផ្នែកធ្វើការងារដែលព្រះសង្ឃ អាចារ្យ និងចាស់ព្រឹទ្ធាចារ្យ ធ្លាប់ធ្វើដូចជាការអង្វេរសបច្ច័យ ហៅអ្នកភូមិលើកថ្នល់ ជុំវិញវត្តភូមិ និងស្ពាន ។ អន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ បានធ្វើឱ្យមានសញ្ញាណ និងភស្តុតាង ដែលបញ្ជាក់ថា ព្រះសង្ឃឈប់ធ្វើការងារមួយចំនួននេះ ដោយទុកអោយអង្គការអភិវឌ្ឍន៍ធ្វើសកម្មភាពនៅក្នុងភូមិជំនួសវិញ ហើយគិតតួរតែពីរឿងទីធ្លាវត្ត ។ ប៉ុន្តែក៏មានសញ្ញា និងភស្តុតាងដែលព្រះសង្ឃចូលរួមយ៉ាងសំខាន់នៅក្នុងគំរោងអភិវឌ្ឍន៍ភូមិ ជាពិសេសក្នុងការប្រកួកប្រកាសប្រជាជន

អោយចូលរួមជាកំលាំងពលកម្ម និងជាថវិកា ។ ដោយសារមានអន្តរាគមន៍ផ្នែកការងារអភិវឌ្ឍន៍ ដូច្នេះទស្សនៈខ្លះយល់ឃើញថា ព្រះសង្ឃប្រហែលជា "សំរាក" ប៉ុន្តែឋានៈ និងអំណាចរបស់ព្រះអង្គ អាចនៅតង់វង្ស និងកាន់តែទូលាយទៅដោយសារការចូលរួមរបស់ព្រះអង្គ ។

*ប្រជាជនមានការលំបាកក្នុងការធ្វើដំណើរតាមផ្លូវ គេដើរកាត់ទឹក កាត់ភក់ ។ ដូច្នេះគេរអ៊ូពីរឿងផ្លូវដាក់គណៈកម្មការអាចារ្យនៅក្នុងភូមិ ។ ពួកគេនិយាយថា "ទៅនិមន្តអោយប្រកូកប្រកាសហៅអ្នកភូមិអោយជួសជុលផ្លូវនេះម៉ោ" ។ អញ្ចឹង វាបានជាផ្លូវហើយ ។ ឥឡូវនេះ មានអង្គការ ហើយអង្គការជួយ ។ ប្រសិនអង្គការមិនជួយ វានៅតែដំណើរបានដដែល ប៉ុន្តែយើងអត់មានគ្រួសក្រហម (អាចារ្យ ខែមិនា ឆ្នាំ២០០០) ។*

*កាលពីដើម ចាស់ៗប្រកូកប្រកាសអ្នកភូមិអោយលើកផ្លូវដោយគ្មានបានរបបទេ ។ ឥឡូវនេះអង្គការអាចប្រើមេភូមិ ឆិល ប៊ី និង វណ្ណី (សមាជិក គ.អ.ភ ស្រី/ប្រុស) ដើម្បីប្រកូកប្រកាសអ្នកភូមិអោយលើកផ្លូវ ព្រោះអង្គការមានលុយជូលអ្នកភូមិ (ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

*ឥឡូវនេះ ព្រះសង្ឃមិនសូវចូលរួមលើកផ្លូវទេ ដោយសារអង្គការជួលអ្នកភូមិ (ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

*អាចារ្យ និងព្រះសង្ឃ ជួយអោយបានសាលារៀន ហើយនាំក្មេងៗ និងអ្នកភូមិផ្សេងៗទៀតលើកផ្លូវ ។ គេបញ្ចេះម៉ាស៊ីនភ្លើង និងដាក់អំពូលភ្លើង ។ បើសិនពិបាកប្រមូលអ្នកភូមិអោយធ្វើការងាររួម អាចារ្យជាអ្នកប្រកាសដោយសារពួកគាត់ស្មោះត្រង់ ហើយអ្នកភូមិចូលចិត្តពួកគាត់ ។ អ្នកភូមិមិនចូលចិត្តអ្នកដែលមានមុខតំណែង ជីកស៊ី និងភ្លេចការងាររបស់ខ្លួន ពេលគេបានលុយនោះទេ (សមាជិក គ.អ.ភស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

*គោកដូង: យើងមិនភ្លេចគ្នាទេ*

- ការជ្រើសរើសអ្នកដែលមិនមានមុខតំណែងផ្នែកអាជ្ញាធរ អោយមានមុខតំណែងផ្នែកអភិវឌ្ឍន៍នោះ បានបង្កើតឱ្យមានការបែងចែកភារកិច្ចដោយមានដំណើរការល្អរវាងមេភូមិ និងអ្នកដឹកនាំខាងការងារអភិវឌ្ឍន៍ ហេតុនេះហើយទើបបណ្តាលអោយមានរចនាសម្ព័ន្ធដឹកនាំនៅថ្នាក់ភូមិដ៏រឹងមាំ ។
- តួនាទីមេក្រុម កំពុងឈានទៅរកការបាត់បង់ ដោយសារភ្នាក់ងារអភិវឌ្ឍន៍ធ្វើការងារជំនួសពួកគេ ។
- បុរសពីរនាក់ដែលធ្លាប់មានមុខតំណែងនៅក្នុងភូមិ បានទទួលឋានៈជាអ្នកដឹកនាំដែលអ្នកភូមិទទួលស្គាល់ ដោយសារតែការចូលរួមរបស់គេនៅក្នុងសកម្មភាពអភិវឌ្ឍន៍ ហើយបុរសទីបី ក៏កំពុងត្រូវបានអ្នកភូមិទទួលស្គាល់ថា ជាអ្នកដឹកនាំដោយសារការចូលរួមរបស់គាត់ក្នុងសកម្មភាពអភិវឌ្ឍន៍ ។
- ប៉ុន្តែការប្រមូលផ្តុំការងារ និងការទទួលខុសត្រូវអោយបុរសទាំងពីរនាក់នោះ បណ្តាលអោយអ្នកផ្សេងទៀត ជាពិសេសនារី នឹងគ្មានឱកាសមានជំនាញដឹកនាំការងារអភិវឌ្ឍន៍ និងមិនមានអ្នកទទួលស្គាល់ ។

នៅភូមិគោកដូង អន្តរាគមន៍ផ្នែកការងារអភិវឌ្ឍន៍បានបង្កើតភារកិច្ច និងការទទួលខុសត្រូវអោយអ្នកដែលមិននៅក្នុងរចនាសម្ព័ន្ធរដ្ឋអំណាច ។ នៅខេត្តបាត់ដំបង តាមគោលការណ៍ដែលគេអនុវត្តមេភូមិ និងអនុប្រធានភូមិមិនត្រូវឈរឈ្មោះបោះឆ្នោត គ.អ.ភ ទេ ប៉ុន្តែមេភូមិធ្វើជា "ទីប្រឹក្សា" អោយ គ.អ.ភ ដោយស្វ័យប្រវត្តិ ។ ពុំមានគោលការណ៍ច្បាស់លាស់ថាតើតួនាទីទីប្រឹក្សាត្រូវធ្វើអ្វីខ្លះ តើដំណើរការបានល្អដល់កំរិតណា ប្រហែលជាពឹងពាក់តែទៅលើអ្នកណាដែលលក្ខណៈសម្បត្តិល្អ ។ នៅភូមិគោកដូង ការបែងចែកភារកិច្ចរវាង "រដ្ឋអំណាច" និង "ការអភិវឌ្ឍន៍" មេភូមិមានការធូរស្រាលដោយមានអ្នកផ្សេងទទួលខុសត្រូវលើការងារអភិវឌ្ឍន៍ និងកំពុងបន្តធ្វើការងារមួយចំនួនរបស់គាត់ ដូចជាការប្រមូលទិន្នន័យភូមិជាដើម ។ អ្នកធ្វើការងារអភិវឌ្ឍន៍អោយតំលៃទៅលើការយល់ព្រម និងការគាំទ្ររបស់មេភូមិ ។ ពួកគេតែងតែជំរាបគាត់ ហើយនៅពេលដែលត្រូវការអំណាចខាងអាជ្ញាធរ ពួកគេត្រូវការសំលេងគាំទ្រ ដើម្បីបានទទួលអំណាចនោះ ។ គាត់ចុះហត្ថលេខារាល់ប្រាក់កម្ចីនៅក្នុងគណនីអភិវឌ្ឍន៍ស្ត្រី ហើយនៅពេលដែលប្រជាជនមិនសងស្រូវ ឬលុយបានខ្លី គាត់ប្រកាសតាមមីក្រូ ។

*បើ ពឿន និង មឿន (អ្នកដឹកនាំការងារអភិវឌ្ឍន៍) ចង់ធ្វើអ្វីមួយ គេពិភាក្សាគ្នា ។ បន្ទាប់មកគេសុំយោបល់ពីអ្នកហៀន (មេភូមិ) ។ អ្នកហៀនជំជាងគេនៅក្នុងភូមិ បន្ទាប់ពីឃុំ ។ គេធ្វើការខុសផ្នែកគ្នា ។ ម្ខាងជាគណៈកម្មការភូមិ ម្ខាងទៀតជាគណៈកម្មការអង្គការ ។ គណៈកម្មការភូមិដោះស្រាយពីរឿងឈ្លោះគ្នា ដូចជា ឈ្លោះរឿងដីស្រែ ។ គណៈកម្មការអង្គការ ធ្វើការងាររបស់គេ (ស្ត្រីម្នាក់ ខែមេសា ឆ្នាំ២០០០) ។*

*យើងមិនភ្លេចគ្នាទេ ។ នៅក្នុងការងារដែលពាក់ព័ន្ធ គេមកជួបមេភូមិ ។ ហើយនៅពេលមានការងារដែលទាក់ទងភូមិ មេភូមិសួរឃុំ ។ ខ្ញុំជាទីប្រឹក្សាអោយក្រុមអភិវឌ្ឍន៍ ។ ឧទាហរណ៍នៅពេលលើកផ្លូវ ឬប្រឡាយ បើសិនប៉ះពាល់ដីស្រែរបស់អ្នកភូមិ គេអោយមេភូមិសម្រុះសម្រួល ។ ខ្ញុំសុំការអនុញ្ញាតពីម្ចាស់ដី ។ ជួនកាលអ្នកនៅក្នុងគណៈកម្មការជាអ្នកសុំ ប៉ុន្តែជួនកាលវាពិបាកពេក គេត្រូវការជំនួយពីមេភូមិ ។ គណៈកម្មការអភិវឌ្ឍន៍ភូមិនៅក្រោមរដ្ឋអំណាច ដូច្នេះគេត្រូវការរដ្ឋអំណាចធ្វើជាសាក្សី និងទទួលស្គាល់នូវអ្វីដែលគេបានធ្វើ (មេភូមិ ខែមេសា ឆ្នាំ២០០០) ។*

*មេភូមិដូចជាអាជ្ញាកណ្តាលអញ្ចឹង ។ នៅពេលមានអ្វីដែលក្រុមអភិវឌ្ឍន៍ធ្វើមិនបាន គេអាចទៅរកមេភូមិ ។ យើងចាត់ទុកគាត់ជាចាស់ទុំដែលយើងអាចសុំជាយោបល់ (សមាជិក គ.អ.ភ ភ្នាក់ងារប្រុសអប់រំសុខភាពភូមិ ប្រុស ខែមេសា ឆ្នាំ២០០០) ។*

ដោយសារអ្នកធ្វើការងារអភិវឌ្ឍន៍ជួយប្រមូលទិន្នន័យប្រជាជន និងហៅប្រជុំជំនួសមេភូមិ (ហើយអ្នកភូមិមួយចំនួនដឹងថា អ្នកធ្វើការងារអភិវឌ្ឍន៍កំពុងតែធ្វើការងារនេះ) ។ ការងារសំខាន់ដែលនៅសល់របស់ប្រធានក្រុមត្រូវចប់ហើយ ពួកគេមិនសូវសោកស្តាយទេ ។ ដូច្នេះប្រធានក្រុមភាគច្រើនយល់ស្របថា តួនាទីរបស់ពួកគេធូរស្រាលច្រើន ។ ប៉ុន្តែប្រធានក្រុមខ្លះជួយធ្វើការងារអភិវឌ្ឍន៍ផ្សេងៗដូចជា ការវាស់វែងដីដើម្បីលើកផ្លូវថ្មី មិនមែនជាជំនាញរបស់គេទេ ប៉ុន្តែដោយសារពួកគេជាមនុស្សដែលគេពេញចិត្ត និងគួរអោយទុកចិត្តបាន ។

ដូចដែលបានជំរាបជូនរួចមកហើយថា ការចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍បានផ្តល់ឋានៈក្នុងការដឹកនាំអោយបុរសពីរនាក់ ។ អ្នកភូមិឧស្សាហ៍និយាយថា បុរសម្នាក់ ឬបុរសទាំងពីរនាក់ ជាអ្នកដឹកនាំជាមួយមេភូមិ និង

អនុប្រធានភូមិ (ជនមាតុភូមិនិវត្តន៍និយាយដល់បុរសម្នាក់ជាងបុរសម្នាក់ទៀត និងជាងមេភូមិទៅទៀត) ។ បុរសទាំង ពីរនាក់នេះធ្លាប់ជាតំណាងយុវជនក្នុងអំឡុងឆ្នាំ១៩៨០ ហើយធ្លាប់ប្រកួតប្រកាសប្រជាជនអោយធ្វើការងាររួមទៅ ក្នុងភូមិ ។ នេះប្រហែលជាមូលហេតុដែលពួកគេត្រូវបានជ្រើសរើសជាលើកដំបូងអោយធ្វើជាគណៈកម្មការអភិវឌ្ឍន៍ ស្ត្រីបន្ទាប់មកធ្វើជា គ.អ.ភ ប៉ុន្តែការងាររបស់ពួកគេនៅក្នុងការងារអភិវឌ្ឍន៍ក្នុងរយៈពេលប្រាំបីឆ្នាំកន្លងមក ក៏បានបន្ថែមទៅលើសមត្ថភាព និងដោយសារតែការខិតខំប្រឹងប្រែងរបស់ពួកគេនេះហើយ បានធ្វើអោយអ្នកភូមិទុកចិត្ត និងទទួលស្គាល់ ។

ទទឹមនឹងនេះដែរ ក៏មានអាចារ្យវ័យក្មេងម្នាក់ដែលអ្នកភូមិចូលចិត្ត និងទុកចិត្ត (ប៉ុន្តែប្រជាជនដែលរស់នៅក្នុងតំបន់មាតុភូមិនិវត្តន៍មិនស្គាល់គាត់ច្បាស់ទេ) ។ ទោះជាគាត់មិនមែនជាសមាជិកគណៈកម្មការអភិវឌ្ឍន៍ក៏ដោយ (ក្នុងពេលបោះឆ្នោតគ.អ.ភ គាត់មិនបាននៅភូមិទេ) គាត់ហាក់ដូចជា យល់ពីកម្មវិធីអភិវឌ្ឍន៍ផ្សេង១នៅក្នុងភូមិច្រើនជាងអ្នកផ្សេង១ ។ គាត់ជាអ្នកចេះដឹង និងមានជីវភាពធូរធារ ហើយគាត់និយាយថា គាត់ខិតខំប្រឹងប្រែងធ្វើអោយរីកចំរើនទៅក្នុងភូមិ និងមានឆន្ទៈធ្វើការដោយឥតគិតកំរៃ ។ ដូច្នេះគាត់មើលទៅហាក់ដូចជាមានឱកាសល្អ ដើម្បីជាប់ឆ្នោតលើកក្រោយ ។

មូលហេតុដែលការងារអភិវឌ្ឍន៍ផ្តោតខ្លាំងទៅលើមនុស្សពីរនាក់នោះ ធ្វើអោយសមត្ថភាពរបស់អ្នកផ្សេងជាពិសេសស្ត្រី មិនមានប្រយោជន៍ និងមិនរីកចំរើន ។ នៅភូមិគោកដូង មានស្ត្រី៤នាក់ មានមុខតំណែងផ្នែកការងារអភិវឌ្ឍន៍ ។ ជាពិសេស អ្នកភូមិមួយចំនួនស្គាល់ហើយចូលចិត្តសមាជិកម្នាក់ក្នុងចំណោមអ្នកទាំង៤ ហើយម្នាក់ទៀតហាក់ដូចជាប្រឹងប្រែងធ្វើការ អាចធ្វើការ និងទទួលខុសត្រូវច្រើនជាងគាត់មាននាពេលបច្ចុប្បន្ននេះ ។ បើសិនជាមានការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ក្នុងអង្គប្រជុំ និងការប្រគល់ភារកិច្ច ត្រូវបានបែងចែកអោយស្មើ១គ្នា ក្នុងចំណោមអ្នកធ្វើការងារអភិវឌ្ឍន៍ស្ត្រី ប្រហែលជាអាចមានសក្តានុពលដូចអ្នកដឹកនាំផ្នែកបុរសទាំងពីរនោះដែរ ដើម្បីអោយក្លាយជាអ្នកដឹកនាំថ្មី និងជាតំណាងរបស់ភូមិ ។

## ឱកាស និងការទទួលខុសត្រូវដែលមានសំរាប់អ្នកភូមិ

ជ្រែងៈ យើងអាចស្នើសុំ ប៉ុន្តែគេជាអ្នកសំរេច

- ទោះបីអ្នកភូមិស៊ាំនឹងការទៅចូលរួមប្រជុំ និងស្នើអ្វី១ពីថ្នាក់លើក៏ដោយ ក៏ពុំមានការយល់ដឹងពីឥទ្ធិពលទៅលើការសំរេចចិត្តអំពីសកម្មភាពអភិវឌ្ឍន៍ទេ ។
- ការចូលរួមជាកំលាំងពលកម្ម និងទឹកប្រាក់ពុំបានធ្វើអោយអ្នកភូមិមានការយល់ដឹងពីភាពជាម្ចាស់ និងការទទួលខុសត្រូវទេ ។
- ការគ្រប់គ្រងមិនច្បាស់លាស់ និងភាពអយុត្តិធម៌ដែលទាក់ទិនទៅនឹងសកម្មភាពអភិវឌ្ឍន៍អាចបណ្តាលអោយអ្នកភូមិខឹងសម្បារ និងរៀបចំធ្វើពាក្យបណ្តឹងអំពីអាជ្ញាធរថ្នាក់ភូមិ ។

ប្រជាជននៅភូមិជ្រែងស៊ាំនឹងប្រធានភូមិដែលហៅទៅប្រជុំពីសកម្មភាពអភិវឌ្ឍន៍ ។ ជាទូទៅប្រជាជននិយាយថា គេមិនហ៊ាននិយាយនៅក្នុងអង្គប្រជុំទាំងនេះទេ ។ ដូច្នេះ ការប្រជុំនៅតាមភូមិ ហាក់ដូចជាមិនមែនជា

ឱកាសដើម្បីផ្លាស់ប្តូរគំនិត ឬការសំរេចចិត្តដ៏ពិតប្រាកដនោះឡើយ ។ វាហាក់ដូចជាប្រាប់អ្នកភូមិពីរឿងអ្វីមួយដែលគេបានសំរេចរួចហើយ ។ ទោះជាប្រជាជន ស៊ាំទៅនឹងការស្នើសុំរបស់របពីថ្នាក់លើក៏ដោយ នៅទីនេះក៏អញ្ចឹងដែរ គេយល់ឃើញថា អ្នកផ្សេងគឺជាអ្នកធ្វើការសំរេចចិត្ត ។ ប៉ុន្តែអ្នកភូមិមួយចំនួនរៀនគិតថាសុំអ្វី ។

> *យើងមិនហ៊ាននិយាយនៅក្នុងអង្គប្រជុំទេ ព្រោះយើងខ្លាចថា គំនិតរបស់យើងអាចខុស ។ ចៅហ្វាយស្រុកក៏មកប្រជុំដែរ ហើយអោយអ្នកភូមិបញ្ចេញយោបល់ ប៉ុន្តែយើងអត់ (ក្រុមស្ត្រីក្រីក្រ ខែតុលា ឆ្នាំ១៩៩៩) ។*

> *ឧទាហរណ៍ផ្លូវ ឬមន្ទីរពេទ្យ អ្នកភូមិចង់បានមួយណា ។ ការជ្រើសរើសទាំងពីរនោះ បានមកពីអង្គការ ពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ពីស្រុក ពីគណៈកម្មការអភិវឌ្ឍន៍ឃុំ ។ គេសួរខ្ញុំ ហើយខ្ញុំរើសយកមួយក្នុងចំណោមជំរើសទាំងពីរនេះ ។ ក្រោយមក ខ្ញុំប្រាប់អ្នកភូមិ (សមាជិកគ.អ.ភប្រុស ខែតុលា ឆ្នាំ១៩៩៩) ។*

> *នៅពេលអ្នកភូមិចង់បានផ្លូវ អណ្តូង ស្រះ គេទៅជួបមេភូមិ ។ មេភូមិស្នើទៅថ្នាក់លើ ហើយថ្នាក់លើអ្នកសំរេច ។ មានអង្គការខុសៗគ្នា ដូចជាអង្គការថ្នល់ អង្គការអណ្តូង អង្គការស្រះ ។ អញ្ចឹង អ្នកភូមិខ្លះបានអ្វីដែលគេចង់បាន អ្នកខ្លះអត់ ។ អោយអ្វី ក៏ប្រជាជនយកដែរ (អ្នកភូមិមួយក្រុមតូច ស្រី/ប្រុស ខែមិនា ឆ្នាំ ២០០០) ។*

> *មេភូមិស្នើសុំឃុំហើយ ឃុំស្នើសុំអង្គការអោយធ្វើស្ពាន ថ្នល់ ឬលូ ។ មេភូមិជាអ្នកសំរេចថា គួរធ្វើនៅកន្លែងណា ។ នៅពេលព្រមព្រៀងដើម្បីធ្វើអ្វីមួយ មេភូមិ និង គ.អ.ភ ប្រជុំជាមួយអ្នកភូមិ (ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

> *អ្នកវៃឆ្លាតមួយចំនួននៅក្នុងភូមិដឹង [អ្វីដែលអង្គការចង់អោយ] ហើយអ្នកផ្សេងទៀតថា គេគួរនិយាយថា គេចង់បានរបស់នេះច្រើន វាអាចត្រូវនឹងគំនិតរបស់ថ្នាក់លើដែលមកប្រជុំជាមួយយើង ។ យើងអាចធ្វើ ស្រេចតែលើគំនិតអង្គការដែលមកប្រជុំ ។ [នៅពេលដែលអ្នកណាម្នាក់និយាយអ្វីដែល] ពួកគេចង់ឮ ពួកគេនិយាយថា "អូ! អ៊ីនេះនិយាយដូចជាត្រូវ ។ អ្វីដែលអ៊ីនិយាយនេះ គឺត្រឹមត្រូវហើយ អ៊ីនិយាយនេះត្រឹមត្រូវ" (អ្នកភូមិ អាចារ្យ ខែមិនា ឆ្នាំ២០០០) ។*

ដំបូង ប្រជាជននៅភូមិជ្រែងបានទទួលរបបស៊ីរាប់ពលកម្មអត់ជំនាញក្នុងការលើកផ្លូវ បន្ទាប់មកមានការផ្លាស់ប្តូរអោយប្រជាជនចូលរួមជាកំលាំងពលកម្ម ហើយចុងក្រោយចូលរួមជាកំលាំងពលកម្ម និងទឹកប្រាក់ ។ ការផ្លាស់ប្តូរនេះ ហាក់ដូចជាដំណើរការបានល្អដោយសមហេតុផល ប៉ុន្តែឆ្នាំនេះគេផ្តល់ជាស្បៀងពលកម្មវិញ ។ ជោគជ័យខាងលើនេះ គឺបានមកពីការចូលរួមយ៉ាងសស្រាក់សស្រាំពីព្រះសង្ឃ ។ ការឯកភាពគ្នាដ៏ធំមួយ គឺនៅពេលគ្មានកំរៃ រដ្ឋអំណាចមិនអាចហៅប្រជាជនអោយធ្វើការដូចមុនបានទេ ហើយ គ.អ.ភ មិនអាចហៅអ្នកភូមិបានដែរ ទាល់តែព្រះសង្ឃទើបអាចហៅអ្នកភូមិបាន ។

*ព្រះសង្ឃគឺជាមនុស្សគួរអោយគោរព ស្មោះត្រង់ មិនដែរប្រជាជន មិនប្រើពាក្យទ្រគោះបោះបោក និងមិនប្រើហិង្សា ។ អ្នកបានបុណ្យ បើសិនជាអ្នកធ្វើការជាមួយព្រះសង្ឃ (សមាជិកស្ត្រី គ.អ.ភ ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

នៅឆ្នាំ១៩៩៩ ប្រជាជននៅក្នុងភូមិជ្រៃងបានចូលរួមវិភាគទានថ្លៃស្រូសក្រហមជាសាច់ប្រាក់តែម្តងគត់ និងមិនទាន់បានប្រមូលគ្រប់នៅឡើយទេ ។ បញ្ហានេះ គឺមិនមែនអ្នកភូមិមិនចង់បង់វិភាគទានទេ ។ អ្នកភូមិភាគច្រើនហាក់ដូចជាបានយល់ពីមូលហេតុដែលពួកគេត្រូវចូលរួមវិភាគទាន និងឯកភាពពីរឿងនេះ ។ បញ្ហាគឺនៅត្រង់ថាអ្នកដែលប្រមូលវិភាគទានមិនមានជំហររឹងមាំ ហើយការប្រមូលនេះ ត្រូវបានប្រព្រឹត្តទៅហួសរដូវប្រមូលផលស្រូវ ។

*យកទុយតូច ទៅស្ទូចយកត្រីធំ (មេភូមិ ការប្រជុំនៅក្នុងភូមិ ខែតុលា ឆ្នាំ១៩៩៩) ។*

*អង្គការ និងអ្នកភូមិជួយគ្នាទៅវិញទៅមក ។ អ្នកភូមិចេញលុយថ្លៃស្រូសក្រហមពី ៥.០០០ ទៅ ១០.០០០រៀល ។ ការពិតអ្នកភូមិអោយតែ ២.០០០ ឬ ៣.០០០រៀលប៉ុណ្ណោះ ប៉ុន្តែគេ (អ្នកដែលប្រមូលលុយ) ដាក់ (កំណត់) ៥.០០០រៀលក្នុងបញ្ជី ។ ខ្ញុំមិនទាន់អោយផង ព្រោះខ្ញុំយកលុយទិញដីពីធនាគារដី (ភ្នាក់ងារសុខភាពភូមិ ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

*នៅពេលបានស្រូសក្រហម អ្នកភូមិមួយចំនួនគិតថា គេបានដោយមិនអស់លុយ ។ គេមិនទុកចិត្តអ្នកដែលប្រមូលលុយ ហើយរឿងនេះបានរាលដាលក្នុងចំណោមអ្នកភូមិ (អាចារ្យ ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

ការប៉ាន់ស្មានដែលគាំទ្រអោយមានការចូលរួមជាកំលាំងពលកម្ម និងសាច់ប្រាក់ វានឹងធ្វើអោយប្រជាជនគិតថា ខ្លួនមានភាពជាម្ចាស់ ទទួលខុសត្រូវចំពោះអ្វីដែលគេបានធ្វើ និងចូលរួម ។ នៅពេលដែលយើងសួរអ្នកភូមិជាច្រើននិយាយថា ថ្នល់ជារបស់អ្នករាល់គ្នានៅក្នុងភូមិ ហើយបើសិនជាព្រះសង្ឃអំពាវនាវឱ្យគេជួយថែរក្សាថ្នល់នេះ ពួកគេនឹងជួយថែរក្សា ។ ប៉ុន្តែនៅក្នុងករណីផ្សេងទៀត ការមន្ទិលសង្ស័យព្រមទាំងការមិនសប្បាយចិត្តធ្វើអោយប្រជាជនរារែកមិនចង់ចូលរួមវិភាគទាន និងជួយថែរក្សាទេ ។ ស្ពានឈើមួយ បានបាក់បែកទ្រុឌទ្រោមទៅៗ ដោយសារតែមានពាក្យចចាមអារ៉ាមថា មានលុយល្មមអាចធ្វើស្ពានថ្មបាន ប៉ុន្តែឈើដែលយកមកធ្វើស្ពាននេះ ជាឈើដែលមានគុណភាពអន់ ព្រោះអ្នកដែលទិញឈើនោះ គិបលុយដែលនៅសល់សំរាប់ពួកគេ ។

ការប៉ាន់ស្មានមួយទៀតដែលគាំទ្របែបផែនខុសៗគ្នានៃ "ការចូលរួម" គឺបទពិសោធន៍នឹង "ផ្តល់អំណាច" អោយអ្នកភូមិ ដោយចូលរួមបង្កើនសមត្ថភាព និងទំនុកចិត្ត ក៏ស្ថិតនៅក្នុងស្ថានភាពដែលទាក់ទងដោយប្រយោលសំរាប់សកម្មភាពអភិវឌ្ឍន៍ ។ ដូចដែលបានបង្ហាញជូនរួចមកហើយថា នៅជ្រៃងអ្នកភូមិកំពុងតែមិនសប្បាយចិត្តជាមួយរដ្ឋអំណាចភូមិកាន់តែខ្លាំងឡើងៗ ។ ការរអ៊ូរទាំដ៏សំខាន់នោះ គឺទាក់ទងនឹងរបៀបដែលរដ្ឋអំណាចបានទទួលផលប្រយោជន៍ពីសកម្មភាពអភិវឌ្ឍន៍ ដើម្បីខ្លួនគេ និងបក្សពួក ។ ការចែកជំនួយសង្គ្រោះបន្ទាន់កាលពីឆ្នាំទៅ ធ្វើអោយអ្នកភូមិ កាន់តែមួម៉ៅ ។ យើង ឬអ្នកភូមិមិនទាន់ដឹងច្បាស់ពីបែបបទនៃការជ្រើសរើសអ្នកដែលត្រូវទៅទទួលអំណោយនៅឡើយទេ ហើយប្រការនេះធ្វើអោយមានពាក្យចចាមអារ៉ាម និងចោទប្រកាន់ដល់អ្នកដែលប្រហែលជាមិនបានពាក់ព័ន្ធ និងប៉ះពាល់ជាអវិជ្ជមានដល់គំនិតចូលរួមរបស់សិលា ។

*ហ៊ានអោយឈ្មោះអ្នកដែលត្រូវបានអំណោយទៅអង្គការ ។ គេឱ្យតែឈ្មោះបងប្អូនគេទេ ។ មានតែអ្នកនៅផ្សារអំពិល (ផ្នែកមួយរបស់ភូមិដែលប្រជាជនទៅចុះឈ្មោះបើកអំណោយ) និងអ្នកធ្វើការងារអភិវឌ្ឍន៍ទេដែលបានទទួលអំណោយ (មេក្រុម ខែមិនា ឆ្នាំ២០០០) ។*

*មានតែអាអ្នកកាន់កាំភ្លើងទេបានអំណោយ (ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

*បើមានផែនការជួសជុលស្ពានឈើ ឬផ្លូវ ខ្ញុំមិនចូលរួមធ្វើ និងមិនចូលលុយទេ ។ ខ្ញុំនឹងពីរឿងអំណោយ ពីអ្នកដែលបានទទួលអំណោយ (ស្ត្រី ខែកុម្ភៈ ឆ្នាំ២០០០) ។*

លទ្ធផលនៃបទអន្តរាគមន៍ផ្នែកការងារអភិវឌ្ឍន៍នៅភូមិជ្រែងអាចនិយាយបានថា ការគ្រប់គ្រងមិនច្បាស់លាស់បានធ្វើអោយមានភាពមិនសប្បាយចិត្តរឹកសុះសាយ និងការកើតឡើងនូវអ្នកដឹកនាំថ្មីដែលមានសក្តានុពលធ្វើអោយភ្លេចមេភូមិ និងជីវពល ។ សំនួររបស់ក្រុមស្រាវជ្រាវដែលគ្រាន់តែលើកយកកំហឹងរបស់ប្រជាជន និងអ្នកដឹកនាំមួយចំនួន ប្រហែលជាអាចធ្វើអោយរឿងនេះកើតឡើង ។ អ្នកភូមិបាននិយាយកាន់តែនិយាយដោយបើកចំហច្រើនឡើងពីភាពមិនសប្បាយចិត្តរបស់ពួកគេ ។ ក្នុងអំឡុងពេលជួបជាមួយក្រុមផ្តល់យោបល់កាលពីលើកមុនមានសំណូមពរអោយសរសេរញត្តិជាបន្ទាន់មួយទាយុំ ហើយការពិភាក្សាជាបន្តបន្ទាប់ទៀត មិនសំណូមពរពតិមានពីក្រុមស្រាវជ្រាវណាស់ណាទេ ។ ប្រជាជនមួយចំនួនទៅតែរារែក និងបារម្ភថា វានឹងមិនដំណើរការ ប៉ុន្តែក៏មានប្រជាជនមួយចំនួនដែលហាក់ដូចជាចង់ដឹកនាំរឿងនេះដែរ ។

*គេ (អ្នកភូមិ) ដឹងថាហ៊ានធ្វើខុស ។ ប៉ុន្តែគ្មានអ្នកណាហ៊ានតវ៉ាទេ ព្រោះគេគិតថា គាត់មានបក្សពួកនៅថ្នាក់លើ ហើយអ្នកនៅថ្នាក់លើត្រូវការតែលុយទេ ។ អ្នកភូមិខ្លាចអំណាចលុយរបស់ហ៊ាន (ប្តីប្រពន្ធ ខែមិនា ឆ្នាំ២០០០) ។*

*ហ៊ាន និងមេឃុំត្រូវគ្នាណាស់ អញ្ចឹងខ្ញុំមិនគិតថា អ្នកភូមិមិនអាចយកឈ្នះលើ ហ៊ានបានទេ (ស្ត្រី ខែមិនា ឆ្នាំ២០០០) ។*

*អ្នកភូមិពីរបីនាក់ បានអោយខ្ញុំធ្វើញត្តិរើសមេភូមិថ្មី ប៉ុន្តែពួកគេជាតំណាងអោយអ្នកភូមិទាំងអស់ ។ ខ្ញុំនៅតែមិនហ៊ានធ្វើ ព្រោះអ្នកភូមិមកមិនស្រុះគ្នា ។ បើគេមកស្រុះគ្នា ខ្ញុំនឹងធ្វើភ្លាមព្រោះឥឡូវនេះ ជាលទ្ធិប្រជាធិបតេយ្យ គេចាត់ទុកប្រជាជនជាធំ ដូច្នេះបើអ្នកភូមិធ្វើការតវ៉ា គេត្រូវតែស្តាប់ (បុរសម្នាក់ ក្នុងក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

*បើអ្នកភូមិចង់ដកមេភូមិនេះ យើងគួរតែប្រមូលអ្នកភូមិទាំងអស់មកប្រជុំហើយផ្តិតមេដៃ ។ មេភូមិនេះ ត្រូវបានចាត់តាំងពីថ្នាក់លើ ដូច្នេះថ្នាក់លើមិនជួយគាំទ្រគំនិតដែលអ្នកភូមិចង់ដកមេភូមិនោះទេ ព្រោះថ្នាក់លើត្រូវគ្នាជាមួយមេភូមិនេះណាស់ ។ ប៉ុន្តែនៅមានការបោះឆ្នោតឃុំ ចាំយើងធ្វើញត្តិនេះ (សមាជិក គ.អ.ក ក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

*យើងអាចធ្វើញត្តិទៅឃុំ ។ ក្នុងអំឡុងឆ្នាំ១៩៨០ ជារបបកុម្មុយនីស្ត ។ ចាប់ពីឆ្នាំ១៩៩០ សិទ្ធិជារបស់អ្នកភូមិ ។ ដូច្នេះបើអ្នកភូមិទាំងអស់ឯកភាព ខ្ញុំនឹងយកលិខិតនេះទៅឃុំ និងស្រុកអោយចុះ*

*ហត្ថលេខា ។ បើសិនអ្នកភូមិចង់ដកមេភូមិ គេអាចដកដូចស្តែអញ្ចឹង ។ ប៉ុន្តែបើយើងចង់ធ្វើ យើងត្រូវតែធ្វើតាំងពីឆ្នាំទៅ ឬក្រោយច្រូតហើយ វាលឿនផង ។ ឥឡូវនេះមិនទាន់បានទេ ព្រោះមេឃុំកំពុងត្រៀមខ្លួនបោះឆ្នោត ។ ប្រហែលបោះឆ្នោតឃុំហើយ ព្រោះឥឡូវនេះ មេឃុំកំពុងគិតថា គាត់ជាប់ឬធ្លាក់ ។ បើសិនជាយើងធ្វើពាក្យបណ្តឹងឥឡូវនេះ គាត់ប្រហែលជាមិនគិតគូរទេ គាត់អាចយកទៅកប់ចោល ។ បើសិនមេឃុំចាស់ជាប់ យើងត្រូវតែតវ៉ា ហើយគាត់ត្រូវតែធ្វើការអោយយើង ។ បើមេឃុំថ្មីជាប់ គាត់ក៏ត្រូវគិតពីយើងដែរ ។ ប៉ុន្តែឥឡូវនេះ បើសិនមានអ្នកឈរឈ្មោះបី ឬបួននាក់ អ្នកភូមិមិនដឹងថា គួរជួបអ្នកណា ដើម្បីអោយគេជួយ ។ ឥឡូវនេះនៅពេលដែលមិនមានការឯកភាពគ្នាទេ គ្មានអ្នកណា គិតពីរឿងយើងទេ អញ្ចឹងការងារនៅដដែល ។ ប៉ុន្តែក្រោយពីការបោះឆ្នោតហើយ បញ្ហានឹងត្រូវបានដោះស្រាយ ទោះជាមេឃុំថ្មី ឬចាស់ជាប់ក៏ដោយ (អាចារ្យ ខែមិនា ឆ្នាំ២០០០) ។*

*គោកដូង: អ្នកភូមិចង់ធ្វើការ មានប្រាក់ខែ*

- វត្តមានរបស់ថ្នាក់ដឹកនាំការងារអភិវឌ្ឍន៍ពុំបានបង្កើតអោយមានការយល់ដឹង (ក្តីរំពឹង រឺការទាមទារ) ពីឥទ្ធិពលក្នុងចំណោមអ្នកភូមិទៅលើការសំរេចចិត្តអំពីសកម្មភាពអភិវឌ្ឍន៍ឡើយ ។
- ដូចនៅក្នុងភូមិជ្រៃងដែរ ការចូលរួមវិភាគទាន ពុំបានធ្វើអោយអ្នកភូមិមានការយល់ដឹងពីភាពជាម្ចាស់ និងការទទួលខុសត្រូវទេ ។

ដូចដែលបានជំរាបជូនរួចមកហើយថា នៅភូមិគោកដូង មានការដឹកនាំដ៏រឹងមាំ និងសហការគ្នាល្អ ។ ប៉ុន្តែអ្នកភូមិហាក់ដូចជាមិនប្រើការដឹកនាំនេះដើម្បីអោយខ្លួនមានឥទ្ធិពលទេ ។ មានភាពអសកម្ម និងការមិនចាប់អារម្មណ៍ចំពោះការដឹកនាំនេះនៅក្នុងចំណោមអ្នកភូមិ ។ នៅថ្ងៃបោះឆ្នោតជ្រើសរើសគ.អ.ភ អ្នកភូមិភាគច្រើនមិនខ្វល់ពីរឿងរង់ចាំលទ្ធផលទេ ហើយគេចេញទៅវិញមុនពេលគេដឹងថា អ្នកណាជាប់ឆ្នោត ។ ឥឡូវនេះ អ្នកភូមិដឹងថា ញៀន (អ្នកដឹកនាំការងារអភិវឌ្ឍន៍) ជូនគាល់ សុំ ប្រឡាយ ឬថ្នល់ ។ ប៉ុន្តែពួកគេមិនទៅប្រាប់គាត់ ឬអ្នកផ្សេងទៀតដោយខ្លួន ឯងដោយមានសំណូមពរចង់បានអ្វីនោះទេ ។

អ្នកភូមិមិនធ្លាប់ស្នើសុំអ្វីទេ ប៉ុន្តគេចូលចិត្តទទួលយកជាង ។ មានការប្រជុំ ប៉ុន្តែការប្រជុំទាំងនោះត្រូវគេយល់ឃើញថា ជាការប្រាប់អ្នកភូមិពីរឿងអ្វីមួយ ។ នៅពេលអ្នកដែលមកពីខាងអង្គការអភិវឌ្ឍន៍សួរអ្នកភូមិត្រូវការ ឬចង់បានអ្វីនោះ អ្នកភូមិមិនយល់ឃើញថា ជាការជ្រើសរើសដ៏ពិតប្រាកដរបស់ខ្លួនទេ ។ នៅក្នុងភូមិមានអង្គការជាច្រើន ហើយអង្គការនីមួយៗមានគំនិតថា ចង់អោយអ្វីខ្លះដល់អ្នកភូមិ ។

*អង្គការអោយអ្នកភូមិទៅអង្គុយកន្លែងផ្សេងៗគ្នា បើអ្នកចង់បានអានេះ សូមមកអង្គុយទីនេះ បើអ្នកចង់បានអានោះ សូមទៅអង្គុយនៅទីនោះ ។ បន្ទាប់មកគេខ្សិបអ្នកម្នាក់ថា "បើអ៊ំចង់បានគោ អាហ្នឹងបាន បាន" (មេក្រុមប្រុស ការពិភាក្សាក្នុងក្រុមទស្សនកិច្ចសិក្សា ខែមេសា ឆ្នាំ២០០០) ។*

*វិន (បុគ្គលិកអភិវឌ្ឍន៍ស្ត្រី) មកសួរថា យើងចង់បានអី ។ ខ្ញុំថា ខ្ញុំមានសព្វគ្រប់អស់ហើយ ខ្ញុំត្រូវការឡាន ។ អញ្ចឹងគាត់នៅស្ងៀម ។ បន្ទាប់មក គាត់កត់ឈ្មោះអ្នកដែលចង់បានពាងទឹក ។ ខ្ញុំដាក់ឈ្មោះខ្ញុំ ប៉ុន្តែឥឡូវ ខ្ញុំចាំ ៥ឆ្នាំហើយ (ស្ត្រី ខែមករា ឆ្នាំ២០០០) ។*

ដូច្នេះ ជាទូទៅអ្នកភូមិមិនសូវបញ្ចេញគំនិត ឬយោបល់ទេ ប៉ុន្តែហាក់ដូចជារង់ចាំទទួលអ្វីដែលគេផ្តល់អោយ និងអ្នកផ្សេងទៀតជាអ្នកសំរេច ដូចជា អង្គការ. ថ្នាក់លើ ឬមេភូមិ និងពឿន ។ កង្វះខាតការចាប់អារម្មណ៍ និងការគិតទុកនេះ ប្រហែលជាមកពីប្រជាជនមានការអន់ចិត្ត ។ មានសេចក្តីបញ្ជាក់ជាញឹកញាប់ពីរឿងដែលអ្នកភូមិទៅប្រជុំសន្យាថា អោយអ្វីមួយ ឬសន្យាអោយគេ តែក្រោយមកមិនមានអ្វីជាក់ស្តែងទេ ។ ប៉ុន្តែពួកគេហាក់ដូចជាមិនមានប្រតិកម្មអ្វីសោះ ។

*គេប្រាប់ប្រជាជនអោយទៅប្រជុំ ។ ខ្ញុំជូនកាលទៅ ជួនកាលអត់ ។ ប្រជុំពីរឿងអ្នកក្រ ប៉ុន្តែមិនបានអីទេ គ្រាន់តែប្រជុំៗ (ស្ត្រីជនមាតុភូមិនិវត្តន៍ ខែមេសា ឆ្នាំ២០០០) ។*

*គេនិយាយថា គេស្តារប្រឡាយផល់ស្ទឹង ។ ប៉ុន្តែឥឡូវ អត់មានអី ។ មើលទៅប្រហែលជាប្រយាលហើយ ។ មេភូមិនិយាយថា គេនឹងស្តារ ។ ជារៀងរាល់ឆ្នាំ តែងតែមានការពិភាក្សាគ្នាពីរឿងស្តារប្រឡាយ ។ ដំបូងមានការពិភាក្សាពីរឿងប្រឡាយពីរ ។ គេនិយាយថា ប្រឡាយមួយទៀតចាំស្តារលើកក្រោយ (ស្ត្រីខែមេសា ឆ្នាំ២០០០) ។*

*មានផែនការលើកថ្នល់ ។ គេថា លើកខែមិនា ។ ខ្ញុំត្រៀមបង្គីទៅលើកដីរួចហើយ ប៉ុន្តែអត់ឃើញមានសកម្មភាពអ្វីកើតឡើងទេ (មេក្រុម ខែមេសា ឆ្នាំ២០០០) ។*

នៅភូមិគោកដូង មានការយល់ព្រមព្រៀងគ្នាយ៉ាងទូលាយមួយថា សព្វថ្ងៃនេះ អ្នកភូមិមិនព្រមធ្វើការដោយគ្មានកំរៃទេ ហើយគេក៏មិនដែលចូលរួមវិភាគទានអ្វីដែរ ។ គេបានធ្វើការងារដោយគ្មានកំរៃនៅឆ្នាំ១៩៩៣ នៅពេលដែលអង្គការអភិវឌ្ឍន៍ស្ត្រី ផ្តល់គ្រួសចាក់ថ្នល់នៅក្នុងភូមិ ។ ថ្នល់នោះត្រូវបានថែរក្សាយ៉ាងល្អ ព្រោះមេភូមិ អ្នកដឹកនាំការងារអភិវឌ្ឍន៍ ឬអាចារ្យ សុំអោយអ្នកភូមិជួសជុលកន្លែងខូចខាតតាមក្រុមរៀង១ខ្លួន ។ ប៉ុន្តែតាំងពីពេលនោះមក អ្នកភូមិហាក់ដូចជាមានការចាប់អារម្មណ៍លើកំរៃ ដែលគេធ្វើអ្វីមួយជាងរបស់ដែលគេបានធ្វើ ។ ក្នុងឆ្នាំ១៩៩៨ នៅក្នុងដំណើរការកសាងផែនការមូលដ្ឋានលើកដំបូង ពេលមានគំរោងស្តារប្រឡាយចាស់មួយ ផ្នែក គ.អ.ភ ប្រើថវិកាអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីអោយរបបអ្នកភូមិ ។ អ្នកដែលធ្វើការបាន ១០ម៉ែត្រ ត្រូវបានរបប ៩ម៉ែត្រ ។ ចំណែកដែលមិនបានរបប គឺការចូលរួមជាកំលាំងពលកម្ម ។

ឆ្នាំបន្ទាប់មកទៀត អ្នកភូមិមិនបានទទួលរបបសំរាប់ពលកម្មអត់ជំនាញទៀតទេ ។ ជំរើសនោះ គឺរកថវិកាសំរាប់បំរើគំរោងភូមិ ជួលម៉ាស៊ីនស្តារប្រឡាយ និងចូលរួមវិភាគទាន ៣% ។ អ្នកភូមិជំទាស់ថា បើពួកគេមិនបានទទួលរបប ពួកគេមិនធ្វើការទេ ហើយសមាជិក គ.អ.ភ ក៏មិនហ៊ានសន្យាថា ពួកគេអាចប្រមូលវិភាគទានបានដែរ ។ គេអះអាងថា អ្នកភូមិអាចសង្ស័យអ្នកដែលប្រមូលវិភាគទាននេះដោយគិតថា អង្គការមានលុយធ្វើហើយ ។

*អ្នកភូមិត្រូវបានគេសន្យាថា នៅឆ្នាំក្រោយៗទៀត គេនឹងបន្តជីកប្រឡាយ រហូតដល់ស្ទឹង ។ ប៉ុន្តែគេដូរផែនការ គេថា បើសិនជាប្រជាជនជីក វាយឺតពេក ។ គេចង់ជួលម៉ាស៊ីនជីកវិញ ហើយអ្នកភូមិត្រូវតែចូលលុយ ។ ប៉ុន្តែអ្នកភូមិមិនព្រម ដោយសារគេមិនបានផលប្រយោជន៍ ។ គេមិនបានរបប យើងមិនព្រមជួលម៉ាស៊ីនទេ អញ្ចឹងទៅ លុយនោះផ្ទេរទៅអោយភូមិគេផ្សេង ។ មេភូមិ និងពឿនស្រែ អ្នកដឹកនាំការងារអភិវឌ្ឍន៍ ថា ពិបាកប្រមូលវិភាគទានណាស់ ព្រោះប្រជាជនក្រ ។ បន្ទាប់មក មេភូមិ និងសមាជិក ៧នាក់ ត្រូវចេញលុយផ្ទាល់ខ្លួន (មេក្រុម ខែមេសា ឆ្នាំ២០០០) ។*

ដូច្នេះ ការចូលរួមរបស់អ្នកភូមិជាកំលាំងពលកម្ម និងថវិកា មិនបានធ្វើអោយមានការយល់ដឹងពីភាពជាម្ចាស់ និងការទទួលខុសត្រូវទេ ។ ប៉ុន្តែការថែរក្សាហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ឱ្យមានដំណើរការល្អ សូមថ្លែងអំណរគុណដល់បុគ្គលមួយចំនួនដែលផ្តួចផ្តើម និងប្រមូលអ្នកភូមិមួយក្រុមតូចកសាង/ជួសជុលអ្វីមួយនៅក្នុងភូមិ ។

*ឥឡូវនេះ អ្នកភូមិមួយចំនួនមានការស្តាយក្រោយក្នុងការដែលគេមិនព្រមទទួលការផ្តល់ឱ្យនៅឆ្នាំ១៩៩៩ និងជជែកពីរឿងប្រឡាយថា តើល្អប៉ុណ្ណាទៅពេលដែលធ្វើរួច ។ នៅតែគ្មានអ្នកណាជឿថា មេភូមិ ឬគ.អ.ភ ឬថ្នាក់លើ នឹងអាចហៅប្រជាជនអោយធ្វើការដោយគ្មានកំរៃបានទេ សូម្បីតែព្រះសង្ឃក៏មិនអាចដែរ ។*

*ឥឡូវនេះដោយសារគ្មានរបប មិនងាយធ្វើទេ... កាលពីដើមគេធ្វើ ដូចជាថ្នល់នេះ ផ្លូវក្នុងភូមិចាស់ ។ កាលពីដើម វាជារបបកុំមុយនីស្ត ប៉ុន្តែឥឡូវនេះ ហាក់ដូចជាសេរីជាង អ្នកភូមិធ្វើទេ ។ កាលពីមុន អត់មានអង្គការទេ ហើយអ្នកភូមិធ្វើដោយឥតកំរៃ ។ បន្ទាប់មក អង្គការមកជួយអ្នកភូមិ និងអោយរបប ។ លើកក្រោយៗ អ្នកភូមិមិនធ្វើដោយឥតកំរៃទេ ។ អង្គការអោយរបប ហើយវាក៏ក្លាយទៅជាទំលាប់របស់អ្នកភូមិ (ស្ត្រី ខែមេសា ឆ្នាំ២០០០) ។*

*ជំនាន់ស្តេច បានស្តារប្រឡាយមួយ ។ គេប្រើរដ្ឋអំណាច បើអ្នកភូមិមិនទៅ គេប្រើហិង្សា ។ ឥឡូវនេះ បើសិនថ្នាក់លើអោយឃុំសុំអោយអ្នកភូមិធ្វើ ពួកគេមិនធ្វើទេ ។ ខ្ញុំ និងគណៈកម្មការមិនអាចប្រមូលប្រជាជនឱ្យចូលរួមបានទេ ។ ពេលគេធ្វើការជាមួយព្រះសង្ឃ គេគិតថា គេបានបុណ្យ ។ ប៉ុន្តែព្រះសង្ឃមិនអាចប្រមូលអ្នកភូមិឱ្យធ្វើអ្វីមួយក្នុងភូមិបានទេ បើអ្វីដែលជារបស់ព្រះសង្ឃ ឬវត្ត គេធ្វើ ។ របស់របរដែលជារបស់ប្រជាជនធម្មតា គេមិនធ្វើទេ (អនុប្រធានភូមិ ខែមេសា ឆ្នាំ២០០០) ។*

ក្នុងរយៈពេលនៃការស្នាក់នៅលើកចុងក្រោយរបស់យើង អ្នកភូមិសង្ឃឹមលើតំលៃពលកម្ម ។ របាយការណ៍ផ្សេងៗគ្នាអំពីការលើកថ្នល់ ឬប្រឡាយ ឬធ្វើទាំងពីរ ហើយវាហាក់ដូចជាមិនមែនជាបញ្ហាណាស់ណាទេ ។ អ្នកភូមិព្រួយបារម្ភសំខាន់ជាងគេ គឺការបានរបប ។ នៅពេលដែលបុគ្គលិកមួយចំនួនដែលមកពីកម្មវិធីស្បៀងអាហារពិភពលោកចុះមកភូមិ ហើយពត៌មានសុះសាយថា ការលើកថ្នល់/ប្រឡាយ នឹងចាប់ផ្តើមធ្វើ ប៉ុន្តែនៅទីបញ្ចប់ អ្នកភូមិខកចិត្ត ព្រោះការងារនេះយឺតពេក ។ ឥឡូវនេះ ប្រជាជនរវល់ភ្ជួររាស់ មានតែអ្នកអត់ដីធ្លីទេទើបមានពេលធ្វើ ។

*អ្នកភូមិក៏រអ៊ូដែរថា ប្រឡាយ [នៅឆ្នាំ១៩៩៨] មិនទាន់ធ្វើហើយទេ ហេតុអ្វីបានជាចាប់ធ្វើផ្លូវថ្មី? ប៉ុន្តែខ្ញុំនិយាយប្រាប់គេថា នៅស្ងៀមសិនទៅ កុំរអ៊ូ បើមិនអញ្ចឹងទេ យើងអត់បានអីទេណា (ស្ត្រី ខែមេសា ឆ្នាំ២០០១) ។*

**ឃុំ**

***បំលាស់ប្តូរ ការយល់ឃើញ និងទំនាក់ទំនងរបស់អ្នកភូមិជាមួយថ្នាក់ឃុំមានការប្រែប្រួល***

*ជ្រែង: មេឃុំមកទីនេះ នៅពេលដែលយើងលើកថ្នល់*

- មេឃុំកាន់តែស្និទ្ធស្នាលបន្តិចម្តង១ជាមួយអ្នកភូមិមួយចំនួនធំ ។ តែទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនដឹងច្បាស់ពីតួនាទីរបស់ឃុំនៅក្នុងសកម្មភាពអភិវឌ្ឍន៍ទេ ហើយនៅតែយល់ថា ឃុំជាកន្លែងដែលនៅឆ្ងាយ ហើយតួនាទីសំខាន់របស់ឃុំ គឺដោះស្រាយពីរឿងសន្តិសុខ និងជម្លោះ ។
- សមាជិក គ.អ.ភ មិនដឹងពីតួនាទីរបស់គណៈកម្មការអភិវឌ្ឍន៍ឃុំ (គ.អ.ឃ) ហើយពុំមានការយល់ដឹងពីឥទ្ធិពលនៅក្នុងឃុំឡើយ មានតែប្រធានគ.អ.ភ (មេភូមិ) ទេដែលមានទំនាក់ទំនងជាមួយឃុំ ។
- ជាទូទៅ អ្នកភូមិគិតថា ឃុំជាផ្នែកតូចមួយរបស់ "ថ្នាក់លើ" ។ ឥទ្ធិពលដ៏សំខាន់បំផុតទៅលើការយល់ដឹង និងទំនាក់ទំនងរបស់អ្នកភូមិជាមួយថ្នាក់លើទាំងនេះ គឺការកើតឡើងរបស់អង្គការ ។

មេឃុំនិយាយថា សកម្មភាពអភិវឌ្ឍន៍បានពង្រីកការងាររបស់ឃុំ ហើយគាត់រវល់ច្រើនជាងពីមុន ។

*កាលពីមុន ខ្ញុំគ្រាន់តែទទួលខុសត្រូវខាងរដ្ឋអំណាចតែប៉ុណ្ណោះ ។ ឥឡូវនេះជាមួយកម្មវិធីអភិវឌ្ឍន៍ ខ្ញុំមានការទទួលបន្ទុកច្រើន ។ ខ្ញុំត្រូវធ្វើជាប្រធានភ្នាក់ងារអភិវឌ្ឍន៍ ។ ឧទាហរណ៍ការចិញ្ចឹមមេក្របី ខ្ញុំទទួលខុសត្រូវគ្រប់ភូមិ ។ នេះជាការបន្ថែមទៅលើការងាររបស់ខ្ញុំ ។ តាំងពីសិលាចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៧ ខ្ញុំមានការទទួលខុសត្រូវច្រើន ។ ខ្ញុំយកចិត្តទុកដាក់លើគំរូវការរបស់អ្នកភូមិដូចជាការលើកផ្លូវជាដើម ។ ខ្ញុំរវល់ខ្លាំងក្នុងការធ្វើសំណើសុំលុយ ឃុំអាចបាន ២៥.០០០ដុល្លារ (មេឃុំ ខែមិនា ឆ្នាំ២០០១) ។*

ចំពោះអ្នកភូមិភាគច្រើននៅជ្រែង ការផ្លាស់ប្តូរតែមួយគត់ក្នុងទំនាក់ទំនងរបស់គេជាមួយឃុំ គឺគេបានឃើញមេឃុំនៅក្នុងភូមិតែពីរបីដងទេ មួយនៅពេលមានប្រជុំពីសកម្មភាពអភិវឌ្ឍន៍ ឬនៅពេលគេកំពុងលើកថ្នល់ ។ ប្រការនេះបានធ្វើអោយអ្នកភូមិជាច្រើនមានភាពស្និទ្ធស្នាលជាមួយមេឃុំជាងមុន ហើយក៏បានធ្វើអោយពួកគេចូលរួមជាមួយសកម្មភាពអភិវឌ្ឍន៍ឃុំដែរ ដោយមិនស្វែងយល់ថា តើតួនាទីឃុំធ្វើអ្វីខ្លះនោះទេ ។ នេះក៏បានបង្ហាញពីការពិតសំរាប់ថ្នាក់ស្រុកដែរ ពីព្រោះចៅហ្វាយស្រុកក៏ចុះមកភូមិនៅពេលចាប់លើកថ្នល់ដែរ ។

*មេឃុំចុះមកប្រជុំ គាត់ប្រាប់អ្នកភូមិអោយលើកថ្នល់ ដូច្នេះគេអាចបានថ្នល់ល្អដើរដែរ (ក្រុមស្ត្រីក្រីក្រ ខែតុលា ឆ្នាំ១៩៩៨) ។*

ប៉ុន្តែទំនាក់ទំនងសំខាន់របស់អ្នកភូមិជាមួយឃុំ (និងថ្នាក់លើ) នៅតែពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀតជាងបញ្ហាអភិវឌ្ឍន៍ដែលបុគ្គលិកឃែរេរម្នាក់បានអះអាង ។

*ការងារសំខាន់របស់រដ្ឋអំណាច គឺសន្តិសុខ និងអ្វីៗដែលពាក់ព័ន្ធនឹងគណបក្សនយោបាយ ។ នៅខាងស្រុក គេមានកាលវិភាគដោយមានប្រធានបទផ្សេងៗគ្នា ។ ជួនកាលគេនិយាយពីការងារអភិវឌ្ឍន៍ ប៉ុន្តែមិនសូវញឹកញាប់ទេ ។ ជាទូទៅគេនិយាយពីរឿងសន្តិសុខ ។ មេឃុំរវល់នឹងការងារសន្តិសុខ ។ ចៅហ្វាយស្រុក និងអនុប្រធានមិនទទួលបន្ទុកខាងការងារអភិវឌ្ឍន៍ទេ ។ គេទៅឃុំ និងភូមិ ដើម្បីនិយាយពីរឿងគណបក្ស រឿងសន្តិសុខ និងនិយាយបន្តិចបន្តួចពីការងារអភិវឌ្ឍន៍ ។ គេធ្វើអោយអ្នកភូមិគាំទ្រ គណបក្សរបស់គេ ។ នៅពេលដែលបុគ្គលិក ឃែរេរ នៅភូមិជាមួយបុគ្គលិកឃុំ គេមិននិយាយរឿងគណបក្សនយោបាយទេ ។ ប៉ុន្តែនៅពេលដែលបុគ្គលិកឃែរេរ ចេញផុត គេនិយាយ (បុគ្គលិក ឃែរេរ ខែតុលា ឆ្នាំ១៩៩៩) ។*

ប្រការដែលគួរអោយកត់សំគាល់ជាងគំនិតដែលមិនច្បាស់លាស់បំផុតរបស់អ្នកភូមិ គឺសមាជិក គ.អ.ភ មានការយល់ដឹងយ៉ាងតិចតួចបំផុត ចំពោះតួនាទីរបស់ឃុំនៅក្នុងការងារអភិវឌ្ឍន៍ និងមិនហ៊ានទំនាក់ទំនងជាមួយឃុំទេ ។ នៅពេល គ.អ.ភ មានលក្ខណៈថ្មីថ្មោង ពួកគេទាំងអស់បានទៅប្រជុំ និងចូលរួមវគ្គបណ្តុះបណ្តាល ដូច្នេះពួកគេក៏បានជិតដិតជាមួយមន្ត្រីឃុំ ។ ប៉ុន្តែចាប់តាំងពីនោះមក មិនសូវមានវគ្គបណ្តុះបណ្តាលប៉ុន្មានទេ ហើយមានតែមេភូមិ និងជីវពលទេដែលទៅប្រជុំ ។

*កាលពីដើម ខ្ញុំមិនដែលមានទំនាក់ទំនងជាមួយមេឃុំទេ ទើបតែពេលខ្ញុំធ្វើការងារអភិវឌ្ឍន៍ ខ្ញុំអាចស្គាល់មេឃុំ ។ ខ្ញុំជួបគាត់នៅពេលដែលខ្ញុំទៅរៀនសូត្រ ។ ដំបូង ខ្ញុំទៅរៀនរាល់ខែ (សមាជិកស្ត្រី គ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

*រៀងរាល់ថ្ងៃច័ន្ទ មានតែប្រធានម្នាក់គត់ទៅប្រជុំនៅឃុំ ។ បើប្រធានរនេះរវល់គាត់អោយខ្ញុំទៅ ។ ខ្ញុំទៅប្រជុំបានម្តង ប៉ុន្តែយូរហើយ (សមាជិកប្រុសគ.អ.ភ. ក្រុម គ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

ប៉ុន្តែដូចដែលបានជំរាបជូនរួចមកហើយថា សូម្បីតែមេភូមិក៏មិនបានទៅប្រជុំឃុំទៀងទាត់ដែរ ។ ដូច្នេះភូមិជ្រែងពុំមានតំណាងសកម្មនៅក្នុងឃុំទេ ហើយសមាជិកហាក់ដូចជាមិនគិតថា ចង់ក្លាយជាតំណាងឃុំឡើយ ។ ពួកគេបានដឹងពីរឿងគណៈកម្មការអភិវឌ្ឍន៍ឃុំ (គ.អ.ឃ) ប៉ុន្តែគ្រាន់តែយល់ថា ជាមនុស្សមួយក្រុមតូចនៅឃុំ ។ ពួកគេជិតដិតនឹងសមាជិក គ.អ.ឃ ស្ត្រីពីរនាក់មកពីភូមិនៅទីរួមឃុំ ដែលសកម្មមែនទែននៅក្នុងការងារអភិវឌ្ឍន៍ ប៉ុន្តែហាក់ដូចជាចាត់ទុកអ្នកទាំងពីរជាមន្ត្រីឃុំ (ប៉ុន្តែអ្នកទាំងពីរមិនមែនជាមន្ត្រីឃុំទេ) ។ សមាជិក គ.អ.ភ មិនដឹងពីធនធានអភិវឌ្ឍន៍ដែល គ.អ.ឃ ជាអ្នកសំរេច ឬដឹងថា នៅភូមិជ្រែង និងនៅភូមិផ្សេងៗទៀតនៅក្នុងឃុំ (តាមទ្រឹស្តី) មានតំណាងរបស់គេផ្ទាល់នៅក្នុងការធ្វើសេចក្តីសំរេចចិត្តផ្សេងៗ ។

មេឃុំមិនច្បាស់ពីរឿង គ.អ.ឃ ។ គាត់ផ្តល់របាយការណ៍ផ្សេងពីអ្នកដទៃដោយបានឱ្យដឹងថា មេភូមិដែលមិនមែនជាប្រធានគ.អ.ភ ជាសមាជិករបស់គ.អ.ឃមែន ឬមិនមែន ហើយឆ្លល់ទៀតថាតើ គ.អ.ឃមានប្រជុំទៀង

ទាត់ឬទេ ។ តាមការពិតទៅ វាហាក់ដូចជាថាមានបញ្ហាការងារអភិវឌ្ឍន៍ម្តងម្កាល ត្រូវបានដោះស្រាយនៅពេលប្រជុំសប្តាហ៍ខាងរដ្ឋអំណាច មានន័យថា ប្រធានគ.អ.ភទាំងអស់ដែលមិនមែនមេភូមិ ក៏អាចមិនចូលរួមបានដែរ ។

ឥទ្ធិពលរបស់សិលាទៅលើការយល់ដឹង និងទំនាក់ទំនងរបស់អ្នកភូមិ ចំពោះឃុំ ត្រូវបានប៉ះពាល់ដោយហេតុថាជាទូទៅ ពួកគេមិនអាចចែកឃុំឱ្យដាច់ពី "ថ្នាក់លើ" បានទេ ។ ប្រជាជនមិនទាន់ដឹងថា ឃុំជាអ្នកធ្វើការងារអភិវឌ្ឍន៍ដ៏សំខាន់ទេ ប៉ុន្តែគេដឹងថា អង្គការ[២] ជាអ្នកធ្វើការងារអភិវឌ្ឍន៍ ។ ដោយមានអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ អ្នកភូមិមានការយល់ដឹងថ្មីនៃពាក្យនេះ ។ អ្នកភូមិមិនច្បាស់ថា អង្គការជាអ្វី ឬជាអ្នកណានោះទេ ប៉ុន្តែគេយល់ថា អង្គការជាផ្នែកមួយរបស់ថ្នាក់លើ និងជាភ្នាក់ងារអភិវឌ្ឍន៍ដ៏ចម្បង ដោយនិយាយអំពីសកម្មភាពអភិវឌ្ឍន៍ទាំងអស់ដែលបានមកពីខាងក្រៅភូមិទៅអោយអង្គការ ។ ដូច្នេះជាទូទៅវាអាចបកប្រែថា ជាអង្គការអភិវឌ្ឍន៍ ប៉ុន្តែអាចរួមមានរដ្ឋអំណាច និងអ្នកនយោបាយផងដែរ ។ ដូចដែលបានជំរាបជូនរួចមកហើយថា នៅពេលប្រជាជននៅភូមិជ្រែង ស្នើសុំអ្វីមួយពីថ្នាក់លើ ការស្នើសុំនោះ មិនមែនមានបំណងសំខាន់ទៅឃុំទេ ។ គេយល់ឃើញថា ការស្នើសុំនោះ គឺចេញពីថ្នាក់មួយទៅថ្នាក់មួយទៀត ទៅកន្លែងដែលគេធ្វើការសំរេចចិត្ត ជម្មតាត្រូវបានធ្វើឡើងដោយអង្គការ ។ នៅថ្នាក់ឃុំ ជាកាំជណ្តើរជាន់ទាបរបស់ជណ្តើរ វាពិបាកខ្លាំងណាស់ដើម្បីដាក់អង្គការ ។ វាជាកន្លែងមួយនៅខាងលើ នៅខាងក្រៅ ឬនៅពាសពេញ ប៉ុន្តែរឹតតែពោរពេញដោយអំណាចលុយ ជាងនៅឃុំយ៉ាងពិតប្រាកដ ។

នៅភូមិជ្រែង អ្នកភូមិមិនសូវជិតដិតជាមួយអង្គការអភិវឌ្ឍន៍ផ្សេងៗទៀតទេ ប៉ុន្តែគេប្រឹងរកនឹកឈ្មោះអង្គការមួយ ឬពីរ ។ គេកម្រនិយាយពីយេរេរណាស់ តែឧស្សាហ៍និយាយថា "DP" ឬអ្វីដែលស្រដៀងនឹង UNDP ។ គេស្គាល់មុខ ហើយជួនកាលស្គាល់ឈ្មោះរបស់ CARERE LCB "ម្នាក់ជិះម៉ូតូធំ" និងអ្នកសរបស់រូលស្រុកម្នាក់ ឬ ២នាក់ ទោះគេទៅជួបតែមេភូមិក៏ដោយ ។ សមាជិក គ.អ.ភ កម្រប្រើពាក្យសិលាណាស់ ។ គេបានលឺពាក្យនេះ ប៉ុន្តែមិនអាចចែកដាច់សិលា ពីអង្គការអភិវឌ្ឍន៍បានឡើយ ។

*បើមេឃុំមិនមានសមត្ថភាព ឬបើសិនគាត់រវល់ ខ្ញុំអាចទៅស្រុក ឬយេរេរដោយខ្លួនឯង ។ បើសិនមេស្រុករវល់ ខ្ញុំទៅជួប ឈុន លី (UNDP LCB) (មេភូមិ ខែមិនា ឆ្នាំ២០០០) ។*

*នៅភូមិជ្រែង ពីទូ (DFT គេបានដូរឈ្មោះ) ជិតដិតនឹងមេភូមិ ។ គេផឹកជាមួយគ្នា ។ កឡូវណារិទ្ធ (DFT គេបានដូរឈ្មោះ) ឧស្សាហ៍ទៅភូមិ ។ ប៉ុន្តែគាត់មិនចេះផឹក អញ្ចឹងគាត់មិនសូវជិតដិតនឹងមេភូមិទេ (សមាជិក គ.អ.ឃ មកពីភូមិផ្សេង ខែមិនា ឆ្នាំ២០០០) ។*

*ខ្ញុំមិនដឹងថា អង្គការមកពីណាទេ ប៉ុន្តែខ្ញុំមិនគិតថា ឃុំ ឬស្រុកមានលុយធ្វើរបស់ (អណ្តូង ស្រះ ផ្លូវ) អញ្ចឹងៗទេ មានតែអង្គការទេ មានលុយ ។ អង្គការសិលាមានន័យថា ធ្វើពីតូចទៅធំ ហើយទៅវិញទៅមក ដូចជាការធ្វើផែនការពីក្រោមទៅថ្នាក់លើ ។ ប៉ុន្តែថ្នាក់លើនៅតែជាអ្នកសំរេចធ្វើអ្វីដែលគេចង់ធ្វើ ។ ដើម្បីដូរពីធនាគារស្រូវទៅជាធនាគារជី គឺជាគំនិតមកពីថ្នាក់លើ ។ បើសិនអ្នកថ្នាក់លើមិនអោយយោបល់ទេ ប្រជាជនមិនហ៊ានធ្វើទេ (សមាជិក គ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

---

[២] ពាក្យថា អង្គការត្រូវបានប្រើប្រាស់ដែលពិបាកយល់មែនទែនក្នុងរបបខ្មែរក្រហម ប៉ុន្តែជាពាក្យដែលគួរអោយខ្លាចនោះមិនបានធ្វើអោយអ្នកភូមិខ្វល់ទេ ព្រោះអ្នកភូមិភាគច្រើនមិនទាន់ឃើញដល់រឿងនោះថា ជាពាក្យតែមួយ ។

*ខ្ញុំមិនដឹងថា អង្គការជាផ្នែកមួយរបស់រដ្ឋអំណាចអីទេ ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា អង្គការមកពីថ្នាក់លើ (សមាជិក គ.អ.ភ ខែមិនា ឆ្នាំ២០០០) ។*

*មេភូមិមិនសូវពូកែទាក់ទងជាមួយថ្នាក់លើដូចមេភូមិនៅភូមិគេទេ ។ អង្គការចែកគោ ក្របី ជ្រូក មាន់ ទា និងសំភារៈ ដូចជា ចប កាំបិត និងពូថៅ អោយប្រជាជននៅភូមិគេផ្សេងទៀត (មេក្រុម ខែមិនា ឆ្នាំ២០០០) ។*

*ប្រសិនអ្នកភូមិមិនស្នើសុំអង្គការធ្វើអ្វីមួយទេ មេឃុំមិនមកទេ ។ គាត់ចុះមកមើលការលើកថ្នល់ ព្រោះគាត់បានប្រយោជន៍ពីវា ។ គាត់មិនដែលគិតពីសុខទុក្ខរបស់អ្នកភូមិទេ ។ រដ្ឋាភិបាលមិនដែលគិតទេ (អាចារ្យ ក្នុងក្រុមផ្តល់យោបល់ ខែមិនា ឆ្នាំ២០០០) ។*

អ្នកនៅឃុំជិតដិតជាមួយសិលាជាងអ្នកភូមិជ្រែង ។ ពួកគេក៏បានធ្វើការជាមួយអង្គការអភិវឌ្ឍផងដែរ ។ ប៉ុន្តែមេឃុំនិយាយថា គាត់រវល់ជាមួយនឹងសកម្មភាពរបស់សិលា ហើយក៏មានស្ត្រីម្នាក់នៅក្នុង គ.អ.ឃ អះអាងថា មេឃុំទុកការងារទាំងអស់អោយគាត់ និងស្ត្រីម្នាក់ផ្សេងទៀតធ្វើ មេឃុំមិនដែលនៅសាលាឃុំ ប៉ុន្តែធ្វើការនៅផ្ទះគាត់ជាកន្លែងដែលកម្មវិធីឥណទានដំណើរការ ហើយដែលធ្វើអោយគាត់ទទួលបានចំណូលផ្ទាល់ខ្លួនយ៉ាងច្រើន ។

*ខ្ញុំក៏រវល់ជាមួយ NGOs ដែលចង់ធ្វើការនៅក្នុងឃុំនេះដែរ ។ ខ្ញុំត្រូវចំណាយពេលជាមួយពួកគេ ។ វាល្អណាស់ បើសិនជា NGOs ធ្វើការផ្ទាល់ជាមួយអ្នកភូមិ (មិនតាមរយៈរដ្ឋអំណាចទេ) ។ ព្រោះ NGOs មានជំនាញពេញលេញ រដ្ឋអំណាចអត់មានជំនាញទេ ។ ប៉ុន្តែយើងនៅតែមើល NGOs ។ ជាពិសេស ឃុំរវល់ជាមួយហត្ថាកសិករ (NGOs ក្នុងស្រុក) ។ ខ្ញុំជាអ្នកធ្វើការងារអភិវឌ្ឍន៍សហគមន៍ ។ ហត្ថាកសិករ អោយខ្ញុំធ្វើជាប្រធានសហគមន៍ ។ អ្នកខ្លះមកសងនៅផ្ទះខ្ញុំ ។ ដំបូងគេគិតជាភាគរយអោយយើង (គាត់ និងគណនេយ្យករ) ម្នាក់១ រកបាន៤ ឬ៥ដុល្លារ ក្នុងមួយខែ ។ ក្រោយមកកម្មវិធីក៏ដំឡើងអោយ ហើយឥឡូវនេះ ក្នុងមួយខែយើងបាន៥០-៦០ដុល្លារ (មេឃុំ ខែមិនា ឆ្នាំ២០០០) ។*

*មេឃុំគិតតែពីកម្មវិធីឥណទានទេ ព្រោះគាត់រកលុយបាន ។ នៅពេលសិលាចាប់ផ្តើម មេឃុំឧស្សាហ៍ទៅភូមិ ប៉ុន្តែតាំងពីហត្ថកសិករចាប់ផ្តើមធ្វើការនៅឃុំ គាត់មិនដែលទៅទេ (សមាជិក គ.អ.ឃ មកពីភូមិផ្សេង ខែមិនា ឆ្នាំ២០០០) ។*

*គោកដូងៈ ខ្ញុំទៅជជែកលេងជាមួយមេឃុំ*

- មេឃុំឧស្សាហ៍ចុះមកភូមិជាងមុន ប៉ុន្តែដូចនៅភូមិជ្រែងដែរ អ្នកភូមិមិនដឹងច្បាស់ពីតួនាទីរបស់ឃុំនៅក្នុងសកម្មភាពអភិវឌ្ឍន៍ទេ ។
- សមាជិក គ.អ.ភ មានភាពស្និទ្ធស្នាលជាមួយឃុំជាងមុន ប៉ុន្តែពួកគេមិនដឹងច្បាស់ថា អ្នកណាខ្លះនៅក្នុងជួរគណៈកម្មការអភិវឌ្ឍន៍ឃុំ (គ.អ.ឃ) ហើយគណៈកម្មការនេះ ត្រូវបានបង្កើតដើម្បីអ្វីនោះទេ ។ បច្ចុប្បន្ន ប្រធាន គ.អ.ភ និងមេភូមិ ជាអ្នកទំនាក់ទំនងជាមួយឃុំ ។

• ដូចនៅភូមិជ្រៃងដែរ ជាទូទៅអ្នកភូមិមិនបានគិតថា ឃុំនៅជាប់ដោយខ្សែកពី "ថ្នាក់លើ" ទេ និងសំខាន់ជាងការផ្លាស់ប្តូរទំនាក់ទំនងរបស់អ្នកភូមិចំពោះថ្នាក់ឃុំ គឺដោយសារវត្តមានរបស់អង្គការ ។

មន្ត្រីឃុំនិយាយថា តួនាទីរបស់ឃុំខុសគ្នាច្រើនជាងពីមុន ហើយនិយាយបន្ថែមទៀតថា ពួកគេមមាញឹកជាមួយការងារអភិវឌ្ឍន៍ ជាពិសេសតាំងពីកម្មវិធីសិលាចាប់ផ្តើម ។

*កាលពីដើមយើងត្រូវជ្រើសរើសពលករ ។ ឥឡូវនេះគ្មានសង្គ្រាមទេ ហើយយើងគ្រាន់តែត្រូវការគិតថាធ្វើយ៉ាងម៉េចអោយឃុំរីកចំរើន ។ យើងមិនធ្វើអោយប្រជាជនព្រួយបារម្ភ មិនអោយភ័យខ្លាច (អនុប្រធានឃុំ ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*មេឃុំចាស់មិនចេះដោះស្រាយជាមួយការងារអភិវឌ្ឍន៍ និងអង្គការ ដូចជាអង្គការអភិវឌ្ឍន៍ស្ត្រី និងកម្មវិធីស្បៀងអាហារពិភពលោកទេ អញ្ចឹងឃុំអត់មានទំនាក់ទំនងជាមួយពួកគេឡើយ ។ នៅពេលគេតែង តាំងខ្ញុំ ខ្ញុំមិនដឹងថា ខ្ញុំអាចដោះស្រាយជាមួយកម្មវិធីអភិវឌ្ឍន៍ ឬអត់ ។ ខ្ញុំធ្លាប់តែធ្វើតាមរយៈខ្សែបណ្តោយប៉ុណ្ណោះ មិនមែនជាមួយការងារអភិវឌ្ឍន៍ទេ ។ នៅពេលកម្មវិធីសិលាចូលមក ខ្ញុំចាប់ផ្តើម រៀនដោះស្រាយជាមួយការងារអភិវឌ្ឍន៍ (មេឃុំ ខែកុម្ភៈ ឆ្នាំ២០០០) ។*

ចំពោះអ្នកភូមិនៅភូមិគោកដូង ការផ្លាស់ប្តូរដ៏ធំនៅក្នុងទំនាក់ទំនងចំពោះឃុំ គឺគេឃើញ មេឃុំចុះទៅភូមិច្រើនជាងមុន ។ កាល២-៣ឆ្នាំមុន គាត់ឧស្សាហ៍មកជួបមេភូមិ និងប្រធាន គ.អ.ភ ហើយគាត់បានចូលរួមបុណ្យ ៨មិនា (ទិវានារី អន្តរជាតិ) របស់អង្គការអភិវឌ្ឍន៍ស្ត្រី ។ ការចុះមកភូមិបែបនេះ ធ្វើអោយអ្នកភូមិចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ជាមួយមេឃុំ ប៉ុន្តែជាទូទៅ ពួកគេមិនដឹងពីតួនាទីរបស់ឃុំធ្វើអ្វីខ្លះ ក្នុងការផ្តល់ថវិកា ការសំរេចចិត្ត និងការអនុវត្តសកម្មភាពបែបនេះទេ ។ សំខាន់អ្នកភូមិនៅតែយល់ថា ឃុំជាអ្នកចេញលិខិតរៀបអាពាហ៍ពិពាហ៍ និងដោះស្រាយជម្លោះដដែល ។

សមាជិក គ.អ.ភ កាន់តែជិតដិតជាមួយឃុំតាមរយៈតួនាទីរបស់ពួកគេ ។ នៅលើកដំបូងគ.អ.ភទាំងអស់គ្នាបានទៅចូលរួមវគ្គបណ្តុះបណ្តាលផ្សេង១ ប៉ុន្តែនៅភូមិគោកដូង តាំងពីមានគំរោងស្តារប្រឡាយនៅឆ្នាំទីមួយ មិនមានសកម្មភាពអ្វីទៀតទេ ហើយឥឡូវនេះមេឃុំគ្រាន់តែមកជួបប្រធាន និងមានតែប្រធានតែប៉ុណ្ណោះដែលទៅឃុំ ។ ប្រធាន គ.អ.ភ និយាយថា ជួនកាលគាត់គ្រាន់តែទៅនិយាយលេងជាមួយមេឃុំប៉ុណ្ណោះ ព្រោះវាមានសារៈសំខាន់ណាស់ ដើម្បីមានទំនាក់ទំនងល្អជាមួយមេឃុំ ។

*មុនកម្មវិធីសិលា យើងជាអ្នកភូមិសាមញ្ញ និងអត់មានឱកាសជួបមេឃុំទេ ។ មានតែមេភូមិប៉ុណ្ណោះ ។ ឥឡូវនេះ យើងអាចសុំជួបគាត់ ។ មេឃុំឧស្សាហ៍មក ប៉ុន្តែគាត់ជួបតែមេភូមិ ។ យើងចង់ដឹងថា មេឃុំអោយផែនការអ្វីទៅមេភូមិ (ក្រុម គ.អ.ភ ស្រី ប្រុស ខែវិច្ឆិកា ឆ្នាំ១៩៩៩) ។*

*មេឃុំចុះមកភូមិ ពេលណាដែលមានផែនការ ហើយពួកគេត្រូវការប្រជុំប្រាប់អ្នកភូមិ ហើយគាត់ចុះមកមើលការស្តារប្រឡាយ និងដាក់លូ ។ កាលពីទើបមានគ.អ.ភថ្មី១ ខ្ញុំមិនដែលទាក់ទងជា*

*មួយឃុំទេ ក្រៅពីពេលទៅរៀន ។ ក្រោយមក ពឿន (ប្រធានអភិវឌ្ឍន៍) និងមេភូមិ ឧស្សាហ៍ទៅប្រជុំ (សមាជិកគ.អ.ភ. ភ្នាក់ងារសុខភាពភូមិ. អ្នកបណ្ដុះបណ្ដាលសុខភាពផ្លូវចិត្ត ខែមេសា ឆ្នាំ២០០០) ។*

*ខ្ញុំគ្រាន់តែទៅអង្គុយនិយាយលេងជាមួយគាត់នៅកន្លែងនោះ (សាលាឃុំ) ។ វាមិនមែនជាផ្លូវការអ្វីទេ ខ្ញុំគ្រាន់តែទៅ និយាយលេងជាមួយគាត់ ។ ជូនកាល ពេលខ្ញុំទៅរៀន ខ្ញុំទៅជួបគាត់មុនម៉ោងធ្វើការ ។ ជូនកាលខ្ញុំជិះកង់តែឯងទៅនិយាយលេងជាមួយគាត់ បញ្ចុះបញ្ចូលគាត់អោយគាត់សុំថវិកាពីស្បៀងអាហារពិភពលោក ។ ខ្ញុំខំយកចិត្តគាត់ ធ្វើអោយគាត់សុំគេម្តងទៀត ។ ខ្ញុំដើរលេងជាមួយគាត់ និងនិយាយថា "លោក! សុំជួយអ្នកភូមិផង" ។ ខ្ញុំមិនដឹងថា បានជួយ ឬមិនជួយទេ ។ ខ្ញុំមិនសូវបានជួបមេឃុំចាស់ទេ ។ ខ្ញុំមានមុខតំណែងមែន ប៉ុន្តែខ្ញុំទៅ តែពេលគេហៅ ។ ឥឡូវនេះ ខ្ញុំអាចទៅពេលណាក៏បានដែរ ទោះព្រឹក ឬល្ងាចក៏ដោយ ។សមាជិកផ្សេងទៀតស្គាល់គាត់ ប៉ុន្តែគេមិនហ៊ានទៅជួបគាត់ ។ ខ្ញុំតែងទៅរៀន (ប្រធានគ.អ.ភ សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី ខែមេសា ឆ្នាំ២០០០) ។*

អ្នកភូមិមិនដឹងថា មានគណៈកម្មការអភិវឌ្ឍន៍ឃុំ (គ.អ.ឃ) ដែលត្រូវបានបញ្ជាក់ដោយក្រុមផ្តល់យោបល់ថា ពោរពេញទៅដោយអ្នកមានការយល់ដឹងយ៉ាងទូលាយ ។ សមាជិក គ.អ.ភ រួមទាំងអ្នកដែលជាសមាជិក គ.អ.ឃ ក៏មិនច្បាស់ពីរឿង គ.អ.ឃ និងការបែងចែកធនធានអភិវឌ្ឍន៍ដែរ ។ ពួកគេមិនច្បាស់ថា អ្នកណាខ្លះនៅក្នុង គ.អ.ឃ ហើយហាក់ដូចមិនដឹងថា មានតំណាងភូមិ ឬឥទ្ធិពល ។ ចំពោះអ្នកដែលមានវត្តមាននៅពេលធ្វើការបែងចែកថវិកាអភិវឌ្ឍន៍មូលដ្ឋាន ហាក់ដូចជាទៅមើលលំហាត់គិតលេខនៅលើក្ដារខៀន ដែលធ្វើដោយអ្នកផ្សេងតែប៉ុណ្ណោះ ។

*ក្រុមផ្តល់យោបល់នៅក្នុងភូមិ ខែមេសា ឆ្នាំ២០០០:*

- សូម្បីតែខ្ញុំ ក៏មិនដឹងថា មានគណៈកម្មការអភិវឌ្ឍន៍ឃុំដែរ ។ មានតែ ពឿន និងមឿន (ប្រធានអភិវឌ្ឍន៍) ទើបដឹង ។ ខ្ញុំស្គាល់តែមេឃុំទេ ។ បើសិនប្រជាជនមិនបោះឆ្នោតគណៈកម្មការអភិវឌ្ឍន៍ឃុំផង ធ្វើម៉េចគេដឹងទៅ? (បុរស អ្នកភូមិ) ។
- បាទ! មូលហេតុដែលអ្នកភូមិមិនស្គាល់គណៈកម្មការអភិវឌ្ឍន៍ឃុំ ឬមន្ត្រីឃុំច្បាស់ គឺដោយសារអ្នកភូមិមិនបានបោះឆ្នោតអោយពួកគេ (អាចារ្យ អ្នកភូមិ) ។
- មិនល្អទេដែលអ្នកភូមិមិនដឹងថា មានគណៈកម្មការអភិវឌ្ឍន៍ឃុំ ។ ឃុំគួរតែប្រជុំមួយថ្ងៃប្រាប់ប្រជាជនក្នុងគ្រប់ៗភូមិ ។ សូម្បីខ្ញុំ ក៏មិនដឹងដែរ ព្រោះយើងមិនដឹងថា អ្នកណាចាត់តាំងពួកគេទេ (មេក្រុម) ។
- ខ្ញុំដឹងថា មានគណៈកម្មការអភិវឌ្ឍន៍ឃុំ ប៉ុន្តែខ្ញុំមិនដឹងថា មានអ្នកណាខ្លះ (សមាជិក គ.អ.ភ. ភ្នាក់ងារអប់រំសុខភាពភូមិ. អ្នកបណ្ដុះបណ្ដាលសុខភាពផ្លូវចិត្ត) ។

គេនិយាយថា ប្រធានគ.អ.ភគ្រប់រូប គឺជាសមាជិក (គ.អ.ឃ) ប៉ុន្តែខ្ញុំមិនដែលចូលរួមប្រជុំទេ ។ គេមិនដែលហៅ ។ កាលមុន ខ្ញុំឧស្សាហ៍ទៅប្រជុំ ។ ប៉ុន្តែឥឡូវនេះ ខ្ញុំខានទៅប្រជុំយូរហើយ ។ គេមិនប្រជុំព្រោះយើងអត់មានផែនការ អត់មានសកម្មភាព ។ ខ្ញុំទៅប្រជុំ (នៅពេលគេសរសេរជ្រើសរើស) ។ នៅឆ្នាំទីមួយ ឃុំទាំងមូល បានទទួលលុយ ហើយគេចែកគ្នា អ្នកណាបានច្រើន និងអ្នកណាបានតិច អាស្រ័យលើចំនួនប្រជាជន ។ ក្រោយមកគេសរសេរលើលេខ ។ ខ្ញុំក៏យល់ស្របតាមគេដែរព្រោះវាត្រូវ ។ គេធ្វើ

លក្ខណៈវិនិច្ឆ័យ ហើយភូមិផ្សេងបាន ។ នៅឆ្នាំទីបី គេធ្វើការវិនិច្ឆ័យ ហើយភូមិផ្សេងបានទៀត ។ អ្នកសំរបសំរួលជាអ្នកសំរេច ប៉ុន្តែវាអាស្រ័យលើលេខ (ប្រធាន គ.អ.ភ សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី ខែមេសា ឆ្នាំ២០០០) ។

ក្នុងការប្រជុំនៅគ.អ.ឃ អ្នកសំរបសំរួលក៏នៅទីនោះដែរ ។ គេអោយខ្ញុំសំរបសំរួល ។ បើមិនអញ្ចឹងទេ វាមិនមានដំណើរការល្អ (មន្ត្រីសំរបសំរួលស្រុក ខែមេសា ឆ្នាំ២០០០) ។

យោងទៅលើតារាងដែលបិទនៅនឹងជញ្ជាំងក្នុងសាលាឃុំ ភូមិគោកដូងមានសមាជិកគ.អ.ឃ ចំនួនបីរូប មេភូមិ, ប្រធាន គ.អ.ភ. និងសមាជិក គ.អ.ភ ម្នាក់ ។ សមាជិកនេះជាតំណាងនារីឃុំម្នាក់ ក្នុងចំណោមតំណាងនារីឃុំបីនាក់ ហើយគាត់បាននិយាយថា តំណាងទាំង ៣រូបនេះ ត្រូវបានបោះឆ្នោតនៅសាលាឃុំ ក្នុងចំណោមបេក្ខជន ១៦រូបដែលសុទ្ធតែជាសមាជិកគ.អ.ភ ។ គាត់ហាក់ដូចជា មានបញ្ញាឈ្លាសវៃ និងខិតខំប្រឹងប្រែងធ្វើការងារ ហើយគាត់មានការយល់ដឹងទៅលើវិស័យផ្សេងៗទៀត ។ តែនៅពេលនិយាយដល់រឿងឃុំ គាត់ដឹងមិនសូវច្បាស់ទេ ។

*ខ្ញុំនៅទាំងសងខាង ឃុំ និងភូមិ ។ នៅខាងឃុំខ្ញុំគ្រាន់តែមានឈ្មោះទៅរៀន និងប្រជុំតែប៉ុណ្ណោះ ។ ខ្ញុំជាសមាជិកធម្មតា អញ្ចឹងខ្ញុំមិនសូវមានការងារធំដុំធ្វើទេ ។ ពេលមានអ្នកមកពី ភ្នំពេញ ខ្ញុំគ្រាន់តែទៅស្វាគមន៍ ។ ខ្ញុំអត់ស្គាល់សមាជិកប្រុសៗទេ ។ ខ្ញុំស្គាល់តែសមាជិកស្រីៗ ។ សមាជិកស្រីៗ អត់មានការងារធ្វើទេ ។ ប្រហែលជា [គណៈកម្មការ] អភិវឌ្ឍន៍ឃុំសំរាប់ឱ្យមានស្រីប្រុសលាយគ្នា ។ លុយមកពីខេត្តធ្លាក់មកឃុំ ហើយឃុំសំរេចអោយលុយ ។ មេឃុំអោយលុយទៅតំបន់ភូមិមួយៗ ។ ខាងស្រុកក៏មកគិតលេខដែរ ។ ភាគច្រើនគេហៅមេភូមិ និងប្រធាន [ទៅប្រជុំកន្លែង គេគិតគូរលេខ] ។ ខ្ញុំចូលរួមបានម្តង ប៉ុន្តែខ្ញុំមិនបានចូលរួមក្នុងការសំរេចចិត្តទេ (ស្ត្រីដែលជាសមាជិក គ.អ.ភ. និង គ.អ.ឃ. ភ្នាក់ងារអប់រំសុខភាពភូមិ. ប្រធានផ្លូវចិត្ត ខែមេសា ឆ្នាំ២០០០) ។*

ដូចនៅភូមិជ្រៃជ្រងដែរការពិតដែលថា ឥទ្ធិពលទៅលើទំនាក់ទំនងរបស់អ្នកភូមិ ចំពោះឃុំមានលក្ខណៈកំណត់ខ្លាំង សូម្បីតែការយល់ដឹងរបស់សមាជិក គ.អ.ភ ចំពោះ គ.អ.ឃ ក៏មានលក្ខណៈខ្សោយណាស់ដែរ នោះប្រហែលដោយសារអ្នកភូមិជាទូទៅមិនបែងចែកឃុំអោយដាច់ចេញពី "ថ្នាក់លើ" ហើយយល់ឃើញថា អង្គការជាផ្នែកមួយសំខាន់ជាងថ្នាក់លើទាំងនេះ និងជាភ្នាក់ងារអភិវឌ្ឍន៍ដ៏ចម្បង ។

ប្រជាជននៅភូមិគោកដូង ស្គាល់ឈ្មោះអង្គការផ្សេងៗ និងមានភាពជិតដិតជាមួយអ្នកមកពីខាងអង្គការអភិវឌ្ឍន៍ស្ត្រីម្នាក់ ឬពីរនាក់ជាងស្គាល់មន្ត្រីឃុំ ។ ជាទូទៅ អ្នកភូមិមិនបែងចែកសិលា អោយដាច់ពីអង្គការអភិវឌ្ឍន៍ទេ (មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលបានលឺពាក្យសិលា) ។ អ្នកភូមិមិនមានភាពជិតដិតជាមួយអ្នកសំរបសំរួលស្រុក និងខេត្តទេ ប៉ុន្តែនៅពេលគេជិះម៉ូតូកាត់មុខផ្ទះអ្នកភូមិ ឬមានវត្តមាននៅក្នុងអង្គប្រជុំ អ្នកភូមិយល់ឃើញថា ជាអ្នកមកពីអង្គការ ។ ប៉ុន្តែសមាជិក គ.អ.ភ ដែលជិតដិតជាមួយពួកគេនោះ និយាយថាក្រុមសំរបសំរួលស្រុកជា "ភាគី" ខាងស្រុក ។ សមាជិក គ.អ.ភ មួយចំនួន ព្រមទាំងអ្នកភូមិមួយចំនួនតូចទៀត ក៏យល់ឃើញពីការខុសប្លែកគ្នា រវាងសិលា និង អង្គការអភិវឌ្ឍន៍ ។

*សិលា និងអង្គការអភិវឌ្ឍន៍ដូចគ្នា គោលបំណងតែមួយគត់របស់ពួកគេ គឺដើម្បីអភិវឌ្ឍន៍ ។ កម្មវិធីសិលា និងការស្តារប្រឡាយ គឺរបស់តែមួយ ។ កម្មវិធីសិលាចេញមកពីថ្នាក់លើ (ស្ត្រីដែលជាសមាជិក គ.អ.ភ ខែមេសា ឆ្នាំ២០០០) ។*

*សិលាអោយចូលរួមវិភាគទាន ហើយគេសុំយោបល់ពីអ្នកភូមិ ។ គេអោយអ្នកភូមិសំរេចចិត្ត ក្រុមរបស់យើង (គ.អ.ភ) មិនសំរេចដោយខ្លួនឯងទេ ។ អង្គការក្រៅរដ្ឋាភិបាល មិនដែលអោយអ្នកភូមិចូលរួមវិភាគទានទេ ប៉ុន្តែនេះជាការងាររបស់រដ្ឋាភិបាល ហើយគេសុំថ្លៃចូលរួម (ស្ត្រីដែលជាសមាជិក គ.អ.ភ និង គ.អ.ឃ ភ្នាក់ងារសុខភាពភូមិ. ប្រធានផ្លូវចិត្ត ខែមេសា ឆ្នាំ២០០០) ។*

*ឥឡូវនេះ កម្មវិធីស្បៀងអាហារពិភពលោក មានការយឺតយ៉ាវ ព្រោះគេធ្វើការជាមួយរដ្ឋាភិបាល ។ គេធ្វើតាមបែបបទរបស់សិលា ។ សិលាសុំការចូលរួមវិភាគទានពីអ្នកភូមិ ហើយស្បៀងអាហារពិភពលោក ក៏សុំការចូលរួមវិភាគទានពីអ្នកភូមិដែរ ។ អង្គការលឿនជាង ។ នៅពេលគេអោយអង្ករតាមរចនាសម្ព័ន្ធរដ្ឋាភិបាល វាយូរ ព្រោះរដ្ឋាភិបាលគិតល្អិតល្អន់ពេក ហើយគេទុកក្នុងហោប៉ៅគេខ្លះ (ស្ត្រី/ បុរសពីរនាក់ ខែមេសា ឆ្នាំ២០០០) ។*

*មានកម្មវិធីផ្សេងៗគ្នា ។ ហេតុនេះហើយបានជាគេបង្កើតគណៈកម្មការផ្សេងៗគ្នា ។ មួយគឺអង្គការ ជាកម្មវិធីរបស់រដ្ឋាភិបាល មួយ គឺសិលា ។ អង្គការអភិវឌ្ឍន៍ស្ត្រីបង្កើតធនាគារស្រូវ ឥណទានគោ ។ សិលាក៏ធ្វើការអភិវឌ្ឍន៍ ប៉ុន្តែស្តារតែប្រឡាយ ឬលើកថ្នល់ប៉ុណ្ណោះ ហើយគេសុំថ្លៃចូលរួម ១០% (ប្រធាន គ.អ.ភ សមាជិកគណៈកម្មការអភិវឌ្ឍន៍ស្ត្រី ខែមេសា ឆ្នាំ២០០០) ។*

*ធនាគារស្រូវ គោ និងលុយ គឺជាផ្នែកមួយដែលនៅក្រៅរដ្ឋាភិបាល ។ គ.អ.ភ ស្របជាមួយរដ្ឋាភិបាល ។ ឧទាហរណ៍បើសិនគេគំរោងធ្វើអ្វីមួយ វាត្រូវចេញពីភូមិទៅឃុំ ទៅស្រុក ទៅខេត្ត មុននឹងសំរេច ។ បើវានៅក្រៅរដ្ឋាភិបាល អ្នកគ្រាន់តែស្នើសុំទៅបុគ្គលិក ហើយបុគ្គលិកយកទៅអោយអង្គការ គឺចប់ (អាចារ្យ ខែមេសា ឆ្នាំ២០០០) ។*

## សេចក្តីសន្និដ្ឋាន

### *ការគ្រប់គ្រងនៅថ្នាក់ភូមិ*

- ឥទ្ធិពលផ្ទាល់របស់សិលាស្តីពីការគ្រប់គ្រងនៅថ្នាក់ភូមិ គឺត្រូវបានកំណត់យ៉ាងទូលាយដោយទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន ប៉ុន្តែមានលទ្ធភាពដើម្បីបង្កើតឱកាសជាច្រើនទៀតសំរាប់អោយអ្នកដឹកនាំជំនួស ឬបន្ថែមទៀត ។

ករណីទាំងពីរនៅក្នុងការសិក្សានេះ បង្ហាញអោយឃើញថា សិលា (និងអន្តរាគមន៍អភិវឌ្ឍន៍ផ្សេងៗទៀត) អាចមានឥទ្ធិពលទៅលើរចនាសម្ព័ន្ធគ្រប់គ្រងអំណាចនៅតាមភូមិ ។ ធម្មជាតិនៃឥទ្ធិពលនេះ ពឹងផ្អែកលើទំនាក់ទំនង និងបរិយាកាសនយោបាយដែលមានស្រាប់សំខាន់គឺ ឋានៈ ឥរិយាបទ និងទង្វើរបស់អាជ្ញាធរភូមិ ។ នៅភូមិ

ជ្រៃង អន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ បន្ថែមទៅលើអំណាចដែលមានស្រាប់ ដូចជាមេភូមិ និងជីវពលប្រើមុខតំណែងរបស់ពួកគេដើម្បីត្រួតត្រា ។ ប៉ុន្តែទង្វើនេះធ្វើអោយពួកគេមានភាពអន់ថយ ហើយរចនាសម្ព័ន្ធដឹកនាំទាំងមូលងាយនឹងបាក់បែក ។ ប៉ុន្តែនៅភូមិគោកដូង អំណាចត្រូវបានចែកគ្នា ព្រោះអាជ្ញាធរថ្នាក់ភូមិបានអនុញ្ញាត និងស្វាគមន៍អ្នកផ្សេងអោយមានភារកិច្ច និងទទួលខុសត្រូវ ដែលបានពង្រឹងពង្រីករចនាសម្ព័ន្ធផ្នែកដឹកនាំមួយរឹងមាំ ។

ដូច្នេះ ទោះជាទំនាក់ទំនងអំណាចដែលមានស្រាប់កំណត់លទ្ធផលផ្ទាល់យ៉ាងទូលាយ ហើយទោះជាការសិក្សានេះបង្ហាញពីស្ថានភាព និងលទ្ធផលខុសគ្នាខ្លាំងក៏ដោយ នៅក្នុងករណីទាំងពីរ អន្តរាគមន៍ផ្នែកអភិវឌ្ឍន៍បង្កើតអោយមានអ្នកដឹកនាំជំនួស ឬអ្នកដឹកនាំបន្ថែម ។ នៅភូមិជ្រៃង សមាជិក គ.អ.ភ ម្នាក់ និងមនុស្សពីរនាក់ទៀត កំពុងទទួលបានការសរសើរ និងទំនុកចិត្តពីអ្នកភូមិ ដែលផ្ទុយពីអាជ្ញាធរថ្នាក់ភូមិ ។ នៅភូមិគោកដូង បុរសពីរនាក់ដែលមានមុខតំណែងផ្នែកអភិវឌ្ឍន៍បានទទួលស្គាល់ផ្នែកដឹកនាំក្បែរនឹងមេភូមិ ។

ប៉ុន្តែ មានអានុភាពសំរាប់បង្កើតឱ្យមានឱកាសច្រើន និងកាន់តែប្រសើរឡើងសំរាប់អភិវឌ្ឍន៍ការទទួលស្គាល់ និងគុណភាពនៃការដឹកនាំ ។ នៅក្នុងចំណោមកង្វះខាតទាំងនេះ គឺការប្រមូលផ្តុំលើការងារអោយតែបុរសម្នាក់ ឬពីរនាក់ប៉ុណ្ណោះ ប្រការដែលមិនបានបង្កើតអោយមានផលប្រយោជន៍ និងសមត្ថភាព និងការខិតខំប្រឹងប្រែង (របស់ស្ត្រី) ផ្សេងៗទៀត ភាពរារែកមិនចង់មាន មុខតំណែងផ្នែកការងារអភិវឌ្ឍន៍ កង្វះខាតភាពច្បាស់លាស់ក្នុងចំណោមអ្នកដែលមានមុខតំណែងអំពីអាណត្តិរបស់ពួកគេ និងការពិតដែលថាពួកគេ និងអំណាចរបស់ពួកគេមិនត្រូវបានស្គាល់យ៉ាងទូលាយក្នុងចំណោមអ្នកភូមិផ្សេងៗទៀតទេ ។

នៅក្នុងសិលា មាននិន្នាការ និងអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ផ្សេងៗទៀត ដើម្បីផ្តោតទៅលើបុគ្គលម្នាក់ ឬពីរនាក់ប៉ុណ្ណោះ ជាទូទៅមេភូមិ និង/ឬប្រធាន គ.អ.ភ ។ មូលហេតុ គឺប្រហែលជាវាងាយស្រួល ដើម្បីបង្កើតទំនាក់ទំនងជាមួយមនុស្សម្នាក់ ឬពីរនាក់ដែលមានជំនាញចាំបាច់ និងទៅលើអ្នកណាដែលអ្នកអាចពឹងពាក់បាន ។ ប៉ុន្តែលទ្ធផលមិនមែនជាបន្ទុកធ្ងន់ធ្ងរ និងចាំបាច់ទៅលើមនុស្សពីរបីនាក់ដែលអាច ឬមិនអាចធានារ៉ាប់រងបន្ទុកនេះបានទេ ប៉ុន្តែសមត្ថភាព និងការខិតខំប្រឹងប្រែងដ៏ខ្លាំងក្លារបស់អ្នកផ្សេងត្រូវខាតបង់ ។ ការជួយគាំទ្រសំខាន់ ចំពោះមេភូមិនៅជ្រៃងត្រូវបង្អាក់ និងធ្វើអោយការងារមានការយឺតយ៉ាវ ព្រោះមេភូមិមិនសូវសកម្មទេ ហើយប្រហែលជាមិនផ្តល់ពត៌មាន ឬប្រគល់ការងារអោយអ្នកផ្សេងទៀតទេ ។ នៅភូមិគោកដូង ប្រធានគ.អ.ភ និងលេខា ប្រឹងប្រែងធ្វើការ ដូច្នេះការងារនេះប្រហែលជាធ្វើរួចហើយ ។ បុរសទាំងពីរនេះបានទទួលស្គាល់ និងមានបទពិសោធន៍ជាច្រើន ហើយក្លាយជាមនុស្សដ៏សំខាន់ ។ នៅក្នុងភូមិទាំងពីរមានមនុស្សផ្សេងៗទៀតជាច្រើន (ជាពិសេសស្ត្រី) ដែលមានចំណេះដឹង និងមានឆន្ទៈធ្វើការងារ ដើម្បីទទួលបទពិសោធន៍ ទំនុកចិត្ត ដើម្បីអោយគេស្គាល់ និងទទួលបាននូវទំនុកចិត្តពីអ្នកភូមិ ប៉ុន្តែអ្នកដែលមិនបានទទួលការយកចិត្តទុកដាក់ដូចគ្នា ក៏ពុំមានឱកាសបានរៀនសូត្រដែរ ។

ការយកចិត្តទុកដាក់ទៅលើតែមនុស្សមួយចំនួនតូច និងការមិនយកចិត្តទៅលើអ្នកដទៃទៀត ដែលមានមុខតំណែងអភិវឌ្ឍន៍បង្កើនអោយមានការរារែកមិនចង់មានមុខតំណែង (ទោះបីមានមូលហេតុពិតប្រាកដផ្សេងៗចំពោះការរារែកនេះក៏ដោយ) ។ នៅក្នុងភូមិទាំងពីរ បុរសដែលមានសមត្ថភាព និងគួរអោយទុកចិត្តមួយចំនួនតូចដែលមិនព្រមទទួលមុខតំណែងផ្នែកអភិវឌ្ឍន៍ ព្រោះគេបានដឹងថា គេនឹងប្រឈមមុខនឹងការងារ និងការទទួលខុស

ត្រូវច្រើន ។ នៅក្នុងភូមិទាំងពីរមានមនុស្សស្រី និងប្រុស ដែលមានមុខតំណែងមិនច្បាស់លាស់ពីការគ្រប់គ្រងរបស់ខ្លួន បានធ្វើឱ្យពួកគេមិនទុកចិត្តនៅក្នុងតួនាទី ។ កង្វះខាតភាពច្បាស់លាស់ ក៏បានបង្កើតអោយមានពាក្យចចាមអារ៉ាមក្នុងចំណោមអ្នកភូមិផ្សេងៗទៀត ពីផលប្រយោជន៍ ដែលធ្វើអោយមានអារម្មណ៍មិនល្អ និងបន្ថែមទៅលើភាពភាំងកែ ។

មូលហេតុ គឺមានច្រើនប្រភេទដែលអ្នកមានមុខតំណែងផ្នែកអភិវឌ្ឍន៍មិនច្បាស់ និងទុកចិត្តនៅក្នុងតួនាទីរបស់ពួកគេ និងមូលហេតុដែលអ្នកភូមិផ្សេងទៀតមិនស្គាល់ និងមិនដឹងពីការទទួលខុសត្រូវរបស់ពួកគេ ។ នៅក្នុងករណីខ្វះប្រព័ន្ធទាំងមូល មិនច្បាស់លាស់អ្នកដែលចូលមកភូមិ ដើម្បីណែនាំមុខតំណែង និងបែបបទថ្មីក៏មិនច្បាស់ពីការគ្រប់គ្រង និងទំនាក់ទំនងដែរ ។ ជាញឹកញាប់ ការចែកចាយពតិមានមិនមានប្រសិទ្ធិភាពទេ ។ មូលហេតុមួយទៀត គឺនិន្នាការដើម្បីបង្កើតអោយមានមុខតំណែង ប៉ុន្តែបន្ទាប់មកមិនធ្វើអោយគេមានសកម្មភាពទេ ។ នៅភូមិគោកដូង សមាជិកគ.អ.ក មិនមានការងារណាមួយអោយច្បាស់លាស់ទេ ចាប់តាំងពីឆ្នាំទីមួយមកម្លេះ ។ ពេទ្យសត្វភូមិ ត្រូវបានជ្រើសរើសជាច្រើនដង ដោយពុំដែលបានចាប់ផ្តើមធ្វើការអោយបានពិតប្រាកដនៅឡើយទេ ។ នៅភូមិជ្រៃង ៧ខែជាងហើយ បន្ទាប់ពីការជ្រើសរើសភ្នាក់ងារអប់រំសុខភាពភូមិ ពួកគេនៅតែមិនទាន់បានទទួលការបណ្តុះបណ្តាលណាមួយទេ សូម្បីចាប់ផ្តើមធ្វើការក៏គ្មានដែរ ។

## *ការទាមទារសិទ្ធិរបស់អ្នកភូមិ*

- ឥទ្ធិពលដែលសិលាអាចមានទៅលើទំនោររបស់អ្នកភូមិក្នុងការទាមទារសិទ្ធិរបស់គេ មិនមែនកើតឡើងពីការប្រជុំ ឬការចូលរួមវិភាគទាននោះទេ ប៉ុន្តែវាលេចចេញពីការបង្ហាញចំពោះភ្នាក់ងារ និងវេទាសម្ព័ន្ធនៅក្រៅភូមិ និងចេញពីការលេចឡើងនៃអ្នកដឹកនាំថ្មី ។

ការសិក្សានេះសូមជូនយោបល់ថា សិលាក៏អាចមានឥទ្ធិពលទៅលើទំនោររបស់អ្នកភូមិចំពោះការទាមទារសិទ្ធិរបស់ពួកគេដែរ ។ ប្រជាជនក្នុងភូមិទាំងពីរពុំមានការយល់ដឹងណាមួយពីឥទ្ធិពលលើការសំរេចចិត្តពីសកម្មភាពអភិវឌ្ឍន៍ឡើយ ។ ទាំងការចូលរួមប្រជុំ និងការចូលវិភាគទានជាកំលាំង ឬថវិកា មិនបានបង្កើតអោយមានការយល់ដឹងដ៏ខ្លាំងក្លាណាមួយ ឬជាទូទៅចំពោះភាពជាម្ចាស់ និងការទទួលខុសត្រូវទេ ។ ការប្រជុំនៅតាមភូមិមិនមែនជាវេទិកាសំរាប់ពិភាក្សា និងការសំរេចចិត្តដ៏ពិតប្រាកដនោះទេ ។ នៅភូមិគោកដូងការចូលរួមជាថវិកា ត្រូវបានគេចវេស ហើយក្តីសង្ឃឹមទៅលើការចូលរួមនេះ ធ្វើអោយអ្នកភូមិមិនទទួលយកគំរោងនេះ ។ អ្នកភូមិបានចូលរួមជាកំលាំងពលកម្មម្តងដែរ ប៉ុន្តែចូលតែអ្នកដែលបានទទួលកំរៃក្នុងការធ្វើការងារ (ដែលត្រូវគេផ្តល់ប្រាក់កំរៃទោះ) របស់ពួកគេតែប៉ុណ្ណោះ ។ នៅភូមិជ្រៃងអ្នកភូមិទទួលយកគំនិតនៃការចូលរួមជាកំលាំងពលកម្ម និងថវិកា ។ ប៉ុន្តែគេអនុវត្តការចូលរួមនេះជាការសុខចិត្តតាមបែបលេងល្បែង ជាវិធីទប់ទល់នឹងម្ចាស់ជំនួយ *គេបង្កើតក្រិតក្រមយើងគួរអនុវត្តតាម បើមិនអញ្ចឹងទេ យើងមិនបានទទួលអ្វីទេ* និងមិនមែនជាវិធីនៃការគ្រប់គ្រងឡើយ ។

ដូច្នេះពុំមានសញ្ញាបង្ហាញថា បច្ចុប្បន្ននេះការអនុវត្តការចូលរួមរបស់សិលាធ្វើអោយអ្នកភូមិមានទំនោរជាងនេះ ក្នុងការទទួលយកការទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានចូលរួម ឬយល់ដឹងពីសិទ្ធិដើម្បីទាមទារអ្វីមួយមកវិញ ដូចជាការបង់ពន្ធដែលអាចធ្វើបាន ។ ប៉ុន្តែអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ដោយពុំមានការទាមទារស្រដៀងគ្នាទៅលើ អ្នកភូមិ បានបង្កើតអោយមានទំលាប់ និងការរំពឹងទុកដែលអាចរារាំងគំនិតរបស់សិលាអោយមានការចូល

រួម និងភាពជាម្ចាស់ ។ ការណ៍ដែលបានទទួលរបស់របរដោយឥតចំណាយប្រាក់ជុំយនឹងបទដ្ឋានទូទៅ ជនមាតុភូមិនិវត្តន៍នៅភូមិគោកដូង ត្រូវបានគេស្តីបន្ទោសដោយថា "ធ្លាប់តែគេចិញ្ចឹម" អ្នកភូមិពុំមានចិត្តចង់បង់លុយ ចំពោះអ្វីដែលគេធ្លាប់បានដោយឥតគិតថ្លៃនោះទេ ។

ទោះជាមិនបានបង្កើតអោយមានការយល់ដឹងភ្លាមពីឥទ្ធិពល ភាពជាម្ចាស់ និងការទទួលខុសត្រូវទៅលើសកម្មភាពអភិវឌ្ឍន៍ពិតប្រាកដមួយចំនួនក៏ដោយនៅពេលថ្មីៗនេះ អ្នកភូមិនៅក្នុងភូមិទាំងពីរបានធ្វើការតវ៉ា ហើយអាចធ្វើនៅពេលឆាប់ៗនេះម្តងទៀត តាមវិធីដែលពួកគេមិនធ្លាប់ធ្វើ មុនពេលអន្តរាគមន៍អភិវឌ្ឍន៍ចាប់ផ្តើម ។ វាមានការពិបាកដើម្បីកំណត់នូវចំណែកអ្វីខ្លះដែលសិលា និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ មាននៅក្នុងការពន្យល់ពីមូលហេតុដែលការតវ៉ានេះ បានកើតឡើង និងអាចកើតឡើងតទៅទៀត ។

សារៈសំខាន់របស់អ្នកដឹកនាំ គឺភស្តុតាង ។ អ្នកដឹកនាំត្រូវតែប្រកបដោយចំណេះដឹង ការពុះពារ មានទំនុកចិត្តគ្រប់គ្រាន់ ហើយអ្នកដែលអ្នកភូមិផ្សេងទៀតទុកចិត្ត និងស្តាប់បង្គាប់ ។ ដូចដែលបង្ហាញជូនហើយថា អ្នកដឹកនាំប្រភេទនេះ បានលេចមុខមាត់ដោយសារលទ្ធផលនៃការចូលរួមក្នុងសិលា និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗទៀត ។

សារៈសំខាន់នៃចំណេះដឹងអំពីរចនាសម្ព័ន្ធរដ្ឋាភិបាល ក៏មិនមែនជាកំហុសឆ្គងទេ ។ ប្រជាជនត្រូវការដឹងពីកន្លែងដែលត្រូវទៅ (យ៉ាងហោចណាស់ក៏ដឹងកន្លែងដែលត្រូវទៅសួររកដែរ) ។ សិលាបានចូលរួមចំណែក ដើម្បីធ្វើអោយប្រជាជនមួយចំនួន យល់ដឹងពីរចនាសម្ព័ន្ធច្រើនជាងមុន ។ នៅភូមិជ្រែងអ្នកភូមិស៊ាំទៅនឹងគំនិតនៃការធ្វើសំណើទៅលើ ហើយនៅក្នុងភូមិទាំងពីរមនុស្សមួយចំនួនតូចយល់ដឹងពី "ថ្នាក់លើ" រួមមានមន្ត្រីឃុំ ព្រមទាំងអ្នកសំរបសំរួលស្រុក និងខេត្ត ។

ការទាមទារដ៏ចាំបាច់មួយ ដើម្បីអោយប្រជាជនធ្វើការទាមទារសិទ្ធិគឺថា ពួកគេយល់ពីសិទ្ធិទាំងនេះ និងយល់ឃើញថា សិទ្ធិទាំងនេះ គឺជាអ្វីដែលទាក់ទង និងការព្រួយបារម្ភ ។ មូលហេតុមួយដែលប្រជាជនមានទំនោរទាមទារសិទ្ធិនេសាទ និងបិតស្រា ជាងការសំរេចដើម្បីប្រើប្រាស់ថវិកាអភិវឌ្ឍន៍មូលដ្ឋានោះគឺថា ការនេសាទ និងបិតស្រា គឺជាសារៈសំខាន់បន្ទាន់សំរាប់របរចិញ្ចឹមជីវិតផ្ទាល់ខ្លួន ។ មូលហេតុមួយទៀតគឺថា ពួកគេមិនដឹងពីថវិកាអភិវឌ្ឍន៍មូលដ្ឋាន ឬសិទ្ធិរបស់ពួកគេដើម្បីចូលរួមក្នុងការសំរេចចិត្តក្នុងការប្រើប្រាស់ថវិកានោះទេ ។ បើសិនជាអ្នកភូមិបានដឹងពីថវិកាអភិវឌ្ឍន៍មូលដ្ឋានរបស់ឃុំ គេនឹងយល់ឃើញថា ថវិកានេះជារបស់អ្នកដែលរស់នៅក្នុងឃុំ ពួកគេនឹងចាប់ផ្តើមទាមទារការគ្រប់គ្រងលុយនោះហើយ ។

### *ទំនាក់ទំនងរបស់អ្នកភូមិចំពោះឃុំ*

- ឥទ្ធិពលរបស់សិលាទៅលើទំនាក់ទំនងរបស់អ្នកភូមិចំពោះឃុំ ត្រូវបានរារាំងដោយសារការកើតឡើងរបស់អង្គការ និងដោយសារអ្នកដទៃមានរបប ជាងបុគ្គលិកឃុំក្នុងការធ្វើការងារអភិវឌ្ឍន៍ ។

ការសិក្សាបង្ហាញអោយដឹងថា ឥទ្ធិពលរបស់សិលាទៅលើការយល់ឃើញ និងទំនាក់ទំនងរបស់អ្នកភូមិចំពោះឃុំនៅមានកំរិត ។ វាជុំយពីគោលបំណងនៃការបង្កើតឃុំអោយក្លាយជាភ្នាក់ងារអភិវឌ្ឍន៍ចម្បងអ្នកភូមិយល់

មិនច្បាស់ពីតួនាទីរបស់ឃុំនៅក្នុងសកម្មភាពអភិវឌ្ឍន៍ ហើយសូម្បីតែការយល់ដឹងចំពោះ គ.អ.ឃ របស់សមាជិក គ.អ.ភ នៅមានលក្ខណៈអន់ខ្សោយនៅឡើយ ។

មូលហេតុចំពោះរឿងនេះ ប្រហែលជាអ្នកភូមិជាទូទៅ មិនបែងចែកឃុំអោយដាច់ពីគំនិតដែលចាត់ទុកឃុំជា "ថ្នាក់លើ" ហើយនៅក្នុងថ្នាក់លើទាំងនេះ មានអ្នកធ្វើការងារអភិវឌ្ឍន៍សំខាន់ជាងឃុំ ។ ឥទ្ធិពលនៃអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ទៅលើការយល់ឃើញ និងទំនាក់ទំនងរបស់អ្នកភូមិ ចំពោះថ្នាក់លើដែលគួរអោយកត់សំគាល់ជាងការផ្លាស់ប្តូរ ដែលត្រូវបានគេយល់ឃើញនៅក្នុងតួនាទីរបស់ឃុំ គឺវត្តមាន-នៅក្នុងភូមិ និងនៅក្នុងផ្នត់គំនិតរបស់ប្រជាជន គឺជាអង្គការ ។ ដោយមានអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ អ្នកភូមិបានបង្កើតការយល់ដឹងនៃពាក្យនេះ ។ ពួកគេមិនច្បាស់ថាអង្គការជាអ្វី ឬជាអ្នកណានោះទេ ប៉ុន្តែចាត់ទុកអង្គការជាផ្នែកមួយរបស់ថ្នាក់លើ និងជាភ្នាក់ងារអភិវឌ្ឍន៍ដ៏ចម្បង ដោយនិយាយថា សកម្មភាពអភិវឌ្ឍន៍ទាំងអស់បានផ្តួចផ្តើមឡើងពីកន្លែងផ្សេងនៅខាងក្រៅជាក់អង្គការ ។ ដូច្នេះ ជាទូទៅ វាអាចបកស្រាយថាជាអង្គការអភិវឌ្ឍន៍ ប៉ុន្តែអាចរួមទាំងរដ្ឋអំណាច និងអ្នកនយោបាយផងដែរ-តែវាហាក់ដូចជាផ្នត់គំនិតរបស់អ្នកភូមិ ជាទូទៅវាមិនមែនអង្គការអភិវឌ្ឍន៍ក៏ដោយ ។

វត្តមាននៃឥទ្ធិពលនេះរួម និងភាពសំបូរបែប គឺអង្គការធ្វើអោយមានការពិបាកដើម្បីបង្កើតឃុំអោយក្លាយជាភ្នាក់ងារអភិវឌ្ឍន៍ចម្បង ។ បទពិសោធន៍បានធ្វើអោយប្រជាជនផ្ញើក្តីសង្ឃឹមនិងការរំពឹងទុកលើអង្គការអភិវឌ្ឍន៍ជាងឃុំ ។ ដូចដែលបានបង្ហាញជូនរួចមកហើយថាពួកគេរៀនយកចិត្ត និងដោះស្រាយជាមួយអង្គការទាំងនោះ ព្រោះហាក់ដូចជាមានភាពងាយស្រួល និងបានទទួលលាភសក្ការៈជាងឃុំ ។

វត្តមានរបស់អង្គការអភិវឌ្ឍន៍ និងអ្នកដែលធ្វើការអោយអង្គការនិងនៅក្នុងវិធីផ្សេងទៀតបានបន្ថែមទៅលើការយល់ដឹងរបស់អ្នកភូមិពីឃុំថា មិនមែនជាភ្នាក់ងារអភិវឌ្ឍន៍ដ៏សំខាន់នោះទេ ។ ការគ្រប់គ្រងទៅលើធនធានផ្នែកអភិវឌ្ឍន៍ហាក់ដូចជាមិននៅជាមួយឃុំទេ ប៉ុន្តែវាស្ថិតជាមួយមន្ត្រី និងបុគ្គលិកឃែរេរេ ដែលបានទទួលថ្លៃឈ្នួលដើមធ្វើការងារអភិវឌ្ឍន៍ ។ អ្នកសំរបសំរួលខាងសិលា និង CARERE/LCB នៅតែចូលរួមប្រជុំ គ.អ.ឃ និងនៅតែដឹកនាំអង្គប្រជុំនៅពេលសំរេចការបែងចែកថវិកាអភិវឌ្ឍន៍មូលដ្ឋាន ។ មានភាពប្រជុយប្រជានយ៉ាងច្បាស់លាស់ដែលពួកគេគ្រប់គ្រងអង្គប្រជុំ និងការសំរេចកិច្ចការ មេភូមិព្រមទាំងសមាជិកគ.អ.ឃ យល់ឃើញថា ការបែងចែកនេះ គឺជាលំហាត់គិតលេខដែលធ្វើឡើងដោយអ្នកសំរបសំរួលប៉ុណ្ណោះ ។ ការពិតគឺថា មានអ្នកផ្សេងដែលបានទទួលប្រាក់ឈ្នួលសំរាប់ធ្វើការងារអភិវឌ្ឍន៍នេះ ក៏មិនមែនជាគ្រឿងលើកទឹកចិត្តចំពោះមន្ត្រីឃុំ និងសមាជិក គ.អ.ឃ ដើម្បីដឹកនាំសកម្មភាពអភិវឌ្ឍន៍នោះឡើយ ។

## ជំពូក ៤

# តើអ្វីដែលជាឥទ្ធិពលពិតប្រាកដរបស់សិលាទៅលើការគ្រប់គ្រងតាមមូលដ្ឋាន?

ចំពោះអ្វីដែលកម្មវិធីសិលា អាចទទួលបាននៅមានព្រំដែនកំណត់នៅឡើយ ។ បទពិសោធន៍កន្លងមក និងការយល់ឃើញជាទូទៅរបស់អ្នកភូមិកំណត់បានជាលទ្ធផលយ៉ាងទូលាយនៃអន្តរាគមន៍ ឬការបង្ហាញនូវគំនិត និងការអនុវត្តថ្មីៗ ។ លក្ខខ័ណ្ឌដែលមានស្រាប់ និងការផ្លាស់ប្តូរដែលមានជាបន្តបន្ទាប់ បណ្តាលមកពីកំលាំងផ្សេងៗទៀត ក៏ប៉ះពាល់ដល់វិធីដែលសកម្មភាពអភិវឌ្ឍន៍ត្រូវបានទទួល និងផ្តល់ជាមូលដ្ឋានវិភាគដែរ ។ អន្តរាគមន៍ផ្នែកអភិវឌ្ឍន៍នៅតែមានឥទ្ធិពលទៅលើអ្វីដែលមានបំណង និងគ្មានបំណង ។ ការធ្វើអន្តរាគមន៍ប្រកបដោយគំនិត និងធនធាន បញ្ជាក់ពីការជះឥទ្ធិពលទៅលើទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋាន និងការជះឥទ្ធិពលលើការរំពឹងទុករបស់ប្រជាជនទៅលើអ្នកធ្វើការនៅក្នុង និងក្រៅមូលដ្ឋាន ព្រមទាំងលើតួនាទីរបស់ពួកគេ ។

ដើម្បីបង្កើតអោយមានការគ្រប់គ្រងនៅតាមមូលដ្ឋានអោយបានល្អ និងស្ថានការណ៍ដែលអ្នកធ្វើការពាក់ព័ន្ធមានសមត្ថភាព និងឆន្ទៈដើម្បីអនុវត្តសិទ្ធិ និងការទទួលខុសត្រូវ វាទាមទារអោយមានច្បាប់បទដ្ឋាន បទបញ្ជា និងការអភិវឌ្ឍន៍ស្ថាប័ន ដើម្បីអនុវត្តអោយមានលទ្ធភាពទទួលបានពត៌មាន និងវាទាមទារអោយមានការផ្លាស់ប្តូរទំនាក់ទំនង និងឥរិយាបទ ។

គោលបំណងនៃជំពូកនេះ គឺដើម្បីទាញយកមេរៀនពីការសិក្សានេះ ដោយជួយបង្កើតការពិភាក្សាអំពីអ្វីដែលជាឥទ្ធិពលដ៏ពិតប្រាកដរបស់សិលាទៅដល់ការគ្រប់គ្រងតាមមូលដ្ឋាន ។ ដូចដែលបាននិយាយនៅក្នុងសេចក្តីផ្តើមរួចមកហើយថា កន្លងមកសិលា គឺជាកម្មវិធីសាកល្បងដោយមានជំនួយឧបត្ថម្ភផ្នែកថវិកាយ៉ាងល្អិតល្អន់លើគំរោងទាំង ៥ខេត្ត ប៉ុន្តែនៅពេលអនាគត វានឹងក្លាយជាកម្មវិធីដែលគ្រប់គ្រងដោយរដ្ឋាភិបាលដោយមានជំនួយឧបត្ថម្ភផ្នែកថវិកាតិចជាងមុន ដែលគាំទ្រដល់វិមជ្ឈការក្នុងការពង្រីកតំបន់បន្តិចម្តងៗ រហូតដល់ទូទាំងប្រទេស ។ នៅក្នុងករណីទាំងពីរសិលាបានផ្តល់គំរោងការងារ សំរាប់កាត់បន្ថយភាពក្រីក្រដែលមានរយៈពេលវែង តាមរយៈការកែលំអការគ្រប់គ្រងនៅតាមមូលដ្ឋាន និងសំរាប់ការគ្រប់គ្រងនៅតាមមូលដ្ឋានដែលមានរយៈពេលខ្លី តាមរយៈការផ្តល់ទុនលើការងារអភិវឌ្ឍន៍បែបវិមជ្ឈការ ។

## សិទ្ធិជាពលរដ្ឋ

- សិលាអាចចូលរួមបង្កើនសិទ្ធិជាពលរដ្ឋ លុះត្រាតែប្រជាពលរដ្ឋដឹងពីសិទ្ធិ និងទំនួលខុសត្រូវរបស់គេដែរ ។

ការសិក្សាបង្ហាញថា នៅក្នុងភូមិទាំងពីរនេះការចូលរួមរបស់ប្រជាជននៅក្នុងបែបផែននៃការប្រជុំ និងការចូលរួមវិភាគទាន មិនបានបង្កើតអោយមានការយល់ដឹងណាមួយពីឥទ្ធិពល និងភាពជាម្ចាស់នោះទេ ។ ការបង់ថ្លៃចូលរួមវិភាគទានមិនត្រូវបានយល់ឃើញថា ជាការទទួលខុសត្រូវទូទៅមួយដែលធ្វើអោយមានសិទ្ធិយ៉ាងពិតប្រាកដ ឬ ជាការឧបត្ថម្ភយ៉ាងសំខាន់មួយដែលតំរោងមួយអាចធ្វើទៅបាននោះទេ ។ ចំពោះអ្នកភូមិ ការបង់ថ្លៃចូលរួមវិភាគទាន គឺជាការទទួលយក ដើម្បីបង់ខ្លះៗសំរាប់តំរោងជាក់លាក់មួយដោយសារអ្នកផ្តល់ជំនួយសំរេចចិត្តថា ពួកគេគួរតែបាន ប៉ុន្តែពួកគេធ្វើអោយជឿជាក់ថា អ្នកផ្តល់ជំនួយនេះអាចចេញថ្លៃទាំងអស់បានដោយងាយស្រួល ។ ដោយមានការយល់ដឹងបែបនេះ ការចូលរួមវិភាគទានមិនមែនជាវិធីដែលឧបត្ថម្ភទេ ព្រោះវាផ្អែកទៅលើគំនិតដែលថាអ្នក ផ្សេងទៀតមានលុយ និងអំណាចកំណត់ច្បាប់ ។

ប៉ុន្តែការសិក្សានេះ ក៏បង្ហាញអោយដឹងដែរថា អ្នកភូមិកំពុងត្រៀមខ្លួនការពារ និងទាមទារអ្វីដែលគេយល់ថា ជាសិទ្ធិរបស់គេ (សិទ្ធិចូលនេសាទតាមបឹងនៅភូមិគោកដូង និងការអនុញ្ញាតអោយបិតស្រានៅភូមិជ្រៃ) ។

សំរាប់សិលា ដើម្បីបង្កើនសិទ្ធិជាប្រជាពលរដ្ឋ ដូច្នេះសំខាន់ គឺត្រូវដឹងពីថវិកាសំរាប់អភិវឌ្ឍន៍ថា ជារបស់អ្នកដែលរស់នៅក្នុងឃុំ ដឹងពីសិទ្ធិដើម្បីសំណូមពរថា ថវិកានេះគួរប្រើដើម្បីអ្វី ហើយសិទ្ធិរបស់ពួកគេជាតំណាងនៅក្នុងឃុំនៅពេលធ្វើការសំរេចចិត្តលើការបែងចែកថវិកានេះ ។ ពត៌មានដ៏គួរអោយចាប់អារម្មណ៍នេះបានបង្កើតអោយមានការយល់ដឹងយ៉ាងសំខាន់ ដែលជាបញ្ហាមួយធ្វើអោយងាយយល់ និងគួរយកជាការបាន ។ ដោយមានការយល់ដឹងថា ថវិកាអភិវឌ្ឍន៍ជារបស់អ្នកណា និងដឹងពីធនធានដែលមានកំនត់ ការបង់វិភាគទានត្រូវបានគេយល់ថា ជាការទទួលខុសត្រូវទូទៅ និងដ៏សំខាន់មួយដែលអ្នកអាចរំពឹងបាននូវអ្វីមួយជាថ្នូរ លើសពីនេះវាបន្ថែមលើការយល់ដឹងពីសិទ្ធិ ដែលអាចជះឥទ្ធិពលការប្រើប្រាស់ថវិកានេះ ។ ដើម្បីបានផលប្រជាពលរដ្ឋនៅក្នុងឃុំ ត្រូវចូលរួមវិភាគទាន (អាចអាស្រ័យដោយលទ្ធភាព) មុនពេលថវិកានេះត្រូវបានសំរេចដើម្បីប្រើប្រាស់ក្នុងសកម្មជាក់លាក់អ្វីនោះ ។

នៅក្នុងអនាគតដ៏យូរអង្វែង ការដឹងពីធនធានដែលមាននៅក្នុងឃុំត្រូវប្រើប្រាស់ អាស្រ័យដោយអាទិភាពរបស់ប្រជាពលរដ្ឋ និងទំលាប់ការបង់វិភាគទានបន្ថែមទៅលើធនធានទាំងនេះ ដើម្បីអាចធ្វើអោយអ្នកភូមិ និងមន្ត្រីទាំងឡាយចាប់ផ្តើមទៅរកសេវាណាមួយដោយពឹងផ្អែកលើធនធានរបស់ឃុំ ថាជាសិទ្ធិរបស់គេម្នាក់ៗ ។ អ្នកភូមិដែលបង់ថវិកាអោយឃុំទៀងទាត់ នឹងសង្ឃឹមលើឃុំដើម្បីផ្តល់សេវាដោយសមស្រប ។ ដូច្នេះការចូលរួមនេះនឹងក្លាយជាពន្ធនៅតាមមូលដ្ឋានខុសពីពន្ធដែលអ្នកភូមិកំពុងតែបង់ វានឹងនៅដកល់ក្នុងឃុំ នឹងប្រើប្រាស់សំរាប់សកម្មភាពអភិវឌ្ឍន៍ទៅលើអ្វីដែលអ្នកភូមិមានសិទ្ធិសំរេច ។

## អ្នកតំណាងភូមិ

- សិលាអាចចូលរួមក្នុងការបង្កើតអ្នកតំណាងដែលទទួលបន្ទុកនៅក្នុងភូមិដោយមានអាណត្តិកំនត់ ប៉ុន្តែវាមិនសង្ឃឹមអោយបានពិតប្រាកដថា សិលាផ្លាស់ប្តូរការគ្រប់គ្រងនៅថ្នាក់ភូមិក្នុងរយៈពេលដ៏ខ្លីនោះទេ ។

ការសិក្សា នេះបង្ហាញអោយដឹងថា ទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋានសំរេចលទ្ធផលយ៉ាងទូលាយ ដូច្នេះវាកំនត់ឥទ្ធិពលដោយចេតនាដែលអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ អាចកំនត់ទៅលើការគ្រប់គ្រងនៅតាមភូមិ ។

ការសិក្សានេះក៏បានបង្ហាញអោយដឹងដែរថា គ.អ.ភ និងតួនាទីរបស់ពួកគេ មិនត្រូវបានប្រជាជននៅក្នុងភូមិទាំងពីរនេះស្គាល់ច្បាស់ឡើយ ។ អ្នកភូមិមិនស្គាល់ គ.អ.ភ ជាក្រុមដែលមានការទទួលខុសត្រូវជារួម សំរាប់ការងារអភិវឌ្ឍន៍ភូមិទេ ហើយក៏មិនដឹងថា គ.អ.ភ ឬ សមាជិក គ.អ.ភ ជាតំណាងភូមិនៅក្នុងឃុំដែរ ។ សមាជិក គ.អ.ភ ក៏មិនដឹងច្បាស់អំពីអំណាចរបស់ខ្លួនដែរ ដូច្នេះហើយបានជាធ្វើឱ្យពួកគេមិនមានទំនុកចិត្តលើតួនាទីរបស់ខ្លួនឡើយ ។

ការសិក្សានេះក៏បានបង្ហាញថា ទោះបីជាវគ្គបណ្តុះបណ្តាលដែលមានរយៈពេលវែង បើកជាលើកដំបូងក្តី ក្នុងចំណោមសមាជិក គ.អ.ភ ទាំងអស់ មានតែពីរបីនាក់ប៉ុណ្ណោះដែលមានសមត្ថភាព និងប្រឹងប្រែងក្នុងការរៀនសូត្រ ។ ការប្រមូលផ្តុំការយកចិត្តទុកដាក់ និងការទទួលខុសត្រូវទៅលើបុគ្គលម្នាក់ៗ ធ្វើអោយពួកគេប្រឹងប្រែងធ្វើការងារ ប៉ុន្តែអ្នកផ្សេងទៀតមិនមានឱកាសដើម្បីអោយមានគុណភាពល្អដូចគ្នាទេ ។

ប៉ុន្តែការសិក្សានេះបង្ហាញទៀតថា មានការទាមទារអោយមានអ្នកដឹកនាំថែមទៀត ឬជំនួសអាជ្ញាធរ និងបង្ហាញថា អ្នកភូមិកំពុងតែសុខចិត្តប្រគល់ការទទួលខុសត្រូវដែលជាតំណាង និងការនិយាយជំនួសអ្នកផ្សេងអោយមនុស្សមួយចំនួន ។

ដូច្នេះសិលាមានសក្តានុពល ដើម្បីរួមចំណែកបង្កើតអោយមានការគ្រប់គ្រងនៅតាមភូមិអោយបានល្អ ប៉ុន្តែវាមានសារៈសំខាន់ណាស់ដោយមិនប្រគល់ការងារទទួលខុសត្រូវ អោយអ្នកណាម្នាក់លើសពីសមត្ថភាពដែលគាត់អាចគ្រប់គ្រងធនធាន និងការគាំទ្រដែលសិលាអាចផ្តល់អោយ ។ វាហាក់ដូចជាមិនប្រាកដថា កម្មវិធីសិលាបង្កើនសមត្ថភាពបានយ៉ាងច្រើននោះទេ និងការខិតខំប្រឹងប្រែងរបស់ក្រុមទាំងមូលនៃអ្នកភូមិដែលនឹងឆាប់ៗនេះអាចនឹងមានផលប៉ះដើម្បីបង្កើតការដឹកនាំបន្ថែម ឬជំនួស ។ សិលានឹងមិនមានធនធានគ្រប់គ្រាន់ដើម្បីធ្វើឱ្យគ.អ.ភ គ្រប់ភូមិ ចេះគ្រប់គ្រងសកម្មភាពអភិវឌ្ឍន៍នៅក្នុងភូមិបានទេ ។ ហើយសិលានឹងមិនមានវត្តមាន/អំណោយគ្រប់គ្រាន់នៅក្នុងភូមិ ដើម្បីធ្វើអន្តរាគមន៍ដោយចេតនា និងយ៉ាងសំខាន់នៅក្នុងទំនាក់ទំនងផ្នែកអំណាចនៅតាមមូលដ្ឋានតាមរបៀបនៃការទទួលខុសត្រូវទេ ។

វាហាក់ដូចជាកាន់តែមានភាពជាក់ស្តែង និងសមរម្យសំរាប់កម្មវិធីសិលា ដើម្បីផ្តល់ភារកិច្ចអោយអ្នកភូមិមួយចំនួនតូច (ប្រហែលជាស្រីម្នាក់ និងប្រុសម្នាក់) ដែលជាប់ឆ្នោតជាតំណាងភូមិនៅពេលធ្វើការសំរេចរឿងបែងចែកធនធានអភិវឌ្ឍន៍ឃុំ ។ បញ្ហានៃការប្រមូលផ្តុំលើការងារ ការទទួលខុសត្រូវ និងអំណាច អោយបុគ្គលពីរបីនាក់ (ជាទូទៅប្រធាន គ.អ.ភ ឬមេភូមិ) នឹងជៀសវាង ដោយសារការងាររបស់តំណាងទាំងនេះតិចតួច និងជាក់លាក់បំផុត ។ ការណែនាំដ៏ខ្លី និងច្បាស់លាស់ជាជាងការបណ្តុះបណ្តាលដែលមានរយៈពេលវែង នឹងគ្រប់គ្រាន់ ដើម្បីធ្វើអោយអ្នកដែលមានកិច្ចការអាចដោះស្រាយកិច្ចការនេះបាន ហើយពតិមានដ៏ខ្លី និងច្បាស់លាស់ នឹងគ្រប់គ្រាន់ដើម្បីធ្វើអោយអ្នកភូមិដឹង និងយល់ពីអំណាចរបស់អ្នកធ្វើការងារនោះ ។ ស្របទៅនឹងការយល់ដឹងយ៉ាងចាំបាច់ពីថវិកាអភិវឌ្ឍន៍មូលដ្ឋាន ការស្គាល់តំណាងភូមិទាំងនេះ និងអំណាចរបស់ពួកគេ នឹងធ្វើអោយអ្នកភូមិមើលការខុសត្រូវទៅលើពួកគេ និងធ្វើអោយពួកគេទទួលខុសត្រូវ បើសិន ជាចាំបាច់ដើម្បីជំនួសពួកគេបាន ។

នៅក្នុងអនាគតដ៏យូរអង្វែង ដោយសារអ្នកភូមិស៊ាំទៅនឹងគំនិតរបស់អ្នកតំណាងភូមិពួកគេអាចចាប់ផ្តើមទាមទារឱ្យមានការរាប់រងរបស់អ្នកដឹកនាំដទៃទៀតផងដែរ ដូចជាអ្វីដែលកំពុងកើតមានឡើងនៅក្នុងភូមិមួយក្នុងចំណោមភូមិទាំងពីរនៅក្នុងការសិក្សានេះ ដែលអ្នកភូមិកំពុងតែមានប្រតិកម្មកាន់តែខ្លាំងឡើងៗ ប្រឆាំងនឹងការរំលោភបំពានរបស់អាជ្ញាធរថ្នាក់ភូមិ និងរបស់អ្នកដឹកនាំដែលមានវត្តមាន និងទទួលបន្ទុកការងារមួយចំនួនតូចទៀតអាចដឹកនាំធ្វើការតវ៉ាមួយជាផ្លូវការក្នុងពេលឆាប់នេះ ។ តាមមធ្យោបាយនេះ សិលាអាចចូលរួមចំណែកក្នុងការផ្លាស់ប្តូររចនាសម្ព័ន្ធអំណាច និងការធ្វើអោយការគ្រប់គ្រងនៅថ្នាក់ភូមិមានលក្ខណៈកាន់តែប្រសើរឡើង ។

## ការគ្រប់គ្រងនៅថ្នាក់ឃុំ

- សិលាអាចពង្រឹងការគ្រប់គ្រងដែលទទួលបន្ទុកនៅថ្នាក់ឃុំ ប៉ុន្តែឥទ្ធិពលរបស់សិលានឹងត្រូវបានកំនត់ដោយបណាភ្នាក់ងារដទៃទៀត ដូចជាអង្គការអភិវឌ្ឍន៍ និងគណបក្សនយោបាយអនុវត្តនៅក្នុងវិធីដែលមិនគាំទ្រគោលបំណងនេះ ។

ការសិក្សានេះបានបង្ហាញអោយដឹងថា អ្នកភូមិមិនច្បាស់ពីតួនាទីរបស់ឃុំក្នុងការងារអភិវឌ្ឍន៍ និងអោយដឹងថា មានភ្នាក់ងារផ្សេងទៀតដែលពួកគេយល់ឃើញថាជាភ្នាក់ងារអភិវឌ្ឍន៍ចម្បង ។ ប៉ុន្តែការសិក្សានេះក៏បានបង្ហាញថា អ្នកភូមិកំពុងតែចាប់ផ្តើមចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ជាមួយមន្ត្រីឃុំមួយចំនួន ។

ដើម្បីអោយសិលារួមចំណែកក្នុងការធ្វើអោយការគ្រប់គ្រងនៅក្នុងឃុំ មានលក្ខណៈកាន់តែប្រសើរឡើង វាមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យឃុំមានតួនាទី ប៉ុន្តែសំខាន់ត្រូវគិតដល់ផ្នែកគ្រប់គ្រងសកម្មភាពអភិវឌ្ឍន៍ផង ។ វាមិនប្រាកដនឹងរំពឹងថា សិលាអាចផ្លាស់ប្តូរការយល់ឃើញ និងសេចក្តីសង្ឃឹមរបស់ប្រជាជន លើភ្នាក់ងារផ្សេងៗ និងដើម្បីបង្កើតឃុំឱ្យក្លាយជាភ្នាក់ងារអភិវឌ្ឍន៍ចម្បងនោះទេ ។ គេឃើញមានអង្គការអភិវឌ្ឍន៍ និងគណបក្សដែលមានអានុភាពផ្ទុយទៅនឹងគោលបំណងរបស់សិលាដោយចេតនា ឬមិនចេតនា ។ បែបបទ និងសកម្មភាពរបស់ពួកគេមួយចំនួន ដោយរួមទាំងការចែកអំណោយដ៏បរិសុទ្ធធ្វើអោយអ្នកភូមិ មានទំលាប់ចាំតែទទួលអ្វីក៏ដោយ អោយតែគេផ្តល់ឱ្យតែប៉ុណ្ណោះ ដោយពុំមានការយល់ដឹងពីឥទ្ធិពល ឬការទទួលខុសត្រូវអ្វីឡើយ ។ អំណោយរបស់អង្គការដែលមានលុយចំណាយជាងឃុំ ហើយដែលធ្វើមិនដឹងមិនលឺពីរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ធ្វើអោយអ្នកភូមិរំពឹង ឬសង្ឃឹមលើជំនួយដែលបានមកពីពួកគេ ជាជាងបានមកពីរដ្ឋាភិបាល ។

ជាមួយនឹងបទពិសោធន៍ និងការរំពឹងទុក ការអនុវត្តន៍ដែលនៅតែបន្តទាំងនេះ មានការលំបាកដើម្បីធ្វើអោយសិលាក្លាយជារបស់មួយផ្សេង ។ សិលាប្រហែលអាចធ្វើអោយការយល់ឃើញ និងការរំពឹងទុកទាំងនេះបន្ថែមទៀតយ៉ាងពិតប្រាកដ ។ សកម្មភាពនៅក្នុងភូមិ និងវិធីសាស្ត្រដំណើរការដ៏ពិតប្រាកដរបស់សិលាស្រដៀងគ្នាទៅនឹងអ្វីដែលអង្គការអភិវឌ្ឍន៍ជាច្រើន ធ្វើគំរោងហេដ្ឋារចនាសម្ព័ន្ធ និងអោយថ្លៃឈ្នួលដល់អ្នកដែលធ្វើការងារអភិវឌ្ឍន៍ដែលចុះមកភូមិច្រើន ឬតិចដោយឡែងទាត់ ដើម្បីមកជួបមេភូមិ ឬប្រធានគ.អ.ភ ឬ មកបើកអង្គប្រជុំ ។

ជាមួយបុគ្គលិកដែលមកពីអង្គការ និងរដ្ឋអំណាចថ្នាក់លើដែលទទួលប្រាក់ឈ្នួល ដើម្បីធ្វើការងារអភិវឌ្ឍន៍នេះ វាក៏អាចជាបញ្ហាលំបាកក្នុងការលើកទឹកចិត្តមន្ត្រីឃុំ និងតំណាងភូមិ ដើម្បីធ្វើការងារនេះដោយគតកំរៃ ។

វាជាការភ្ញាក់ផ្អើលដោយកម្រថា មេឃុំនៅករណីខេត្តពោធិសាត់ ចូលចិត្តចំណាយពេលវេលារបស់គាត់ជាមួយកម្មវិធីឥណទានរបស់ NGO ព្រោះវាផ្តល់ផលប្រយោជន៍ដល់គាត់ ។

នៅពេលអនាគតដ៏ខ្លីខាងមុខនេះ វាកាន់តែច្បាស់ និងសង្ឃឹមថា សិលា នឹងបង្កើតអង្គភាពឃុំ[១] ដែលធានារ៉ាប់រងមួយដ៏ប្រសើរ ប៉ុន្តែជាអំណាចដែលមានការដឹងឮ ដើម្បីគ្រប់គ្រងការប្រើប្រាស់ថវិកាអភិវឌ្ឍន៍នេះ ។ ដោយសារមានតំណាងភូមិទាំងនេះ ដើម្បីសំរេចការងារ គឺទាមទារឱ្យមានការណែនាំមួយដែលច្បាស់លាស់ដល់សមាជិកនៃអង្គភាពនេះ និងផ្តល់ពត៌មានដ៏ច្បាស់លាស់អោយប្រជាជនដែលរស់នៅក្នុងឃុំ ។ ប៉ុន្តែ វាក៏មានសារៈសំខាន់ដើម្បីធានាថា អំណាចដ៏ពិតប្រាកដដែលគេយល់ឃើញ ដើម្បីសំរេចនោះស្ថិតនៅជាមួយអង្គភាពឃុំ ហើយមិនស្ថិតនៅជាមួយបុគ្គលិកកម្មវិធី (ឬតំរោងរបស់ថ្នាក់លើទេ) ។

អង្គភាពឃុំដែលមានភារកិច្ច និងគ្រប់គ្រងច្បាស់លាស់ ប៉ុន្តែការងារសំខាន់គឺ នឹងផ្តល់បទពិសោធន៍ដ៏មានដែលរីកដាលការរំពឹងទុកបន្តិចម្តងៗ ដល់ឃុំ និងរដ្ឋាភិបាល ។ វានឹងផ្តល់ឱ្យមន្ត្រីឃុំ និងតំណាងភូមិនូវបទពិសោធន៍ដ៏មាន សេចក្តីរំពឹងទុកលើតួនាទី និងសមត្ថភាព រួមទាំងការពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយថ្នាក់លើ ។

នៅក្នុងអនាគតដ៏យូរអង្វែង ដោយសារអ្នកភូមិស៊ាំទៅនឹងអង្គភាពឃុំដែលធានារ៉ាប់រង គ្រប់គ្រងធនធានអភិវឌ្ឍន៍ និងខ្លួនគេផ្ទាល់ ដោយជះឥទ្ធិពលទៅលើការប្រើប្រាស់នេះ ពួកគេនឹងចាប់ផ្តើមរំពឹងអោយឃុំផ្តល់ការបំរើឱ្យទូលាយ ហើយចាប់ផ្តើមទាមទារការរ៉ាប់រងពីឃុំនេះ (និងរដ្ឋអំណាចថ្នាក់លើ) ចំពោះបញ្ហាដទៃទៀតផងដែរ ។

ដោយការបង្កើនសមត្ថភាព និងការទទួលខុសត្រូវរបស់អង្គភាពភូមិ រចនាសម្ព័ន្ធរបស់សិលាទំនងដូចជាទទួលការគាំទ្រផ្នែកនយោបាយ ហើយអង្គការអភិវឌ្ឍន៍ទំនងដូចជាទៅកាន់បណ្តាញថវិការបស់ពួកគេតាមរយៈនេះ ។ ធនធានកាន់តែច្រើនដែលឃុំកំពុងគ្រប់គ្រង វាក៏នឹងអាចកាន់ តែបំរើជាភ្នាក់ងារអភិវឌ្ឍន៍ចម្បង ។

---

[១] បច្ចុប្បន្ន អង្គភាពនេះគឺជាគណៈកម្មាធិការអភិវឌ្ឍន៍ឃុំ ប៉ុន្តែក្រោយពីបោះឆ្នោតឃុំរួច ក្រុមប្រឹក្សាឃុំប្រហែលជាធ្វើការងារនេះ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើពុំមានតំណាងភូមិធានាខុសត្រូវចំពោះក្រុមប្រឹក្សាឃុំនេះទេ វានឹងត្រូវបានផ្តល់ការចាត់ចែងធនធានអភិវឌ្ឍន៍ឃុំ ។

# ឧបសម្ព័ន្ធ

# ការបង្ហាញករណីសិក្សានៅភូមិចំរុងពីរ[1]

## ភូមិជ្រែង

### *ទីតាំង ចំនួនប្រជាជន និងស្ថានភាពជន*

ជ្រែង ជាភូមិមួយក្នុងចំណោមភូមិទាំង១៣ នៅក្នុងឃុំស្វាយលួង ស្រុកកណ្ដៀង ដែលមានចំងាយប្រមាណ ១២គីឡូម៉ែត្រពីទីរួមខេត្តពោធិសាត់ ។ ភូមិនេះមានប្រជាជនចំនួន ១៣៤គ្រួសារ ចំនួនមនុស្សសរុប ៦៥៥នាក់ (ស្រ្តី ៣៦៤នាក់ ប្រុស ២៩១នាក់) ។ ២៨គ្រួសារ ជាគ្រួសារដែលមានបុរសជាមេគ្រួសារ ហើយក៏មានជនមាតុភូមិនិវត្តន៍ ៤គ្រួសារដែរ ដែលបានមកតាំងទីលំនៅនៅក្នុងភូមិនេះប្រហែលជានៅឆ្នាំ១៩៩២ ។

ភូមិនេះមានប្រាំមួយផ្នែកដាច់ពីគ្នា ។ កន្លែងដែលឆ្ងាយជាងគេ ចំងាយប្រហែលពី ៣គីឡូម៉ែត្រ ។ អ្នកក្រ និងអ្នកមាន ក៏រស់នៅដាច់ដោយឡែកពីគ្នាបន្តិចដែរ ។ ប្រជាជនដែលរស់នៅកន្លែងមួយក្នុងចំណោម ៦កន្លែង គឺសុទ្ធតែអ្នកមាន (ពួកគេនិយមហៅថា "ចិន") ហើយមួយកន្លែងទៀត គឺសុទ្ធតែអ្នកក្រ ប៉ុន្តែកន្លែងដែលធំ និងកណ្ដាលនោះ មានការរស់នៅលាយឡំគ្នា ។

ប្រហែលជា ២ ភាគ ៣ នៃផ្ទះសម្បែងត្រូវបានធ្វើឡើងអំពីឈើ ហើយ ១ ភាគ ៣ ធ្វើអំពីឫស្សី ។ គេឃើញមានផ្ទះពីរជំ និងម៉ាំល្អ ប៉ុន្តែមិនមានបង្គន់អនាម័យទេ ។ ក្នុងភូមិនោះមាន ៦គ្រួសារមានអណ្ដូងផ្ទាល់ខ្លួន ៧គ្រួសារ មានទូរទស្សន៍សខ្មៅ ហើយប្រហែល ១០០គ្រួសារមានវិទ្យុ កង់ជាង ១២០ ម៉ូតូជិត ២០ ប៉ុន្តែពុំមានរថយន្តទេ ។

### ប្រវត្តិ

ភូមិដែលនៅផ្សេងគ្នាទាំង ៦ផ្នែក សព្វថ្ងៃគឺជាភូមិតែមួយ ។ ភូមិក្រាំងក្នុងជា ផ្នែកដែលធំ និងនៅចំកណ្ដាលជាងគេ ហើយក៏ជាភូមិដែលមានវ័យចំណាស់ជាងគេដែរ ។ ប្រជាជនប្រហែលជារស់នៅទីនោះ អស់រយៈពេលជាង ១០០ឆ្នាំហើយ ។ ឈ្មោះនេះសំដៅលើកន្លែងមួយដែលមានន័យថា "ក្នុង" កន្លែងដែលប្រជាជនបានទៅឃ្វាលសត្វពាហនៈរបស់ពួកគេបណ្ដោះអាសន្នដែលនៅទល់មុខកន្លែងខាង "ក្រៅ" *ក្រាំងក្រៅ* ។

---

[1] នេះបានមកពីសៀវភៅទិន្នន័យភូមិ មូលដ្ឋានទិន្នន័យបញ្ជីសារពើភណ្ឌ និងបទសម្ភាសន៍ជាមួយអ្នកភូមិ ។

នៅជំនាន់អាណានិគមនិយមបារាំងអ្នកភូមិមានដីគ្រប់គ្រាន់ ហើយពួកគេធ្វើស្រែ និងដាំបន្លែ ដូចសព្វថ្ងៃនេះដែរ ។ ពួកគេបានបង់ពន្ធជាទឹកប្រាក់ ហើយអ្នកខ្លះទៅលើកថ្នល់ជាតិដែលបានកំរៃជារូបិយប័ណ្ណបារាំង ។

ក្នុងអំឡុងពេល ២ឆ្នាំកងទ័ពឥស្សរៈ[៦] បានបង្កភាពភ័យខ្លាចក្នុងចំណោមអ្នកភូមិ ព្រោះពួកគេបានចូលមកភូមិដើម្បីចាប់ប្រជាជនអោយច្បាំងជាមួយបារាំង ហើយចាប់ក្មេងស្រី១អោយធ្វើជាអ្នករាំរបាំ ។ អ្នកដែលចូលខាងឥស្សរៈ ត្រូវបានបំពាក់ដោយអាវុធ ។ ប៉ុន្តែពុំមានការច្បាំងគ្នានៅក្នុងភូមិទេ ។

ក្នុងជំនាន់សីហនុ ប្រជាជននៅតែមានដីស្រែគ្រប់គ្រាន់ ។ ពួកគេក៏នៅតែបង់ពន្ធដដែល និងត្រូវ បានកេណ្ឌទៅជីកទំនប់ដ៏ធំមួយ ហើយលើកផ្លូវសព្វថ្ងៃនេះដោយពុំបានកំរៃឡើយ ។ នៅពេលដែលទំនប់ជិតនោះរួចស្រេចបាច់ ហើយសម្តេចបានយាងមកសម្ពោធទំនប់នោះ ដែលចាស់ៗនៅតែនិយាយពីទំនប់នោះ ។

ក្នុងរបប លន់ នល់ ភូមិនេះគ្មានមានមនុស្សទេ ។ រដ្ឋាភិបាលបានបោះបន្ទាយនៅម្ខាងមកពីកន្លែងដែលពួកគេមកចាប់ទាហាន ហើយខ្មែរក្រហមរស់នៅក្នុងព្រៃម្ខាងទៀត មកពីកន្លែងដែលពួកគេមកបញ្ចុះបញ្ចូលប្រជាជនអោយចូលខាងគេ ។ ដំបូងប្រុសៗរត់គេចខ្លួននៅពេលថ្ងៃ ប៉ុន្តែស្រីៗ និងក្មេងៗ អាចនៅក្នុងភូមិ ហើយប្រុសៗអាចត្រឡប់មកវិញនៅពេលយប់ ។ ប៉ុន្តែដោយសារភូមិនេះស្ថិតនៅចំកណ្តាលសមរភូមិប្រជាជនត្រូវតែចាកចេញ ។ ប្រជាជនភាគច្រើនបានទៅ នៅភូមិដែលគ្រប់គ្រងដោយរដ្ឋាភិបាល អ្នកផ្សេងទៀតទៅខាងខ្មែរក្រហម ។

នៅពេលខ្មែរក្រហមឈ្នះ អ្នកភូមិមួយចំនួន ត្រូវបានគេប្រាប់អោយត្រលប់មកភូមិដ្រេងវិញ ប៉ុន្តែអ្នកភូមិភាគច្រើន បានស្នាក់នៅ និងធ្វើការនៅកន្លែងផ្សេងៗជុំវិញខេត្តក្នុងរបបប៉ុលពត ។

នៅពេលដែលវៀតណាមចូលកាន់តែកៀក មេដឹកនាំខ្មែរក្រហមបង្ខំអ្នកភូមិអោយទៅជាមួយពួកគេ ។ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៧៩ អ្នកភូមិចាប់ផ្តើមត្រលប់ចូលមកភូមិជាបណ្តើរៗ ។ ក្នុងរយៈពេលពីរបីឆ្នាំដំបូងពួកគេមកភូមិតែពេលថ្ងៃទេ ។ វាមានគ្រោះថ្នាក់ណាស់ក្នុងការស្នាក់នៅក្នុងភូមិពេលយប់ ព្រោះនៅមានទាហានខ្មែរក្រហមនៅក្នុងតំបន់នោះ ។ ភូមិនេះត្រូវបានបំផ្លាញទាំងស្រុង ដូច្នេះអ្នកភូមិ ត្រូវកាប់ឆ្ការដីដើម្បីធ្វើស្រែ និងបន្លែ ។ ពួកគេក៏ឡើងត្នោតធ្វើស្ករដែរ ។

ចាប់តាំងពីឆ្នាំ១៩៨៣ ពុំមានបញ្ហារឿងអសន្តិសុខទៀតទេ ហើយប្រជាជនក៏បានមករស់នៅក្នុងភូមិនេះជាអចិន្ត្រៃយ៍ដែរ ដំបូងប្រជាជនរស់នៅក្នុងខ្ទមតូចៗ ហើយនៅពេលដែលគេអាចមានលទ្ធភាពជាបណ្តើរៗ គេសង់ផ្ទះល្អៗ ។ អ្នកដែលបានមកដល់មុន គេយកដី និងក្របីណាក៏បានដែរ អោយតែពួកគេចង់បាន ។ ក្នុងរយៈពេលមួយឆ្នាំឬពីរឆ្នាំប្រជាជនក៏បានធ្វើស្រែរួមគ្នា ។ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៨៣ មេភូមិបានចែកដីស្រែអោយគ្រួសារទាំងអស់ធ្វើជាកម្មសិទ្ធិផ្ទាល់ ។

---

[៦] ឥស្សរៈ គឺជាចលនាតស៊ូដណ្តើមយកឯករាជ្យកម្ពុជាក្នុងកំឡុងឆ្នាំ១៩៤០ និង ១៩៥០ ។

ការព្រួយបារម្ភដ៏សំខាន់ក្នុងអំឡុងឆ្នាំ១៩៨០ គឺការជ្រើសរើសទាហាន និងពលករ ។ ប្រជាជនមិនត្រូវបានជំរុញលើកទឹកចិត្តអោយច្បាំងជាមួយខ្មែរក្រហមទេ ដូច្នេះប្រុសៗមានទំលាប់រត់គេចនៅពេលថ្ងៃ ហើយប្រជាជនមួយចំនួនតូចរួចខ្លួនពីការជ្រើសរើសទ័ព ដោយសារពួកគេអោយលុយអ្នកចុះមកចាប់ ។ ភូមិនេះក៏ត្រូវបញ្ជូនពលករទៅកាប់ព្រៃនៅតំបន់ភ្នំផងដែរ ។ ដំបូងប្រជាជនស្ម័គ្រចិត្ត ប៉ុន្តែក្រោយមកពួកគេខ្លាចកើតជំងឺគ្រុនចាញ់ ហើយពួកគេក៏ចាប់ផ្តើមរត់គេចពីរឿងនោះដែរ ។

ឥឡូវនេះអ្នកភូមិនៅភូមិជ្រែងហាក់ដូចជាគិតថា ពួកគេមានជីវិតសប្បាយរីករាយ និងងាយស្រួល ដោយសារគ្មានការច្បាំងគ្នា និងការជ្រើសរើសទ័ព ។ ប៉ុន្តែការព្រួយបារម្ភរបស់ពួកគេឥឡូវនេះ គឺ ទឹកសំរាប់ធ្វើស្រែ តើនឹងមានភ្លៀងគ្រប់គ្រាន់ទេ មានមិនច្រើនឬ ខុសពេលឬ ចោរលួចសត្វពាហនៈ ។

## ធនធានសេដ្ឋកិច្ច និងរបរចិញ្ចឹមជីវិត

នៅភូមិជ្រែងមានដីស្រែ ១០៥ហិកតា ។ ដីស្រែទាំងនោះ ជាដីស្រែមិនស្រោចស្រព ប៉ុន្តែអ្នកភូមិមានដីស្រែនៅភូមិផ្សេងទៀតដែលគេអាចបូមទឹកពីប្រឡាយ (បីគ្រួសារក្នុងចំណោមគ្រួសារទាំងនោះ មានម៉ាស៊ីនបូមទឹក) ។ មានសត្វដែលជាកំលាំងអូសទាញ ២៣០ក្បាល និងសត្វដែលមិនមែនជាកំលាំងអូសទាញចំនួន ១៤០ក្បាល ។ ភាគច្រើនស្ទើរតែជាក្របីទាំងអស់ ។ នៅរដូវប្រាំង អ្នកភូមិទៅតំបន់ព្រៃលិចទឹកនៅតាមដងទន្លេសាប ដើម្បីឃ្វាលសត្វពាហនៈ ។ រទេះគោមានប្រហែលជា ១០០គ្រឿង ប៉ុន្តែគ្មានត្រាក់ទ័រ ឬគោយន្តទេ (ប្រើសំរាប់ដឹកជញ្ជូន និងភ្ជួរ) តែគ្រួសារមួយនោះមានគោយន្ត ដែលគេប្រើនៅលើដីស្រែឆ្ងាយពីភូមិ ។ អ្នកភូមិធ្វើស្រែដោយការស្ទូង ។ គ្មានអ្នកណាធ្វើស្រែប្រាំងទេ ។

ក្រៅពីស្រូវ ដីចំនួន ១១ហិកតា ត្រូវបានប្រើប្រាស់សំរាប់ដាំដំណាំផ្សេង ហើយការដាំបន្លែ គឺជាប្រភពបន្ថែមដ៏សំខាន់បំផុតនៃរបរចិញ្ចឹមជីវិតសំរាប់គ្រួសារភាគច្រើន ។ នៅរដូវវស្សាប្រជាជនដាំបន្លែផ្សេងៗដូចជា ប៉េងប៉ោះ ស្ពៃ ត្រប់ ត្រសក់ ត្រឡាច ល្ពៅ ដំឡូងជ្វា និងម្រះ ។ ផ្លែឈើ គឺជាប្រាក់ចំណូលបន្ថែមផ្សេងទៀត ទោះជាមិនសូវសំខាន់ណាស់ណាក៏ដោយ ។ ស្ករត្នោត គឺជាប្រាក់ចំណូលដ៏សំខាន់មួយសំរាប់គ្រួសារជាច្រើន ។ អ្នកខ្លះដែលគ្មានមានដើមត្នោត ជួលពីអ្នកដែលមានដើមត្នោត ។

ការចិញ្ចឹមជ្រូក បានក្លាយជាការរកប្រាក់ចំណូលកាន់តែច្រើនឡើង សំខាន់សំរាប់អ្នកដែលមានជីវភាពធូរធារបន្តិចបន្តួច ។ បច្ចុប្បន្ននេះមានជ្រូកប្រហែលជា ៣៥០ក្បាល ។ ភាគច្រើននៃអ្នកដែលចិញ្ចឹមជ្រូក ក៏បិតស្រាដែរ ព្រោះគេអាចយកបាយស្រាទៅអោយជ្រូកស៊ី ដូច្នេះគេមានកំរៃរួមនឹងសកម្មភាពទាំងពីរនេះបញ្ចូលគ្នា ។ ប្រជាជនក៏ចិញ្ចឹម និងលក់មាន់ផងដែរ ។

នៅរដូវប្រាំង គ្រួសារភាគច្រើនរកត្រីនៅតាមបឹងជិតៗភូមិ និងនៅតាមទន្លេដែលមានចំងាយ ១៧គីឡូម៉ែត្រពីភូមិ ។ អ្នកភូមិជាច្រើន ក៏បានធ្វើការនេសាទត្រីនៅតំបន់ទន្លេសាបដែលពួកគេស្នាក់នៅទីនោះមួយរយៈពេលឃ្វាលសត្វពាហនៈរបស់ពួកគេ ។ ចាប់ពីខែធ្នូ ដល់ខែឧសភា អ្នកភូមិរកកង្កែប ព្រោះនៅពេលនោះកង្កែបបានថ្លៃណាស់ ។ ការរកត្រី គឺសំខាន់សំរាប់ហូបតែប៉ុណ្ណោះ ប៉ុន្តែប្រជាជនក៏លក់អោយអ្នកដែលមិនបានទៅរកត្រី ហើយ

ជូនកាលយកទៅលក់នៅផ្សារទីរួមស្រុក និងខេត្តផងដែរ ។ ថ្មីៗនេះមានបុរសម្នាក់ដែលទើបនឹងមកនៅភូមិនេះ បានចាប់ផ្តើមជិះម៉ូតូពេញភូមិ ដើម្បីទិញត្រី និងកង្កែបពីអ្នកភូមិដទៃទៀត ហើយលក់អោយម៉ូយនៅផ្សារពោធិសាត់ ។ មានឈ្មួញម្នាក់ផងដែរដែលមកទិញជន្លេន ពីអ្នកភូមិហើយលក់អោយម៉ូយនៅផ្សារពោធិសាត់ ។ ប៉ុន្តែអ្នកភូមិមិនសូវជញ្ជាត់កន្ទេលឡង់ ឬរកខ្យង និងក្តាមលក់ទេ ព្រោះតំលៃវាថោក ។ ពួកគេរកពស់ និងអណ្តើក បើសិនពួកគេបានជួប ប៉ុន្តែយកមកសំរាប់តែហូបទេព្រោះគ្មានម៉ូយទិញ ។ អ្នកភូមិក៏ចាប់សត្វស្លាបដោយដាក់អន្ទាក់សំរាប់ហូបផងដែរ និងដោយសារសត្វស្លាបទាំងនោះបំផ្លាញស្រូវ ។

ព្រៃដែលជិតជាងគេបំផុត មានចំងាយតិចជាង ១គីឡូម៉ែត្រ ។ នៅទីនោះអ្នកភូមិអាចរកអុសបានគ្រប់គ្រាន់សំរាប់ប្រើប្រាស់ និងលក់ខ្លះអោយអ្នកផ្សេងទៀត ជាពិសេសលក់អោយអ្នកបិតស្រា ។ នៅក្នុងព្រៃនេះប្រជាជនអាចរកឈើយកមកធ្វើរបងហើយអ្នកក្រីក្រអាចជីកដំឡូងព្រៃលក់ ។

នៅជុំវិញបឹង និងនៅតំបន់ជិតនោះផ្សេងៗទៀត ប្រជាជអាចបេះបន្លែផ្សេងៗដូចជា ត្រកួន ព្រលិត និងស្លឹកអំពិល ។ គេកាប់ស្លឹកត្នោតមកត្បាញកន្ទេលនេះ គឺជាការរកប្រាក់ចំណូលដ៏សំខាន់សំរាប់ស្ត្រីក្រីក្រមួយចំនួនតូចនៅរយៈពេលខ្លះក្នុងមួយឆ្នាំ? និងនៅឯវាលឆ្ងាយៗមួយចំនួនអ្នកភូមិច្រូតស្បូវមកក្រង ដើម្បីប្រក់ដំបូលផ្ទះរបស់ខ្លួននិងលក់ ។ ប៉ុន្តែគេព្រួយបារម្ភថានឹងលែងមានស្បូវគ្រប់គ្រាន់ ក្នុងពេលឆាប់ៗនេះ ដោយសារមនុស្សចាប់ផ្តើមច្រូតវាលទាំងនោះដើម្បីធ្វើស្រែ ។

អ្នកភូមិមួយចំនួនជួលអ្នកផ្សេងភ្ជួរ ដក/ស្ទូង និងច្រូត ។ ក្នុងរដូវដកស្ទូង ច្រូតកាត់ អ្នកដែលធ្វើការងារល្អអាចជ្រើសរើសអ្នកជួលបាននៅក្នុងភូមិជ្រែង និងនៅភូមិជិតខាង ។ ប៉ុន្តែមនុស្សមួយចំនួនតូចតែប៉ុណ្ណោះចេញពីភូមិដើម្បីរកការងារដែលមានប្រាក់ឈ្នួល ។ អ្នកភូមិមួយចំនួនតូចរកលុយក្រៅបានដោយសារការរត់ម៉ូតូឌុប ។ ស្ត្រីម្នាក់លក់នំបញ្ចុកនៅក្នុងភូមិ ។ អ្នកភូមិពីរនាក់រកស៊ីបញ្ចាំងវីដេអូ ។ មានតែគ្រូបង្រៀន និងមេភូមិទេដែលមានប្រាក់ខែទៀងទាត់ ។

**សេវានៅក្នុង និងក្រៅភូមិ**

ភូមិជ្រែងមានចំងាយ ៥គីឡូម៉ែត្រ ពីទីរួមឃុំ និង ៧គីឡូម៉ែត្រពីទីរួមស្រុក ។ នៅក្នុងភូមិនេះមានផ្លូវល្អដែលមានប្រវែង ២.២០០ម៉ែត្រ ។

មានអណ្តូងលូរួមចំនួន ៨ អណ្តូងស្នប់ ២ និងស្រះរួម ៣ លើកលែងតែអណ្តូងមួយ ឬពីរប៉ុណ្ណោះដែលមិនផ្តល់ទឹកស្អាតពេញមួយឆ្នាំ ។

ចំពោះការថែទាំសុខភាព អ្នកភូមិចូលចិត្តទៅមជ្ឈមណ្ឌលសុខភាពដែលជិតជាងគេបំផុត ចំងាយប្រហែលជា ៣គីឡូម៉ែត្រ ឬក៏ហៅពេទ្យមកពីទីនោះ ។ ពេទ្យស្រុកមានចំងាយប្រហែល ៧គីឡូម៉ែត្រ និងមន្ទីរពេទ្យខេត្តមានចំងាយ ១២គីឡូម៉ែត្រ ។ នៅក្នុងភូមិមានឆ្មបបុរាណដែលជួយបង្កើតកូនអោយស្ត្រីមានផ្ទៃពោះស្ទើរតែទាំងអស់គ្នា ។ អ្នកភូមិចំនួនពីរ ឬបីនាក់ បានទទួលការបណ្តុះបណ្តាលនៅឃុំ ជាអ្នកស្ម័គ្រអប់រំសុខភាពតាមភូមិ ប៉ុន្តែ

ពួកគេមិនច្បាស់ពីតួនាទីរបស់ពួកគេទេ ហើយអ្នកភូមិក៏មិនបានមកពិគ្រោះជាមួយពួកគេដែរ ។ ទន្ទឹមនឹងនេះ មានពេទ្យសត្វមានពីរបីនាក់ដែរ ប៉ុន្តែអ្នកភូមិមិនសូវពិគ្រោះជាមួយពួកគេទេ ។ គ្រូខ្មែរជូនកាលជួយអោយស្ត្រីឆាប់សំរាលកូន ឬព្យាបាលពោះចុក និងសត្វឈឺ ។

នៅក្នុងភូមិ មានសាលាបឋមសិក្សាមួយខ្នង ៦បន្ទប់ ។ គ្រូ ៤នាក់បង្រៀនសិស្សប្រហែលជា ១៥០នាក់ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៤ (ថ្នាក់ទី១មានសិស្ស ៧០នាក់ ថ្នាក់ទី២ មានសិស្ស ២៧នាក់ ថ្នាក់ទី៣ មានសិស្ស ៣០នាក់ និងថ្នាក់ទី៤ មានសិស្ស ២៣នាក់) ។ ពួកគេរៀនតែពេលព្រឹកទេ ហើយនៅរដូវមមាញឹកនឹងការងារស្រែចំការ ក្មេង១ភាគច្រើនមិនទៅរៀនទេ ។ កុមារ ៥-៦នាក់ ទៅរៀននៅសាលាបឋមសិក្សាផ្សេងទៀតចំងាយ ៣គីឡូម៉ែត្រ ដែលពួកគេ អាចបន្តរៀនដល់ថ្នាក់ទី៦ ។ សាលាមធ្យមសិក្សាដែលជិតជាងគេបំផុត ចំងាយ ៥គីឡូម៉ែត្រ ។ នៅក្នុងភូមិសព្វថ្ងៃនេះមានក្មេងប្រុសតែម្នាក់គត់ រៀនថ្នាក់ទី១០ នៅវិទ្យាល័យនៅទីរួមខេត្តចំងាយ ១២គីឡូម៉ែត្រ ។ ថ្នាក់អក្ខរកម្មមានបើកនៅក្នុងភូមិពីរបីដងដែលមានសិស្សប្រហែលជា ២៥នាក់ ដោយមានអាយុពី១៥ ដល់ ២០ឆ្នាំ និងប្រុស១ ២-៣នាក់ មានអាយុចាស់ជាងពួកគេបន្តិច ។

ម៉ាស៊ីនកិនស្រូវតូច១ចំនួន ១០គ្រឿង និងមួយគ្រឿងធំនៅជ្រែង ។ អ្នកភូមិទាំងអស់កិនស្រូវរបស់ពួកគេនៅក្នុងភូមិនេះ ដោយអោយម្ចាស់ម៉ាស៊ីនទុកកន្ទក់ ឬ អោយឈ្នួលកិន ។

អ្នកភូមិចំនួន៥ ឬ ៦នាក់ បើកតៀមតូច១នៅតាមផ្ទះរបស់ពួកគេ ដោយមានលក់ទំនិញសំខាន់១បន្តិចបន្តួចប៉ុណ្ណោះ និងស្ត្រីម្នាក់លក់នំបញ្ចុក ។ ផ្សារដែលនៅជិតជាងគេបំផុត ហើយអ្នកភូមិភាគច្រើនទៅនោះមានចំងាយ ៣គីឡូម៉ែត្រ ។ អ្នកលក់កម្រចូលមកភូមិណាស់ ។

អ្នកភូមិម្នាក់រកស៊ីប៉ះម៉ូតូ/កង់ ប៉ុន្តែចំងាយ ៣គីឡូម៉ែត្រ ទើបមានជាងដែកដែលនៅជិតជាងគេ និងចំងាយ ១២គីឡូម៉ែត្រ ទើបមានជាងឈើដែលជិតជាងគេបំផុត ។ ចំងាយ ២គីឡូម៉ែត្រ ទើបមានជាងកាត់ដេរ និងចំងាយ ៣គីឡូម៉ែត្រ ទើបមានជាងអ៊ុតសក់ ។ ប៉ុន្តែមុនចូលឆ្នាំខ្មែរ ជាងអ៊ុតសក់ជាច្រើននាក់មកពីទីរួមខេត្តចូលមកភូមិ ហើយបុរសវ័យក្មេងម្នាក់នៅក្នុងភូមិនេះចាប់ផ្តើមកាត់សក់អោយប្រុស១ ។

គ្រួសារចំនួនពីររកស៊ីបញ្ចាំងវីដេអូ ហើយនៅផ្ទះអ្នកភូមិពីរគ្រួសារទៀត គេនាំគ្នាលេងបៀរ ។

វត្តនៅជិតជាងគេ ដែលអ្នកភូមិភាគច្រើនទៅមានចំងាយ ២គីឡូម៉ែត្រ និងមានវត្តមួយទៀត មានចំងាយ ៣គីឡូម៉ែត្រដែលអ្នកភូមិមួយចំនួនជូនកាលទៅ ។

## សកម្មភាពអភិវឌ្ឍន៍

CARERE ៖ បានចាប់ផ្តើមធ្វើការនៅភូមិជ្រែងនៅឆ្នាំ១៩៩៣ ។ ក្នុងរយៈពេលពីរបីឆ្នាំដំបូង ពួកគេឧបត្ថម្ភអោយអ្នកភូមិជីកអណ្តូងលូប្រាំ ។ កាកបាទក្រហមអូស្ត្រាលី ជាអ្នកផ្តល់សំភារៈ ហើយអ្នកភូមិជាអ្នកជីកអណ្តូងលូទាំង៥នោះ ដោយពុំបានកំរៃឡើយ ។ អណ្តូង៤ក្នុងចំណោមអណ្តូងទាំងអស់ បានផ្តល់ទឹកស្អាតសំរាប់ប្រើប្រាស់ពេញ

មួយឆ្នាំ១ រហូតដល់មានគ្រោះទឹកជំនន់នៅចុងឆ្នាំ១៩៩៥ ។ ចាប់ពីពេលនោះមកទឹកនៅក្នុងអណ្តូងមួយក្នុងចំណោមអណ្តូងទាំងអស់មិនស្អាតទេ ។

នៅឆ្នាំ១៩៩៤-១៩៩៥ ឃែរេរ សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក បានផ្តល់ស្បៀងពលកម្មអោយអ្នកភូមិជីកស្រះរួម៣ ។ អ្នកភូមិជាអ្នកជីកហើយបានទទួលរបបអង្ករពីកម្មវិធីស្បៀងអាហារពិភពលោក និងលុយមួយចំនួនបានមកពីឃែរេរ ។ មានតែស្រះមួយទេដែលអ្នកភូមិប្រើប្រាស់ទឹកហូបបាន ចំនែកពីរទៀតអ្នកភូមិប្រើសំរាប់តែស្រោចស្រពដំណាំ និងសំណាបមួយចំនួនប៉ុណ្ណោះ ។

នៅឆ្នាំ១៩៩៤ ឃែរេរ និងកម្មវិធីស្បៀងអាហារពិភពលោកបានបង្កើតធនាគារស្រូវ ។ ឃែរេរ បានផ្តល់ជីគីមីកម្មវិធីស្បៀងអាហារពិភពលោកបានផ្តល់អង្ករ ២៥.០០០គីឡូក្រាមក្រាម ហើយអ្នកភូមិ បានបោះឆ្នោតជ្រើសរើសគណៈកម្មាធិការទទួលខុសត្រូវធនាគារស្រូវចំនួន ៥រូប ។ នៅឆ្នាំដំបូង អ្នកភូមិអាចទទួលជីដោយពាក់កណ្តាលអោយមិនគិតថ្លៃ និងពាក់កណ្តាល ពួកគេត្រូវសងវិញជាស្រូវ ។ នៅពេលជាមួយគ្នានេះដែរ ផ្នែកកសិកម្មរបស់ឃែរេរ បានផ្តល់ការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ជី ។ អ្នកភូមិក៏អាចខ្ចីស្រូវបានយ៉ាងច្រើន ២០០គីឡូក្រាមក្នុងមួយគ្រួសារ ដែលគេត្រូវសងការប្រាក់ចំនួន ២០% ។ ក្នុងរយៈពេលបីឆ្នាំបន្ទាប់ទៀត ចំនួនស្រូវសរុបដែលអ្នកខ្ចីសងនោះ បានថយចុះពី ២០.០០០គីឡូក្រាម នៅត្រឹម ៨.០០០គីឡូក្រាម រហូតដល់អស់ ។ នៅពេលនោះគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ក៏បានទទួលខុសត្រូវជំនួស ហើយនៅឆ្នាំ១៩៩៩ ពួកគេសំរេចដូរពីធនាគារស្រូវ ទៅជាធនាគារជី ។ ពួកគេលក់ស្រូវដែលនៅសល់ ៣.០០០គីឡូក្រាម ហើយទិញជី ៥០ការ៉ុង ។ អ្នកភូមិដែលមានដីស្រែ និងអាចបង់ថ្លៃចូលជាសមាជិកចំនួន១០.០០០រៀល អាចខ្ចីរហូតដល់បីការ៉ុង ដែលគេនឹងត្រូវសងការប្រាក់ចំនួន ២០% ។ នៅក្នុងខែមីនាឆ្នាំនេះ អ្នកមួយចំនួនបានសងតាមកំណត់ ។

នៅក្នុងឆ្នាំ១៩៩៥ កម្មវិធីស្បៀងអាហាពិភពលោក បានផ្តល់ស្បៀងពលកម្មសំរាប់លើកផ្លូវមួយខ្សែដែលមានចំងាយ ៣.៥០០ម៉ែត្រឆ្ពោះទៅទីរួមខេត្តពោធិសាត់ ។ មួយឆ្នាំក្រោយមក ផ្លូវនេះបានខូចខាតដោយសារទឹកជំនន់ ប៉ុន្តែអ្នកភូមិអាចធ្វើដំណើរដោយរទេះគោបាន ។

នៅឆ្នាំ១៩៩៦ កម្មវិធីសិលា បានចូលមកធ្វើការនៅក្នុងឃុំនេះ ហើយគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងភូមិជ្រៃ ។ សមាជិក ៤រូបក្នុងចំណោមសមាជិកទាំង ៥រូប របស់ធនាគារស្រូវ ជាសមាជិកក្នុងចំណោម គ.អ.ភ ទាំងប្រាំពីររូប ។ ក្រោយមកដោយមានសមាជិកម្នាក់ស្លាប់ និងម្នាក់ទៀតទៅភ្នំពេញ ហើយមានការបោះឆ្នោតជ្រើសរើសថ្មី ដែលសមាជិកម្នាក់ត្រូវបានជំនួស ។ សព្វថ្ងៃនេះមានសមាជិក គ.អ.ភ ៦នាក់ ក្នុងនោះមានប្រុស ៤នាក់ និងស្រី ២នាក់ ។

នៅឆ្នាំទីមួយរបស់កម្មវិធីសិលា ក្នុងដំណើរការកសាងផែនការមូលដ្ឋាន បានលើកផ្លូវមួយខ្សែដែលមានចំងាយ ២គីឡូម៉ែត្រពីភូមិឆ្ពោះទៅវត្ត ។ អ្នកភូមិបានចូលរួមជាកំលាំងពលកម្មដែលមានតំលៃ ២០% នៃតំលៃសរុប ប៉ុន្តែមិនមែនជាសាច់ប្រាក់ទេ ។ អ្នកភូមិដែលធ្វើការដោយបន្ថែមទៅលើការចូលរួមជាកំលាំងពលកម្មបានទទួលរបប ២.០០០រៀលក្នុង ១ម៉ែត្រគូប ។

ឆ្នាំទីពីរនៃដំណើរការកសាងផែនការមូលដ្ឋាន បានដាក់លូកាត់ថ្នល់ពីរកន្លែងនៅលើផ្លូវដដែល ។ អ្នកភូមិបានចូលរួមដាក់កំលាំងពលកម្មប៉ុណ្ណោះ ប៉ុន្តែពេលនេះពុំមានការជូលសំរាប់ពលកម្មអត់ជំនាញទេ ។

ឆ្នាំទីបី ភូមិបានទទួលទុនអភិវឌ្ឍន៍មូលដ្ឋានចំនួន ៤.៤៥០ដុល្លារ សំរាប់ដាក់លូកាត់ថ្នល់ផ្សេងទៀត និងក្រាលគ្រួសក្រហម ។ ពេលនេះអ្នកភូមិ ត្រូវចូលរួម ៣% ក្នុងចំណោម ២០ភាគ (ប្រហែលជា១៥០ដុល្លារ) ជាសាច់ប្រាក់ ។ ក្នុងខែមីនា ឆ្នាំ២០០០ សមាជិក គ.អ.ភ ប្រមូលការចូលរួមនេះបានបណ្តើរៗហើយ ។

នៅក្នុងឆ្នាំ១៩៩៦ មន្ទីរកសិកម្មខេត្តបានបណ្តុះបណ្តាលពេទ្យសត្វភូមិមួយចំនួន ហើយនៅឆ្នាំ១៩៩៩ ផ្នែកសុខភាពរបស់ ឃែរេរ បានឧបត្ថម្ភមន្ទីរសុខាភិបាល ដើម្បីបណ្តុះបណ្តាលអ្នកអប់រំសុខភាពភូមិពីរនាក់ ។

នៅឆ្នាំ១៩៩៧ ផ្នែកអប់រំរបស់ឃែរេរ បានផ្តល់ទុន ដើម្បីបើកថ្នាក់អក្ខរកម្មមានរយៈពេល ៦ខែ ដោយមានមេភូមិជាគ្រូបង្រៀនដែលរៀបចំធ្វើឡើងដោយអង្គការក្នុងស្រុកមួយមានឈ្មោះថា សាមគ្គីធម៌ ។ នៅឆ្នាំ១៩៩៩ មន្ទីរអប់រំបានបង្កើតថ្នាក់អក្ខរកម្មមួយទៀត និងរើសគ្រូបង្រៀនមកពីឃុំ ។ នៅដើមឆ្នាំ២០០០ មន្ទីរអប់រំបានផ្តល់សំភារៈ សំរាប់សាងសង់បណ្ណាល័យមួយនៅក្នុងភូមិ ។ សមាជិកគ.អ.ភ ជាអ្នកទទួលបន្ទុកសាងសង់បណ្ណាល័យនេះ បន្ទាប់មកម្នាក់ក្នុងចំណោមអ្នកទាំងអស់ និងទៅទទួលការបណ្តុះបណ្តាល អំពីរបៀបប្រើប្រាស់បណ្ណាល័យនេះ ។ នៅឆ្នាំ១៩៩៩ ឃែរេរ បានផ្តល់ថវិកាសំរាប់វគ្គបណ្តុះបណ្តាលស្តីពីសុខភាពផ្លូវចិត្តនៅក្នុងភូមិ ដែលរៀបចំឡើងដោយអង្គការក្នុងស្រុកមួយ ។ អ្នកភូមិ ៥នាក់ បានទទួលការបណ្តុះបណ្តាលនៅក្នុងខេត្តដើម្បីក្លាយជាប្រធានក្រុមផ្លូវចិត្ត ហើយបន្ទាប់មកដឹកនាំក្រុមនៅក្នុងអ្នកភូមិជាច្រើន (ស្ត្រី និងបុរសដោយឡែកពីគ្នា) ដែលមកជួបគ្នា ១០ដង ដើម្បីពិភាក្សាពីអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាផ្សេងៗទៀត ហើយដើម្បីធ្វើការណែនាំ ។

កាកបាទក្រហមកម្ពុជា និងកម្មវិធីស្បៀងអាហារពិភពលោក បានផ្តល់ជំនួយសង្គ្រោះបន្ទាន់នៅក្នុងភូមិជ្រែងពីរដង ។ ក្រោយពីមានគ្រោះថ្នាក់ទឹកជំនន់នៅឆ្នាំ១៩៩៥-១៩៩៦ ដំបូងឃែរេរ បានជួយធ្វើអង្កេតស្ថានភាព និងបន្ទាប់ពីមានគ្រោះថ្នាក់ទឹកជំនន់នៅឆ្នាំ១៩៩៩ គណៈកម្មាធិការសង្គ្រោះបន្ទាន់ (រួមមានអង្គការក្រៅរដ្ឋាភិបាលទាំងអស់នៅក្នុងខេត្ត ឃែរេរ និងមន្ទីរខេត្តនានា) បានសហការវាយតំលៃតំរូវការ និងពិភាក្សាអ្នកណាអាចផ្តល់អ្វីបាន ។ បន្ទាប់មកកម្មវិធីស្បៀងអាហារពិភពលោក និងកាកបាទក្រហមកម្ពុជា បានចុះមកភូមិជ្រែង ហើយចែក "ប័ណ្ណ" អោយអ្នកភូមិចំនួន ៧០នាក់ ដែលគេអាចយកទៅមជ្ឈមណ្ឌលចែកបានឃុំ ហើយបានទទួលអំណោយដែលមានអង្ករ ២០គីឡូក្រាម ទឹកស៊ីអ៊ីវ ២ដប ទឹ២កញ្ចប់ និងត្រីខកំប៉ុងមួយចំនួន ។ បន្ទាប់មកអ្នកភូមិចំនួន ១៧នាក់ បានទទួលកៅស៊ូតង់ពីអង្គការ ADRA និងនៅក្នុងការចែកលើកទីបី គ្រួសារមួយចំនួន បានទទួលសំភារៈជួសជុលផ្ទះមួយសំរាប់ពីកាកបាទក្រហមកម្ពុជា ។

## ភូមិគោកដូង

### ទិដ្ឋភាពទី១ ចំនួនប្រជាជន និងស្ថានភាពជាងគេជន

ភូមិគោកដូង គឺជាភូមិមួយក្នុងចំណោមភូមិទាំង៨ របស់ឃុំពាមឯក ស្រុកឯកភ្នំ ដែលមានចំងាយ ១៥គីឡូម៉ែត្រ ស្ថិតនៅភាគខាងជើងនៃទីរួមខេត្តបាត់ដំបង ។ ភូមិនេះមាន ១៧១គ្រួសារ ចំនួនមនុស្សសរុប

៨៥៤នាក់ (ស្រី ៤៣១នាក់ ប្រុស ៤២៣នាក់) ។ គ្រួសារចំនួន៧៨ ពុំមានបុរសជាមេគ្រួសារទេ ហើយ ២៥គ្រួសារជាគ្រួសារជនមាតុភូមិនិវត្តន៍ ភាគច្រើននៃអ្នកទាំងនោះមកតាំងទីលំនៅក្នុងភូមិគោកដូងនៅឆ្នាំ១៩៩២ ។

អ្នកភូមិនិយាយពីភូមិ "ចាស់" និង "ថ្មី" ឬ "ក្នុង" និង "ក្រៅ" នៃភូមិនេះ ។ នៅពេលជនមាតុភូមិនិវត្តន៍ (លើកដំបូងមាន ៧៤គ្រួសារ) ពួកគេបានទទួលដីឡូ នៅតាមដងផ្លូវដែលចូលទៅភូមិនេះ ដីខ្លះនៅឆ្ងាយពីភូមិចាស់ចំងាយ ២គីឡូម៉ែត្រ ហើយកៀកទៅនឹងភូមិជិតខាងទៅវិញ ។ ចាប់តាំងពីពេលនោះមកដីឡូទាំងនោះ បានទាក់ទាញប្រជាជនដែលមិនមានដីគ្រប់គ្រាន់នៅក្នុងភូមិ "ចាស់" ដូច្នេះសព្វថ្ងៃនេះជនមាតុភូមិនិវត្តន៍ និងប្រជាជនដែលមិនមែនជាជនមាតុភូមិនិវត្តន៍ បានមករស់នៅក្នុងតំបន់ដែលឆ្ងាយពីភូមិចាស់ ។ នៅក្នុងភូមិ "ចាស់" អ្នកមានជីវភាពធូរធាររស់នៅម៉ុំ ប៉ុន្តែអ្នកក្រមួយចំនួនរស់នៅដាច់ដោយឡែកពីផ្នែកកណ្តាលនៃភូមិ ។

ផ្ទះជាច្រើនខ្នង ត្រូវបានធ្វើឡើងពីឈើប្រហែលជាពាក់កណ្តាលនៃផ្ទះទាំងនោះប្រក់ដំបូលស្បូវ ហើយពាក់កណ្តាលទៀតប្រក់ស័ង្កសី ។ យ៉ាងតិចក៏មានផ្ទះថ្ម១ និងស្លាត១ ចំនួន ១០ខ្នងដែរ ប៉ុន្តែប្រហែលជា ១៥គ្រួសាររស់នៅក្នុងជំរកដែលធ្វើអំពីឫស្សី ។ គ្រួសារចំនួន ១៩ មានបង្គន់អនាម័យ ២គ្រួសារមានម៉ាស៊ីនភ្លើង ហើយយ៉ាងហោចណាស់ ក៏មាន ៣០គ្រួសារមានទូរទស្សន៍ (ទូរទស្សន៍បីក្នុងចំណោមទូរទស្សន៍ទាំងអស់ជាទូរទស្សន៍ពណ៌) ។ ឡានមានមួយគ្រឿង ម៉ូតូជាង ២០គ្រឿង មានកង់មនុស្សចាស់ ១០០គ្រឿង ប៉ុន្តែគ្រួសារអ្នកធូរធារក៏មានកង់សំរាប់កូនក្មេងតូច១ដែរ ។

**ប្រវត្តិ**

*"ដំបូង គឺបារាំង បន្ទាប់មកថៃ បន្ទាប់មកបារាំងទៀត បន្ទាប់ពីបារាំង គឺឥស្សរៈ បន្ទាប់មកខ្មែរក្រហម..." (ចាស់ទុំ)* ។

ភូមិគោកដូង ត្រូវបានបង្កើតឡើងដោយយាយបីនាក់យ៉ាងតិច ១០០ឆ្នាំកន្លងទៅដែរ ។ លោកយាយទាំងបីនាក់នោះឈ្មោះ យាយ អ៊ីវ យាយអោ និងយាយអៅ ហើយពួកគាត់ស្រលាញ់គ្នាណាស់ និងសំរេចតាំងទីលំនៅរួមគ្នាជាមួយគ្រួសាររបស់ពួកគាត់ ។ នៅពេលនោះតំបន់នេះពោរពេញដោយព្រៃដែលពួកគាត់ត្រូវតែកាប់ឆ្ការ ដើម្បីធ្វើស្រែ ។ ឈ្មោះគោកដូងសំដៅលើពាក្យ គោក ដែលមានន័យថា រឹងស្ងួត និង ដូង ដែលមានន័យថា អណ្តូង ។ អណ្តូងល្អបុរាណមួយនៅតែជាប្រភពទឹកតែមួយគត់ដែលអាចទុកចិត្តបាននៅក្នុងភូមិនេះ ។

ចាស់១នៅចាំថា សម័យដែលស្ថិតនៅក្រោមអាណានិគមនិយមបារាំងជាសម័យមួយដែលល្អ ។ ប្រជាជនប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែ ដាំបន្លែ នេសាទ និងជញ្ជាត់កន្ទេលឡង់ ។ អ្នកខ្លះក៏បានទៅធ្វើការលើកថ្នល់ជាតិ និងផ្លូវអោយស្វ័យយាននៅខេត្ត ហើយបានទទួលកំរៃពីការងារនេះ ។

បន្ទាប់មកទៀតក្នុងអំឡុងពេលពីរបីឆ្នាំ តំបន់នេះត្រូវបានគ្រប់គ្រងដោយជនជាតិថៃ ។ សម័យនេះក៏ហាក់ដូចជាសម័យមួយដ៏ល្អ និងមានសន្តិភាពដែរ ។ មានជនជាតិថៃ រស់នៅក្នុងភូមិនេះ និងបង្រៀនអ្នកភូមិអោយចេះភាសាថៃ ។ ប៉ុន្តែពួកគេចាកចេញដោយគ្មានចម្បាំង ហើយបារាំងក៏ត្រលប់មកវិញ ។

ក្រោយមក ក៏មានសម័យជម្លោះរវាងបារាំង និងឥស្សរៈដែលអ្នកភូមិនិយាយឡើងវិញថា ជាសម័យមួយគួរអោយភ័យខ្លាច ។ កងទ័ពឥស្សរៈបានស្នាក់នៅតាមដងទន្លេដែលមានចំងាយជាច្រើនគីឡូម៉ែត្រពីភូមិគោកដូង ។ ពួកគេបានចូលមកភូមិដើម្បីយកស្បៀង និងជ្រើសរើសអ្នកដែលគាំទ្របារាំង ក៏បានជ្រើសរើសអ្នកភូមិអោយធ្វើជាទាហានដែរ ។ អ្នកខ្លះចូលខាងឥស្សរៈអ្នកខ្លះចូលខាងបារាំង ហើយភាគីទាំងពីរបានចូលមករកអ្នកដែលគាំទ្រសត្រូវរបស់ខ្លួន ។ ប៉ុន្តែអ្នកភូមិភាគច្រើនមិនគាំទ្រខាងណាមួយទេ ។ ជួនកាលមានការច្បាំងគ្នានៅក្នុងភូមិ ឬជិតភូមិ ដូច្នេះប្រជាជនត្រូវរត់គេចមួយរយៈសិន ហើយនៅពេលដែលពួកគេទៅស្រែពួកគេភ័យខ្លាចត្រូវគេមួយចាប់ ។

នៅជំនាន់សីហនុ ការរស់នៅក្នុងភូមិហាក់ដូចជាមានភាពសប្បាយម្តងទៀត ។ ប្រជាជននិយាយពីសម័យនោះថា ជាសម័យមួយដែលមានសន្តិភាព និងស្រួលប្រកបរបរចិញ្ចឹមជីវិត ។

ចាប់ពីឆ្នាំ១៩៧២ មានការច្បាំងគ្នាយ៉ាងខ្លាំងនៅក្នុងតំបន់នេះ ហើយប្រជាជនរត់គេចខ្លួននៅពេលយប់ ។ ប៉ុន្តែនៅក្នុងរបបលន់ នល់ អ្នកភូមិបន្តរស់នៅក្នុងភូមិនេះ ។ មិនមានការច្បាំងគ្នាពិតប្រាកដនៅក្នុងភូមិទេ ប៉ុន្តែមានការច្បាំងគ្នានៅតាមវាលស្រែដែលមានចំងាយ ៥គីឡូម៉ែត្រពីភូមិ ។ ទាំងសងខាងក៏បានចូលមកជ្រើសរើសអ្នកភូមិអោយធ្វើជាទាហាន ។ យុវជនបីនាក់បានចេញពីភូមិដើម្បីចូលខាងខ្មែរក្រហមនៅតំបន់ទន្លេសាប ។ ប៉ុន្តែភូមិនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទាហានរដ្ឋាភិបាលដែលបានស្នាក់ការក្នុងភូមិ ។ អ្នកភូមិមួយចំនួនតូចក៏ជាទាហានរបស់រដ្ឋាភិបាលដែលទៅបោះទីតាំងនៅកន្លែងផ្សេងទៀតនៅក្នុងប្រទេស? អ្នកផ្សេងទៀតជាជីវពលដែលជួយការពារភូមិកុំអោយខ្មែរក្រហមចូល ហើយបានទៅតំបន់ជិតៗមួយរយៈដើម្បីវាយខ្មែរក្រហម ។ ខ្មែរក្រហមបានដុតផ្ទះនៅក្នុងភូមិពីរបីផងដែរ ។

នៅពេលដែលខ្មែរក្រហមឈ្នះអ្នកភូមិដែលធ្លាប់ធ្វើជាទាហាន លន់ នល់ ឬធ្លាប់មានមុខតំណែងផ្សេងៗត្រូវតែចាកចេញទៅកន្លែងផ្សេងៗទៀតដែលគ្មានអ្នកណាស្គាល់ពួកគេ ។ ក្នុងរបបប៉ុល ពត អ្នកភូមិភាគច្រើនរស់នៅក្នុងភូមិគោកដូង ប៉ុន្តែប្រជាជនជាច្រើនដែលមកពីភ្នំពេញ និងកន្លែងផ្សេងទៀតក៏បានមករស់នៅទីនោះដែរ ។ អ្នកដែលពេញកំលាំងទៅធ្វើស្រែ និងជីកប្រឡាយ នៅកន្លែងឆ្ងាយៗ ហើយមកលេងភូមិបានតែក្នុង៣ ឬ ៤ខែម្តងប៉ុណ្ណោះ ។ មនុស្សចាស់ និង អ្នកមិនសូវមានកំលាំងធ្វើការនៅក្នុងភូមិ ។

នៅពេលដែលវៀតណាមចូលមកក្នុងភូមិ ពុំមានការច្បាំងគ្នារវាងវៀតណាម និងខ្មែរក្រហម នៅក្នុងតំបន់នេះទេ ហើយមានមនុស្សមួយចំនួនតូចប៉ុណ្ណោះ ត្រូវបានបង្ខំអោយទៅជាមួយខ្មែរក្រហមនៅពេលដែលពួកគេភៀសខ្លួន ។ ក្នុងអំឡុងឆ្នាំ១៩៨០ រហូតដល់អំឡុងឆ្នាំ១៩៩០ មានទាហានខ្មែរក្រហមនៅតំបន់នេះ ហើយអ្នកភូមិមិនហ៊ានទៅធ្វើស្រែនៅឆ្ងាយៗទេ ។ បើសិនជាពួកគេចង់ទៅធ្វើស្រែនៅឆ្ងាយៗ ឬចង់ទៅដញ្ញាត់កន្ទេលឡង់នៅតាមបឹងឆ្ងាយៗ ពួកគេត្រូវអោយលុយខ្មែរក្រហម ។

នៅក្នុងអំឡុងដើមឆ្នាំ១៩៨០ ជាញឹកញយមានការច្បាំងគ្នារវាងខ្មែរក្រហមនិងវៀតណាម ។ ផ្ទះសម្បែងត្រូវបានដុតបំផ្លាញ ហើយខ្មែរក្រហមចូលមកជ្រើសរើសអ្នកភូមិដែលជាយុវជនមួយចំនួនតូចបានចូលខាងខ្លួន ហើយបានទៅនៅជាមួយពួកគេនៅតាមព្រំដែនថៃ ។ ដូច្នេះអ្នកភូមិទំលាប់ទទួលទានបាយពេលល្ងាចពីភ្លឺ បន្ទាប់មកចាក

ចេញពីភូមិដើម្បីពួននៅពេលយប់ ។ នៅឆ្នាំ១៩៨៦ ផ្ទះសម្បែងពីរបីខ្នងត្រូវបានដុតបំផ្លាញម្តងទៀត ហើយទាហានខ្មែរក្រហមនៅតែចូលមកក្នុងភូមិ ដើម្បីសុំអង្ករ និងថ្នាំជក់ ។ អ្នកភូមិក៏ស៊ាំទៅនឹងបញ្ហានេះដែរ ហើយតែងតែត្រៀមអង្ករ ២កំប៉ុង និងថ្នាំជក់មួយកញ្ចប់អោយខ្មែរក្រហម ។

នៅក្នុងអំឡុងដើមឆ្នាំ១៩៨០ អ្នកភូមិបានទៅជំរំនៅតាមព្រំដែនថៃ ។ អ្នកខ្លះស្នាក់នៅទីនោះ ប៉ុន្តែអ្នកភូមិភាគច្រើនគ្រាន់តែទៅបើកអង្ករត្រឡប់មកផ្ទះវិញប៉ុណ្ណោះ ។ អ្នកភូមិគោកដូងដែលមានគ្នា ៥០-៦០នាក់ និងអ្នកភូមិជិតខាងបានទៅជំរំទាំងអស់គ្នា ។ ពួកគេដើររយៈពេលបីថ្ងៃបីយប់ទើបទៅដល់ ។ អ្នកភូមិមួយចំនួនតូចបានធ្វើដំណើរទៅជំរំជាច្រើនដង ។

អ្នកភូមិបានធ្វើស្រែរួមមួយរយៈពេលខ្លី និងត្រូវជូនស្រូវឱ្យរដ្ឋាភិបាល ដើម្បីផ្គត់ផ្គង់ដល់កងទ័ពរដ្ឋាភិបាល ។ បន្ទាយរបស់កងទ័ពវៀតណាមមាននៅក្នុងស្រុក ហើយពួកគេក៏ចូលមកភូមិដើម្បីសុំស្បៀងពីអ្នកភូមិដែរ ។

អ្នកភូមិក៏ត្រូវទៅជាមួយកងទ័ពរដ្ឋាភិបាលដែរ ដើម្បីលីអាវុធ គ្រាប់រំសេវ និងស្បៀង ។ អ្នកភូមិទាំងនោះមិនបានចូលរួមក្នុងការបាញ់គ្នាទេ *"យើងទុកអោយទ័ពបាញ់"* ។ ប៉ុន្តែអ្នកខ្លះក៏បានស្លាប់ ព្រោះពួកគេគេចមិនទាន់ ។ ចាប់ពីឆ្នាំ១៩៨៣ មានការរើសទាហាន និងពលករ ។ ដំបូងហាក់ដូចជាមានការងាយស្រួលក្នុងការរើសអ្នកស្ម័គ្រចិត្តនៅភូមិគោកដូង ។ ប្រជាជនធ្លាប់មានភាពជូរចត់ដោយសារខ្មែរក្រហម និងត្រូវបានជំរុញលើកទឹកចិត្តអោយវាយពួកគេ ។ ប៉ុន្តែក្រោយមកប្រជាជនកាន់តែរារែក ហើយការជ្រើសរើសកាន់តែបង្ខំ យុវជនភាគច្រើនបានចេញពីភូមិមួយរយៈ ដើម្បីចូលទ័ព ហើយអ្នកដែលទៅធ្វើស្រែមានការលំបាក ។ មានរឿងដំណាលជាច្រើនស្តីពីក្រុមគ្រួសាររបស់ទ័ពដែលត្រូវបានសន្យាថា ជួយភ្ជួរ និងច្រូត ប៉ុន្តែគ្មានអ្នកណាជួយទេ ហើយស្តីពីប្រជាជនព្យាយាមលាក់ខ្លួន ឬឱ្យលុយទៅរដ្ឋអំណាច ដើម្បីកុំឱ្យចូលទ័ព ជូនកាលក្រោយពីស្រែ និងកំលាំងអូសទាញត្រូវបានលក់ ។

ពលករបានទៅកាប់ព្រៃ និងជីកផ្លូវនៅតាមព្រំដែនថៃ ដើម្បីលើកផ្លូវជាផ្នែកមួយនៃការការពារជាតិ ។ អ្នកភូមិជាច្រើនត្រឡប់មកវិញដោយមានជំងឺគ្រុនចាញ់ ហើយក្នុងរយៈពេលជ្រើសរើសពលករក៏អញ្ចឹងដែរ ប្រជាជនព្យាយាមគេចខ្លួន ឬបង់លុយដើម្បីរួចខ្លួន ។

នៅឆ្នាំ១៩៩២ គ្រួសារចំនួន៧៤ ដែលមកពីជំរំនៅព្រំដែន បានតាំងទីលំនៅក្នុងភូមិគោកដូង ដូច្នេះតំបន់ដែលជាលំនៅដ្ឋាន ព្រមទាំងចំនួនប្រជាជនកើនឡើងយ៉ាងសម្បើម ។ ក្នុងភូមិនេះមាន ២១០គ្រួសារដែលរស់នៅច្រើនបំផុត ។ ចាប់ពីពេលនោះមកបញ្ហាសន្តិសុខក៏មានលក្ខណៈកាន់តែប្រសើរឡើងជាលំដាប់ ។ ខ្មែរក្រហមលែងចូលមកភូមិនេះទៀតហើយ ប៉ុន្តែប្រជាជននៅតែមានការភ័យខ្លាច ព្រោះមានការច្បាំងគ្នានៅឆ្ងាយពីភូមិ ហើយពួកគេនៅតែមិនអាចទៅធ្វើស្រែនៅតំបន់ឆ្ងាយៗ ។ ប៉ុន្តែនៅឆ្នាំ១៩៩៧ ខ្មែរក្រហមមិនបានបង្កបញ្ហាសន្តិសុខទេ ។

## ធនធានសេដ្ឋកិច្ច និងមធ្យោបាយជីវិត

នៅភូមិគោកដូង មានដីស្រែប្រហែល ២៥០ហិកតា ។ មានប្រឡាយជាកសាស្ត្រមួយដែលមានប្រវែង ១.២០០ម៉ែត្រ ប៉ុន្តែមានតែអ្នកភូមិមួយចំនួនតូចប៉ុណ្ណោះ អាចបូមទឹកពីប្រឡាយនេះបញ្ចូលស្រែរបស់ពួកគេ ។

មានសត្វពាហនៈដែលជាកំលាំងអូសទាញ ១០០ក្បាល សុទ្ធតែគោទាំងអស់មានក្របីតែ ២ក្បាលប៉ុណ្ណោះ និងមានគោប្រហែលជា ១៥០ក្បាលទៀត ដែលមិនអាចប្រើប្រាស់ជាកំលាំងអូសទាញបាន ។ ប្រហែលជា ៤០គ្រួសារមានរទេះគោនិងគ្រួសារមួយចំនួនតូចមានរម៉ក ។ ត្រាក់ទ័រ ឬគោយន្តពុំដែលមានទេ ប៉ុន្តែអ្នកមានជីវភាពធូរធារប្រហែលជា ១០គ្រួសារជួលត្រាក់ទ័រភ្ជួរមួយ ឬពីរហិកតា ។ អ្នកភូមិធ្វើស្រែពង្រោះ ។ ការដកស្ទូងត្រូវបានធ្វើឡើងពីរបីហិកតាប៉ុណ្ណោះនៅក្នុងភូមិទាំងមូល ។ គ្មានអ្នកណាធ្វើស្រែរដូវប្រាំងទេ ។

មានដី ២ហិកតាសំរាប់ដាំដំណាំក្រៅពីធ្វើស្រែ ប៉ុន្តែកង្វះទឹកធ្វើអោយពិបាកដាំបន្លែ ។ នៅរដូវវស្សាអ្នកភូមិមួយចំនួនដាំស្ពៃ ត្រសក់ ត្រប់ ល្ពៅ ត្រឡាច និងម្ទេស ប៉ុន្តែភាគច្រើនសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ ។

ដើមឈើហូបផ្លែមានដូចជា ចេក ក្រូច ដូង ផ្លែទឹកដោះគោ ប៉ុន្តែដើមខ្លះងាប់នៅខែប្រាំង ហើយដីមិនមានជីជាតិល្អសំរាប់ដំណាំក្រូច និងក្រូចឆ្មា ដូចកន្លែងផ្សេងទៀតនៅក្នុងខេត្តទេ សូម្បីតែនៅក្នុងឃុំជាមួយគ្នាក៏ដោយ ។

ការចិញ្ចឹមសត្វក៏ជាបញ្ហាមួយដែរព្រោះសត្វទាំងនោះតែងតែឈឺហើយងាប់ ។ ជ្រូកមានប្រហែលជា ៦០ក្បាល ប៉ុន្តែអ្នកភូមិមិនបានរកប្រាក់ចំណូលដ៏សំខាន់ពីមាន់និងទាទេ ។

ផ្ទុយទៅវិញការនេសាទ គឺជារបរចិញ្ចឹមជីវិត និងជាប្រាក់ចំណូលយ៉ាងសំខាន់បំផុត ជាពិសេសក្នុងរដូវបន្ទាប់ពីច្រូតកាត់ហើយ ។ ស្ទឹងនិងបឹងដែលជិតជាងគេបំផុតមានចំងាយប្រហែល៥គីឡូម៉ែត្រ ។ អ្នកភូមិពី១៥ ទៅ ២០នាក់មានទូកក្តារ ឬទូកត្នោត ប៉ុន្តែអត់មានកាណូតទេ ។ ក្នុងរយៈពេលពីរបីឆ្នាំកន្លងទៅនេះ សិទ្ធិរបស់អ្នកភូមិដើម្បីចូលទៅនេសាទនៅតាមតំបន់មួយចំនួន ត្រូវបានដាក់កំរិតយ៉ាងតឹងតែង ព្រោះឈ្មួញបានទិញសិទ្ធិនេសាទ និងហាមអ្នកភូមិមិនអោយទៅនេសាទនៅទីនោះ ។

ការជញ្ជាត់កន្ត្រែសឡង់តាមបឹង គឺជាសកម្មភាពដ៏សំខាន់មួយទៀត ចំពោះអ្នកភូមិភាគច្រើននារដូវប្រាំង ។ អ្នកផ្សេងទៀតរកកង្កែប ។ ត្រី កន្ត្រែសឡង់ និងកង្កែប គឺត្រូវលក់អោយម៉ូយមួយចំនួនដែលជាអ្នកឯកទេសផ្នែកជួញដូរនីមួយៗរបស់ពួកគេនិងអ្នកដែលមកភូមិរាល់ថ្ងៃ ។ នៅពេលដែលអស់កន្ត្រែសឡង់នៅជិតៗ ម៉ូយដឹកអ្នកភូមិជាក្រុមៗ ទៅបឹងឆ្ងាយៗ មួយចំនួនដែលពួកគេស្នាក់នៅរហូតដល់ពីរអាទិត្យ ហើយម៉ូយមករាល់ថ្ងៃ ឬរាល់ពីរថ្ងៃមកម្តងដើម្បីទិញកន្ត្រែសឡង់ ។

ស្ត្រីក្រីក្រច្រូតកក់ ដើម្បីត្បាញកន្ទេលដែលជាមុខរបរសំខាន់របស់ពួកគេក្នុងរដូវនោះ ។ អ្នកភូមិលក់កន្ទេលអោយម៉ូយពិសេសមួយចំនួនតូចដែលចូលមកទិញដល់ភូមិដូចត្រី កន្ត្រែសឡង់ និងកង្កែបដែរ ។

បន្លែផ្សេងទៀតក៏ដុះនៅតាមបឹងមួយចំនួនដូចជា ក្រអៅឈូក ត្រកួន និងព្រលិត ដែលជាពិសេសស្ត្រីក្រីក្របេះយកមកហូប និងលក់ ។ អ្នកភូមិមួយចំនួនរករបរចាប់ពស់ ហើយរយៈពេល ២ខែក្នុងរដូវប្រាំងអ្នកភូមិខ្លះចាប់សត្វស្លាប ជាពិសេសមាន់ទឹកដោយការធ្វើសំលេងតាមសត្វទាំងនោះ ។ ជួនកាលនរគបាលមកជាកអ្នកភូមិដែលចាប់ពស់ និងសត្វស្លាប ប៉ុន្តែក៏មានម៉ូយពិសេសដែលទិញសត្វទាំងនោះដែរ ។

ព្រៃដែលនៅជិតជាងគេបំផុតមានចំងាយប្រហែល៨គីឡូម៉ែត្រ ។ ក្រោយពីច្រូតកាត់អ្នកដែលមានរទេះគោទៅព្រៃនោះរៀងរាល់ថ្ងៃ ដើម្បីកាប់អុសយកមកប្រើប្រាស់ និងលក់អោយអ្នកដែលមិនអាចទៅកាប់ ហេតុដូច្នេះហើយពួកគេអាចរកប្រាក់ចំណូលប្រចាំថ្ងៃបានច្រើនខែ ។ បន្ទាប់ពីច្រូតកាត់ អ្នកភូមិច្រូតស្បូវនៅវាល ជាពិសេសដើម្បីក្រងប្រក់ដំបូលផ្ទះខ្លួនឯង និងសំរាប់លក់ផងដែរ ។

អ្នកមានជួលអ្នកផ្សេងទៀតអោយច្រូត ។ ជូនកាលអ្នកក្រស៊ីឈ្នួលលើកទំនប់ ឬប្រឡាយ អោយអ្នកភូមិគ្នាឯង ដើម្បីលើកដីអោយខ្ពស់ ស៊ីឈ្នួលធ្វើផ្ទះ ឬរែកទឹកពីអណ្តូងមួយនៅក្នុងភូមិ ដែលផ្តល់ទឹកហូបពេញមួយឆ្នាំ ។

អ្នកភូមិមួយចំនួនធ្វើការបណ្តោះអាសន្ននៅទីរួមខេត្ត ដូចជាកម្មករសំណង់ ឬនៅផ្សារ ។ អ្នកភូមិជាច្រើនពិសេសក្នុងចំណោមជនមាតុភូមិនិវត្តន៍ទៅព្រំដែនថៃកាន់តែច្រើនឡើងៗ ដើម្បីធ្វើជាកម្មករកសិកម្ម ឬរោងចក្រ ។ អ្នកខ្លះអោយលុយគេដើម្បីអោយបានការងារធ្វើនៅទីនោះ ហើយអ្នកខ្លះមិនត្រឡប់មកវិញទេ ។ អ្នកខ្លះទៅធ្វើការបណ្តោះអាសន្ននៅរោងចក្រអារឈើ ដូចជានៅកោះកុង ឬកំពត ។

ប្រុស១មួយចំនួនតូចរកស៊ីរត់ម៉ូតូឌុបកាន់តែទៀងទាត់ ឬមិនសូវទៀតទាត់ ។ យ៉ាងតិចណាស់មាន ១៣គ្រួសារ បើកតៀមលក់ដូរនៅក្នុងភូមិ ។ គ្រួសារមួយក្នុងចំណោមគ្រួសារទាំងអស់នេះ ក៏រកស៊ីបញ្ចាំងវីដេអូការ៉ាអូខេ និងកន្លែងរាំ ។ បុរសម្នាក់រកស៊ីលក់មាន់ទិញមាន់ អ្នកផ្សេងទៀតរកលុយក្រៅ ដោយសារការលក់គោទិញគោម្តងម្កាល ។ មន្ត្រីរាជការមានពី ៤ ទៅ ១០នាក់ បានប្រាក់ខែទៀងទាត់ ។ ស្ត្រីមេម៉ាយ ៣ ទៅ ៤នាក់ដែលប្តីរបស់ខ្លួនធ្លាប់ធ្វើជាទាហាន មានសិទ្ធិបើកប្រាក់និវត្តន៍ប្រចាំខែ ប៉ុន្តែគ្រួសារអ្នកមានម្នាក់បានទិញសិទ្ធិនេះពីអ្នកទាំងនោះ ។

## សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ

គោកដូងមានចំងាយ ៥គីឡូម៉ែត្រពីទីរួមឃុំ និង ៨គីឡូម៉ែត្រពីទីរួមស្រុក ។ នៅក្នុងភូមិមានផ្លូវល្អ ដែលមានប្រវែងជាង ៣.០០០ម៉ែត្រ ។

កង្វះខាតទឹកនៅក្នុងភូមិគឺជាបញ្ហាសំខាន់មួយ ។ នៅក្នុងភូមិមានអណ្តូងជីកដែចាស់មួយ និងអណ្តូងលូមួយដែលមិនរីង ។ ប៉ុន្តែទឹកចេញមកពីអណ្តូងលូហូបមិនកើតទេ ។ ស្រះរួមមាន ៤ធំៗផងដែរ ប៉ុន្តែស្រះទាំងនោះរីងក្នុងរយៈពេល៣ ឬ ៤ខែរៀងរាល់ឆ្នាំ ។ នៅតំបន់ជនមាតុភូមិនិវត្តន៍មានអណ្តូងស្នប់២ ដែលអ្នកភូមិបានអោយដឹងថាមិនរីងទេ ។ ប៉ុន្តែអណ្តូងមួយអ្នកភូមិមិនដែលប្រើសោះ ហើយមួយទៀតប្រើ សំរាប់តែបោកគក់ ដោយសារទឹកនេះហូបមិនកើត ។ នៅពេលដែលស្រះប្រចាំគ្រួសារ នៅក្នុងតំបន់ជនមាតុភូមិនិវត្តន៍រីង ប្រជាជនប្រើទឹកពីស្រះនៅខាងមុខវត្តដែលជិតជាងអណ្តូងដៃនៅក្នុងភូមិចាស់ ។

សាលាបឋមសិក្សាមានមួយខ្នងដែលមានបីបន្ទប់ ។ គ្រូមាន៤នាក់បង្រៀនសិស្ស ១៦៦នាក់ ។ គ្រូពីរនាក់បង្រៀនថ្នាក់ទី២ និងទី៣ (ថ្នាក់ទី២ មានសិស្ស ៣៣នាក់ និងថ្នាក់ទី៣ មានសិស្ស ៣៨នាក់) នៅពេលព្រឹក ហើយ

គ្រូពីរនាក់ទៀតបង្រៀនថ្នាក់ទី១ និងទី៤ (ថ្នាក់ទី១ មានសិស្ស៧០នាក់ និងថ្នាក់ទី៤ មានសិស្ស ២៥នាក់) នៅពេលរសៀល ។

សាលាបឋមសិក្សាមានមួយផ្សេងទៀត (ថ្នាក់ទី១-៤) នៅវត្តដែលមានចំងាយប្រហែល ៣គីឡូម៉ែត្រ ដែលមានក្មេង១ពីភូមិគោកដូងប្រហែលជា ២០នាក់ទៅរៀន ជាពិសេសមកពីតំបន់ជនមាតុភូមិនិវត្តន៍ដែលនៅឆ្ងាយពីសាលារៀននៅក្នុងភូមិនេះ ។ នៅវត្ត UNESCO បើកមតេយ្យសាលា សាលាបឋមសិក្សា (ថ្នាក់ទី១-២) និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាថ្នាក់អក្ខរកម្ម កាត់ដេរ និងតម្បាញ ។ ក្មេង១មានប្រហែល ៥នាក់ ទៅរៀននៅសាលាមធ្យមសិក្សាដែលនៅជិតជាងគេបំផុត ចំងាយ ៥គីឡូម៉ែត្រ ហើយក្មេងស្រីម្នាក់ រៀននៅវិទ្យាល័យចំងាយ ៧គីឡូម៉ែត្រ (ថ្នាក់ទី១-២ ប៉ុន្តែបើទៅផ្លូវកាត់តែ ៣គីឡូម៉ែតទេ) ។

នៅក្នុងឃុំ មានមជ្ឈមណ្ឌលសុខភាពមួយ ចំងាយ៥គីឡូម៉ែត្រ ប៉ុន្តែអ្នកភូមិកម្រទៅទីនោះណាស់ ។ ពេទ្យស្រុកមានចំងាយ ៨គីឡូម៉ែត្រ ហើយមន្ទីរពេទ្យដែលនៅជិតជាងគេបំផុត គឺនៅទីរួមខេត្ត ចំងាយ ១៥គីឡូម៉ែត្រ ។ បុគ្គលិកពេទ្យដែលមកពីមជ្ឈមណ្ឌលសុខភាពឃុំមកចាក់ថ្នាំការពារអោយកុមារនៅក្នុងភូមិ ហើយមានស្ត្រីម្នាក់ជាអ្នកអប់រំសុខភាពដ៏សកម្ម ។ មានឆ្មបបុរាណ្យ និងគ្រូខ្មែរពីរនាក់ដែលជួយអោយស្ត្រី ឆាប់សំរាលកូនព្យាបាលពស់ចឹក ។ល។ ពុំមានពេទ្យសត្វភូមិទេ ជូនកាលពេទ្យសត្វដែលមកពីស្រុក និងខេត្តចុះមកភូមិ ប៉ុន្តែអ្នកភូមិមិនចង់អោយពេទ្យនោះ ចាក់ថ្នាំអោយសត្វរបស់ពួកគេទេ ។

នៅក្នុងភូមិមានម៉ាស៊ីនកិនស្រូវ ១គ្រឿង ។ ប៉ុន្តែអ្នកភូមិភាគច្រើនកិនស្រូវបន្តិចបន្តួចប៉ុណ្ណោះ ហើយយកស្រូវយ៉ាងច្រើនទៅកិននៅម៉ាស៊ីនធំមួយដែលមានចំងាយ ២គីឡូម៉ែត្រ ។

យ៉ាងតិចណាស់ក៏មានតៀមចំនួន១៣ដែរ តៀមជាច្រើនមានលក់ទំនិញច្រើនមុខ វាយនភ័ណ្ឌ និងវិទ្យុក៏មានដែរ ។ មានតូបលក់នំបញ្ចុក និងបបរមួយកន្លែង ហើយស្ត្រីជាច្រើនដើរលក់ម្ហូបអាហារ នំចំណីឆ្អិនស្រាប់នៅក្នុងភូមិ ។ ផ្សារដែលនៅជិតជាងគេបំផុតដែលអ្នកភូមិភាគច្រើនទៅនោះមានចំងាយបីគីឡូម៉ែត្រ ។ អ្នកលក់ឧស្សាហ៍ចូលមកភូមិដើម្បីលក់សំលៀកបំពាក់ នំប៉័ង ទឹកសណ្តែក ការ៉េម និងរបស់របរផ្សេងទៀត ។ ផ្សារដែលនៅជិតជាងគេបង្អស់មានចំងាយ ៤គីឡូម៉ែត្រ ហើយ ៧គីឡូម៉ែត្រទៅដល់ផ្សារធំជាងនេះ ។

អ្នកភូមិម្នាក់រកស៊ីប៉ះម៉ូតូ/កង់ ប៉ុន្តែចំងាយ ២គីឡូម៉ែត្រកន្លះ ទើបមានជាងដែកដែលនៅជិតជាងគេ និងចំងាយ ៥គីឡូម៉ែត្រកន្លះ ទើបមានជាងឈើដែលជិតជាងគេបំផុត ។

ស្ត្រីម្នាក់បើកហាងកាត់ដេរ នៅភូមិជិតនោះ តិចជាង២គីឡូម៉ែត្រ មានជាងអ៊ុតសក់ម្នាក់ ប៉ុន្តែជាងអ៊ុតសក់ម្នាក់ទៀតមកភូមិយ៉ាងទៀតទាត់ ។

គ្រួសារមួយរកស៊ីបញ្ចាំងវីដេអូ ការ៉ាអូខេ និងកន្លែងរាំដែលទាក់ទាញអ្នកនៅភូមិផ្សេង១ទៀត ។ សព្វថ្ងៃនេះមានកន្លែងលេងប៊ូល យ៉ាងតិចណាស់មានតាបប៊ីយ៉ែ៥ ដែលអ្នកភូមិអាចលេងមួយយប់ទល់ភ្លឺ ។ នៅតាមផ្ទះ

ជាច្រើន មានការរៀបចំលេងល្បែង (បៀរ អាប៉ោង ឡូតូ .ហើយក៏ទាក់ទាញប្រជាជននៅភូមិផ្សេងៗទៀតអោយមកលេងផងដែរ ។

វត្តដែលនៅជិតជាងគេបំផុតមានចំងាយ ២គីឡូម៉ែត្រ ។ កាលមុនមានវិហារសាសនាគ្រិះនៅក្នុងភូមិ ប៉ុន្តែឥឡូវនេះ វិហារទាំងនោះត្រូវបានគេទុកចោល ។

## សកម្មភាពអភិវឌ្ឍន៍នៅភូមិគោកដូង

អង្គការអភិវឌ្ឍន៍ដែលបានធ្វើការលើកដំបូងនៅភូមិគោកដូង គឺ Oxfam UK/Ireland ។ នៅឆ្នាំ១៩៩១ ពួកគេបានចាប់ផ្តើមធ្វើកម្មវិធីអភិវឌ្ឍន៍សហគមន៍ និងនៅពេលដែលជនមាតុភូមិនិវត្តន៍ បានមកតាំងទីលំនៅឆ្នាំ១៩៩២-១៩៩៣ ភ្នាក់ងារផ្សេងៗក៏បានចាប់ផ្តើមធ្វើសកម្មភាពអភិវឌ្ឍន៍ និងជំនួយសង្គ្រោះបន្ទាន់នានា ។

នៅឆ្នាំ១៩៩២ Oxfam UK/I បានបង្កើតកម្មវិធីធនាគារស្រូវមួយ ។ ពួកគេបានផ្តល់សំភារៈសំរាប់សាងសង់ជង្រុកស្រូវ និងកម្មវិធីស្បៀងអាហារពិភពលោកបានផ្តល់អង្ករចំនួន ៩.២០០គីឡូក្រាម ។ គណៈកម្មាធិការទទួលខុសត្រូវធនាគារស្រូវនេះមាន ៥រូប ហើយនៅឆ្នាំដំបូង ៨១គ្រួសារ បានខ្ចីអង្ករ ។ ២ឆ្នាំដំបូងការប្រាក់គឺ ៥០% ហើយគ្រប់គ្នាបានសង ។ បន្ទាប់មកប្រជាជនមិនអាចសងបានទេ ដោយសារមានទឹកជំនន់ ហើយបន្ទាប់មកការប្រាក់ត្រូវបានបន្ថយនៅ ៣០% ។ ធនាគារស្រូវនេះ កំពុងដំណើរការដដែល ហើយចំនួនសរុបទាំងអស់ ១០៧គ្រួសារ ដោយរាប់បញ្ចូលទាំងគ្រួសារ ជនមាតុភូមិនិវត្តន៍ចំនួន ៣គ្រួសារផងដែរបានខ្ចីទាំងអស់ ៤៤.០០០គីឡូក្រាម ។

Oxfam ក៏បានជីកអណ្តូងលូថ្មីមួយ និងផ្តល់លូសំរាប់ដាក់អណ្តូងចាស់ ។ អណ្តូងលូថ្មីនេះមិនដែលរីងទេ ប៉ុន្តែទឹកហូបមិនកើតទេព្រោះវាមានជាតិកំបោរ ។ អណ្តូងចាស់នោះខូចហើយ ។ នៅពេលជនមាតុភូមិនិវត្តន៍បានមកដល់អង្គការពលកម្មអន្តរជាតិ (ILO) ធ្វើផ្លូវក្រួសក្រហមដែលភ្ជាប់ពីផ្លូវធំចូលទៅភូមិគោកដូង ហើយ CARERE ។ សហការជាមួយ UNHCR សង់សាលាបឋមសិក្សាមួយខ្នងមានបីបន្ទប់ ។ នៅឆ្នាំបន្ទាប់មក សាលារៀននេះ ត្រូវបានបំផ្លាញយ៉ាងខ្ទេចខ្ទាំដោយសារខ្យល់ព្យុះ ហើយអាជ្ញាធរខេត្ត និងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀតដែលមកពីភ្នំពេញ បានជួយជួសជុលសាលារៀននេះឡើងវិញ ។

ជនមាតុភូមិនិវត្តន៍ភាគច្រើនបានទទួលដី និងសំភារៈដើម្បីសង់លំនៅដ្ឋាននៅពេលដែលពួកគេបានមកដល់ ។ រដ្ឋអំណាចមូលដ្ឋានក៏បានចែកស្រែឡើងទឹកមួយចំនួនដែរហើយ UNHCR ផ្តល់គ្រាប់ពូជ ហើយភ្ជួរដោយត្រាក់ទ័រ និងអោយអ្នកភូមិចាស់ជួយបង្រៀនជនមាតុភូមិនិវត្តន៍អោយចេះធ្វើស្រែឡើងទឹក ។ ប៉ុន្តែនៅឆ្នាំបន្ទាប់មកទៀតពុំមានការឧបត្ថម្ភទៀតឡើយ ហើយជនមាតុភូមិនិវត្តន៍ក៏មិនអាចបន្តការធ្វើស្រែបានទៀតដែរ ។ ពួកគេពុំមានដីស្រែទៀតទេ ។

នៅឆ្នាំដំបូងជនមាតុភូមិនិវត្តន៍បានទទួលអង្ករសំរាប់ហូប ។ បន្ទាប់មក Oxfam បានផ្តល់ស្បៀងពលកម្ម ។ អ្នកភូមិបានទទួលរបបអង្ករ ត្រីខកំប៉ុង ។ល។ ក្នុងការជីកស្រះប្រចាំគ្រួសារ និងប្រឡាយ នៅមុខផ្ទះរបស់ពួកគេ

ដើម្បីកុំអោយលិចទឹក ។ ពួកគេយកអាចម៍ដីនោះទៅចាក់បំពេញដីលំនៅដ្ឋាន ដូច្នេះពួកគេអាចដាំបន្លែ និងដំណាំហូបផ្លែ ។

នៅឆ្នាំ១៩៩៣ Oxfam បានជួយអោយអ្នកភូមិលើកផ្លូវនៅក្នុងភូមិ "ចាស់" ដោយសហការជាមួយ DCC ដែលបានផ្តល់ជំនាញ និងគ្រូស ។ នៅឆ្នាំដដែល Oxfam ក៏បានផ្តល់ស្បៀងពលកម្ម ដើម្បីជីកស្រះរួមមួយ ប៉ុន្តែភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ (IWDA) បានជីកស្រះរួមពីរផ្សេងទៀត ។

នៅឆ្នាំ១៩៩៤ Oxfam បានបង្កើតកម្មវិធីចិញ្ចឹមគោមេសំរាប់ប្រជាជន (ម្ចាស់ដីព្រមទាំងអ្នក អត់មានដីធ្លី) ដែលអត់មានគោ និងជាពិសេសស្ត្រីដែលជាមេគ្រួសារ ។ ពួកគេបានបង្កើតគណៈកម្មាធិការមួយទៀតដែលមានសមាជិក ៥រូប ដើម្បីទទួលបន្ទុកការងារនេះ ។ Oxfam បានចែកគោអោយ ២៦គ្រួសារដែលបានទទួលការបណ្តុះបណ្តាលមួយចំនួន បន្ទាប់មកគ្រួសារនីមួយៗចិញ្ចឹមគោនោះ រហូតដល់បានកូនមួយ ហើយទើបបង្វិលមេគោអោយទៅគ្រួសារថ្មីទៀត ។ គណៈកម្មាធិការបានលក់គោចាស់ៗ ហើយទិញគោថ្មីដាក់កម្មវិធីវិញ ។ ដើម្បីបានគោស្ទាវដាក់នៅក្នុងកម្មវិធីនេះនៅឆ្នាំ១៩៩៨ គ្រួសារចំនួន៤ ក៏បានទទួលគោពីរក្នុងមួយគ្រួសារៗ ដែលគេចិញ្ចឹមរហូតបានកូនគោពីរ បន្ទាប់មកទុកកូនគោពីរសំរាប់ខ្លួនឯង ហើយកូនគោពីរទៀតទុកអោយកម្មវិធី ។ កម្មវិធីនេះនៅតែកំពុងដំណើរការដដែលហើយគោនៅតែកំពុងចរាចរណ៍ ។

នៅឆ្នាំ១៩៩៥ អង្គការក្នុងស្រុកឈ្មោះថា ផ្ទះតឹកដូង បានជួយសង់ផ្ទះអោយស្ត្រីម្នាក់នៅក្នុងភូមិបានផ្តល់ការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈអោយគាត់ ហើយអោយគាត់ខ្ចីលុយដើម្បីធ្វើជំនួញ ប៉ុន្តែឥឡូវនេះស្ត្រីនោះឈប់រស់នៅភូមិនេះទៀតហើយ ។

នៅឆ្នាំបន្ទាប់មកទៀតដោយសារអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលមានឈ្មោះថា អភិវឌ្ឍន៍ស្ត្រីត្រូវបានបង្កើតហើយ Oxfam បានប្រគល់ការងាររបស់ខ្លួនអោយអង្គការនេះ ។ អង្គការនេះបានបង្កើតកម្មវិធីឥណទានមួយ ។ នៅពេលនេះគណៈកម្មាធិការដែលមានសមាជិក ៥រូប ដើម្បីទទួលបន្ទុកកម្មវិធីនេះ ត្រូវបានបង្កើតឡើង និងដឹកនាំដោយជនមាតុភូមិនិវត្តន៍ ។ Oxfam បានផ្តល់ថវិកាចំនួន ១.៧០០ដុល្លារ ហើយប្រជាជនចំនួន ៦៧គ្រួសារ (ជនមាតុភូមិនិវត្តន៍មាន ១៩គ្រួសារ អ្នកភូមិចាស់មាន៤៨គ្រួសារ) គ្រួសារបានខ្ចីនៅលើកទីមួយ ។ កម្មវិធីនេះនៅតែដំណើរការដដែល ។

នៅឆ្នាំ១៩៩៧ អភិវឌ្ឍន៍ស្ត្រីបានបង្កើតមូលនិធិសង្គមសង្គ្រោះ ដើម្បីប្រើប្រាស់សំរាប់ប្រជាជនក្រីក្រក្នុងស្ថានភាពពេលមានអាសន្ន ។ សមាជិកនៃកម្មវិធីឥណទានបានបង់លុយចូលមូលនិធិនិងអោយទៅសមាជិកនៅពេលពួកគេជួបការលំបាក ដូចជានៅពេលសាច់ញ្ញាតិស្លាប់ ឈឺធ្ងន់ ឬឆេះផ្ទះ ។ មូលនិធិនេះនៅតែកំពុងដំណើរការដដែល ។ នៅខែមេសា ឆ្នាំ១៩៩៧ គណៈកម្មាធិការបីផ្សេងគ្នា (គណៈកម្មាធិការធនាគារស្រូវ គោ និងឥណទាន) ត្រូវបានច្របាច់បញ្ចូលគ្នាអោយទៅជាគណៈកម្មាធិការតែមួយដោយមានសមាជិកជាប់ឆ្នោតចំនួន ៧រូប ដែលគ្រប់គ្រងសកម្មភាពការងារទាំងអស់របស់អភិវឌ្ឍន៍ស្ត្រីនៅក្នុងភូមិ ។ នៅឆ្នាំ១៩៩៨ មានការបោះឆ្នោតជ្រើសរើសថ្មីមួយលើកនេះយកតែ ៥នាក់ទេ ។ សព្វថ្ងៃនេះមានសមាជិកតែ ៤រូបទេដែលសកម្ម ។ អភិវឌ្ឍន៍ស្ត្រីមិនបាន

អោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ទទួលស្គាល់គណៈកម្មាធិការនេះ ជាគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ទេ ហើយនៅខែធ្នូ ឆ្នាំ១៩៩៧ គ.អ.ភ ត្រូវបានបោះឆ្នោតជ្រើសរើសដោយអ្នកភូមិនៅពេលដែលត្រូវបានរួមបញ្ចូលនៅក្នុងកម្មវិធីសិលា ។

នៅឆ្នាំដំបូងនៃដំណើរការកសាងផែនការមូលដ្ឋានភូមិនេះ បានទទួលថវិកា ២.៩០០ដុល្លារ ពីទុនអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីស្តារប្រឡាយស្រោចស្រពប្រវែង ១.២០០ម៉ែត្រ ។ អ្នកភូមិជាអ្នកស្តារប្រឡាយនេះ ដោយបានទទួលរបបនិងចូលរួមជាកំលាំងពលកម្ម ។ ពួកគេពុំមានការចូលរួមជាទឹកប្រាក់ទេ ។ សព្វថ្ងៃនេះ មានតែ ៤ ឬ ៥ គ្រួសារប៉ុណ្ណោះ រាប់ទាំងគ្រួសារមួយចំនួនតូចនៅភូមិក្បែរនោះ អាចទទួលប្រយោជន៍ពីប្រឡាយ ព្រោះប្រឡាយនេះមានទឹកមិនគ្រប់គ្រាន់ទេ ។

នៅវគ្គនៃដំណើរការកសាងផែនការមូលដ្ឋានលើកទី២ ភូមិគោកដូង មិនបានទទួលថវិកាពីទុនអភិវឌ្ឍន៍មូលដ្ឋានទេ ដោយសារការបែងចែកថវិកាភាគច្រើនរបស់ឃុំ ត្រូវបានប្រើសំរាប់ម៉ាស៊ីនបូមទឹកដែលផ្តល់ប្រយោជន៍អោយភូមិទាំងអស់ លើកលែងតែភូមិពីរដែលនៅដាច់ស្រយាលជាងគេបំផុត រួមមានភូមិគោកដូងផងដែរ ។

នៅឆ្នាំ១៩៩៨ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានផ្តល់បង្គន់អនាម័យចំនួន ១៩គ្រួសារដែលបានទទួលទុនពីឃែរេរ ។ នៅឆ្នាំដដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តជាមួយ Oxfam បានផ្តល់ស្បៀងពលកម្មដើម្បីធ្វើផ្លូវលំពីរខ្សែនៅក្នុងភូមិ "ចាស់" និង ស្រះរួមពីរនៅតំបន់ជនមាតុភូមិនិវត្តន៍ ។

នៅឆ្នាំ១៩៩៨ អភិវឌ្ឍន៍ស្ត្រីចាប់ផ្តើមកម្មវិធីកសិកម្ម ជាពិសេសនៅតំបន់ជនមាតុភូមិនិវត្តន៍ ប៉ុន្តែក៏សំរាប់ប្រជាជនមួយចំនួននៅក្នុងភូមិ "ចាស់" ដែរ ។ គេបង្កើតស្បៀងពលកម្ម ដើម្បីជីកប្រឡាយតូចៗសំរាប់ការស្រោចស្រពនៅតាមផ្ទះនៅតំបន់ជនមាតុភូមិនិវត្តន៍ និងបំពេញដី ដើម្បីដាំបន្លែនិងដើមឈើហូបផ្លែ ។ បន្ទាប់មកគេបានផ្តល់ពាងទឹកអោយអ្នកដែលសកម្មក្នុងការដាំដំណាំ ដើម្បីប្រើធ្វើជីកំប៉ុស្ត សំរាប់ការដាំបន្លែ ។ CARERE ក៏បានបណ្តុះបណ្តាលប្រជាជនអោយចេះដាំដើមឈើហូបផ្លែ និងមានការគាំទ្រ មន្ទីរកសិកម្ម ដើម្បីធ្វើការពិសោធន៍ស្រូវយ៉ាងតិចណាស់អ្នកភូមិម្នាក់បានចូលរួមវគ្គបណ្តុះបណ្តាលដោយ CIAP អូស្ត្រាលី (គំរោងអូស្ត្រាលីអ៊ីរីកម្ពុជា) នៅទីរួមខេត្ត ហើយ Ausaid បានផ្តល់ពត៌មានផ្នែកកសិកម្មនៅវគ្គជិតនោះ ។

នៅវគ្គដដែលនោះ LICADHO (សម្ព័ន្ធកម្ពុជាសំរាប់ការជំរុញ និងការពារសិទ្ធិមនុស្ស) ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សសំរាប់អ្នកភូមិដែលត្រូវបានគេជ្រើសរើស ហើយនៅឆ្នាំ១៩៩៩ គំរោងកម្មវិធីអភិវឌ្ឍន៍សិទ្ធិមនុស្សកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលសំរាប់សមាជិកគ.អ.ភនិងអ្នកភូមិដទៃទៀត ។ នៅឆ្នាំ១៩៩៨ មន្ទីរអប់រំ បានបើកថ្នាក់អក្ខរកម្មដោយមានការឧបត្ថម្ភពី UNESCO ។

អភិវឌ្ឍន៍ស្ត្រីបានធ្វើការអប់រំសុខភាពក្រៅផ្លូវការនៅពេលដែលពួកគេចុះមកសួរសុខទុក្ខអ្នកភូមិ ឬបើកអង្គប្រជុំ ។ នៅចុងឆ្នាំ១៩៩៦ មន្ទីរសុខាភិបាលដោយមានការឧបត្ថម្ភពី ឃែរេរ បានបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តអប់រំសុខភាពភូមិមួយចំនួន ប៉ុន្តែមានតែម្នាក់ប៉ុណ្ណោះដែលសកម្ម ។ ឆ្មបក៏បានទទួលការបណ្តុះបណ្តាលដែរ ។

ក្នុងអំឡុងឆ្នាំ១៩៩៨-១៩៩៩ អ្នកភូមិចំនួន៤នាក់ បានទទួលការបណ្តុះបណ្តាលពីអង្គការសុខភាពផ្លូវចិត្ត (TPO) ហើយបន្ទាប់មកបានបើកវគ្គអប់រំដល់បុរសមួយក្រុមដែលផឹកស្រាច្រើន និងស្ត្រីមួយក្រុម ដែលមានវិបត្តផ្លូវចិត្ត ។

ក្នុងអំឡុងឆ្នាំ១៩៩៩ អភិវឌ្ឍន៍ស្ត្រី បានទិញដីស្រែចំនួន ៨ហិកតានៅក្នុងភូមិ ។ នៅឆ្នាំបន្ទាប់មកទៀត ពួកគេបានបែងចែកអោយគ្រួសារជនមាតុភូមិនិវត្តន៍ដែលបានចូលរួមចំណែកនៅក្នុងការងារកសិកម្ម ។ គ្រួសារទាំងនោះត្រូវបង់លុយពី ៥០០-១០០០រៀល ក្នុងមួយថ្ងៃក្នុងរយៈពេល៥ឆ្នាំ បន្ទាប់មកដីនោះនឹងក្លាយជារបស់ពួកគេ ។ ពួកគេចង់ជួលដីទាំងនោះក៏បានដែរ ប៉ុន្តែដីនោះនៅតែជា "ទ្រព្យរបស់សហគមន៍" ដដែល ។

នៅខែកុម្ភះ ឆ្នាំ២០០០ កម្មវិធីសហគ្រាសអភិវឌ្ឍន៍នៅកម្ពុជា (IDE) បានធ្វើអណ្តូងឈ្នាន់ចំនួន៩ នៅក្នុងភូមិចាស់ដោយបានការឧបត្ថម្ភពីសប្បុរសជនមកឃុំជិតនោះដែលរស់នៅសហរដ្ឋ ។ នៅខែមេសាអណ្តូងទាំងនេះមិនទាន់ត្រូវបានធ្វើរួចស្រេចបាច់នៅឡើយទេ ។ អង្គការនានា (ព្រមទាំងមន្ត្រី និងអ្នកនយោបាយ) បានចែកអំណោយសន្ទឹកសន្ទាប់ច្រើនលើកច្រើនសារ ។ នៅក្នុងឆ្នាំ១៩៩៣ និង ឆ្នាំ១៩៩៤ បានចែកថ្នាំពេទ្យដែលបានមកពីមជ្ឈមណ្ឌលសុខភាពស្រុក ដើម្បីព្យាបាលជំងឺរាគ គ្រុនក្តៅ ផ្តាសសាយ ។ល។

ចាប់ពីឆ្នាំ១៩៩៣ដល់១៩៩៦ សេវាអភិវឌ្ឍន៍គ្រួសារកម្ពុជា (CFDS) បានជួយស្ត្រីមេម៉ាយក្នុងចំណោមជនមាតុភូមិនិវត្តន៍ដោយជួយសង់ផ្ទះ ផ្តល់អង្ករប្រចាំខែ ឯកសណ្ឋានសិស្សដល់កូនស្ត្រីមេម៉ាយទាំងនោះដើម្បីទៅរៀន។ ក្រោយពីមានខ្យល់ព្យុះនៅឆ្នាំ១៩៩៥ អង្គការដដែលនេះបានផ្តល់ភួយ មុង សារ៉ុង អង្ករ តង់ ឱ្យជនមាតុភូមិនិវត្តន៍មួយចំនួន ហើយ LWS បានផ្តល់គ្រាប់ពូជសំរាប់ដាំបន្លែ ។

ក្នុងអំឡុងឆ្នាំ១៩៩៤-៩៥ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិជួយជនចាស់ជរា (HELP AGE) បានជួយសង់ផ្ទះព្រមទាំងបង្គន់អនាម័យ ចាន ឆ្នាំង អង្ករ និងលុយដល់ជនចាស់ជរាចំនួន ៥គ្រួសារ ក្នុងនោះមានជនមាតុភូមិនិវត្តន៍ ២គ្រួសារ និងអ្នកភូមិចាស់ ៣គ្រួសារ ។

នៅចុងឆ្នាំ១៩៩៨ អភិវឌ្ឍន៍ស្ត្រីចែកមុង អោយគ្រួសារដែលមានកូនតូចៗ ដើម្បីការពារកូនៗ ពីជំងឺគ្រុនឈាម ។ ចាប់តាំងពីឆ្នាំ១៩៩៦ ពួកគេបានប្រារព្ធទិវានារីអន្តរជាតិ ។ នៅឆ្នាំដំបូង ពួកគេបានអញ្ជើញអ្នកក្រីក្រចំនួនពី១៥-២០នាក់ (ស្ត្រី និងបុរស) ទៅភូមិជិតខាងដែលពួកគេមានសំនួរចម្លើយ ដែលទាក់ទិនទៅនឹងបញ្ហារបស់ស្ត្រី និងចែកអំណោយអោយអ្នកចូលរួម ។ នៅឆ្នាំ១៩៩៩ អត់មានការផ្តល់ថវិកាទេ ប៉ុន្តែនៅឆ្នាំ២០០០ នេះប្រជាជនដែលមកពីពាភូមិមកជួបជុំគ្នានៅភូមិគោកដូង ។ក្មេងៗដែលអាចឆ្លើយសំនួរដែលទាក់ទងនឹងបញ្ហាសុខភាពបានទទួលសាប៊ូ ថ្នាំដុសធ្មេញ និងច្រាសដុសធ្មេញ ប៉ុន្តែចាស់ៗដែលអាចឆ្លើយសំនួរដែលទាក់ទងនឹងបញ្ហាស្ត្រី បានទទួលធុងទឹក កំសៀវ និងសារ៉ុង ។

អភិវឌ្ឍន៍ស្ត្រី ក៏បានចុះសួរសុខទុក្ខគ្រួសារក្រីក្រនៅក្នុងភូមិដោយចែកចានដែក ចោកខោអាវ ភួយ និងមី ។

# ការសិក្សាស្រាវជ្រាវស្តីពីការយល់ឃើញ និង បទពិសោធន៍របស់អ្នកភូមិ

ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០០

## ឯកសារយោង

### ១. ប្រវត្តិកម្មវិធីសិលា

សិលាគឺជាកម្មវិធីកែទំរង់ថ្មីរបស់រដ្ឋាភិបាលដោយមានការឧបត្ថម្ភគាំទ្រពីគំរោងកម្មវិធី UNDP/CARERE ។ ដោយមានការសង្កត់ធ្ងន់ទៅលើការរៀនសូត្រ និងការចែករំលែកបទពិសោធន៍ គំរោងកម្មវិធីសំដៅលើ *"ការកត់ត្រាជាឯកសារអោយបានពេញលេញទៅលើការពិសោធន៍របស់សិលា..."* (លទ្ធផល? នៅក្នុងចំនុច៥.១ ក្នុងឯកសារគំរោងកម្មវិធីនៅឆ្នាំ១៩៩៦ លទ្ធផល? នៅក្នុងចំនុច៤.១ក្នុងកំនែប្រែនៅឆ្នាំ១៩៩៧) ។

SIDAកំពុងឧបត្ថម្ភគាំទ្រ SEILA/CARERE ដោយពុំមានការផ្តល់ថវិកាដោយឡែកនិងក្រុមប្រឹក្សា (AT) ម្នាក់ ។ ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៧ SIDA ក៏បានកំពុងឧបត្ថម្ភផ្នែកថវិកាអោយមន្រ្តីផ្នែកវិជ្ជាជីវជាន់ខ្ពស់ម្នាក់ (JPO) ដោយដាក់កិច្ចការសំរាប់ធ្វើការកត់ត្រាឯកសារ និងការរៀនសូត្រ ។ ក្នុងអំឡុងឆ្នាំទីពីររបស់គាត់ (JPO) នេះនឹងធ្វើការសិក្សាស្តីពីការយល់ឃើញ និងបទពិសោធន៍របស់អ្នកភូមិដែលទាក់ទិនទៅនឹង SEILA/CARERE ។

### ឯកសារយោង

គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីស្វែងយល់ថាតើ SEILA/ CARERE (ស្រ្តី និងបុរសដែលជាគំរូដែលបានបង្ហាញ និងមានឥទ្ធិពលនៃអន្តរាគមន៍ផ្នែកការងារអភិវឌ្ឍន៍ដែលបានអនុវត្តនៅតាមមូលដ្ឋាន?) ជ្រាបចូលក្នុងផ្នត់គំនិត និងជីវិតរស់នៅរបស់អ្នកភូមិនៅតាមជនបទដោយដាក់វានៅក្នុងបរិបទនៃការយល់ឃើញ និងបទពិសោធន៍របស់អ្នកភូមិទៅការផ្លាស់ប្តូរពីអតីតកាល និងបច្ចុប្បន្ន ។

JPO នេះនឹង:

- បង្កើតការវិភាគទៅលើការយល់ឃើញ និងបទពិសោធន៍របស់អ្នកភូមិដែលទាក់ទិនទៅនឹង SEILA/ CARERE (ស្រ្តី និងបុរសដែលជាគំរូដែលបានបង្ហាញ និងមានឥទ្ធិពលនៃអន្តរាគមន៍ផ្នែកការងារ

អភិវឌ្ឍន៍ដែលបានដាក់ចុះនិងអន្តរាគមន៍អភិវឌ្ឍន៍ដទៃដែលបានអនុវត្តនៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា) ។

- ធ្វើសេចក្តីសន្និដ្ឋានលើតួនាទីនិងឥទ្ធិពលរបស់ SEILA/ CARERE ទៅលើជីវិតរស់នៅ និងផ្នត់គំនិតរបស់អ្នកភូមិ ។
- ពិភាក្សានូវអ្វីដែលអាចរំពឹងបានយ៉ាងពិតប្រាកដពីអន្តរាគមន៍ផ្នែកការងារអភិវឌ្ឍន៍ ដែលបានអនុវត្តនៅថ្នាក់ភូមិនៅក្នុងបរិបទនៅតំបន់ជនបទនៃប្រទេសកម្ពុជា ។

JPO នេះនឹងទទួលខុសត្រូវលើការរៀបចំការស្រាវជ្រាវនេះ ។ ការស្រាវជ្រាវនេះរួមមានការកំណត់បញ្ហាសំខាន់ៗ ការបង្កើតវិធីសាស្ត្រ និងការវិភាគ ។

JPO នេះត្រូវបានជំរុញលើកទឹកចិត្តដើម្បីអោយស្វែងរកការដាក់ចូល? ស្តីពីការរៀបចំ និងវិធីសាស្ត្រដើម្បីធ្វើការស្រាវជ្រាវនេះពីការសិក្សា និងអ្នកផ្សេងទៀតដែលមានបទពិសោធន៍ដែលទាក់ទិននឹងបញ្ហានេះ ប៉ុន្តែត្រូវទទួលការអនុញ្ញាតពី CARERE មុននឹងពិភាក្សាៈកលទ្ធផលណាមួយក្រៅគំរោងនេះ ។

JPO នេះនឹងដាក់របាយការណ៍ព្រាងជូន CARERE និង SIDA អោយបានមុនថ្ងៃទី១ ខែឧសភា ឆ្នាំ២០០០ និងរបាយការណ៍សំរេចមានប្រហែលជា៣០ទំព័រ រួមមាន ២ទំព័រនិយាយពីសេចក្តីសង្ខេប នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០០ ។ គេរំពឹងថា CARERE និង SIDA នឹងផ្តល់យោបល់ក្នុងរយៈពេល ២អាទិត្យ បន្ទាប់ពីការដាក់ជូននូវរបាយការណ៍ព្រាងនេះ ។

JPO នេះមិនត្រូវបានទាមទារអោយធ្វើអនុសាស្ត្រជាក់លាក់អោយ SIDA/ CARERE ប៉ុន្តែបើលទ្ធផលនៃការស្រាវជ្រាវជូនយោបល់ថាវាសមរម្យ ជាងអាចធ្វើអញ្ចឹងបាន ។

JPO នេះនឹងទទួលខុសត្រូវលើការគ្រប់គ្រងថវិកាដែលត្រូវបានបែងចែកសំរាប់ការស្រាវជ្រាវនេះ និងសំរាប់ការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកអោយស្របទៅនឹងការតាក់តែងច្បាប់របស់ UNDP/UNOP ។

JPO នេះរាយការណ៍អោយអនុប្រធានកម្មវិធីរបស់ CARERE ។